ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

# គោលការណ៍ណែនាំ

# ជាជំនួយសម្រាប់ទីក្រុងបេក្ខភាព

## (Clean City External Guideline)

# មាតិកា


**ជំពូកទី១ សេចក្តីផ្តើម** ........ **១**

**ជំពូកទី២ គោលការណ៍ណែនាំសម្រាប់ទីក្រុងបេក្ខភាព** ........ **៦**

**ផ្នែកទី១ សូចនាករគោលនៃការគ្រប់គ្រងនិងរៀបចំបរិស្ថាន** ........ **៧**

E១. សូចនាករលំអិតនៃការរៀបចំទីក្រុង ........ ៨

E២. សូចនាករលំអិតនៃលិខិតបទដ្ឋានគតិយុត្តស្តីពីបរិស្ថាន ........ ១៣

E៤. សូចនាករលំអិតនៃគុណភាពខ្យល់ ........ ១៩

E៥. សូចនាករលំអិតនៃការប្រយុទ្ធប្រឆាំងនឹងការបំពុលដោយសម្លេង ........ ២៣

E៦. សូចនាករលំអិតនៃដៃគូសហប្រតិបត្តិការ ........ ២៥

E៧. សូចនាករលំអិតនៃការធ្វើដំណើរដែលគិតគូរដល់បរិស្ថាន ........ ២៦

E៨. សូចនាករលំអិតនៃការប្រើប្រាស់ថាមពលដែលគិតគូរដល់បរិស្ថាន ........ ២៨

**ផ្នែកទី២ សូចនាករគោលនៃភាពស្អាត** ........ **៣៤**

P១. សូចនាករលំអិតនៃភាពស្អាតនៅទីកន្លែងសាធារណៈ ........ ៣៥

P៣. សូចនាករលំអិតនៃភាពស្អាតនៅតាមកន្លែងនិងសម្បទាទេសចរណ៍ ........ ៤៧

P៤. សូចនាករលំអិតនៃភាពស្អាតនៅតាមទីកន្លែងនិងដងវិថីសំខាន់ៗ ........ ៥៤

P៥. សូចនាករលំអិតនៃភាពស៊ីគ្នានៃស្ថាបត្យកម្មរបស់តំបន់ ដែលជាអគារសាធារណៈ និងផ្ទះរបស់ប្រជាពលរដ្ឋ ........ ៦១

P៦. សូចនាករលំអិតនៃការតុបតែងលម្អនៅតាមទីរមណីយដ្ឋានសំខាន់ៗ និងសម្បទាទេសចរណ៍...... ៦៤

**ផ្នែកទី៣ សូចនាករគោលស្តីអំពីការគ្រប់គ្រងសំណល់** ........ **៦៨**

D១. សូចនាករលំអិតនៃការប្រមូលសំណល់រាវ ........ ៦៨

D២. សូចនាករលំអិតនៃការប្រមូលសំណល់រឹង ........ ៧២

D៣.សូចនាករលំអិតអំពីការស្តុក និងការធ្វើប្រព្រឹត្តកម្មសំណល់រាវ ........................ ៧៥

D៤.សូចនាករលំអិតនៃការស្តុក និងការធ្វើប្រព្រឹត្តកម្មលើសំណល់រឹង ................... ៧៨

D៥.សូចនាករលំអិតនៃការបែងចែកសំណល់រឹង ................................................. ៧៩

**ផ្នែកទី៤ សូចនាករគោលនៃការបញ្ជ្រាបការយល់ដឹង** ................................ **៨២**

I១. សូចនាករលំអិតនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថាននិងភាពស្អាតដល់ប្រជាជនមូលដ្ឋាន ................................................................................ ៨៣

I២. សូចនាករលំអិតនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថាននិងភាពស្អាតដល់ប្រតិបត្តិករទេសចរណ៍ ................................................................................ ៨៦

I៣. សូចនាករលំអិតនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថានដល់ភ្ញៀវទេសចរ....... ៨៩

**ផ្នែកទី៥ សូចនាករគោលនៃតំបន់បៃតង** ........................................................ **៩២**

V១.សូចនាករលំអិតនៃការបង្កើត និងបែងចែកតំបន់បៃតង .................................. ៩៣

V២. សូចនាករលំអិតនៃការថែទាំនិងរៀបចំតំបន់បៃតង ...................................... ៩៦

V៣. សូចនាករលំអិតនៃការគ្រប់គ្រងតំបន់បៃតង .................................................. ៩៨

**ផ្នែកទី៦ សូចនាករគោលនៃសុវត្ថិភាពសុខាភិបាល សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង** ................................................................................ **១០១**

S១.សូចនាករលំអិតនៃសុវត្ថិភាពសុខាភិបាល ................................................... ១០២

S២.សូចនាករលំអិតនៃសន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង................................... ១១០

S៣.សូចនាករលំអិតនៃសកម្មភាពបង្ការ និងទប់ស្កាត់អំពើល្មើស ...................... ១១៧

**ផ្នែកទី៧ សូចនាករគោលនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍** ........................ **១២៣**

T១.សូចនាករលំអិតនៃហេដ្ឋារចនាសម្ព័ន្ធទីក្រុង ............................................... ១២៤

T២. សូចនាករលំអិតនៃប្លង់មេសម្រាប់អភិវឌ្ឍទេសចរណ៍ ................................ ១៣២

T៣. សូចនាករលំអិតនៃមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ ........ ១៣៦
T៤. សូចនាករលំអិតនៃទីតាំងលក់ទំនិញ ........ ១៣៨
T៥. សូចនាករលំអិតនៃកម្រិតភាពពេញចិត្តរបស់ភ្ញៀវទេសចរ ........ ១៤១
**ផ្នែកទី៨ ឧបសម្ព័ន្ធ ........ ១៤៧**
តារាងទី០១ ........ ១៤៨
តារាងទី០២ ........ ១៥១
តារាងទី០៣ ........ ១៥៣
តារាងទី០៤ ........ ១៥៥
តារាងទី០៥ ........ ១៥៦
តារាងទី០៦ ........ ១៥៧
តារាងទី០៧ ........ ១៥៨
តារាងទី០៨ ........ ១៦០
តារាងទី០៩ ........ ១៦២
តារាងទី១០ ........ ១៦៤
តារាងទី១១ ........ ១៦៥
តារាងទី១២ ........ ១៦៦
តារាងទី១៣ ........ ១៦៧
តារាងទី១៤ ........ ១៦៨
តារាងទី១៥ ........ ១៧០
តារាងទី១៦ ........ ១៧២
តារាងទី១៧ ........ ១៧៣
តារាងទី១៨ ........ ១៧៤

តារាងទី១៩ .......... ១៧៥
តារាងទី២០ .......... ១៧៦
តារាងទី២១ .......... ១៧៧
តារាងទី២២ .......... ១៧៨
តារាងទី២៣ .......... ១៨០
តារាងទី២៤ .......... ១៨៣
តារាងទី២៥ .......... ១៨៥
តារាងទី២៦ .......... ១៨៦
តារាងទី២៧ .......... ១៨៧
តារាងទី២៨ .......... ១៨៨
តារាងទី២៩ .......... ១៩០
តារាងទី៣០ .......... ១៩១
តារាងទី៣១ .......... ១៩២
តារាងទី៣២ .......... ១៩៣
តារាងទី៣៣ .......... ១៩៤
តារាងទី៣៤ .......... ១៩៦
តារាងទី៣៥ .......... ១៩៧
តារាងទី៣៦ .......... ១៩៨
តារាងទី៣៧ .......... ២០០
តារាងទី៣៨ .......... ២០១
តារាងទី៣៩ .......... ២០២
តារាងទី៤០ .......... ២០៥

តារាងទី៤១ ....................................................................................... ២០៦

តារាងទី៤២ ....................................................................................... ២០៩

តារាងទី៤៣ ....................................................................................... ២១១

តារាងទី៤៤ ....................................................................................... ២១២

តារាងទី៤៥ ....................................................................................... ២១៣

តារាងទី៤៦ ....................................................................................... ២១៥

តារាងទី៤៧ ....................................................................................... ២១៨

# ជំពូកទី១

# សេចក្តីផ្តើម

# ទិដ្ឋភាពទូទៅ

ចាប់តាំងពីដើមសតវត្សទី២១នេះមក ប្រទេសកម្ពុជាមានការអភិវឌ្ឍយ៉ាងខ្លាំងក្លាលើវិស័យទេសចរណ៍គួរឲ្យកត់-សម្គាល់។ ចំនួនភ្ញៀវទេសចរអន្តរជាតិមកទស្សនាកម្ពុជាមានសន្ទុះកើនឡើងយ៉ាងខ្លាំងក្នុងអត្រាកំណើន២ខ្ទង់ជាមធ្យម ដោយបានលោតផ្លោះពី **៧០១.០១៤ នាក់** នៅ ឆ្នាំ២០០៣ ដល់ **២.៥០៨.២៨៩ នាក់** នៅឆ្នាំ២០១០។

អ្វីដែលគួរឲ្យកត់សំគាល់នោះ កំណើនភ្ញៀវទេសចរនៅកម្ពុជានៅតែមានសូម្បីក្នុងដំណាក់កាលវិបត្តិសេដ្ឋកិច្ចសកលលោកក៏ដោយ។ ជាការពិតណាស់ ភ្ញៀវទេសចរអន្តរជាតិសរុបនៅកម្ពុជាក្នុងឆ្នាំ២០០៩ នៅតែរក្សាបាននូវកំណើនក្នុងអត្រាប្រមាណ **១,៧០%** **ធៀបនឹងឆ្នាំ២០០៨** ខណៈពេលដែលវិស័យទេសចរណ៍សកលលោកមានការធ្លាក់ចុះ ៤%។

លទ្ធផលសម្រេចបានទាំងនេះ សុទ្ធសឹងជាមោទនភាពរបស់ប្រទេសជាតិក៏ដូចជាក្រសួងទេសចរណ៍ដែលបានខិតខំប្រឹងប្រែងអនុវត្តតាមគោលនយោបាយ និងយុទ្ធសាស្ត្រដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា។ យ៉ាងណាមិញ ក្រសួងទេសចរណ៍មានទស្សនវិស័យចង់សម្រេចឲ្យបាននូវសមិទ្ធផលធំៗចំនួន **០៣** បន្ថែមទៀតរួមមាន៖

- រក្សាឲ្យបាននូវកំណើន **២ខ្ទង់** រៀងរាល់ឆ្នាំ
- ជំរុញការធ្វើពិពិធកម្មផលិតផល និងតំបន់ទេសចរណ៍តាមរយៈការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍នានាឲ្យមានសន្ទុះខ្លាំងក្លាដូចករណីតំបន់អង្គរ
- បង្កើនរយៈពេលស្នាក់នៅរបស់ភ្ញៀវទេសចរឲ្យកាន់តែយូរ។

ដើម្បីសម្រេចបាននូវវត្ថុបំណងទាំងនេះ ក្រសួងទេសចរណ៍មានគោលបំណងរៀបចំ និងអភិវឌ្ឍសក្ដានុពលតំបន់ទីក្រុងឲ្យក្លាយទៅជាតំបន់ទាក់ទាញភ្ញៀវទេសចរដ៏សំខាន់មួយរបស់ប្រទេសកម្ពុជា ដូចតំបន់ទេសចរណ៍ វប្បធម៌សៀមរាបអង្គរ និងតំបន់ឆ្នេរសមុទ្រកម្ពុជាដែលសុទ្ធសឹងជាប៉ូលទេសចរណ៍សំខាន់ៗ។

ឆ្លើយតបនឹងបញ្ហានេះ **ការប្រឡងប្រណាំងទីក្រុងស្អាត** ត្រូវបានផ្ដួចផ្ដើមគំនិតរៀបចំឡើង ហើយនឹងត្រូវអនុវត្តដោយយោងលើឯកសារស្តង់ដាមួយ ដែលត្រូវបានរៀបចំឡើងដោយផ្អែកលើសូចនាករសំខាន់ៗទាក់ទងនឹងផ្នែកហេដ្ឋារចនាសម្ព័ន្ធ នគរូបនីយកម្ម បរិស្ថាន ទេសចរណ៍ សេដ្ឋកិច្ច និងសង្គម។ ការប្រឡងប្រណាំងនេះមានគោលបំណងបញ្ជ្រាបការយល់ដឹង និងលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រតិបត្តិករទេសចរណ៍សំខាន់ៗដែលអនុវត្តសកម្មភាពរបស់ខ្លួននៅក្នុងទីក្រុង ឲ្យយកចិត្តទុកដាក់បន្ថែមទៀតទៅលើភាពស្អាត និងមជ្ឈដ្ឋានរស់នៅនៅក្នុងទីក្រុង ដែលនឹងបានជាប្រយោជន៍ដល់សកម្មភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាជន។ ទាំងនេះគឺដើម្បីធ្វើឲ្យមានភាពប្រសើរឡើងនូវគុណភាពផលិតផល និងសេវាកម្ម ព្រមទាំងជួយលើកកំពស់សោ-ភណ្ឌភាពទូទៅនៃទីក្រុងទាំងអស់ ដែលសុទ្ធសឹងជាកត្តាចំបងចូលរួមចំណែកដល់ការអភិវឌ្ឍវិស័យទេសចរណ៍ ដោយហេតុថា សោភណ្ឌភាពទីក្រុងគឺជាឧបករណ៍ផ្សព្វផ្សាយដ៏ទាក់ទាញមួយយ៉ាងសំខាន់បម្រើឲ្យការអភិវឌ្ឍ ទេសចរណ៍តំបន់ទីក្រុង។

ការចូលរួមយ៉ាងសកម្មពីសំណាក់អាជ្ញាធរដែនដី ពិសេសអាជ្ញាធរទីក្រុង និងប្រតិបត្តិករទេសចរណ៍សំខាន់ៗនៅក្នុងចលនាប្រឡងប្រណាំងនេះ ជាកត្តាគន្លឹះដ៏សំខាន់ដែលមិនអាចខ្វះបាន។

លទ្ធផលនៃការវាយតម្លៃទីក្រុងបេក្ខភាព នឹងត្រូវបានបញ្ជាក់ដោយស្លាកសញ្ញាគុណភាពដែលត្រូវបានចែកចេញជា **៣កម្រិត** ទៅតាមកម្រិតពិន្ទុដែលទទួលបានផ្អែកលើតារាង**សូចនាករគោលចំនួន៧** ដែលចែកចេញជា **៧៧លក្ខណវិនិច្ឆ័យ** ទាក់ទងនឹងប្រធានបទដូចខាងក្រោម៖

- ការរៀបចំ និងការគ្រប់គ្រងបរិស្ថាន
- ភាពស្អាត

- ការគ្រប់គ្រងសំណល់
- ការបញ្ជ្រាបការយល់ដឹង
- តំបន់បៃតង
- សុវត្ថិភាពសុខាភិបាល សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង
- ហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍

ការប្រកួតប្រជែងនេះទាមទារឲ្យមានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធច្រើន ដែលមានសមត្ថកិច្ចផ្សេងៗគ្នា ដូចនេះ កិច្ចសហការនិងការរក្សាឲ្យបាននូវតម្លាភាពរវាងគ្រប់ភាគី គឺជាកត្តាជំរុញឲ្យការប្រឡងប្រណាំងនេះទទួលបានជោគជ័យ។

***

## កម្មវត្ថុរបស់ឯកសារគោលការណ៍ណែនាំសម្រាប់ទីក្រុងបេក្ខភាព

គោលការណ៍ណែនាំដែលបានរៀបចំឡើងនេះ គឺសម្រាប់បំរើជាជំនួយដល់គ្រប់ទីក្រុងបេក្ខភាពក្នុងការត្រៀមរៀបចំខ្លួន និងធ្វើការកែតម្រូវនូវរាល់គំរោងអនុវត្តរបស់ខ្លួនឲ្យសមស្របនឹងលក្ខខណ្ឌតម្រូវរបស់ស្តង់ដាទីក្រុងស្អាតដែលបានដាក់ចេញ។

ឯកសារនេះដើរតួជាកញ្ចក់ឆ្លុះបញ្ចាំងដល់គ្រប់ទីក្រុងបេក្ខភាពឲ្យយល់ដាក់ច្បាស់ពីអត្ថន័យ និងអំពីលក្ខខណ្ឌដែលពួកគេអាចនឹងទទួលបានពិន្ទុសម្រាប់លក្ខណៈវិនិច្ឆ័យនីមួយៗ។ ជារួម ឯកសារនេះដើរតួនាទីជាអ្នកចង្អុលបង្ហាញដល់គ្រប់ទីក្រុងបេក្ខភាពនូវអ្វីដែលចលនាប្រឡងប្រណាំងនេះកំពុងទន្ទឹងរង់ចាំពីពួកគេ និងផ្តល់សេចក្តីណែនាំដល់បេក្ខភាពទាំងនោះនូវប្រភេទលិខិតបទដ្ឋាន សំណុំឯកសារ និងភស្តុតាងទាំងឡាយណាដែលពួកគេអាចនឹងលើកយកមកធ្វើជាសំអាងបញ្ជាក់ដើម្បីទទួលបានពិន្ទុសម្រាប់លក្ខណវិនិច្ឆ័យនីមួយៗ។

តារាងវិនិច្ឆ័យដែលរួមផ្សំឡើងពីលក្ខណវិនិច្ឆ័យជាច្រើនផ្សេងៗគ្នា (ដូចមានលើកឡើងជាផ្នែកៗទៅតាមប្រភេទនៃសូចនាករគោលក្នុងឯកសារនេះស្រាប់) ដើរតួជាឧបករណ៍រង្វាស់យ៉ាងសំខាន់សម្រាប់គណៈកម្មាធិការជាតិក្នុងការវាយតម្លៃទីក្រុងបេក្ខភាពទាំងឡាយ[1]។

ចលនាប្រឡងប្រណាំង និងលក្ខណវិនិច្ឆ័យទាំងឡាយដែលត្រូវបានជ្រើសរើសឡើងមកនេះ គឺត្រូវបានរៀបចំឡើងក្នុងគោលបំណងចំបងចំនួន២គឺ៖

**<u>កម្មវត្ថុទី១៖</u>** ជំរុញកិច្ចសហការរវាងអាជ្ញាធរទីក្រុង ជាមួយនឹងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងបញ្ហាបរិស្ថានពោលគឺជំរុញឲ្យស្ថាប័នមានសមត្ថកិច្ចទាំងនោះចូលរួមសហការអនុវត្តកិច្ចការងារនេះជាមួយទីក្រុងបេក្ខភាព ដើម្បីជៀសវាងករណីដែលទីក្រុងបេក្ខភាពអនុវត្តការងារនេះតែឯកឯង ព្រមទាំងជួយឲ្យទីក្រុងបេក្ខភាពទាំងនោះ ត្រូវអនុវត្តការងារនេះដោយកិច្ចសហ-ការជាមួយគ្រប់ភាគីពាក់ព័ន្ធដើម្បីធានាប្រសិទ្ធភាព ។

**<u>កម្មវត្ថុទី២៖</u>** បង្កើតឲ្យមានការផ្លាស់ប្តូរបទពិសោធន៍ជោគជ័យទៅវិញទៅមក រវាងទីក្រុងបេក្ខភាពទាំងឡាយ។ យើងបានដឹងហើយថា ចលនាប្រឡងប្រណាំងនេះអនុវត្តឈរលើគោលការណ៍តម្លាភាពដោយតម្រូវឲ្យទីក្រុងបេក្ខភាពទាំងអស់ត្រូវលើកអំណះអំណាង និងសំអាងផ្សេងៗសម្រាប់បញ្ជាក់លើសកម្មភាពអនុវត្តរបស់ខ្លួនដែលបានធ្វើកន្លងមក។ យើងអាចនិយាយបានថា នេះជាយន្តការមួយដែលអាចអនុញ្ញាតឲ្យគណៈកម្មាធិការជាតិបានយល់កាន់តែច្បាស់ពីបទពិសោធន៍អនុវត្តរបស់ក្រុង/ខណ្ឌបេក្ខភាពនីមួយៗ ហើយដែលយន្តការនេះអាចឲ្យយើងធ្វើការចែករំលែកបទពិសោធន៍ និងគំរូអនុវត្តល្អៗទាំងនេះទៅទីក្រុងបេក្ខ-ភាពទាំងអស់ប្រកបដោយប្រសិទ្ធភាព។

ទីក្រុងបេក្ខភាពទាំងអស់គួរកត់សម្គាល់ផងដែរ អំពីលក្ខណៈបន្សីភ្ជាប់គ្នារវាងសូចនាករលំអិតនីមួយៗ។ ទីក្រុងបេក្ខ-ភាពនីមួយៗ គួរគប្បីចងចាំថា ចលនាប្រឡងប្រណាំងនេះត្រូវបានចាត់ទុកដូចជាធាតុស្នូលដែលទីក្រុងបេក្ខភាពទាំងអស់ត្រូវយកចិត្តទុកដាក់សម្រាប់គំរោងអភិវឌ្ឍរបស់ខ្លួន ដើម្បីជម្រុញការអភិវឌ្ឍវិស័យទេស-ចរណ៍ក្នុងដែនសមត្ថកិច្ចរបស់

---

[1] **សំគាល់៖** អវត្តមានសមាសភាពដើមសម្រាប់បំពេញលក្ខខណ្ឌតម្រូវណាមួយស្មើនឹងមិនបានបំពេញលក្ខខណ្ឌតម្រូវ និងអាចជាមូលហេតុនាំឲ្យទីក្រុងបេក្ខភាពមិនអាចទទួលបានពិន្ទុសម្រាប់លក្ខណៈវិនិច្ឆ័យនោះថែមទៀតផង។

**ឧទាហរណ៍៖** សូចនាករលំអិតP៦ ក្នុងលក្ខណៈវិនិច្ឆ័យទី២ដែលទាមទារឲ្យមានភាពស៊ីសង្វាក់គ្នានៃការតុបតែងលំអមធ្យោបាយដឹកជញ្ជូនទេសចរណ៍។ ដូចនេះ ប្រសិនបើទីក្រុងបេក្ខភាពអះអាងថា លក្ខណៈវិនិច្ឆ័យនេះមិនឆ្លើយតបនឹងស្ថានភាពជាក់ស្តែងនៅក្នុងទីក្រុងរបស់គាត់នោះទេ ដោយហេតុថា ក្នុងទីក្រុងរបស់គាត់ពុំមានមធ្យោបាយដឹកជញ្ជូនទេសចរណ៍ឡើយ។ ក្នុងករណីយនេះ មិនមែនមានន័យថា ទីក្រុងបេក្ខភាពមួយនេះទទួលបានពិន្ទុ ០១ ដោយស្វ័យប្រវត្តិនោះទេ តែស្មើនឹងការមិនបានបំពេញលក្ខណៈវិនិច្ឆ័យមួយនេះតែម្តង។

ខ្លួនឲ្យកាន់តែល្អប្រសើរថែមទៀត។

មួយវិញទៀត ទីក្រុងបេក្ខភាពទាំងឡាយមិនត្រូវយកភាពខុសគ្នារវាងស្ថានភាព និងតថភាពពិតរបស់ទីក្រុងខ្លួន និងទីក្រុងដទៃធ្វើជាចំនុចមិនស្មើភាពគ្នានោះទេ។ ផ្ទុយមកវិញ គួរគប្បីផ្តោតជាសំខាន់លើវត្ថុបំណងចំបងរបស់ចលនាប្រឡងប្រណាំងដូចដែលបានរៀបរាប់ខាងលើ។

គួរកត់សម្គាល់ផងដែរថា កិច្ចការងារនេះជាប្រភេទការងារដែលត្រូវអនុវត្តសម្រាប់រយៈពេលវែង ដូចនេះ ក្នុងដំណាក់កាលដំបូងនេះ សម្រាប់ទីក្រុងបេក្ខភាពទាំងឡាយណាដែលជួបនឹងការលំបាកខ្លាំង គួរចាប់ផ្តើមយកតែសូចនាករលំអិតណាដែលខ្លួនគិតថាអាចធ្វើទៅបាន និងកំពុងអនុវត្តស្រាប់យកមកអនុវត្តជាជំហ៊ានៗសិនដែលនឹងបានជាមូលដ្ឋានឈានទៅដល់ការអភិវឌ្ឍទីក្រុងបេក្ខភាពរបស់ខ្លួនឲ្យបានពេញលេញ តាមការតម្រូវរបស់ស្តង់ដាទីក្រុងស្អាត។

ឯកសារគោលការណ៍ណែនាំសម្រាប់ទីក្រុងបេក្ខភាពនេះត្រូវបានចែកចេញជា ៣ជំពូក គឺ៖

**ជំពូកទី១៖** សេចក្តីផ្តើម

**ជំពូកទី២៖** ខ្លឹមសារនៃគោលការណ៍ណែនាំជាជំនួយសម្រាប់ទីក្រុងបេក្ខភាព ដែលត្រូវបានរៀបចំឡើងជា៧ផ្នែកធំៗ យោងតាមលក្ខណៈពិសេសនៃសូចនាករគោលទាំង៧

**ជំពូកទី៣៖** ឧបសម្ព័ន្ធ

ដោយឡែក ដើម្បីងាយស្រួលក្នុងការពន្យល់ណែនាំសម្រាប់លក្ខណវិនិច្ឆ័យនីមួយៗ (សរុបមាន **៧៧** លក្ខណវិនិច្ឆ័យ) ត្រូវបានធ្វើការបែងចែកជា **២ចំនុច** បន្ថែមទៀត គឺ៖

**ចំនុចទី១៖** ការពន្យល់បង្ហាញអំពីកម្មវត្ថុរបស់សូចនាករលំអិតនីមួយៗ និងការបរិយាយអំពីលក្ខណៈពិសេសរបស់សូចនាករលំអិតទាំងនោះភ្ជាប់នឹងចលនាប្រឡងប្រណាំងទីក្រុងស្អាត។ តាមរយៈផ្នែកទី១នេះ យើងនឹងបានឃើញយ៉ាងច្បាស់អំពីសារៈប្រយោជន៍ និងការចូលរួមរបស់សូចនាករលំអិតនីមួយៗនៃសូចនាករ-គោលទាំង៧ ទៅក្នុងចលនាប្រឡងប្រណាំងនេះ ។

**ចំនុចទី២៖** គឺជាការបរិយាយអំពីលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យនីមួយៗ ដែលទីក្រុងត្រូវបំពេញឲ្យបានដើម្បីទទួលបានពិន្ទុសម្រាប់លក្ខណវិនិច្ឆ័យនីមួយៗ។

## ជំពូកទី២

# គោលការណ៍ណែនាំសម្រាប់ទីក្រុងបេក្ខភាព

# ផ្នែកទី១
# សូចនាករគោលនៃការគ្រប់គ្រងនិងរៀបចំបរិស្ថាន

**ការរៀបចំ និងការគ្រប់គ្រងបរិស្ថាន**សំដៅលើសំណុំវិធីសាស្ត្រទាំងឡាយដែលគិតគូរដល់ផលប៉ះពាល់បរិស្ថាន ដែលអាចកើតចេញពីសកម្មភាពអភិវឌ្ឍប្រទេស ទីក្រុង ឬដើម្បីរៀបចំគំរោងអភិវឌ្ឍអ្វីមួយ។

ជាទូទៅការវាយតម្លៃផលប៉ះពាល់បរិស្ថានរបស់សកម្មភាពនីមួយៗត្រូវបានធ្វើឡើងនៅកំរិត និងតាមរបៀបផ្សេងៗពីគ្នា។ ជាមួយគ្នានេះដែរ សកម្មភាពច្រើនរូបភាពដែលយើងអាចអនុវត្តបានដើម្បីឆ្លើយតបនឹងបញ្ហាទាំងនេះ ក្នុងនោះមានដូចជា៖ *ការបញ្ជ្រាបការយល់ដឹង ការដាក់កំហិត ឬក៏បម្រាមផ្សេងៗ និងការរៀបចំគំរោងអភិវឌ្ឍទីក្រុង*ជាដើម។ សូចនាករលម្អិតដែលត្រូវបានជ្រើសរើសសម្រាប់សូចនាករគោលនេះមានកម្មវត្ថុរួម គឺពញ្ញាក់ និងតម្រង់ការចាប់អារម្មណ៍របស់បណ្ដាទីក្រុងបេក្ខភាពទាំងអស់ឲ្យយល់ដឹង និងជ្រួតជ្រាបអំពីចំនុចគន្លឹះដែលគួរយកចិត្តទុកដាក់ ដើម្បីបញ្ចៀសការប៉ះពាល់ដល់បរិស្ថានដែលអាចកើតចេញពីសកម្មភាពគ្រប់គ្រង និងអភិវឌ្ឍរបស់ពួកគេឲ្យបានជាអតិបរមា។ ទន្ទឹមគ្នានេះដែរ ដើម្បីសម្រេចឲ្យបានតាមអ្វីដូចដែលសូចនាករលំអិតបានស្នើទីក្រុងបេក្ខភាពទាំងអស់ត្រូវបង្ហាញឲ្យឃើញថា ពួកគេបានរៀបចំខ្លួនយ៉ាងប្រសើរទុកជាមុន មុននឹងចាប់ផ្ដើមសកម្មភាពអភិវឌ្ឍណាមួយនោះ។

សូចនាករគោលទី១នេះ ឈរនៅក្នុងចំណោមសូចនាករគោលលំដាប់ឈានមុខគេក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាតនេះ ដោយហេតុថា សូចនាករគោលនេះគ្របដណ្ដប់ប្រមាណ១/៦នៃពិន្ទុសរុប។

សូចនាករគោលនេះ គឺជាធាតុផ្សំសំខាន់មួយដែលមិនអាចខ្វះបានដែលយើងរមែងតែងតែប្រទះឃើញនៅក្នុងស្ទើរតែគ្រប់គោលនយោបាយផ្សេងៗដែលពាក់ព័ន្ធនឹងការកែលម្អ និងលើកកំពស់លក្ខខណ្ឌល្អនៃការរស់នៅរបស់ប្រជាពលរដ្ឋជាទូទៅ។ ជាការពិតណាស់ យើងអាចសង្កេតបានថា សូចនាករគោលនេះបានប្រមូលផ្ដុំរាល់ធាតុផ្សំទាំងឡាយដែលចង្អុលបង្ហាញ ពីកត្តារង្វាស់ស្ថានភាពបច្ចុប្បន្នរបស់បរិស្ថានជុំវិញនៅក្នុងមជ្ឈដ្ឋានរស់នៅ ដោយផ្ដោតលើផ្នែកសំខាន់ៗនៃកត្តារួមផ្សំអំពីបញ្ហាសុខភាពសាធារណៈ ដូចជា៖ គុណភាព ខ្យល់ គុណភាពទឹកសម្រាប់ប្រើប្រាស់ទូទៅ និងអំពីគុណភាពទឹកស្អាតសម្រាប់បរិភោគជាដើម។ ដូច្នេះ តាមរយៈសូចនាករគោលទី១នេះ ការប្រឡងប្រណាំងទីក្រុងស្អាតសំដៅជម្រុញនិងលើកទឹកចិត្តឲ្យទីក្រុងបេក្ខភាពជូនដំណឹងដល់ប្រជាជនក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន ក៏ដូចជាអ្នកដែលចូលមកទស្សនាទីក្រុងរបស់ខ្លួនទាំងអស់ឲ្យជ្រួត-ជ្រាបអំពីស្ថានភាពបរិស្ថានដែលពួកគេកំពុងស្ថិតនៅ។

លើសពីនេះទៅទៀត សូចនាករលំអិតមួយចំនួននៃសូចនាករគោលនេះមានកម្មវត្ថុជម្រុញឲ្យទីក្រុងបេក្ខ-ភាពទាំងអស់ចាប់ផ្ដើមអនុវត្តវិធានការទប់ស្កាត់អំពើអសកម្មផ្សេងៗ ដែលអាចជះឥទ្ធិពលអវិជ្ជមានដល់មជ្ឈដ្ឋានរស់នៅ និងជម្រុញអនុវត្តការរៀបចំប្លង់គ្រប់គ្រងនិងអភិវឌ្ឍទីក្រុងរបស់ខ្លួនដើម្បីកម្រិតខ្លួនឯងឲ្យបានច្បាស់អំពីផលវិជ្ជមាន និងអវិជ្ជមានដែលអាចកើតចេញពីសកម្មភាពអភិវឌ្ឍរបស់ទីក្រុងបេក្ខភាពទាំងនោះ។ វិធានការទាំងនេះសុទ្ធសឹងតែអាចយកមកធ្វើជាមូលដ្ឋានបម្រើដល់ការគ្រប់គ្រងរបស់ទីក្រុងបេក្ខភាព។

ជាចុងក្រោយ សូចនាករគោលទី១នេះបានលើកឡើងផងដែរអំពីដំណោះស្រាយផ្សេងៗដែលចូលរួមដល់ការកាត់បន្ថយការបញ្ចេញឧស្ម័នពុលទៅក្នុងបរិយាកាស ដោយបានក្រើនរំលឹកដល់ទីក្រុងបេក្ខភាពទាំងឡាយឲ្យចាប់ផ្ដើមកាត់បន្ថយការប្រើប្រាស់ថាមពលខ្ជះខ្ជាយ និងគិតគូរពីការប្រើប្រាស់ថាមពលដែលកកើតឡើងវិញ។

# E១. សូចនាករលំអិតនៃការរៀបចំទីក្រុង

**កម្មវត្ថុនៃសូចនាករលំអិតE១**

ការគ្រប់គ្រង និងរៀបចំថែរក្សាបរិស្ថានរស់នៅក្នុងក្រុងឲ្យបានល្អប្រសើរ ត្រូវពឹងផ្អែកមួយផ្នែកធំលើ**<u>បច្ចេកទេសរៀបចំក្រុង</u>**។ ជាទូទៅ បរិស្ថានរស់នៅមានការប្រែប្រួល អាស្រ័យលើទង្វើរបស់មនុស្សដែលរស់នៅក្នុងមជ្ឈដ្ឋាននោះផ្ទាល់។ ក្នុងន័យនេះ ដើម្បីរក្សាលំនឹងតុល្យភាពធនធានធម្មជាតិឲ្យបានយូរអង្វែង រាល់ការប្រើប្រាស់ប្រភពទឹក និងដីត្រូវឆ្លងកាត់ការគិតគូរឲ្យបានហ្មត់ចត់និងមានយន្តការគ្រប់គ្រងមួយត្រឹមត្រូវ។

ទីប្រជុំជនមួយ ឬទីក្រុងមួយគួរមិនត្រូវសាងសង់ ឬបង្កើតឡើងតាមតែតម្រូវការចំពោះមុខដោយមិនមានផែនការត្រឹមត្រូវនោះទេ។ ការអភិវឌ្ឍទីប្រជុំជន ឬតំបន់ទីក្រុងណាមួយគួរត្រូវអនុវត្តដោយអនុលោមតាម**<u>ផែនការ</u>**មួយជាក់លាក់ដោយមានការសិក្សា និងកំណត់ជាយន្តការអនុវត្តសមស្រប។

លើសពីនេះទៅទៀត យោងតាមអ្នកជំនាញនគរូបនីយកម្ម និងរៀបចំដែនដីផែនការរៀបចំក្រុងនីមួយៗមាន **៣** ប្រភេទសំខាន់ៗគឺ៖

- ប្លង់គោលប្រើប្រាស់ដីទីក្រុង
- ផែនការប្រើប្រាស់ដីទីក្រុង
- គម្រោងអភិវឌ្ឍក្រុង។

ផែនការទាំង **៣** ប្រភេទនេះ មានលក្ខណៈផ្សាភ្ជាប់គ្នាពីមួយទៅមួយតាមលំដាប់គឺគម្រោងអភិវឌ្ឍក្រុង ត្រូវធ្វើឡើងស្របតាមការចង្អុលបង្ហាញរបស់ផែនការប្រើប្រាស់ដីទីក្រុង រីឯផែនការនេះត្រូវធ្វើឡើងស្របតាមការគ្រោងទុករបស់ប្លង់គោលប្រើប្រាស់ដីទីក្រុងនោះផ្ទាល់តែម្តង។

តារាងខាងក្រោមនេះបង្ហាញអំពីលក្ខណវិនិច្ឆ័យទាំង **៣** នៃសូចនាករលំអិតE១ និងជាកម្មវត្ថុ ដើម្បីធ្វើការណែនាំដល់ទីក្រុងបេក្ខភាពនៃការប្រឡងប្រណាំងទីក្រុងស្អាត។

| **លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|
| E១.១. វត្តមាននៃ**<u>ប្លង់គោលប្រើប្រាស់ដីទីក្រុង</u>** | មាន-មិនមាន | ១ |
| E១.២. វត្តមាននៃ**<u>ផែនការប្រើប្រាស់ដីទីក្រុង</u>** | មាន-មិនមាន | ១ |
| E១.៣. វត្តមាននៃ**<u>គម្រោងអភិវឌ្ឍក្រុង</u>** | មាន-មិនមាន | ១ |

***(ផ្តល់ពិន្ទុ ៣/១៣ នៃពិន្ទុសរុបរបស់សូចនាករគោលនៃការគ្រប់គ្រងនិងរៀបចំបរិស្ថាន)***

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

**១. លក្ខណវិនិច្ឆ័យ E១.១**

*"វត្តមាននៃ**<u>ប្លង់គោលប្រើប្រាស់ដីទីក្រុង</u>**។"*

*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**<u>មាន</u>**"*

**ក. សេចក្តីពន្យល់ពាក្យគន្លឹះ**

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ប្លង់គោលប្រើប្រាស់ដីទីក្រុង | សំដៅដល់**ផែនការដែលកំណត់អំពីចក្ខុវិស័យ និងយុទ្ធសាស្រ្តរួមសម្រាប់ការអភិវឌ្ឍរូបវ័ន្ត** និង**កំណត់អំពីប្រភេទតំបន់** *(តំបន់អាចសាងសង់បាន និងតំបន់កម្រិតការសាងសង់)* ព្រមទាំង**បង្ហាញអំពីទម្រង់ទីក្រុង** **បណ្តាញហេដ្ឋារចនាសម្ព័ន្ធទីក្រុងគមនាគមន៍សំខាន់ៗ នៃទីក្រុង** និង**ការធ្វើសមាហរណកម្ម**។ ប្លង់គោលប្រើប្រាស់ដីត្រូវភ្ជាប់មកជាមួយនូវ គម្រោងអភិវឌ្ឍទីក្រុងទៅតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី មធ្យម និងវែង។ ប្លង់គោលប្រើប្រាស់ដី គឺជាប្លង់ដែលត្រូវបានអនុម័តដោយអាជ្ញាធរមានសមត្ថកិច្ច។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថាអ្វីដែលលក្ខណវិនិច្ឆ័យE១.១ តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃ គឺ "**ឯកសារប្លង់គោលប្រើប្រាស់ដីទីក្រុង**"។ ដោយសារការងារនេះជាការងារថ្មី ***(ទើបនឹងមានការណែនាំពីក្រសួងរៀបចំដែនដីនគូបនីយកម្ម និងសំណង់)*** និងមានលក្ខណៈបច្ចេកទេសខ្លាំង ក្នុងដំណាក់កាលប្រឡងប្រណាំងដំបូងនេះ **គ.ជ.វ.ទ.** ផ្តល់លទ្ធភាពផ្សេងគ្នាសម្រាប់ទីក្រុងបេក្ខភាពក្នុងការទទួលបានពិន្ទុពីលក្ខណវិនិច្ឆ័យE១.១ នូវជំរើស ២ ដូចខាងក្រោម៖

**<u>ករណីទី១</u>៖ ឯកសារប្លង់គោលប្រើប្រាស់ដីទីក្រុងត្រូវបានចងក្រងរួចរាល់**

- ប្រគល់ជូនមក គ.ជ.វ.ទ. នូវ "**ឯកសារប្លង់គោលប្រើប្រាស់ដីទីក្រុង**" មួយច្បាប់។

**<u>ករណីទី២</u>៖ ឯកសារប្លង់គោលប្រើប្រាស់ដីទីក្រុងមិនទាន់ចងក្រងរួចចប់សព្វគ្រប់**

- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការរៀបចំចងក្រង "**ឯកសារប្លង់គោលប្រើប្រាស់ដីទីក្រុង**"
- បង្ហាញអំពីសកម្មភាពដែលបានអនុវត្តជាក់ស្តែងដើម្បីរៀបចំចងក្រង "**ឯកសារប្លង់គោលប្រើប្រាស់ដីទីក្រុង**"។

ខាងក្រោមនេះ ជាការពិភាក្សា ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌនីមួយៗនៃករណីទាំងពីរខាងលើនេះ។

| តារាងពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវនិច្ឆ័យE១.១ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| **<u>ករណីទី១</u>៖** | | | |
| ១ | ឯកសារប្លង់គោលប្រើប្រាស់ដីទីក្រុង | រៀបរាងជាឯកសារប្លង់គោលប្រើប្រាស់ដីមួយច្បាប់ និងមានភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនានា | - ឯកសារប្លង់គោលប្រើប្រាស់ដីរបស់ទីក្រុងបេក្ខភាពដែលមានការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច |
| **<u>ករណីទី២</u>៖** | | | |
| ១ | វត្តមានអ្នកទទួលខុសត្រូវលើការរៀបចំឯកសារ | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់ សម្រាប់អនុវត្តការងារនេះ | - សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់ តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ។ |

| | | | |
|---|---|---|---|
| ២ | សកម្មភាពអនុវត្តជាក់ស្តែង | មានរៀបចំជាផែនការសកម្មភាព ឬផែន ការអនុវត្តនានាសម្រាប់ដំណើរការការ រៀបរាងជាឯកសារប្លង់គោលប្រើប្រាស់ ដីទីក្រុង | - តារាងផែនការសកម្មភាព[2]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | មានរៀបចំជារបាយការណ៍បូកសរុបការងារដែលសម្រេចបានគិតត្រឹមថ្ងៃដាក់ ពាក្យ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់ពីអាជ្ញាធរទីក្រុងបេក្ខភាព<br>- រូបថត រូបភាពខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែងដែលបានអនុវត្តកន្លងមក |

## ២. លក្ខណវិនិច្ឆ័យ E១.២៖

*"វត្តមាននៃ**<u>ផែនការប្រើប្រាស់ដីទីក្រុង</u>**។"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**<u>មាន</u>**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ផែនការប្រើប្រាស់ដីទីក្រុង | សំដៅដល់**<u>ផែនការលំអិត</u>**ចេញពីប្លង់គោលដែល**<u>កំណត់អំពីប្រភេទដី</u>** និង**<u>តំបន់នៃការ ប្រើប្រាស់ដី</u>**នីមួយៗ កំណត់អំពី**<u>បទប្បញ្ញត្តិប្រើប្រាស់ដី ការអភិវឌ្ឍ ការអភិរក្ស</u>** និង **<u>បទប្បញ្ញត្តិសាងសង់ក្នុងតំបន់</u>**នីមួយៗ ព្រមទាំងកំណត់អំពី**<u>បណ្តាញគមនាគមន៍</u>** និង **<u>ការធ្វើសមាហរណកម្ម</u>**។ ផែនការប្រើប្រាស់ដី គឺជាផែនការដែលត្រូវបានអនុម័តដោយ អាជ្ញាធរមានសមត្ថកិច្ច។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យE១.២តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះគឺ "**ឯកសារផែនការប្រើប្រាស់ដីទីក្រុង**"។ ដោយសារការងារនេះជាការងារ ថ្មី ***(ទើបនឹងមានការណែនាំពីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់)*** និងមានលក្ខណៈបច្ចេកទេសខ្លាំង ក្នុងដំណាក់កាលប្រឡងប្រណាំងនេះ **គ.ជ.វ.ទ.** ផ្តល់លទ្ធភាពផ្សេងគ្នាសម្រាប់ទីក្រុងបេក្ខភាពទទួលបានពិន្ទុពី លក្ខណវិនិច្ឆ័យE១.២ នូវជំរើស ២ ដូចខាងក្រោម៖

**<u>ករណីទី១</u>៖ ឯកសារផែនការប្រើប្រាស់ដីទីក្រុងត្រូវបានចងក្រងរួចរាល់**

- ប្រគល់ជូនមក គ.ជ.វ.ទ. នូវ "**ឯកសារផែនការប្រើប្រាស់ដីទីក្រុង**" មួយច្បាប់។

**<u>ករណីទី២</u>៖ ឯកសារផែនការប្រើប្រាស់ដីទីក្រុងមិនទាន់ចងក្រងរួចចប់សព្វគ្រប់**

- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការរៀបចំចងក្រង "**ឯកសារផែនការប្រើប្រាស់ដីទីក្រុង**"
- បង្ហាញអំពីសកម្មភាពដែលបានអនុវត្តជាក់ស្តែងដើម្បីរៀបចំចងក្រង "**ឯកសារផែនការប្រើប្រាស់ដី ទីក្រុ ង**"។

ខាងក្រោមនេះ ជាការពិភាក្សាក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌ នីមួយៗ

[2] តារាងទី៤២

នៃករណីទាំងពីរខាងលើ។

| **តារាងពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណៈវិនិច្ឆ័យE១.២** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| **<u>ករណីទី១៖</u>** | | | |
| ១ | ឯកសារផែនការប្រើប្រាស់ដីទីក្រុង | រៀបរាងជាឯកសារផែនការប្រើប្រាស់ដីមួយច្បាប់ និងមានភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនានា | - ឯកសារផែនការប្រើប្រាស់ដីរបស់ទីក្រុងបេតិ្តភាពដែលមានការបញ្ជាក់សុពលភាព ពីអាជ្ញាធរមានសមត្ថកិច្ច |
| **<u>ករណីទី២៖</u>** | | | |
| ១ | វត្តមានអ្នកទទួលខុសត្រូវលើការរៀបចំឯកសារ | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់ សម្រាប់អនុវត្តការងារនេះ | - សេចក្ដីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្ដីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ។ |
| ២ | សកម្មភាពអនុវត្តជាក់ស្ដែង | មានរៀបចំជាផែនការសកម្មភាព ឬ ផែនការអនុវត្តនានាសម្រាប់ដំណើរការ ការរៀបរាងជាឯកសារផែនការប្រើប្រាស់ ដីទីក្រុង | - តារាងផែនការសកម្មភាព[3]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | មានរៀបចំជារបាយការណ៍បូកសរុបការងារដែលសម្រេចបានគិតត្រឹមថ្ងៃដាក់ ពាក្យ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់ ពីអាជ្ញាធរ ទីក្រុងបេតិ្តភាព<br>- រូបថត រូបភាពខ្សែវីដេអូ ឬឯកសារផ្សេងៗ ដែលបញ្ជាក់អំពីសកម្មភាពជាក់ ស្ដែង ដែលបានអនុវត្តកន្លងមក |

## ៣. លក្ខណៈវិនិច្ឆ័យ E១.៣៖

*"វត្តមាននៃ**<u>គំរោងអភិវឌ្ឍក្រុង</u>**។"*
*"នឹងផ្ដល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**<u>មាន</u>**"*

## ក. សេចក្ដីពន្យល់ពាក្យគន្លឹះ

| **ល.រ** | **ពាក្យគន្លឹះ** | **សេចក្ដីពន្យល់** |
|---|---|---|
| ១ | គំរោងអភិវឌ្ឍក្រុង | សំដៅដល់**<u>គំរោងផ្សេងៗដែលមានរំលេចរូបវ័ន្តលំអិត</u>**នៃការរៀបចំផ្ទៃក ទីតាំង ឬតំបន់ប្រើប្រាស់ដីណាមួយនៃទីក្រុងជាអាទិ៍ការបង្ហាញអំពីការរៀបចំ និងរចនាទម្រង់រូប រាង និងសោភ័ណភាពនៃហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសម្រាប់ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់តាមរយៈគំនូរ ឬរូបសំណាក។ គំរោងអភិវឌ្ឍក្រុងត្រូវគោរពតាមផែន ការប្រើប្រាស់ដី។ |

[3] តារាងទី ៤២

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យE១.៣តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ឯកសារគំរោងអភិវឌ្ឍក្រុង"**។ ដោយសារ ការងារនេះជាការងារថ្មី ***(ទើបនឹងមានការណែនាំពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់)*** និងមានលក្ខណៈបច្ចេកទេសខ្លាំងក្នុងដំណាក់កាលប្រឡងប្រណាំងដំបូងនេះ **គ.ជ.វ.ទ.** ផ្តល់លទ្ធភាពផ្សេងគ្នា[4]សម្រាប់ទីក្រុងបេក្ខភាពទទួលបានពិន្ទុពីលក្ខណវិនិច្ឆ័យE១.១ នូវជំរើស ២ ដូចខាងក្រោម៖

**<u>ករណីទី១</u>៖ ឯកសារគំរោងអភិវឌ្ឍក្រុងទាំងអស់ដែលមានត្រូវបានចងក្រងរួចរាល់**

- ប្រគល់ជូនមក គ.ជ.វ.ទ. នូវ **"ឯកសារគំរោងអភិវឌ្ឍក្រុង"** មួយច្បាប់សម្រាប់គំរោងនីមួយៗ។

**<u>ករណីទី២</u>៖ ឯកសារគំរោងអភិវឌ្ឍក្រុងទាំងអស់ដែលមានមិនទាន់ចងក្រងរួចចប់សព្វគ្រប់**

- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការរៀបចំចងក្រង **"ឯកសារគំរោងអភិវឌ្ឍក្រុង"**
- បង្ហាញអំពីសកម្មភាពដែលបានអនុវត្តជាក់ស្តែងដើម្បីរៀបចំចងក្រង **"ឯកសារគំរោងអភិវឌ្ឍក្រុង"។**

ខាងក្រោមនេះ ជាការពិភាក្សា និងជាការណែនាំដល់បេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌនីមួយៗនៃករណីទាំងពីរខាងលើ។

| តារាងពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យE១.៣ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| **<u>ករណីទី១៖</u>** | | | |
| ១ | ឯកសារគំរោងអភិវឌ្ឍក្រុង | រៀបរាងជាឯកសារគំរោងអភិវឌ្ឍក្រុងមួយច្បាប់សម្រាប់គំរោងនីមួយៗ និងមានភ្ជាប់ មកជាមួយនូវឯកសារពាក់ព័ន្ធនានា | - ឯកសារគំរោងអភិវឌ្ឍក្រុង ១ច្បាប់ សម្រាប់គំរោងអភិវឌ្ឍនីមួយៗ ដែល មានក្នុងទីក្រុងបេក្ខភាព និងមានការ បញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថ កិច្ច |
| **<u>ករណីទី២៖</u>** | | | |
| ១ | វត្តមានអ្នកទទួលខុសត្រូវលើការរៀបចំឯកសារ | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាព និងយន្តការគ្រប់គ្រាន់ សម្រាប់អនុវត្តការងារនេះ | - សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្មីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវ បំពេញការងាររៀបចំឯកសារនេះ សម្រាប់គំរោងនីមួយៗ |
| ២ | សកម្មភាពអនុវត្តជាក់ស្តែង | មានរៀបចំជាផែនការសកម្មភាព ឬផែន ការអនុវត្តនានាសម្រាប់ដំណើរការការ រៀប រាងជាឯកសារគំរោងអភិវឌ្ឍក្រុងនេះឡើងមក | - តារាងផែនការសកម្មភាព[5]សម្រាប់ គំរោងនីមួយៗដែលមានការបញ្ជាក់ពី អាជ្ញាធរមានសមត្ថកិច្ច |

[4]បញ្ជាក់៖ ចំពោះទីក្រុងបេក្ខភាពទាំងឡាយណាដែលមានគំរោងអភិវឌ្ឍទីក្រុងលើសពី១ ហើយមានគំរោងខ្លះចងក្រងរួច និងខ្លះទៀតមិនទាន់ចងក្រងរួច នោះចំពោះគំរោងផែនការដែលចងក្រងរួចត្រូវគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងករណីទី១ និងចំពោះគំរោងផែនការដែលមិនទាន់ចងក្រងរួចរាល់ត្រូវគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងករណីទី២។

[5] តារាងទី៤២

| | | | |
|---|---|---|---|
| | *និង* | មានរៀបចំជារបាយការណ៍បូកសរុបការងារដែលសម្រេចបានគិតត្រឹមថ្ងៃដាក់ពាក្យ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់ពីអាជ្ញាធរ ទីក្រុងបេក្ខភាព<br>- រូបថត រូបភាពខ្សែវីដេអូ ឬឯកសារផ្សេង ៗ ដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែងដែលបានអនុវត្តកន្លងមក |

## E២. សូចនាករលំអិតនៃលិខិតបទដ្ឋានគតយុត្តស្តីពីបរិស្ថាន

### កម្មវត្ថុនៃសូចនាករលំអិត E២

នៅក្នុងមជ្ឈដ្ឋានមួយ បរិស្ថានជុំវិញអាចល្អស្អាតទៅបាន គឺ **<u>អាស្រ័យលើសកម្មភាពរបស់មនុស្ស</u>** ដែលរស់នៅក្នុងមជ្ឈដ្ឋាននោះផ្ទាល់។ ដូចនេះ ដើម្បីថែរក្សាការពារបរិស្ថានរស់នៅជុំវិញឲ្យបានល្អស្អាតជាប់ជានិច្ចគឺត្រូវផ្តើមចេញពី**<u>ការកំណត់</u> <u>និងគ្រប់គ្រង</u>**សកម្មភាពរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងមជ្ឈដ្ឋាននោះផ្ទាល់តែម្តង (អាកប្បកិរិយាទាំងឡាយណាដែលអាចបង្កផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន) ក៏ដូចជាជនគ្រប់រូបដែលចូលទៅតាំងទីបណ្តោះអាសន្ន ឬឆ្លងកាត់ទីកន្លែងនោះ។

ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាព **<u>ការត្រួតពិនិត្យរមែងភ្ជាប់នឹងការពិន័យ</u>**។ ដោយឡែក នៅក្នុងចំនុចនេះការពិន័យគួរតែស្ថិតនៅក្នុងកម្រិតមួយដែលគ្រាន់តែជា**<u>ការដាស់តឿនក្រើនរំលឹក</u>**ដែលអាចជា៖ **ការស្តីបន្ទោសដោយផ្ទាល់មាត់ លិខិតព្រមាន ការពិន័យជាប្រាក់ជាដើម។ល។**

សូចនាករលំអិតនេះ មានលក្ខណវិនិច្ឆ័យនៃការវាយតម្លៃតែមួយគត់ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោមនេះ។

| លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| E២.១.វត្តមាននៃ**<u>យន្តការដែលអាចដាក់ទណ្ឌកម្ម</u>**ដោយអាជ្ញាធរមូលដ្ឋាន *(ការពិន័យ ជាប្រាក់ ឬការបិទអាជីវកម្ម)* ចំពោះការមិនគោរព និងមិនចូលរួមថែរក្សាបរិស្ថាន *(ដូចជា ការបញ្ចេញសំណល់ឥតសណ្តាប់ធ្នាប់ ការមិនគោរពបទប្បញ្ញត្តិនគរូបនីយ- កម្ម។ល។)* | មាន-មិនមាន | ១ |

*(ផ្តល់ពិន្ទុ ១/១៣ នៃពិន្ទុសរុបរបស់សូចនាករគោលនៃការគ្រប់គ្រងនិងរៀបចំបរិស្ថាន)*

## ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

### លក្ខណៈវិនិច្ឆ័យE២.១៖

*"វត្តមាននៃ**<u>យន្តការដែលអាចដាក់ទណ្ឌកម្ម</u>**ដោយអាជ្ញាធរមូលដ្ឋាន (ការពិន័យជាប្រាក់ ឬការបិទអាជីវកម្ម) ចំពោះការមិនគោរព និងមិនចូលរួមថែរក្សាបរិស្ថាន (ដូចជា ការបញ្ចេញសំណល់ឥតសណ្តាប់ធ្នាប់ ការមិនគោរពបទប្បញ្ញត្តិនគរូបនីយកម្ម។ល។)"*

*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា<u>មាន</u>"*

**ក. សេចក្តីពន្យល់ពាក្យគន្លឹះ**

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | យន្តការដាក់ទណ្ឌកម្ម | សំដៅដល់**<u>លទ្ធភាពក្នុងការដាក់ពិន័យដល់ជនគ្រប់រូប (ទាំងរូបវន្តបុគ្គល និងនីតិបុគ្គល)</u>** ចំពោះសកម្មភាពអសកម្មនិងអាកប្បកិរិយាទាំងឡាយណាដែលអាចបង្កផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន។ "ទណ្ឌកម្ម" នៅក្នុងន័យនេះសំដៅត្រឹមការពិន័យទាំងឡាយដែលជាការក្រើនរំលឹក និងមិនប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ជននោះឡើយ។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យE២.១តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**ប្រសិទ្ធភាព**" នៃវិធានការនៃការដាក់ទណ្ឌកម្មដោយអាជ្ញាធរមូលដ្ឋានចំពោះការមិនគោរព និងមិនចូលរួមថែរក្សាបរិស្ថាន។ ដូចនេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យគណៈកម្មាធិការជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺ៖

- បង្ហាញអំពីវត្តមានវិធានការនៃការដាក់ទណ្ឌកម្មចំពោះសកម្មភាពអសកម្មទាំងឡាយ
- បង្ហាញអំពីវត្តមានអង្គភាពទទួលខុសត្រូវអនុវត្តវិធានការទាំងនេះ
- បង្ហាញអំពីសកម្មភាពអនុវត្តជាក់ស្តែងរបស់អង្គភាពនោះ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យE២.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០៣** ខាងលើ។

**តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ□២.១**

| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
|---|---|---|---|
| ១ | វត្តមានយន្តការ សម្រាប់ការដាក់ទណ្ឌកម្មចំពោះសកម្មភាពអសកម្មទាំងឡាយ | រៀបចំចងក្រងជាយន្តការ វិធាន ឬនីតិវិធីសម្រាប់ទប់ស្កាត់ និងដាក់ទណ្ឌកម្មដល់ជនទាំងឡាយណាដែលប្រព្រឹត្តសកម្មភាពអសកម្មផ្សេងៗ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការកំណត់ និងហាមឃាត់រាល់អំពើអសកម្មផ្សេងៗដែលចាត់ទុកថាមានផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន |
| ២ | វត្តមានអង្គភាពទទួលខុសត្រូវលើការដាក់ទណ្ឌកម្មដល់សកម្មភាពទាំងនោះ | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៣ | សកម្មភាពជាក់ស្តែង | ធ្វើការបែងចែកជាក្រុមការងារតូចៗសម្រាប់ចុះត្រួតពិនិត្យ (ក្រុមល្បាត) | -បញ្ជីរាយនាមក្រុមការងារទាំងនោះ ដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុង ឬអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបចំជាតារាងផែនការសកម្មភាព | -តារាងផែនការសកម្មភាព[6]របស់អង្គភាពដែលទទួលខុសត្រូវការងារនេះ |
| | ***និង*** | ចងក្រងរបាយការណ៍បូកសរុបការងារគិតត្រឹមថ្ងៃដាក់ពាក្យ | - របាយការណ៍បូកសរុបការងារដែលមាន ហត្ថលេខា និងការបញ្ជាក់សុពលភាពពីអាជ្ញាធរមាន |

[6] តារាងទី៤២

| | | | |
|---|---|---|---|
| | | | សមត្ថកិច្ចនិងមានភ្ជាប់មកជាមួយនូវតារាងសម្រង់ស្ថិតិស្តីពីការអនុវត្តការពិន័យ[7]ដែលសម្រេចបានកន្លងមក<br>- រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែង |

# E៣. សូចនាករលំអិតនៃគុណភាពទឹក

## កម្មវត្ថុនៃសូចនាករលំអិត E៣

"**ទឹកគឺជាប្រភពនៃជីវិត**" គឺជាពាក្យស្លោកមួយដែលត្រូវបានទទួលស្គាល់ទូទាំងពិភពលោក នេះគឺជាការពិតដែលគ្មានអ្នកណាម្នាក់អាចបដិសេធបានទេ។

ទីក្រុងគឺជាបណ្តុំនៃទីប្រជុំជនផងជាកន្លែងសម្រាប់តាំងទីរបស់មនុស្សរាប់ម៉ឺន រាប់សែន រាប់លាននាក់។ ក្នុងន័យនេះ ប្រភពទឹកសម្រាប់ផ្គត់ផ្គង់ការប្រើប្រាស់នៅក្នុងទីក្រុងគឺជាចំនុចជីពចរស្លាប់រស់របស់ប្រជាជនទាំងអស់។ ជាការពិត សកម្មភាពមនុស្សមិនទទួលខុសត្រូវគឺជាប្រភពបំពុលមួយយ៉ាងសំខាន់ដល់ធនធានធម្មជាតិ។ ការបំពុលទឹកនៅក្នុងតំបន់ទីក្រុងគឺជាបញ្ហាដែលតែងតែកើតមានឡើងជារឿយៗ នៅតាមបណ្តាទីក្រុងផ្សេងៗ នៅទូទាំងពិភពលោក។

ដូច្នេះ ការគ្រប់គ្រងប្រភពទឹកសម្រាប់ប្រើប្រាស់នៅទីក្រុងមួយ គឺជាកាតព្វកិច្ចដែលត្រូវតែអនុវត្តឲ្យបានខ្ជាប់ខ្ជួន។

តារាងខាងក្រោមនេះបង្ហាញអំពីលក្ខណវិនិច្ឆ័យទាំង **២** នៃសូចនាករលំអិតE៣ និងជាកម្មវត្ថុនៃការពិភាក្សាដើម្បីធ្វើការណែនាំដល់ទីក្រុងបេក្ខភាពក្នុងការប្រឡងប្រណាំងទីក្រុងស្អាត។

| **លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|
| E៣.១.វត្តមាននៃ**ការត្រួតពិនិត្យភាពស្អាតរបស់ទឹក** (ទន្លេ ស្ទឹង សមុទ្រ) | មាន-មិនមាន | ១ |
| E៣.២.វត្តមាននៃ**ការត្រួតពិនិត្យភាពស្អាតរបស់ទឹកសម្រាប់បរិភោគ** | មាន-មិនមាន | ១ |

***(ផ្តល់ពិន្ទុ ២/១៣ នៃពិន្ទុសរុបរបស់សូចនាករគោលនៃការគ្រប់គ្រងនិងរៀបចំបរិស្ថាន)***

# ការណែនាំសម្រាប់បេក្ខភាព

## ១. លក្ខណវិនិច្ឆ័យ E៣.១៖

*"វត្តមាននៃ**ការត្រួតពិនិត្យភាពស្អាតរបស់ទឹក** (ទន្លេ ស្ទឹង សមុទ្រ)។"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**មាន**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| **ល.រ** | **ពាក្យគន្លឹះ** | **សេចក្តីពន្យល់** |
|---|---|---|

[7] តារាងទី៤១

| | | |
|---|---|---|
| ១ | ការត្រួតពិនិត្យភាពស្អាតរបស់ ទឹក | សំដៅដល់**<u>យន្តការផ្សេងៗ</u>**ដែលបានដាក់ចេញដោយអាជ្ញាធរមានសមត្ថកិច្ចដើម្បីធ្វើការតាមដានត្រួតពិនិត្យលើគុណភាព**<u>ទឹកប្រើប្រាស់ដែលជាប្រភពទឹកសាធារណៈ</u>**។ ការត្រួតពិនិត្យនេះមានន័យដូចគ្នានឹង**<u>ការត្រួតពិនិត្យការបំពុលទឹក</u>**ដោយយោងតាមកំរិតកំណត់ស្តង់ដាគុណភាពទឹករបស់ក្រសួងបរិស្ថាន។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យE៣.១ តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ប្រសិទ្ធិភាព"** នៃវិធានការនៃការត្រួតពិនិត្យភាពស្អាតរបស់ទឹកដែលជាប្រភពទឹកសាធារណៈ។ វិធានការនេះអាចជាបទដ្ឋានណាមួយដែលចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិថ្នាក់ក្រុងនោះផ្ទាល់ ឬមួយក៏រដ្ឋបាលថ្នាក់ក្រោមជាតិថ្នាក់ទីក្រុងនោះដើរតួជាអ្នកអនុវត្ត។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបញ្ជាក់នូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យគណៈកម្មាធិការជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៤ គឺ៖

- ផ្តល់ព័ត៌មានអំពីចំនួននិងទីតាំងនៃប្រភពទឹកសាធារណៈទាំងអស់ដែលមាន
- បង្ហាញអំពីវត្តមានវិធានការនៃការត្រួតពិនិត្យភាពស្អាតរបស់ទឹកនៅតាមប្រភពទឹកទាំងនោះ
- បង្ហាញអំពីវត្តមានអង្គភាពទទួលខុសត្រូវអនុវត្តវិធានការនេះ
- បង្ហាញអំពីសកម្មភាពអនុវត្តជាក់ស្តែងរបស់អង្គភាពនោះ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យE៣.១ ក៏ដូចជាការណែនាំដល់បេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៤ ខាងលើ។

| **តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ□៣.១** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ឧស្សាហកបញ្ជាក់** |
| ១ | ព័ត៌មានអំពីចំនួន និងទីតាំងប្រភពទឹកសាធារណៈដែលមាន | ស្រង់ស្ថិតិអំពីប្រភពទឹកដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីទឹកន្លែងទាំងនោះ | - តារាងសម្រង់ស្ថិតិ[8]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបរាងជាផែនទីទីក្រុងដែលមានបញ្ជាក់ចំនុចទីតាំងប្រភពទឹកទាំងនោះ។ | - ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានយន្តការត្រួតពិនិត្យភាពស្អាតរបស់ទឹក | រៀបរាងជាវិធាន យន្តការ ឬបទដ្ឋានផ្សេងៗសម្រាប់អនុវត្តការត្រួតពិនិត្យគុណភាពទឹកយោងតាមការណែនាំរបស់ក្រសួងបរិស្ថាន | - សេចក្តីសម្រេច ឬដីកា ឬនីតិវិធីផ្សេងៗដែលមានតម្លៃស្មើស្មើពីការកំណត់យន្តការត្រួតពិនិត្យភាពស្អាតរបស់ទឹក |

[8] តារាងទី០៨

| | | | |
|---|---|---|---|
| ៣ | វត្តមានអង្គភាពមានសមត្ថកិច្ចដែលទទួលខុសត្រូវលើការត្រួតពិនិត្យ | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | - សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៤ | សកម្មភាពជាក់ស្តែង | ធ្វើការបែងចែកជាក្រុមការងារតូចៗសម្រាប់ចុះត្រួតពិនិត្យ (ក្រុមល្បាត) | -បញ្ជីរាយនាមក្រុមការងារទាំងនោះដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុង ឬអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបចំជាតារាងផែនការសកម្មភាព | -តារាងផែនការសកម្មភាព[9]របស់អង្គភាពដែលទទួលខុសត្រូវការងារនេះ |
| | *និង* | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច<br>- រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែង |

## ២. លក្ខណវិនិច្ឆ័យ E៣.២៖

*"វត្តមាននៃ__ការត្រួតពិនិត្យភាពស្អាតរបស់ទឹកសម្រាប់បរិភោគ__។"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា__មាន__"*

### ក. សេចក្តីពន្យល់

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ការត្រួតពិនិត្យភាពស្អាតរបស់ទឹកសម្រាប់បរិភោគ | សំដៅដល់**__យន្តការផ្សេងៗ__**ដែលបានដាក់ចេញដោយអាជ្ញាធរមានសមត្ថកិច្ចដើម្បីធ្វើការតាមដានត្រួតពិនិត្យលើគុណភាព**__ទឹកសម្រាប់បរិភោគដែលបានឆ្លងកាត់ប្រព័ន្ធចំរោះ ឬ វេចខ្ចប់តាមបទដ្ឋានបច្ចេកទេសផ្សេងៗ__**។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យE៣.២ តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ប្រសិទ្ធិភាព"** នៃយន្តការការត្រួតពិនិត្យភាពស្អាតរបស់ទឹកសម្រាប់បរិភោគ។ យន្តការនេះអាចជាវិធាន ឬបទដ្ឋានណាមួយ ដែលចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិថ្នាក់ទីក្រុងនោះផ្ទាល់ ឬមួយក៏រដ្ឋបាលថ្នាក់ក្រោមជាតិថ្នាក់ទីក្រុងនោះដើរតួជាអ្នកអនុវត្ត។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបញ្ជាក់នូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យគណៈកម្មាធិការជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៤ គឺ៖

- ផ្តល់ព័ត៌មានអំពីចំនួននិងទីតាំងនៃប្រភពផ្គត់ផ្គង់ទឹកសម្រាប់បរិភោគទាំងអស់ដែលមាន
- បង្ហាញអំពីវត្តមានយន្តការនៃការត្រួតពិនិត្យភាពស្អាតរបស់ទឹកនៅតាមប្រភពផ្គត់ផ្គង់ទាំងនោះ
- បង្ហាញអំពីវត្តមានអង្គភាពទទួលខុសត្រូវអនុវត្តយន្តការនេះ

[9] តារាងទី៤២

- បង្ហាញអំពីសកម្មភាពអនុវត្តជាក់ស្តែងរបស់អង្គភាពនោះ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យE៣.២ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៤ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ□៣.២ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
| ១ | ព័ត៌មានអំពីចំនួន និង ទីតាំងប្រភពផ្គត់ផ្គង់ទឹកសម្រាប់បរិភោគដែលមាន | ស្រង់ស្ថិតិអំពីប្រភពផ្គត់ផ្គង់ទឹកសម្រាប់បរិភោគដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | -តារាងសម្រង់ស្ថិតិ[10]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានយន្តការត្រួតពិនិត្យភាពស្អាតរបស់ទឹកសម្រាប់បរិភោគ | រៀបរាងជាវិធាន យន្តការ ឬបទដ្ឋានផ្សេងៗសម្រាប់អនុវត្តការត្រួតពិនិត្យគុណភាពទឹកសម្រាប់បរិភោគ | -សេចក្តីសម្រេច ឬដីកា ឬនីតិវិធីផ្សេងៗដែលមានតម្លៃស្មើស្តីពីការកំណត់យន្តការត្រួតពិនិត្យភាពស្អាតរបស់ទឹកសម្រាប់បរិភោគ |
| ៣ | វត្តមានអង្គភាពមានសមត្ថកិច្ចទទួលខុសត្រូវលើការត្រួតពិនិត្យ | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៤ | សកម្មភាពជាក់ស្តែង | ធ្វើការបែងចែកជាក្រុមការងារតូចៗសម្រាប់ចុះត្រួតពិនិត្យ (ក្រុមល្បាត) | -បញ្ជីរាយនាមក្រុមការងារទាំងនោះ ដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុង ឬអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបចំជាតារាងផែនការសកម្មភាព | -តារាងផែនការសកម្មភាព[11]របស់អង្គភាពដែលទទួលខុសត្រូវការងារនេះ |
| | *និង* | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច<br>- រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែង |

## E៤. សូចនាករលំអិតនៃគុណភាពខ្យល់

### កម្មវត្ថុនៃសូចនាករលំអិត E៤

មនុស្សគ្រប់រូបតែងចង់រស់នៅដោយមានសេចក្តីសុខនិងជាសុខភាព ពោលគឺរស់នៅប្រកបដោយ**សុខសុវត្ថិភាព**

[10] តារាងទី០៩

[11] តារាងទី៤២

និងមាន**សុខភាពល្អបរិបូណ៌**។ នៅក្នុងប៉ុន្មានទសវត្សចុងក្រោយនេះ អ្នកវិទ្យាសាស្ត្របានអះអាងថា ប្រជាជនដែលរស់នៅក្នុងតំបន់ទីក្រុងមានសុខភាពខ្សោយជាងប្រជាជនដែលរស់នៅនៅតាមទីជនបទ ដោយហេតុថាពួកគេមានប្រព័ន្ធភាពស៊ាំខ្សោយជាង និងស្រូបយកជាតិពុលពីបរិយាកាសច្រើនជាងប្រជាជនដែលរស់នៅនៅតាមតំបន់ជនបទដែលនៅជិតធម្មជាតិ។

ដូច្នេះ ការបំពុលខ្យល់ជាមូលហេតុយ៉ាងសំខាន់ដែលបង្កឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពមនុស្សដែលរស់នៅក្នុងបរិយាកាសនោះផ្ទាល់។ **ការលើកកម្ពស់គុណភាពខ្យល់ចូលរួមចំណែកយ៉ាងសំខាន់ដល់ការលើកកម្ពស់សុខភាពរបស់ប្រជាជនដែលរស់នៅក្នុងមជ្ឈដ្ឋាននោះផ្ទាល់** និងចូលរួមដល់ការលើកកម្ពស់សោភណ្ឌភាពទីក្រុងនោះ ព្រមទាំងបង្កើននូវភាពទាក់ទាញរបស់ខ្លួនដល់ភ្ញៀវទេសចរមកទស្សនាកំសាន្ត ឬឆ្លងកាត់ផងដែរ។

តារាងខាងក្រោមនេះបង្ហាញអំពីលក្ខណវិនិច្ឆ័យតែមួយគត់ នៃសូចនាករលំអិតE៤ និងជាកម្មវត្ថុនៃការពិភាក្សាដើម្បីធ្វើការណែនាំដល់ទីក្រុងបេក្ខភាពក្នុងការប្រឡងប្រណាំងទីក្រុងស្អាត។

| លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| E៤.១.មាន**<u>វិធានការដែលទាក់ទងនឹងគុណភាពខ្យល់</u>** (ឧទាហរណ៍ គំរោងនៃការកាត់បន្ថយការស្ទះចរាចរណ៍) | មាន-មិនមាន | ១ |

*(ផ្តល់ពិន្ទុ ១/១៣ នៃពិន្ទុសរុបរបស់សូចនាករគោលនៃការគ្រប់គ្រងនិងរៀបចំបរិស្ថាន)*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

**លក្ខណៈវិនិច្ឆ័យ** E៤.១៖

*"មាន**<u>វិធានការដែលទាក់ទងនឹងគុណភាពខ្យល់</u>** (ឧទាហរណ៍ គំរោងនៃការកាត់បន្ថយការស្ទះចរាចរណ៍)។"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**<u>មាន</u>**"*

## ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | វិធានការដែលទាក់ទងនឹងគុណភាពខ្យល់ | សំដៅដល់វិធានការ យន្តការ ឬសកម្មភាពផ្សេងៗដែលចូលរួមដល់ការកាត់បន្ថយការបំពុលខ្យល់ ក្នុងន័យចូលរួមដល់ការលើកកម្ពស់គុណភាពខ្យល់នៃទីក្រុងនោះឲ្យមានភាពប្រសើរឡើង ឬកាន់តែល្អប្រសើរឡើង។<br><br>វិធានការដែលទាក់ទងនឹងគុណភាពខ្យល់នេះ **<u>អាចជាវិធានការលើកទឹកចិត្ត វិធានការជំរុញការអនុវត្ត ឬគំរោងអនុវត្តផ្ទាល់របស់ទីក្រុងបេក្ខភាព</u>**ផ្ទាល់តែម្តង។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យE៤.១ តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ អាចមាន **០៣** ករណីផ្សេងៗគ្នាដែលក្នុងករណីនីមួយៗរាល់ព័ត៌មានដែលទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក គ.ជ.វ.ទ. ត្រូវភ្ជាប់មកជាមួយនូវភស្តុតាងបញ្ជាក់។

**<u>ករណីទី១</u>៖ ជាប្រភេទ "វិធានការលើកទឹកចិត្ត"**

- បង្ហាញពីវត្តមាននៃវិធានការ ឬយន្តការសម្រាប់លើកទឹកចិត្តដល់ប្រជាជនក៏ដូចជាគ្រប់ភាគីពាក់ព័ន្ធឲ្យចូលរួមដល់ការកាត់បន្ថយការបំពុលខ្យល់
- បង្ហាញពីវត្តមានអ្នកទទួលខុសត្រូវលើការអនុវត្តការងារនេះ
- បង្ហាញពីលទ្ធផលដែលសម្រេចបាន។

**<u>ករណីទី២</u>៖ ជាប្រភេទ "វិធានការជំរុញការអនុវត្ត"**

- បង្ហាញពីវត្តមាននៃវិធានការ ឬយន្តការសម្រាប់ជំរុញការអនុវត្តរបស់ប្រជាជនក៏ដូចជាគ្រប់ភាគីពាក់ព័ន្ធក្នុងន័យចូលរួមដល់ការកាត់បន្ថយការបំពុលខ្យល់
- បង្ហាញពីវត្តមានអ្នកទទួលខុសត្រូវលើការអនុវត្តការងារនេះ
- បង្ហាញពីសកម្មភាពអនុវត្តជាក់ស្តែង។

**<u>ករណីទី៣</u>៖ ជាប្រភេទ "គំរោងផ្សេងៗ[12]ដែលមានកម្មវត្ថុចូលរួមដល់ការកាត់បន្ថយការបំពុលខ្យល់"។** ក្នុងករណីនេះយើងចែកចេញជា **០៣** ចំនុចតូចផ្សេងៗគ្នាបន្តទៀតគឺ៖

**<u>ទី១</u>៖** ប្រសិនបើមានគំរោងណាមួយត្រូវបានដាក់ឲ្យអនុវត្តរួចហើយ ហើយបានអនុវត្តចប់សព្វគ្រប់

- បង្ហាញពីរបាយការណ៍បូកសរុបលទ្ធផល។

**<u>ទី២</u>៖** ប្រសិនបើមានគំរោងណាមួយត្រូវបានដាក់ឲ្យអនុវត្តរួចហើយ ហើយកំពុងតែអនុវត្តគិតដល់ថ្ងៃដាក់ពាក្យសុំចូលរួមការប្រឡងប្រណាំង

- បង្ហាញពីរបាយការណ៍ស្តីពីយន្តការអនុវត្តគំរោង និងទិដ្ឋភាពផ្សេងៗ
- បង្ហាញពីវត្តមានអ្នកទទួលខុសត្រូវលើការបន្តការអនុវត្តគំរោងនេះ
- បង្ហាញពីរបាយការណ៍បច្ចុប្បន្នភាពគំរោង។

**<u>ទី៣</u>៖** ប្រសិនបើគំរោងទាំងអស់ដែលមានស្ថិតនៅជាផែនការនៅឡើយ

- បង្ហាញពីព័ត៌មានគំរោងទាំងអស់ដែលមាន
- បង្ហាញពីវត្តមានអ្នកទទួលខុសត្រូវលើការអនុវត្តគំរោងនេះ
- បង្ហាញពីសកម្មភាពអនុវត្តជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យE៤.១ ក៏ដូចជាការណែនាំដល់បេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវនីមួយៗនៃករណីទាំង **០៣** ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ□៤.១ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| **ករណីទី១៖ "វិធានការលើកទឹកចិត្ត"** | | | |
| ១ | វត្តមានវិធានការលើកទឹកចិត្តឲ្យមានការចូល | រៀបចំចងក្រងជាយន្តការ វិធាន ឬនីតិវិធីផ្សេងៗដែលមានកម្មវត្ថុទាក់ទង | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីយន្តការផ្សេងៗដែល |

[12]**បញ្ជាក់៖** ចំពោះទីក្រុងបេក្ខភាពទាំងឡាយណាដែលមានគំរោងអភិវឌ្ឍទីក្រុងលើសពី១ ហើយមានគំរោងខ្លះចងក្រងរួច និងខ្លះទៀតមិនទាន់ចងក្រងរួច នោះចំពោះគំរោងផែនការដែលចងក្រងរួចត្រូវគោរពតាមលក្ខខណ្ឌដូមមានចែងក្នុងករណីទី១ និងចំពោះគំរោងផែនការដែលមិនទាន់ចងក្រងរួចរាល់ត្រូវគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងករណីទី២។

| | | | |
|---|---|---|---|
| | រួមដល់ការកាត់បន្ថយការបំពុលខ្យល់ | នឹងការលើកទឹកចិត្តឲ្យដល់ប្រជាជនក៏ដូចជាសាធារណជនទាំងឡាយចូលរួមដល់ការកាត់បន្ថយការបំពុលខ្យល់ | លើកទឹកចិត្តដល់សាធារណជនឲ្យចូលរួមដល់ការកាត់បន្ថយការបំពុលខ្យល់ |
| ២ | វត្តមានអង្គភាពទទួលខុសត្រូវលើការអនុវត្ត | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្ដីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្ដីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៣ | លទ្ធផលដែលសម្រេចបាន | រៀបចំជាសម្រង់ស្ថិតិគ្រប់ភាគីដែលបានចូលរួមជាមួយនឹងយន្តការដែលបានដាក់ចេញ | -បញ្ជីរាយនាម[13]ដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុង ឬអាជ្ញាធរមានសមត្ថកិច្ច |
| **ករណីទី២៖ "វិធានការជំរុញការអនុវត្ត"** | | | |
| ១ | វត្តមានវិធានការជំរុញការអនុវត្ត | រៀបចំចងក្រងជាយន្តការ វិធានការ ឬនីតិវិធីផ្សេងៗដែលមានកម្មវត្ថុទាក់ទងនឹងការជំរុញការអនុវត្តដល់ប្រជាជនក៏ដូចជាសាធារណជនទាំងឡាយឲ្យបញ្ឈប់នូវរាល់សកម្មភាពដែលបង្កផលប៉ះពាល់ដល់បរិយាកាសក្នុងទីក្រុង | -សេចក្ដីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្ដីពីយន្តការផ្សេងៗដែលកំណត់និងដាក់ពិន័យចំពោះសកម្មភាពអសកម្មដែលជាមូលហេតុនៃការបំពុលខ្យល់ |
| ២ | វត្តមានអង្គភាពទទួលខុសត្រូវលើការអនុវត្ត | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្ដីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្ដីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៣ | សកម្មភាពជាក់ស្ដែង | ធ្វើការបែងចែកជាក្រុមការងារតូចៗសម្រាប់ ចុះត្រួតពិនិត្យ (ក្រុមល្បាត) | -បញ្ជីរាយនាមក្រុមការងារទាំងនោះ ដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុង ឬអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបចំជាតារាងផែនការសកម្មភាព | -តារាងផែនការសកម្មភាព[14]របស់អង្គភាពដែលទទួលខុសត្រូវការងារនេះ |
| | ***និង*** | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច<br>- រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីសកម្មភាពជាក់ស្ដែង |
| **ករណីទី៣៖ "គំរោងផ្សេងៗដែលមានកម្មវត្ថុចូលរួមដល់ការកាត់បន្ថយការបំពុលខ្យល់"** | | | |
| **ស្ថានភាពទី១៖ គំរោងគ្រួសារឋានអនុវត្តចប់សព្វគ្រប់** | | | |

[13] តារាងទី៣៩

[14] តារាងទី៤២

| | | | |
|---|---|---|---|
| ១ | របាយការណ៍លទ្ធផលដែលទទួលបានពីការអនុវត្តគំរោង | រៀបចំជារបាយការណ៍លទ្ធផលមួយដែលបង្ហាញអំពីការវាយតម្លៃរបស់អ្នកអនុវត្តលើគំរោងនេះ | -របាយការណ៍លទ្ធផលដែលមានការបញ្ជាក់ពីអង្គភាពទទួលខុសត្រូវអនុវត្តគំរោង ឬអាជ្ញាធរដែលមានសមត្ថកិច្ច |
| **ស្ថានភាពទី២៖ គំរោងកំពុងអនុវត្ត** | | | |
| ១ | របាយការណ៍ស្តីពីយន្តការអនុវត្តគំរោង និងទិដ្ឋភាពផ្សេងៗ | រៀបចំជារបាយការណ៍វាយការណ៍លំអិតអំពីយន្តការអនុវត្តគំរោងដែលបានដាក់ឲ្យអនុវត្ត | -របាយការណ៍ស្តីពីយន្តការអនុវត្តគំរោងដែលមានការបញ្ជាក់សុពលភាពពីអង្គភាពទទួលខុសត្រូវអនុវត្តគំរោង ឬអាជ្ញាធរដែលមានសមត្ថកិច្ច |
| ២ | វត្តមានអង្គភាពទទួលខុសត្រូវ | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៣ | របាយការណ៍វាយតម្លៃការអនុវត្តគំរោង | រៀបចំជារបាយការណ៍វាយតម្លៃលទ្ធផលនៃការអនុវត្តគំរោងប្រចាំខែ | -របាយការណ៍វាយតម្លៃលទ្ធផលដែលមានការបញ្ជាក់ពីអង្គភាពទទួលខុសត្រូវអនុវត្តគំរោង ឬអាជ្ញាធរដែលមានសមត្ថកិច្ច |
| **ស្ថានភាពទី៣៖ គំរោងទាំងអស់ស្ថិតនៅជាផែនការ** | | | |
| ១ | ព័ត៌មានអំពីគំរោងទាំងអស់ដែលមាន | ធ្វើសម្រង់ស្ថិតិអំពីគំរោងដែលអាចចូលរួមដល់ការកាត់បន្ថយការបំពុលខ្យល់ | -តារាងសម្រង់ស្ថិតិ[15]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអង្គភាពទទួលខុសត្រូវលើការអនុវត្ត | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៣ | សកម្មភាពជាក់ស្តែង | រៀបចំជាតារាងផែនការសកម្មភាព | -តារាងផែនការសកម្មភាព[16]របស់អង្គភាពដែលទទួលខុសត្រូវការងារនេះ |
| | *និង* | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច<br>- រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែង |

# E៥. សូចនាករលំអិតនៃការប្រយុទ្ធប្រឆាំងនឹងការបំពុលដោយសម្លេង

## កម្មវត្ថុសូចនាករលំអិត E៥

ការរំខានផ្សេងៗ ដែលអាចប៉ះពាល់ដល់បរិស្ថានរស់នៅរបស់ប្រជាពលរដ្ឋអាចកើតមានឡើងក្រោមរូបភាពច្រើន

[15] តារាងទី៤៣

[16] តារាងទី៤២

ក្នុងនោះការរំខានដោយសម្លេងក៏ជាមូលហេតុចំបងមួយត្រូវមានការគិតគូរឲ្យហ្មត់ចត់ថ្វីត្បិតការរំខានដោយសម្លេងភាគច្រើនត្រូវបានចាត់ទុកថាជារឿងសាមញ្ញ ដែលតែងតែកើតមានជារឿយៗនិងជាធម្មតានៅតាមទីប្រជុំជននានា ប៉ុន្តែ យើងក៏គួរពិចារណាចំពោះចំនុចមួយចំនួន ដូចខាងក្រោមនេះ៖

- នៅតាមមន្ទីរពេទ្យ ទីវត្តអារាម ទីសក្ការបូជានានា បណ្ណាល័យ...។ល។ តើការរំខានដោយសម្លេងជាបញ្ហាប្រក្រតីដែរឬទេ?
- អ្នកជិតខាងរបស់អ្នកឡូឡា ឬជប់លៀងស្រែកច្រៀងនៅពេលយប់អាធ្រាត តើនេះជាករណីធម្មតាដែរឬទេ?

ថ្វីត្បិតការរំខានដោយសម្លេងផ្សេងៗពេលខ្លះត្រូវបានចាត់ទុកថាជាបញ្ហាធម្មតា និងពេលខ្លះមិនមែនជាបញ្ហាធម្មតាដែលត្រូវឲ្យ**យើងគិតគូរពីមជ្ឈដ្ឋានជុំវិញ (កន្លែង និងទីតាំងដែលទទួលរងការបំពុលរំខានដោយសម្លេង) និងម៉ោងពេលផងដែរ**។

នទេសចរជាទីសម្រាកកំសាន្តលំហែសម្រាប់សាធារណៈជនទាំងឡាយ ដូចនេះ ភាព

| លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| E៥.១.វត្តមាននៃ**វិធានការប្រយុទ្ធប្រឆាំងនឹងការបំពុលដោយសម្លេង** (សម្លេង មីក្រូ ខារ៉ាអូខេ។ល។) | មាន-មិនមាន | ១ |

*(ផ្តល់ពិន្ទុ ១/១៣ នៃពិន្ទុសរុបរបស់សូចនាករគោលនៃការគ្រប់គ្រងនិងរៀបចំបរិស្ថាន)*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណៈវិនិច្ឆ័យ E៥.១៖

*"វត្តមាននៃ**វិធានការប្រយុទ្ធប្រឆាំងនឹងការបំពុលដោយសម្លេង** (សម្លេងមីក្រូ ខារ៉ាអូខេ។ល។)"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**មាន**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | វិធានការប្រយុទ្ធប្រឆាំងនឹងការបំពុលដោយសម្លេង | សំដៅដល់**វិធានការ យន្តការឬសកម្មភាពផ្សេងៗ**ដែលសំដៅទប់ស្កាត់និងដាក់ពិន័យរាល់ការរំខានផ្សេងៗដែលបង្កឡើងដោយសម្លេងដែលបញ្ចេញពីប្រភពបំពុលទាំងឡាយក្រោមរូបភាពផ្សេងៗ។<br><br>តាមរយៈលក្ខណវិនិច្ឆ័យនេះ វិធានការទប់ស្កាត់នឹងការរំខានដោយសម្លេងផ្តោតជាសំខាន់លើ**វិធានការជំរុញការអនុវត្ត**ជាក់ស្តែងតែមួយគត់ ដោយហេតុថាការរំខានប្រភេទនេះ**មានលក្ខណៈដោយប្រយោលខ្លាំង**។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថាអ្វីដែលលក្ខណវិនិច្ឆ័យE៥.១ តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**ប្រសិទ្ធិភាព**" នៃវិធានការនៃការប្រយុទ្ធប្រឆាំងនឹងការបំពុលដោយសម្លេង។ វិធានការនេះសំដៅកំណត់ត្រឹមវិធានការជំរុញការអនុវត្តតែមួយគត់។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យគណៈកម្មាធិការជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៣ គឺៈ

- បង្ហាញអំពីវត្តមានវិធានការប្រយុទ្ធប្រឆាំងនឹងការបំពុលដោយសម្លេង ដែលបានដាក់អនុវត្ត
- បង្ហាញអំពីវត្តមានអង្គភាពទទួលខុសត្រូវអនុវត្តវិធានការនេះ
- បង្ហាញអំពីសកម្មភាពអនុវត្តជាក់ស្តែងរបស់អង្គភាពនោះ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យE៥.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខ-ភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណាវនិច្ឆ័យ□៥.១ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
| ១ | វត្តមានវិធានការប្រយុទ្ធប្រឆាំងនឹងការបំពុលដោយសម្លេង | រៀបចំជាវិធាន យន្តការ ឬបទដ្ឋានផ្សេងៗសម្រាប់ទប់ស្កាត់និងដាក់ពិន័យចំពោះរាល់សកម្មភាពដែលជាប្រភពនៃសម្លេងរំខាន | -សេចក្តីសម្រេច ឬដីកា ឬនីតិវិធីផ្សេងៗដែលមានតម្លៃស្មើស្តីពីការកំណត់វិធានការទប់ស្កាត់រាល់ការរំខានដោយសម្លេង |
| ២ | វត្តមានអង្គភាពមានសមត្ថកិច្ចដែលទទួលខុសត្រូវ | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៣ | សកម្មភាពជាក់ស្តែង | ធ្វើការបែងចែកជាក្រុមការងារតូចៗសម្រាប់ ចុះត្រួតពិនិត្យ (ក្រុមល្បាត) | -បញ្ជីរាយនាមក្រុមការងារទាំងនោះ ដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុង ឬអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបចំជាតារាងផែនការសកម្មភាព | -តារាងផែនការសកម្មភាព[17]របស់អង្គភាពដែលទទួលខុសត្រូវ |
| | *និង* | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច<br>- រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែង |

# E៦. សូចនាករលំអិតនៃដៃគូសហប្រតិបត្តិការ

## កម្មវត្ថុសូចនាករលំអិត E៦

ការអភិវឌ្ឍទីក្រុងតំរូវឲ្យមានការចូលរួមគាំទ្រពីគ្រប់ភាគី ដែលក្នុងនោះកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍគឺ

[17] តារាងទី៤២

ជាកត្តាមិនអាចខ្វះបានសំរាប់បណ្តាប្រទេសកំពុងអភិវឌ្ឍ ពោលគឺការអភិវឌ្ឍជាការងារចំបងមួយដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវស្វែងរកកិច្ចសហការ ជាពិសេសលើផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីបណ្តាគ្រប់ដៃគូអភិវឌ្ឍនានា និងភាគីពាក់ព័ន្ធដទៃទៀត។ យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រដ្ឋបាលថ្នាក់ក្រោមជាតិតាមលំដាប់ថ្នាក់ទាំងនេះ មានសិទ្ធិ និងកាតព្វកិច្ចមើលការខុសត្រូវផ្ទាល់ និងអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនតាមតួនាទី និងភារកិច្ចដូចដែលច្បាប់ប្រគល់ជូន។

ដោយសម្លឹងមើលឃើញអំពីសារសំខាន់នៃភាពជាដៃគូសហប្រតិបត្តិការនេះហើយ ទើបចំនុចនេះត្រូវបានចាត់ចូលជាសូចនាករលំអិត១នៃសូចនាករគោលស្តីពីការគ្រប់គ្រងនិងរៀបចំបរិស្ថាននេះ។

| **លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|
| E៦.១.វត្តមាន**<u>ដៃគូសហប្រតិបត្តិការ</u>** *(ដូចជា អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងសហប្រតបត្តិការនៅក្នុងតំបន់ ដែលទាក់ទងនឹងការបញ្ជ្រាបការយល់ដឹង ភាពស្អាត និងការគ្រប់គ្រងសំណល់)* | មាន-មិនមាន | ១ |

***(ផ្តល់ពិន្ទុ ១/១៣ នៃពិន្ទុសរុបរបស់សូចនាករគោលនៃការគ្រប់គ្រងនិងរៀបចំបរិស្ថាន)***

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណៈវិនិច្ឆ័យ E៦.១៖

*"វត្តមាន**<u>ដៃគូសហប្រតិបត្តិការ</u>** (ដូចជា អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងសហប្រតិបត្តិការនៅក្នុងតំបន់ដែលទាក់ទងនឹងការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថាន ភាពស្អាតឬការគ្រប់គ្រងសំណល់)"*

*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា<u>មាន</u>"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| **ល.រ** | **ពាក្យគន្លឹះ** | **សេចក្តីពន្យល់** |
|---|---|---|
| ១ | ដៃគូសហប្រតិបត្តិការ | សំដៅដល់**<u>នីតិបុគ្គល ឬរូបវន្តបុគ្គល</u>** ដែលអាចជាស្ថាប័នសាធារណៈ ឯកជន ជាតិ អន្តរជាតិ ឯករាជ្យ មានគោលបំណងដើម្បីសប្បុរសធម៌ អភិវឌ្ឍ អភិរក្ស ឬ**<u>គោលបំណងស្របច្បាប់</u>**ផ្សេងៗទៀត និងដែលដើរតួជាភាគីមួយ**<u>ចូលរួម</u>**ដល់ការអនុវត្តគំរោងអភិវឌ្ឍផ្សេងៗដែលអាជ្ញាធរទីក្រុងបេក្ខភាពនោះបានដាក់ចេញ។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យE៦.១ តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**ឯកសារ**" សម្រង់ព័ត៌មានអំពីដៃគូសហប្រតិបត្តិការ ឬអភិវឌ្ឍនានាដែលរដ្ឋបាលថ្នាក់ក្រោមជាតិថ្នាក់ក្រុង/ខណ្ឌបានធ្វើការសហការក្នុងការបំពេញការងារកន្លងមក។ ក្នុងន័យនេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យគណៈកម្មាធិការជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០២** គឺ៖

- ព័ត៌មានអំពីគំរោងអភិវឌ្ឍនានាដែលមាន និងដែលពាក់ព័ន្ធទៅនឹងលក្ខខណ្ឌតម្រូវនានានៃសូចនាករគោលទី១នេះ
- បង្ហាញអំពីវត្តមានដៃគូសហប្រតិបត្តិការដែលចូលរួមអនុវត្តគំរោងអភិវឌ្ឍទាំងនេះ

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យE៦.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០២ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវនិច្ឆ័យ៦.១ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
| ១ | ព័ត៌មានអំពីគំរោងអភិវឌ្ឍនានាដែលមាន | ធ្វើសម្រង់ស្ថិតិអំពីគំរោងទាំងឡាយដែលពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវនានានៃសូចនាករគោលទី១ | -តារាងសម្រង់ស្ថិតិដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានដៃគូសហប្រតិបត្តិការដែលចូលរួមក្នុងការអនុវត្តគំរោងអភិវឌ្ឍនីមួយៗ | ធ្វើសម្រង់ស្ថិតិអំពីដៃគូសហប្រតិបត្តិការដែលបានចូលរួមក្នុងការអនុវត្តគំរោង | -តារាងសម្រង់ស្ថិតិដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច<br>-លិខិតបញ្ជាក់ពីការចូលរួមរបស់ដៃគូសហប្រតិបត្តិការ |

## E៧. សូចនាករលំអិតនៃការធ្វើដំណើរដែលគិតគូរដល់បរិស្ថាន

### កម្មវត្ថុសូចនាករលំអិត E៧

ការរស់នៅ និងសុខមាភាពរស់នៅរបស់ប្រជាជនពឹងផ្អែកសំខាន់លើបរិស្ថានមួយដែលស្អាតបរិសុទ្ធ។ ក្នុងន័យនេះ ការចូលរួមថែរក្សាបរិស្ថាននឹងបានជាប្រយោជន៍សំរាប់ជនគ្រប់ៗរូប។ យ៉ាងណាមិញ នៅលើពិភព- លោក ការបំពុលបរិស្ថានដែលបង្កគ្រោះថ្នាក់ជាងគេនោះ គឺ**<u>ការបំពុលបរិយាកាស</u>**។ គេសង្កេតឃើញថា ការបំពុលបរិយាកាស នៅក្នុងទីក្រុងភាគច្រើន គឺបណ្ដាលមកពី**<u>ឧស្ម័នកាបូនឌីអុកស៊ីត</u>**ដែលកើតចេញពី**<u>ចំហេះប្រេងឥន្ធនៈក្នុងយានយន្ត</u>**។

លក្ខណវិនិច្ឆ័យE៧.១.មានគោលបំណងដូចគ្នានឹងលក្ខណវិនិច្ឆ័យE៤.១. *(ស្ដីពីការបំពុលខ្យល់)*។ប៉ុន្តែ អ្វីដែលខុសគ្នាគឺគ្រាន់តែលក្ខណវិនិច្ឆ័យនេះផ្ដោតចំពោះវិធានការកាត់បន្ថយការបំពុលខ្យល់និងឈានដល់យន្ត-ការដាក់ឲ្យមានមធ្យោបាយធ្វើដំណើរដែលមានការគិតគូរដល់បរិស្ថាន។

| លក្ខណវនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| E៧.១.វត្តមាននៃមធ្យោបាយធ្វើដំណើរដែលលើកទឹកចិត្តដល់ការគិតគូរពីបរិស្ថាន (ឧទាហរណ៍ដូចជា រថយន្តក្រុង រថយន្តធ្វើដំណើរដោយថាមពលអគ្គិសនី។ល។) | មាន-មិនមាន | ១ |

*(ផ្ដល់ពិន្ទុ ១/១៣ នៃពិន្ទុសរុបរបស់សូចនាករគោលនៃការគ្រប់គ្រងនិងរៀបចំបរិស្ថាន)*

## ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

**១. លក្ខណវនិច្ឆ័យ E៧.១៖**

*"វត្តមាននៃ**<u>មធ្យោបាយធ្វើដំណើរដែលលើកទឹកចិត្តដល់ការគិតគូរពីបរិស្ថាន</u>** (ឧទាហរណ៍ដូចជា រថយន្តក្រុង រថយន្តធ្វើដំណើរដោយថាមពលអគ្គិសនី ។ល។)"*

*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**<u>មាន</u>**"*

## ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | មធ្យោបាយធ្វើដំណើរដែលលើកទឹកចិត្តដល់ការគិតគូរពីបរិស្ថាន | សំដៅដល់**<u>របៀបនៃការធ្វើដំណើរសាធារណៈ</u>**ទាំងឡាយណាដែល**<u>មិនបង្កផលប៉ះពាល់</u>**ជាអវិជ្ជមានដល់បរិស្ថានជុំវិញ (បរិយាកាស) ឬ**<u>បង្កផលប៉ះពាល់តិចតួច</u>** ឬ**<u>ផលប៉ះពាល់នោះត្រូវបានកាត់បន្ថយ</u>**ធៀបនឹងរបៀប (មធ្យោបាយ) ចាស់។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យE៧.១តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ប្រសិទ្ធិភាព"** នៃការជំរុញគាំទ្រឲ្យមានមធ្យោបាយធ្វើដំណើរដែលគិតគូរដល់បរិស្ថាន។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យគណៈកម្មាធិការជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៣ គឺ៖

- ព័ត៌មានអំពីប្រភេទផ្សេងៗនៃមធ្យោបាយធ្វើដំណើរសាធារណៈដែលគិតគូរដល់បរិស្ថានដែលដាក់ឲ្យដំណើរការ
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវជាប្រចាំលើមធ្យោបាយធ្វើដំណើរទាំងនោះ
- បង្ហាញអំពីលទ្ធផលដំណើរការជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យE៧.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ៧.១ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
| ១ | ព័ត៌មានអំពីប្រភេទផ្សេងៗនៃមធ្យោបាយធ្វើដំណើរសាធារណៈដែលគិតគូរដល់បរិស្ថាន | ធ្វើសម្រង់ស្ថិតិអំពីមធ្យោបាយធ្វើដំណើរសាធារណៈដែលគិតគូរដល់បរិស្ថានទៅតាមប្រភេទនីមួយៗដែលមាន | -តារាងសម្រង់ស្ថិតិ[18]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអង្គភាពមានសមត្ថកិច្ចទទួលខុសត្រូវលើមធ្យោបាយធ្វើដំណើរសាធារណៈ | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្ពីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៣ | លទ្ធផលដំណើរការជាក់ស្តែង | រៀបចំជាតារាងសកម្មភាពដំណើរការ (ចល័ត) ប្រចាំថ្ងៃ ឬប្រចាំសប្តាហ៍ | -តារាងម៉ោងពេលដំណើរការ[19]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

[18] តារាងទី១០

[19] តារាងទី១១

| | | | |
|---|---|---|---|
| | *និង* | របាយការណ៍អំពីលទ្ធផលនៃការដាក់ឲ្យដំណើរការមធ្យោបាយដឹកជញ្ជូនទាំងនេះ | -របាយការណ៍បូកសរុបលទ្ធផលដែលមានការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច |

## E៨. សូចនាករលំអិតនៃការប្រើប្រាស់ថាមពលដែលគតគូរដល់បរិស្ថាន

### កម្មវត្ថុសូចនាករលំអិត E៨

ជាការពិត មនុស្ស និងធម្មជាតិមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ។ សកម្មភាពរបស់មនុស្សតែងតែមានអំពើដោយផ្ទាល់ ដោយប្រយោលលើធម្មជាតិ និងបរិស្ថាន (អាចជាឥទ្ធិពលវិជ្ជមាន ឬអវិជ្ជមាន) ហើយពេលខ្លះប្រភពធនធានធម្មជាតិអាចសឹករិចរិលជាបន្តបន្ទាប់ដោយសារតែតំរូវការមិនចេះឈប់របស់មនុស្ស។

បច្ចុប្បន្ន ដើម្បីធានានិរន្តរភាពនៃការប្រើប្រាស់ធនធានធម្មជាតិ ការប្រើប្រាស់ប្រភពធនធានដែលកកើតឡើងវិញ ដូចជា៖ ពន្លឺព្រះអាទិត្យ ទឹក ខ្យល់... បាននឹងកំពុងត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង។

| លក្ខណាវនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| E៨.១.**<u>វត្តមានសកម្មភាព និងវិធានការលើកទឹកចិត្ត</u>**ដល់**<u>សម្បទាទេសចរណ៍</u>** *(សណ្ឋាគារ ភោជនីយដ្ឋាន។ល។)* និង**<u>ប្រជាពលរដ្ឋ</u>**ឲ្យប្រើប្រាស់**<u>ថាមពលដែលកកើតឡើងវិញ</u>** *(Renewable Energy)* | មាន-មិនមាន | ១ |
| E៨.២.ភាគរយនៃ**<u>ការប្រើប្រាស់ថាមពលដែលកកើតឡើងវិញ</u>**នៅតាម**<u>សម្បទាទេសចរណ៍</u>** *(សណ្ឋាគារ ភោជនីយដ្ឋាន។ល។)* | យ៉ាងហោចណាស់មាន៣០% នៃចំនួនសម្បទាទេសចរណ៍សរុបក្នុងទីក្រុង | ១ |
| E៨.៣.វត្តមាន**<u>សកម្មភាព និងវិធានការលើកទឹកចិត្ត</u>**ដល់**<u>សម្បទាទេសចរណ៍</u>** *(សណ្ឋាគារ ភោជនីយដ្ឋាន។ល។)* និង**<u>ប្រជាពលរដ្ឋ</u>**ក្នុង**<u>ការសន្សំសំចៃការប្រើប្រាស់</u>** *(Efficient Energy use) (ឧទាហរណ៍ ការប្រើប្រាស់អំពូលស៊ីថាមពលតិច ការប្រើប្រាស់សោរផ្តាច់អគ្គិសនីដោយស្វ័យប្រវត្តិតាមសណ្ឋាគារ។ល។)* | មាន-មិនមាន | ១ |

***(ផ្តល់ពិន្ទុ ៣/១៣ នៃពិន្ទុសរុបរបស់សូចនាករគោលនៃការគ្រប់គ្រងនិងរៀបចំបរិស្ថាន)***

## ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

### ១. លក្ខណាវនិច្ឆ័យ E៨.១៖

*"វត្តមាន**<u>សកម្មភាព និងវិធានការលើកទឹកចិត្ត</u>**ដល់**<u>សម្បទាទេសចរណ៍</u>** (សណ្ឋាគារ ភោជនីយដ្ឋាន។ល។) និង**<u>ប្រជាពល-រដ្ឋ</u>**ឲ្យប្រើប្រាស់**<u>ថាមពលដែលកកើតឡើងវិញ</u>** <u>(□□□□□□□□□□ □□□□□□□)</u>"*

*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**<u>មាន</u>**"*

## ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | សកម្មភាពនិងវិធានការលើកទឹកចិត្តឲ្យប្រើប្រាស់ថាមពលដែលកកើតឡើងវិញ | សំដៅដល់**វិធានការ ឬយន្តការលើកទឹកចិត្ត**ឲ្យប្រើប្រាស់ប្រភពថាមពលដែល**កកើតឡើងវិញ** (ការប្រើប្រាស់ប្រកបដោយនិរន្តរភាពនិងអាចប្រើប្រាស់ឡើងវិញ) ដូចជា៖ ពន្លឺព្រះអាទិត្យ ខ្យល់ ទឹក...។<br>វិធានការលើកទឹកចិត្តមិនសំដៅតែលើវិធានការជំរុញការអនុវត្តដោយចាប់បង្ខំនោះទេ។ ករណីនេះ ការលើកទឹកចិត្តគឺ(អាចជា**ការគាំទ្រខាងផ្នែកស្មារតី**ឲ្យអនុវត្តអ្វីមួយ ដោយអាចភ្ជាប់ជាមួយការ**តបស្នង**អ្វីមួយ)។ |
| ២ | សម្បទាទេសចរណ៍ | សំដៅដល់**ទីតាំងសេវាកម្ម**ទាំងឡាយណាដែលបំរើឲ្យដល់វិស័យទេសចរណ៍។ |
| ៣ | ប្រជាពលរដ្ឋ | សំដៅដល់**លំនៅដ្ឋានរបស់ប្រជាពលរដ្ឋទូទៅ**ដែលបំរើការក្នុងគោលបំណងសម្រាប់ការស្នាក់នៅជាចំបង។ ត្រូវបានរាប់បញ្ចូលផងដែរនូវផ្ទះជួល បុរី អាផាត់មែន។ល។<br><br>តែមិនត្រូវបានរាប់បញ្ចូលទេនូវទីតាំងមួយចំនួនដូចជា៖ អគារក្រុមហ៊ុន អគារការិយាល័យទូទៅ ហាងលក់ទំនិញ ភោជនីយដ្ឋាន ។ល។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យE៨.១ តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ប្រសិទ្ធិភាព"** នៃវិធានការលើកទឹកចិត្តឲ្យប្រើប្រាស់ថាមពលដែលកកើតឡើងវិញ។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យគណៈកម្មាធិការជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៥** គឺ៖

- ព័ត៌មានអំពីប្រភេទផ្សេងៗនៃសម្បទាទេសចរណ៍(ដែលមាន)
- ព័ត៌មានអំពីចំនួនប្រជាពលរដ្ឋ(ដែលមាន)
- បង្ហាញអំពីវត្តមានវិធានការលើកទឹកចិត្តឲ្យប្រើប្រាស់ថាមពលកកើតឡើងវិញ(ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវជាប្រចាំលើការអនុវត្តវិធានការដែលបានដាក់ចេញ
- បង្ហាញអំពីសកម្មភាពអនុវត្តជាក់ស្តែងរបស់អង្គភាពទទួលខុសត្រូវនោះ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យE៨.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខ-ភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០៥** ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ□៨.១ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |

| | | | |
|---|---|---|---|
| ១ | ព័ត៌មានអំពីប្រភេទផ្សេងៗនៃសម្បទាទេសចរណ៍ (ដែលមាន) | ធ្វើសម្រង់ស្ថិតិអំពីទីសម្បទាទេសចរណ៍ (ដែលមាន) | -តារាងសម្រង់ស្ថិតិ[20]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | ព័ត៌មានអំពីចំនួនប្រជាជន (ដែលមាន) | ធ្វើសម្រង់ស្ថិតិអំពីលំនៅដ្ឋានប្រជាពលរដ្ឋដែលមាន | -តារាងសម្រង់ស្ថិតិ[21]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ៣ | វត្តមានវិធានការលើកទឹកចិត្តឲ្យមានការប្រើប្រាស់ធនធានកកើតឡើងវិញ | រៀបរាងជាវិធាន យន្តការ ឬរង្វាន់ផ្សេងៗសម្រាប់លើកទឹកចិត្តចំពោះរាល់ការចូលរួមប្រើប្រាស់ធនធានកកើតឡើងវិញ | -សេចក្តីសម្រេច ឬដីកា ឬនីតិវិធីផ្សេងៗដែលមានតម្លៃស្មើស្តីពីការកំណត់ការលើកទឹកចិត្តឲ្យមានការប្រើប្រាស់ធនធានកកើតឡើងវិញ |
| ៤ | វត្តមានអង្គភាពមានសមត្ថកិច្ចទទួលខុសត្រូវជាប្រចាំលើការអនុវត្ត | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៥ | សកម្មភាពជាក់ស្តែង | រៀបចំជាតារាងផែនការសកម្មភាព | -តារាងផែនការសកម្មភាព[22]របស់អង្គភាពដែលទទួលខុសត្រូវការងារនេះ |
| | *និង* | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច<br>- រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែង |

### ២. លក្ខណវិនិច្ឆ័យ E៨.២៖

"ភាគរយនៃ**ការប្រើប្រាស់ថាមពលដែលកកើតឡើងវិញ**នៅតាម**សម្បទាទេសចរណ៍** *(សណ្ឋាគារ ភោជនីយដ្ឋាន។ល។)*"
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**មានសម្បទាទេសចរណ៍យ៉ាងហោចណាស់៣០%នៃចំនួនសរុបប្រើប្រាស់ថាមពលដែលកកើតឡើងវិញ**"*

## ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ការប្រើប្រាស់ | សំដៅដល់ការទាញយក ស្រូបយក បំលែងប្រភពថាមពល**ដែលកកើតឡើងវិញ** (ការប្រើ |

[20] តារាងទី២៣

[21] តារាងទី២០

[22] តារាងទី ៤២

| | | |
|---|---|---|
| | ថាមពលដែលកកើតឡើងវិញ | ប្រាស់ប្រកបដោយនិរន្តរភាពនិងអាចប្រើប្រាស់ឡើងវិញ) ដូចជា៖ ពន្លឺព្រះអាទិត្យ ខ្យល់ ទឹក...។ |
| ២ | សម្បទាទេសចរណ៍ | សំដៅដល់**ទីតាំងសេវាកម្ម**ទាំងឡាយណាដែលបំរើឲ្យដល់វិស័យទេសចរណ៍។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យE៨.២តម្រូវឲ្យទីក្រុងបេតិកភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (**បរិមាណ**) នៃអ្នកដែលបានចូលរួមគាំទ្រវិធានការលើកទឹកចិត្តឲ្យប្រើប្រាស់ថាមពល ដែលកកើតឡើងវិញដែលបានដាក់ចេញ។ ដូច្នេះ ទីក្រុងបេតិកភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យគណៈកម្មាធិការជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៤ គឺ៖

- ព័ត៌មានអំពីប្រភេទផ្សេងៗនៃសម្បទាទេសចរណ៍(ដែលមាន)
- បង្ហាញអំពីវត្តមានវិធានការលើកទឹកចិត្តឲ្យប្រើប្រាស់ថាមពលកកើតឡើងវិញ (ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវជាប្រចាំលើការអនុវត្តវិធានការដែលបានដាក់ចេញ
- បង្ហាញអំពីលទ្ធផល ឬការគាំទ្ររបស់សាធារណជនចំពោះវិធានការ ឬយន្តការដែលបានដាក់ចេញ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យE៨.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេតិកភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៤ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ□៨.២ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីប្រភេទផ្សេងៗនៃសម្បទាទេសចរណ៍ដែលមាន | ធ្វើសម្រង់ស្ថិតិអំពីទីសម្បទាទេសចរណ៍ (ដែលមាន) | -តារាងសម្រង់ស្ថិតិ[23]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានវិធានការលើកទឹកចិត្តឲ្យមានការប្រើប្រាស់ធនធានកកើតឡើងវិញ | រៀបរាងជាវិធាន យន្តការ ឬរង្វាន់ផ្សេងៗសម្រាប់លើកទឹកចិត្តចំពោះរាល់ការចូលរួមប្រើប្រាស់ធនធានកកើតឡើងវិញ | -សេចក្តីសម្រេច ឬដីកា ឬនីតិវិធីផ្សេងៗដែលមានតម្លៃ ស្មើស្តីពីការកំណត់ការលើកទឹកចិត្តឲ្យមានការប្រើប្រាស់ធនធានកកើតឡើងវិញ |
| ៣ | វត្តមានអង្គភាពមានសមត្ថកិច្ចទទួលខុសត្រូវជាប្រចាំលើការអនុវត្ត | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៤ | លទ្ធផលដែលសម្រេចបាន | បញ្ជាក់បង្ហាញពីការគាំទ្ររបស់សាធារណជនចំពោះវិធានការដែលបានដាក់ចេញគឺមានសម្បទាទេសចរណ៍យ៉ាងតិច៣០%នៃចំនួន | -តារាងសម្រង់ស្ថិតិ[24]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

[23] តារាងទី ២៣

[24] តារាងទី ២៣

| | | | |
|---|---|---|---|
| | | សរុបដែលមានប្រើប្រាស់ប្រភព ថាមពលដែលកកើតឡើងវិញ | |

## ៣. លក្ខណវិនិច្ឆ័យ E៨.៣៖

"វត្តមាន**<u>សកម្មភាព និងវិធានការលើកទឹកចិត្ត</u>**ដល់**<u>សម្បទាទេសចរណ៍</u>** *(សណ្ឋាគារ ភោជនីយដ្ឋាន។ល។)* និង**<u>ប្រជាពល-រដ្ឋ</u>**ក្នុង**<u>ការសន្សំសំចៃការប្រើប្រាស់</u>** *(Efficient Energy use) (ឧទាហរណ៍ ការប្រើប្រាស់អំពូលស៊ីថាមពលតិច ការប្រើប្រាស់សោរផ្តាច់អគ្គិសនីដោយស្វ័យប្រវត្តិតាមសណ្ឋាគារ។ល។)"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**<u>មាន</u>**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | សកម្មភាពនិងវិធានការលើកទឹកចិត្តឲ្យប្រើប្រាស់ថាមពលដោយសន្សំសំចៃ | សំដៅដល់**<u>វិធានការ ឬយន្តការលើកទឹកចិត្ត</u>**ឲ្យប្រើប្រាស់ថាមពលឲ្យបានត្រឹមត្រូវ និងសមស្របតាមតម្រូវការកំណត់ ជៀសវាងការប្រើប្រាស់ខ្ជះខ្ជាយ (ត្រូវប្រើប្រាស់ឲ្យចំគោលដៅ ត្រូវតាមពេលវេលានិងកាលៈទេសៈ និងប្រកបដោយប្រសិទ្ធភាព)។<br><br>វិធានការលើកទឹកចិត្តមិនសំដៅតែលើវិធានការជំរុញការអនុវត្តដោយចាប់បង្ខំនោះទេ។ ក្នុងន័យនេះ ការលើកទឹកចិត្តគឺជា**<u>ការគាំទ្រខាងផ្នែកស្មារតី</u>**ឲ្យអនុវត្តអ្វីមួយ ដោយអាចនឹងមានការ**<u>តបស្នង</u>** អ្វីមួយ។ |
| ២ | សម្បទាទេសចរណ៍ | សំដៅដល់**<u>ទីតាំងសេវាកម្ម</u>**ទាំងឡាយណាដែលបំរើឲ្យដល់វិស័យទេសចរណ៍។ |
| ៣ | ប្រជាពលរដ្ឋ | សំដៅដល់**<u>លំនៅដ្ឋានរបស់ប្រជាពលរដ្ឋទូទៅ</u>**ដែលបំរើការក្នុងគោលបំណងសម្រាប់ការស្នាក់នៅជាចំបង។ ត្រូវបានរាប់បញ្ចូលផងដែរនូវផ្ទះជួល បុរី អាផាត់ម៉ែន។ល។<br><br>តែមិនត្រូវបានរាប់បញ្ចូលទេនូវទីតាំងមួយចំនួនដូចជា៖ អគារក្រុមហ៊ុន អគារការិយាល័យទូទៅ ហាងលក់ទំនិញ ភោជនីយដ្ឋាន ។ល។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យE៨.៣ តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក (**គ.ជ.វ.ទ.**) សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ប្រសិទ្ធិភាព"** នៃវិធានការលើកទឹកចិត្តឲ្យប្រើប្រាស់ថាមពលដោយសន្សំសំចៃ។ ដូចច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យគណៈកម្មាធិការជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៥** គឺ៖

- ព័ត៌មានអំពីប្រភេទផ្សេងៗនៃសម្បទាទេសចរណ៍(ដែលមាន)
- ព័ត៌មានអំពីចំនួនប្រជាពលរដ្ឋ(ដែលមាន)
- បង្ហាញអំពីវត្តមានវិធានការលើកទឹកចិត្តឲ្យប្រើប្រាស់ថាមពលដោយសន្សំសំចៃ (ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវជាប្រចាំលើការអនុវត្តវិធានការដែលបានដាក់ចេញ
- បង្ហាញអំពីសកម្មភាពអនុវត្តជាក់ស្តែងរបស់អង្គភាពទទួលខុសត្រូវ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យE៨.៣ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខ-ភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៥ ខាងលើ។

| **តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណៈវិនិច្ឆ័យ□៨.៣** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីប្រភេទផ្សេងៗនៃសម្បទាទេសចរណ៍(ដែលមាន) | ធ្វើសម្រង់ស្ថិតិអំពីទីសម្បទាទេសចរណ៍(ដែលមាន) | -តារាងសម្រង់ស្ថិតិ[25]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | ព័ត៌មានអំពីចំនួនប្រជាជន (ដែលមាន) | ធ្វើសម្រង់ស្ថិតិអំពីលំនៅដ្ឋានប្រជាពលរដ្ឋ(ដែលមាន) | -តារាងសម្រង់ស្ថិតិ[26]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ៣ | វត្តមានវិធានការលើកទឹកចិត្តដល់ការប្រើប្រាស់ថាមពលដោយសន្សំសំចៃ | រៀបចំជាវិធាន យន្តការ ឬរង្វាន់ផ្សេងៗសម្រាប់លើកទឹកចិត្តចំពោះរាល់ការចូលរួមសន្សំសំចៃការប្រើប្រាស់ថាមពល | -សេចក្តីសម្រេច ឬដីកា ឬនីតិវិធីផ្សេងៗ ដែលមានតម្លៃ ស្មើស្តីពីការកំណត់ការលើកទឹកចិត្តឲ្យមានការប្រើប្រាស់ថាមពលដោយសន្សំសំចៃ |
| ៤ | វត្តមានអង្គភាពមានសមត្ថកិច្ចទទួលខុសត្រូវជាប្រចាំលើការអនុវត្ត | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៥ | សកម្មភាពជាក់ស្តែង | រៀបចំជាតារាងផែនការសកម្មភាព | -តារាងផែនការសកម្មភាពរបស់អង្គភាពដែលទទួលខុសត្រូវការងារនេះ |
| | ***និង*** | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច<br>- រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗ ដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែង |

[25] តារាងទី ២៣

[26] តារាងទី ២១

# ផ្នែកទី២
# សូចនាករគោលនៃភាពស្អាត

ភាពស្អាតនៅតាមទីសាធារណៈគឺចំនុចសំខាន់ក្នុងការលើកកម្ពស់សោភ័ណភាព និងភាពទាក់ទាញនៅក្នុងទីក្រុងក៏ដូចជាសុខមាលភាពរបស់ប្រជាពលរដ្ឋ។ ជាការពិត ភាពស្អាតនៅតាមទីសាធារណៈអាស្រ័យលើអាក-ឬកិរិយារបស់បុគ្គលម្នាក់ៗ ហើយការគិតគូរថែទាំទីកន្លែងសាធារណៈទាមទារឲ្យមានការចូលរួមទាំងអស់គ្នា។

ក្នុងសូចនាករគោលទី២នេះ ទីតាំងដែលចាត់ទុកជាទីកន្លែងសាធារណៈមាន៣គឺៈ

- ទីតាំង និងហេដ្ឋារចនាសម្ព័ន្ធ បដិសណ្ឋារកិច្ចសម្រាប់ទទួលភ្ញៀវទេសចរ (អាគាររដ្ឋបាលសាធារណៈ មជ្ឈមណ្ឌលពត៌មាន តំបន់បៃតង និងមជ្ឈមណ្ឌលពាណិជ្ជកម្ម...)
- រមណីយដ្ឋានទេសចរណ៍ និងឧទ្យាននានា (សារមន្ទីរ សួនសត្វ ប្រាសាទ ឆ្នេរ និងឧទ្យានកំសាន្ត...)
- ផ្លូវសាធារណៈ (ផ្លូវ និងវិថីសំខាន់ៗ...)។

ជាការពិត សូចនាករគោលទី២ ដែលបានជ្រើសរើសសម្រាប់ការប្រលងប្រណាំងទីក្រុងស្អាតផ្តោតលើការថ្លឹងថ្លែងរវាងស្ថានភាពជាក់ស្តែងនៃទិដ្ឋភាពរួមនៅតាមទីសាធារណៈរបស់ទីក្រុងបេក្ខភាព និងកម្រិតនៃការយកចិត្តទុកដាក់លើភាពស្អាត និងវិធានការរបស់អាជ្ញាធរទីក្រុង។

**សូចនាករគោលស្តីពីភាពស្អាតនេះ គឺជាប្រធានបទដែលផ្តល់ពិន្ទុច្រើនជាងគេក្នុងស្តង់ដាទីក្រុងស្អាត។** ជាទូទៅក៏ដូចជាប្រជាពលរដ្ឋ រូបភាពសោភ័ណភាពខាងក្រៅនៃទីក្រុងគឺជាកត្តាទាក់ទាញដំបូងបំផុតសំរាប់ភ្ញៀវទេសចរ និងប្រជា-ពលរដ្ឋក្នុងដំណើរកំសាន្តរបស់ពួកគាត់។ ម្យ៉ាងទៀត ក្រៅពីសោភ័ណភាពផ្នែកខាងក្រៅនេះ បញ្ហាអនាម័យ និងលក្ខណៈពិសេសនៃវប្បធម៌របស់ទីក្រុងក៏ជាចំនុចត្រូវគិតគូរ និងយកចិត្តទុកដាក់ផងដែរ។ ក្នុងន័យនេះ ការយកចិត្តទុកដាក់លើសកម្មភាពអវិជ្ជមានមួយចំនួនដូចជាៈ ការចោលសំរាមផ្តេសផ្តាស ការកាត់បន្ថយភាពកខ្វក់ដែលជាមូលហេតុនៃជំងឺឆ្លងផ្សេងៗ សុទ្ធសឹងជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ប្រយុទ្ធប្រឆាំងសំដៅធ្វើយ៉ាងណាឲ្យទីក្រុងមានអនាម័យល្អ និងសោ-ភ័ណភាពស្រស់ស្អាតនៅតាមទីសាធារណៈ និងនៅតាមទីប្រជុំជននានារបស់ខ្លួន។

ការគិតគូរដល់បេតិកភណ្ឌស្ថាបត្យកម្មរបស់សំណង់នានានៅក្នុងទីក្រុង (ដែលជាលក្ខណៈសម្គាល់ពិសេសរបស់ក្រុងនីមួយៗ) នឹងចូលរួមដល់ការផ្សព្វផ្សាយរបស់ទីក្រុង និងទាក់ទាញភ្ញៀវទេសចរជាតិ អន្តរជាតិឲ្យកាន់តែច្រើនថែមទៀត។ ទន្ទឹមនឹងនោះ ការរៀបចំរបៀបរៀបរយចរាចរណ៍ និងមធ្យោបាយធ្វើដំណើរក្នុងក្រុងក៏ជាចំណុចសំខាន់គួរយកចិត្តទុកដាក់ខ្ពស់ ដោយហេតុថាកិច្ចការទាំងនេះនឹងមិនត្រឹមតែចូលរួមលើកកម្ពស់ភាពស្អាតនៅទីក្រុងប៉ុណ្ណោះទេ តែវាថែមទាំងបង្កើនទំនុកចិត្ត និងភាពពេញចិត្តដល់ភ្ញៀវទេសចរថែមទៀតផង។

# P១. សូចនាករលំអិតនៃភាពស្អាតនៅទីកន្លែងសាធារណៈ

## កម្មវត្ថុសូចនាករលំអិត P១

ភាពស្អាតនៅទីកន្លែងសាធារណៈគឺជាកត្តាចាំបាច់ក្នុងការលើកកម្ពស់សោភ័ណភាព និងភាពទាក់ទាញរបស់ទីក្រុងបេក្ខភាព។ ក្នុងន័យតំរូវឲ្យអាជ្ញាធរទីក្រុងត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការរក្សាឲ្យទីកន្លែងនេះស្អាត។

ដើម្បីជាជំនួយដល់ទីក្រុងបេក្ខភាព ក្នុងការបំពេញនូវលក្ខខណ្ឌតម្រូវទាំងឡាយដែលជាការទាមទាររបស់សូចនាករលម្អិត P១ គណៈកម្មាធិការសូមណែនាំអំពីលក្ខណវិនិច្ឆ័យទាំង ៣ នៃសូចនាករលម្អិតនេះដល់ទីក្រុងបេក្ខភាព ដូចខាងក្រោម៖

| លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| P១.១. **<u>ភាពស្អាត</u>**នៅតាម**<u>កន្លែងសំខាន់ៗដែលអាចជាកន្លែងទទួលសាធារណៈជន</u>** ដូចជាការិយាល័យរដ្ឋបាលសាធារណៈ តំបន់បៃតង ទីស្នាក់ការព័ត៌មាន និងទីផ្សារសំខាន់ៗ | មាន-មិនមាន | ១ |
| P១.២. តើ**<u>កន្លែងទាំងនោះ</u>**គឺជាកម្មវត្ថុនៃ**<u>ការថែរក្សានិងសម្អាត</u>**យ៉ាងទៀតទាត់ឬទេ? | យ៉ាងហោច ១ដងក្នុង១ថ្ងៃ | ១ |
| P១.៣. មាន**<u>ធុងសំរាម</u>**គ្រប់គ្រាន់នៅតាម**<u>ទីកន្លែងសំខាន់ៗទាំងនោះ</u>** | មាន-មិនមាន | ១ |

***(ផ្តល់ពិន្ទុ ៣/១៧ នៃពិន្ទុសរុបរបស់សូចនាករគោលនៃភាពស្អាត)***

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

### ១. លក្ខណៈវិនិច្ឆ័យ P១.១៖

*"**<u>ភាពស្អាត</u>**នៅតាម**<u>កន្លែងសំខាន់ៗ</u>**ដែលអាចជាកន្លែងទទួលសាធារណៈជន ដូចជាការិយាល័យ រដ្ឋបាលសាធារណៈ តំបន់បៃតង ទីស្នាក់ការព័ត៌មាន និងទីផ្សារសំខាន់ៗ។"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**<u>មាន</u>**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ភាពស្អាត | ភាពស្អាតអាចកំណត់បានតាមរយៈ**<u>អវត្តមាននូវសមាសធាតុ៣</u>**គឺ៖ ភាពកខ្វក់ សំរាម/កាកសំណល់ផ្សេងៗដែលនៅរាយប៉ាយ និងក្លិនមិនល្អ។ |
| ២ | កន្លែងសាធារណៈសំខាន់ៗ | សំដៅដល់ទីកន្លែងទាំងឡាយណាដែលត្រូវបានរៀបចំឡើងសំរាប់ទទួលនិងអនុញ្ញាតឲ្យ**<u>សាធារណជនទូទៅ</u>** *(ដោយមិនគិតពីភេទ អាយុ ស្ថានភាពជីវភាព និន្នាការសាសនា...)* ចេញចូលបាន**<u>ដោយសេរី</u>** *(ដោយឥតគិតថ្លៃ គិតថ្លៃ ឬតម្រូវតាមលក្ខខណ្ឌពាណិជ្ជកម្មផ្សេងៗ)* ក្នុងគោលបំណង**<u>ស្របច្បាប់</u>**ដែលអាចជា៖ សំរាកលំហែ ឬប្រើប្រាស់សេវាកម្មណាមួយ...ជាដើម។ ទីតាំងដែលអាចត្រូវបានចាត់ទុកជាទីកន្លែងសាធារណៈសំខាន់ៗ**<u>ជាអាទិភាព</u>** រួមមាន៖ |

| | | | |
|---|---|---|---|
| | | -អគារសាធារណៈ[27]<br>-មណ្ឌលសុខភាព<br>-ទីផ្សារសំខាន់ៗ<br>-មជ្ឈមណ្ឌលពាណិជ្ជកម្ម<br>-មជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ | -តំបន់បៃតង<br>-សួនកុមារ<br>-ទីតាំងសំរាប់លេងកីឡា<br>-ចំណតរថយន្តក្រុង/ឈ្នួល/រថយន្តទេសចរណ៍<br>-ចំណតសាធារណៈសំរាប់យានជំនិះ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យP១.១តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះគឺ **"ចំនួន"** (**បរិមាណ**) ទីកន្លែងសាធារណៈសំខាន់ៗដែលរក្សាបានភាពស្អាត។ ក្នុងន័យនេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាមូលដ្ឋានសម្រាប់ឲ្យគណៈកម្មាធិការជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺ៖

- ព័ត៌មានអំពីទីកន្លែងសាធារណៈសំខាន់ៗ (ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវជាប្រចាំលើការសម្អាតនៅតាមទីកន្លែងទាំងនោះ
- បង្ហាញអំពីសកម្មភាពអនុវត្ត និងលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យP១.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០៣** ខាងលើ។

**តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យP១.១**

| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
|---|---|---|---|
| ១ | ព័ត៌មានអំពីទីកន្លែងសាធារណៈសំខាន់ៗ (ដែលមាន) | ស្រង់ស្ថិតិអំពីទីកន្លែងសាធារណៈសំខាន់ៗទាំងឡាយ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ ដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | -តារាងសម្រង់ស្ថិតិ[28]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវលើការសម្អាតនៅតាមទីកន្លែងទាំងនោះ | បញ្ជាក់ពីវត្តមានអ្នកទទួលបន្ទុកលើការសម្អាតជាប្រចាំនៅតាមទីកន្លែងទាំងនោះដែលអាចជា៖<br>- ស្ថាប័ន ឬអង្គភាពដែលគ្រប់គ្រងលើទីកន្លែងនោះផ្ទាល់ | - ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់ខ្លួនលើទីតាំងនោះ<br>- ឯកសារបញ្ជាក់អំពីវត្តមាននិងចំនួនអ្នកដែលទទួលបន្ទុកសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ *(អង្គការលេខ/រចនាសម្ព័ន្ធ/ការចាត់តាំង/កិច្ចសន្យា...)* |
| | *ឬ* | - ក្រុមហ៊ុនឯកជន | - កិច្ចសន្យារវាងម្ចាស់ទីតាំង និងក្រុមហ៊ុនឯកជនដែលមានកម្មវត្ថុនៃការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ |

[27] អគារសាធារណៈ៖ សំដៅដល់អគារស្នាក់ការដែលបំពីសេវាកម្មសាធារណៈ។

[28] តារាងទី ០១

| | | | |
|---|---|---|---|
| | | | - ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់ភាគីជាម្ចាស់ទីតាំងនោះ |
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកសម្អាតនៅតាមទីកន្លែងទាំងនោះតាមការចាត់តាំងរបស់អាជ្ញាធរមានសមត្ថកិច្ច | - កិច្ចសន្យារវាងម្ចាស់ទីតាំង និងអង្គភាពនោះ ដែលមានកម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ<br>- ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់អង្គភាពសម្អាត<br>- ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់ភាគីជាម្ចាស់ទីតាំងនោះ |
| ៣ | លទ្ធផលជាក់ស្តែង | រៀបចំជារបាយការណ៍រូបភាពស្តីពីសោភណ្ឌភាពនៅតាមទីកន្លែងសាធារណៈសំខាន់ៗនីមួយៗ | - រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីទិដ្ឋភាពជាក់ស្តែងនៅតាមទីតាំងនីមួយៗ |

## ២. លក្ខណវិនិច្ឆ័យ P១.២៖

*"តើកន្លែងទាំងនោះគឺជាកម្មវត្ថុនៃ**ការថែរក្សានិងសម្អាត**យ៉ាងទៀងទាត់ដែរឬទេ?"*
*"នឹងទទួលបាន ១ពិន្ទុប្រសិនបើមានការថែរក្សានិងសម្អាត**យ៉ាងហោចណាស់១ដងក្នុងមួយថ្ងៃ**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ការថែរក្សានិងសម្អាត | ក្នុងន័យនេះសំដៅដល់**ទង្វើ**ទាំងឡាយណាដែលត្រូវបានគិតគូរ**ធ្វើឡើងដោយអង្គភាពមានសមត្ថកិច្ចណាមួយជាក់លាក់** ក្នុងគោលបំណងធ្វើយ៉ាងណារក្សាឲ្យបាននូវ **"ភាពស្អាត"** នៅតាមទីកន្លែងសាធារណៈសំខាន់ៗទាំងនោះ។<br><br>**ឧទាហរណ៍៖** សកម្មភាពទាំងនោះអាចជា ការដាក់វេនសម្អាត ឬការចាត់តាំងក្រុម/ជនណាមួយឲ្យនៅសម្អាតជាប្រចាំជាដើម។ |
| ២ | យ៉ាងហោចណាស់១ដងក្នុងមួយថ្ងៃ | មានន័យថា កើតឡើងជា**រៀងរាល់ថ្ងៃ**ដោយកំណត់ជាអប្បបរិមាត្រឹម**១ដងក្នុងមួយថ្ងៃ**។<br><br>ដោយឡែក ដោយហេតុថាការវាយតម្លៃតាមរយៈលក្ខណវិនិច្ឆ័យនេះត្រូវអនុវត្តចំពោះទីកន្លែងសាធារណៈសំខាន់ៗ ដែលទីតាំងទាំងនោះអាចមានសណ្ឋាននិងប្រភេទខុសៗគ្នា។ ការកំណត់នេះត្រូវបានចែកចេញជា **២ករណី**គឺ៖<br>- ចំពោះទីកន្លែងសាធារណៈសំខាន់ៗទាំងឡាយណាដែលជាទីតាំងបំរើឲ្យស្ថាប័ន/អង្គភាពរដ្ឋបាលសាធារណៈណាមួយ អត្ថន័យនៃពាក្យថា "រៀងរាល់ថ្ងៃ" អាចនឹងត្រូវកំណត់ត្រឹមថ្ងៃធ្វើការដែលអាចរាប់ចាប់ពីថ្ងៃច័ន្ទ-សុក្រ ឬពីថ្ងៃច័ន្ទ-សៅរ៍។<br>- ចំពោះទីកន្លែងសាធារណៈសំខាន់ៗផ្សេងទៀតដែលជាទីសាធារណៈសុទ្ធសាធដែលមិនបំរើជាទីតាំងសំរាប់ទីតាំងរដ្ឋបាលណាមួយទេនោះ។ (**ឧទាហរណ៍៖** សួនសាធារណៈ សួនសំរាប់កុមារ...។ល។) អត្ថន័យនៃពាក្យថា "រៀងរាល់ថ្ងៃ" អាចនឹងត្រូវកំណត់តាមន័យទូទៅ ពោលគឺចាប់ពីថ្ងៃច័ន្ទ-អាទិត្យ។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យP១.២តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**ចំនួន**" (**បរិមាណ**) នៃការថែរក្សាសម្អាតនៅតាមទីកន្លែងសាធារណៈសំខាន់ៗឲ្យបានយ៉ាងហោច១ដងក្នុង១ថ្ងៃ។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាមូលដ្ឋានសម្រាប់ឲ្យគណៈកម្មាធិការជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺ៖

- ព័ត៌មានអំពីទីកន្លែងសាធារណៈសំខាន់ៗ(ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវជាប្រចាំលើការសម្អាតនៅតាមទីកន្លែងទាំងនោះ
- បង្ហាញអំពីសកម្មភាពនិងលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យP១.២ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខ-ភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០៣** ខាងលើ។

**តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យP១.២**

| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
|---|---|---|---|
| ១ | ព័ត៌មានអំពីទីកន្លែងសាធារណៈសំខាន់ៗ (ដែលមាន) | ស្រង់ស្ថិតិអំពីទីកន្លែងសាធារណៈសំខាន់ៗទាំងឡាយ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ ដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | - តារាងសម្រង់ស្ថិតិ[29]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវលើការសម្អាតនៅតាមទីកន្លែងទាំងនោះ | បញ្ជាក់ពីវត្តមានអ្នកទទួលបន្ទុកលើការសម្អាតជាប្រចាំនៅតាមទីកន្លែងទាំងនោះដែលអាចជា៖<br>- ស្ថាប័ន ឬអង្គភាពដែលគ្រប់គ្រងលើទីកន្លែងនោះផ្ទាល់ | - ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់ខ្លួនលើទីតាំងនោះ<br>- ឯកសារបញ្ជាក់អំពីវត្តមាននិងចំនួនអ្នកដែលទទួលបន្ទុកសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ *(អង្គការលេខ/រចនាសម្ព័ន្ធ/ការចាត់តាំង/កិច្ចសន្យា...)* |
| | *ឬ* | - ក្រុមហ៊ុនឯកជន | - កិច្ចសន្យារវាងម្ចាស់ទីតាំង និងក្រុមហ៊ុនឯកជនដែលមានកម្មវត្ថុនៃការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ<br>- ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់ភាគីជាម្ចាស់ទីតាំងនោះ |
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកសម្អាតនៅតាមទីកន្លែងទាំងនោះតាមការចាត់តាំងរបស់អាជ្ញាធរមានសមត្ថកិច្ច | - កិច្ចសន្យារវាងម្ចាស់ទីតាំង និងអង្គភាពនោះ ដែលមានកម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ |

[29] តារាងទី ០១

| | | | |
|---|---|---|---|
| | | | - ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់អង្គ-ភាពសម្អាត<br>- ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់ភាគីជាម្ចាស់ទីតាំងនោះ |
| ៣ | សកម្មភាពនិងលទ្ធផលជាក់ស្តែង | ការណែនាំរបស់អាជ្ញាធរទីក្រុងឲ្យមានការសម្អាតយ៉ាងទៀងទាត់នៅតាមទីកន្លែងសាធារណៈសំខាន់ៗទាំងនោះ | - ដីកា/សារាចរណែនាំរបស់ទីក្រុងបេក្ខភាព*(ក្នុងករណីដែលកិច្ចការនេះមិនមែនជាសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាព ត្រូវមានដីកាសម្រេច/សារាចរណែនាំរបស់អាជ្ញាធរដែលមានសមត្ថកិច្ចនោះអមមកជាមួយ)* |
| | *និង* | រៀបចំជាតារាងអំពីសកម្មភាពនៃការសម្អាតសម្រាប់ទីតាំងនីមួយៗដោយមានបញ្ជាក់អំពីប្រភេទផ្សេងៗនៃការសម្អាត និងភាពញឹកញាប់នៃការសម្អាត(យ៉ាងហោចណាស់១ដងក្នុង១ថ្ងៃ) | - តារាងសម្រង់ស្ថិតិ[30]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

### ៣. លក្ខណៈវិនិច្ឆ័យ P១.៣៖

*"មាន**ធុងសំរាម**គ្រប់គ្រាន់នៅតាម**ទីកន្លែងសំខាន់ៗទាំងនោះ**"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**មាន**"*

## ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ធុងសំរាម | ក្នុងន័យនេះ យើងសំដៅត្រឹម**ធុងសំរាមធម្មតា**ដែលអាចត្រឹម**ផ្ទុកសំណល់គ្រប់ប្រភេទ**ក្នុងចំណុះណាមួយ។<br>ធុងសំរាមត្រូវតែជា**ធុងសំរាមសាធារណៈសំរាប់សាធារណជន** មិនមែនជាធុងសំរាមនៅតាមតូបលក់ចំណីអាហារ ឬហាងទំនិញណាមួយដែលមាននៅក្នុងរមណីយដ្ឋាននោះទេ។ |
| ២ | កន្លែងសាធារណៈសំខាន់ៗ | សំដៅដល់ទីកន្លែងទាំងឡាយណាដែលត្រូវបានរៀបចំឡើងសំរាប់ទទួលនិងអនុញ្ញាតឲ្យ**សាធារណជនទូទៅ** *(ដោយមិនគិតពីភេទ អាយុ ស្ថានភាពជីវភាព និន្នាការសាសនា...)* ចេញចូលបាន**ដោយសេរី** *(ដោយឥតគិតថ្លៃ គិតថ្លៃ ឬតម្រូវតាមលក្ខខណ្ឌពាណិជ្ជកម្មផ្សេងៗ)* ក្នុងគោលបំណង**ស្របច្បាប់**ដែលអាចជា៖ សំរាកលំហែ ឬប្រើប្រាស់សេវាកម្មណាមួយ...ជាដើម។<br><br>ទីតាំងដែលអាចត្រូវបានចាត់ទុកជាទីកន្លែងសាធារណៈសំខាន់ៗ**ជាអាទិភាព** រួមមាន៖ |

30 តារាងទី ៣១

| | | | |
|---|---|---|---|
| | | -អគារសាធារណៈ[31]<br>-មណ្ឌលសុខភាព<br>-ទីផ្សារសំខាន់ៗ<br>-មជ្ឈមណ្ឌលពាណិជ្ជកម្ម<br>-មជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ | -តំបន់បៃតង<br>-សួនកុមារ<br>-ទីតាំងសំរាប់លេងកីឡា<br>-ចំណតរថយន្តក្រុង/ឈ្នួល/រថយន្តទេសចរណ៍<br>-ចំណតសាធារណៈសំរាប់យានជំនិះ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យP១.៣តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**ចំនួន**" (**បរិមាណ**) ធុងសំរាមនៅតាមទីកន្លែងសាធារណៈសំខាន់ៗដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យគណៈកម្មាធិការជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺ៖

- ព័ត៌មានអំពីទីកន្លែងសាធារណៈសំខាន់ៗ(ដែលមាន)
- បង្ហាញអំពីវត្ថុមានអ្នកទទួលខុសត្រូវលើការបំពាក់និងថែរក្សាធុងសំរាមទាំងនោះ
- បង្ហាញអំពីចំនួនធុងសំរាមដែលមាននៅតាមទីកន្លែងសាធារណៈសំខាន់ៗទាំងនោះ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យP១.៣ ក៏ដូចជាការណែនាំដល់បេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០៣** ខាងលើ។

**តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យP១.៣**

| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
|---|---|---|---|
| ១ | ព័ត៌មានអំពីទីកន្លែងសាធារណៈសំខាន់ៗ (ដែលមាន) | ស្រង់ស្ថិតិអំពីទីកន្លែងសាធារណៈសំខាន់ៗទាំងឡាយ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ ដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | - តារាងសម្រង់ស្ថិតិ[32]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្ថុមានអ្នកទទួលខុសត្រូវលើការសម្អាតនៅតាមទីកន្លែងទាំងនោះ | បញ្ជាក់ពីវត្ថុមានអ្នកទទួលបន្ទុកលើការសម្អាតជាប្រចាំនៅតាមទីកន្លែងទាំងនោះដែលអាចជា៖<br>- ស្ថាប័ន ឬអង្គភាពដែលគ្រប់គ្រងលើទីកន្លែងនោះផ្ទាល់ | - ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់ខ្លួនលើទីតាំងនោះ<br>- ឯកសារបញ្ជាក់អំពីវត្ថុមាននិងចំនួនអ្នកដែលទទួលបន្ទុកសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ *(អង្គការលេខ/ របនាសម្ព័ន្ធ/ការចាត់តាំង/កិច្ចសន្យា...)* |
| | *ឬ* | - ក្រុមហ៊ុនឯកជន | - កិច្ចសន្យារវាងម្ចាស់ទីតាំង និងក្រុមហ៊ុនឯកជនដែលមានកម្មវត្ថុនៃការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ |

---

[31] <u>អគារសាធារណៈ៖</u> សំដៅដល់អគារស្នាក់ការដែលបំរើសេវាកម្មសាធារណៈ។

[32] តារាងទី ៣១

| | | | |
|---|---|---|---|
| | | | - ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់ភាគីជាម្ចាស់ទីតាំងនោះ |
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកសម្អាតនៅតាមទីកន្លែងទាំងនោះតាមការចាត់តាំងរបស់អាជ្ញាធរមានសមត្ថកិច្ច | - កិច្ចសន្យារវាងម្ចាស់ទីតាំង និងអង្គភាពនោះ ដែលមានកម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ<br>- ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់អង្គ-ភាពសម្អាត<br>- ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់ភាគីជាម្ចាស់ទីតាំងនោះ |
| ៣ | ធុងសំរាមត្រូវមានចំនួនគ្រប់គ្រាន់ | ការណែនាំរបស់អាជ្ញាធរទីក្រុងអំពីការតម្រូវឲ្យមានធុងសំរាមនៅតាមទីតាំងទាំងនោះ | - ដីកា/សារាចរណែនាំរបស់ទីក្រុងបេក្ខភាព*(ក្នុងករណីដែលកិច្ចការនេះមិនមែនជាសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាពត្រូវមានដីកាសម្រេច/សារាចរណែនាំរបស់អាជ្ញាធរដែលមានសមត្ថកិច្ចនោះអមជាមួយ)* |
| | *និង* | កំណត់ប្រភេទ/ចំនួន/ទីតាំងដាក់ធុងសំរាមនៅតាមទីកន្លែងសាធារណៈសំខាន់ៗទាំងនោះ | - តារាងព័ត៌មាន[33]ដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុងបេក្ខភាព |

# P២. សូចនាករលំអិតនៃភាពស្អាតនៅតាមបង្គន់សាធារណៈ

## កម្មវត្ថុសូចនាករលំអិត P២

សូចនាករលំអិត P២ បានតម្រូវឲ្យមានបង្គន់សាធារណៈនៅតាមរមណីយដ្ឋានទេសចរណ៍នីមួយៗសម្រាប់បំរើដល់សេចក្តីត្រូវការរបស់សាធារណជនដែលចូលមកកំសាន្តនៅតាមទីសាធារណៈ ឬរមណីយដ្ឋានទេសចរណ៍នានា។ លើសពីនេះទៀត បង្គន់សាធារណៈត្រូវតែស្អាតនិងមានអនាម័យ (រមណីយដ្ឋានដែលមានបង្គន់មិនស្អាត និងគ្មានអនាម័យស្មើគ្នានឹងគ្មានបង្គន់ដែរ)។

ដើម្បីជាជំនួយដល់ទីក្រុងបេក្ខភាពទាំងអស់ ក្នុងការបំពេញនូវលក្ខខណ្ឌតម្រូវទាំងឡាយដែលតំរូវក្នុងសូចនាករលម្អិត P២ ឯកសារខាងក្រោមនេះ នឹងបរិយាយណែនាំលម្អិតអំពីលក្ខណវិនិច្ឆ័យទាំង ៣ នៃសូចនាករលម្អិតនេះដល់ទីក្រុងបេក្ខភាពឲ្យយល់ និងអាចរៀបចំខ្លួនដើម្បីធ្វើយ៉ាងណាទទួលបានពិន្ទុ។

| លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| P២.១.មាន<u>**បង្គន់សាធារណៈ**</u>នៅតាម<u>**រមណីយដ្ឋានទេសចរណ៍**</u>ទាំងឡាយ | មាន-មិនមាន | ១ |
| P២.២.<u>**ភាពស្អាត**</u>នៅតាម<u>**បង្គន់សាធារណៈ**</u>ទាំងនោះ | មាន-មិនមាន | ១ |
| P២.៣.តើ<u>**បង្គន់សាធារណៈ**</u>ទាំងនោះជាកម្មវត្ថុនៃ<u>**ការថែរក្សានិងសម្អាត**</u>យ៉ាងទៀងទាត់ដែរឬទេ? | យ៉ាងហោច៤ដងក្នុង១ថ្ងៃ | ១ |

[33] តារាងទី ៣៣

*(ផ្តល់ពិន្ទុ ៣/១៧ នៃពិន្ទុសរុបរបស់សូចនាករគោលនៃភាពស្អាត)*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណៈវិនិច្ឆ័យ P២.១៖

*"មាន__បង្គន់សាធារណៈ__នៅតាម__រមណីយដ្ឋានទេសចរណ៍__ទាំងឡាយ។"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា__មាន__"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | បង្គន់សាធារណៈ | សំដៅដល់បង្គន់ទាំងឡាយណា ដែលអនុញ្ញាតឲ្យ**__សាធារណជនទូទៅ__** *(ដោយមិនគិតពីភេទ អាយុ ស្ថានភាពជីវភាព និន្នាការសាសនា...)* **__អាចប្រើប្រាស់បានដោយសេរី។__**<br><br>ក្នុងករណីនេះ បង្គន់សាធារណៈអាចស្ថិតនៅទីសាធារណៈសុទ្ធសាធ ឬអាចស្ថិតនៅអាគារ ឬទីតាំងណាមួយដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ ឬឯកជនក៏ដោយ *(បង្គន់នៅតាមហាងទំនិញ ស្ថានីយ៍ប្រេង...*ឲ្យតែសាធារណជនអាចប្រើប្រាស់បាន ទោះត្រូវបង់ប្រាក់ក្តី ឬត្រូវគោរពតាមលក្ខខណ្ឌមួយចំនួនក្តី)។ |
| ២ | រមណីយដ្ឋានទេសចរណ៍ | សំដៅដល់ទីតាំង ដែលមាន**__ភាពទាក់ទាញទេសចរណ៍__**ដូចជា វប្បធម៌ ប្រវត្តិសាស្ត្រ ធម្មជាតិ ឆ្នេរសមុទ្រ ឬដែលរៀបចំកែច្នៃឡើង ហើយត្រូវបានអនុញ្ញាតឲ្យរៀបចំសម្រាប់ធ្វើ**__អាជីវកម្មបម្រើឲ្យការសម្រាកលំហែ និងកម្សាន្តតាមគោលបំណងទេសចរណ៍ស្របច្បាប់__**។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថាអ្វីដែលលក្ខណវិនិច្ឆ័យP២.១តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (**បរិមាណ**) បង្គន់សាធារណៈនៅតាមរមណីយដ្ឋានទេសចរណ៍ដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យគណៈកម្មាធិការជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៣ គឺ៖

- ព័ត៌មានអំពីរមណីយដ្ឋានទេសចរណ៍ដែលមាន
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការបំពាក់ និងថែរក្សាផុងសំរាមទាំងនោះ
- បង្ហាញអំពីចំនួនបង្គន់សាធារណៈដែលមាននៅតាមរមណីយដ្ឋានទេសចរណ៍នីមួយៗ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យP២.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណៈវិនិច្ឆ័យP២.១ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |

| | | | |
|---|---|---|---|
| ១ | ព័ត៌មានអំពីរមណីយដ្ឋានទេសចរណ៍ (ដែលមាន) | ស្រង់ស្ថិតិអំពីរមណីយដ្ឋានទេសចរណ៍ទាំងឡាយ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ ដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីរមណីយដ្ឋាននោះ | - តារាងសម្រង់ស្ថិតិ[34]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបចំជាផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងរមណីយដ្ឋានទេសចរណ៍ទាំងនោះ។ | - ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវលើការគ្រប់គ្រងថែរក្សាបង្គន់សាធារណៈនៅតាមរមណីយដ្ឋានទេសចរណ៍ទាំងនោះ | បញ្ជាក់ពីវត្តមានអ្នកដែលទទួលខុសត្រូវជាប្រចាំលើបញ្ហាទាំងនេះ នៅតាមរមណីយដ្ឋានទេសចរណ៍ខាងលើ ដែលអ្នកទទួលខុសត្រូវទាំងនោះអាចជា៖<br>- ម្ចាស់រមណីយដ្ឋាន | - ឯកសារបញ្ជាក់អំពីសមត្ថភាពជាម្ចាស់រមណីយដ្ឋាន *(អាជ្ញាប័ណ្ណរមណីយដ្ឋាន...)*<br>- អង្គការលេខ/រចនាសម្ព័ន្ធ/ការចាត់តាំងដែលអាចបញ្ជាក់ពីវត្តមាននិងចំនួនអ្នកដែលទទួលបន្ទុកអនាម័យនៅតាមទីតាំងទាំងនោះ |
| | ***ឬ*** | - ក្រុមហ៊ុនឯកជនដែលទទួលបន្ទុកចែកចាយធុងសំរាម និងប្រមូលសំរាមជាប្រចាំតាមរយៈកាតព្វកិច្ចកើតចេញពីកិច្ចសន្យាណាមួយ | - កិច្ចសន្យារវាងម្ចាស់ទីតាំង និងក្រុមហ៊ុនឯកជន<br>- ឯកសារបញ្ជាក់អំពីសមត្ថភាពជាម្ចាស់រមណីយដ្ឋាន *(អាជ្ញាប័ណ្ណរមណីយដ្ឋាន...)* |
| | ***ឬ*** | - អង្គភាពដែលទទួលបន្ទុកលើការគ្រប់គ្រងធុងសំរាមនៅតាមទីកន្លែងទាំងនោះ តាមការចាត់តាំងរបស់អាជ្ញាធរទីក្រុង | - កិច្ចសន្យារវាងម្ចាស់ទីតាំង និងអង្គភាពដែលមានកម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ<br>- ឯកសារបញ្ជាក់អំពីសមត្ថភាពជាម្ចាស់រមណីយដ្ឋាន *(អាជ្ញាប័ណ្ណរមណីយដ្ឋាន...)* |
| ៣ | បង្គន់សាធារណៈត្រូវមានចំនួនគ្រប់គ្រាន់ | ការណែនាំរបស់អាជ្ញាធរទីក្រុងអំពីការតម្រូវឲ្យមានធុងសំរាមនៅតាមទីតាំងទាំងនោះ | - ដីកា/សារាចរណែនាំរបស់ទីក្រុងបេក្ខភាព *(ក្នុងករណីដែលកិច្ចការនេះមិនមែនជាសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាពត្រូវមានដីកាសម្រេច/សារាចរណែនាំរបស់អាជ្ញាធរដែលមានសមត្ថកិច្ចនោះអមមកជាមួយ)* |
| | ***និង*** | កំណត់ប្រភេទ/ចំនួន/ទីតាំងដាក់ធុងសំរាមនៅតាមរមណីយដ្ឋានទេសចរណ៍ | - តារាងព័ត៌មាន[35]ដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុងបេក្ខភាព |

## ២. លក្ខណាវិនិច្ឆ័យ P២.២៖

[34] តារាងទី ២៥

[35] តារាងទី ៣២

"***ភាពស្អាត**នៅតាម**បង្គន់សាធារណៈ**ទាំងនោះ។*"
"*នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**មាន***"

## ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ភាពស្អាត | ភាពស្អាតអាចកំណត់បានតាមរយៈអវត្តមាននូវ**សមាសធាតុ៣**គឺ៖ ភាពកខ្វក់ សំរាម/កាកសំណល់ផ្សេងៗដែលនៅរាយប៉ាយ និងក្លិនមិនល្អ។ |
| ២ | បង្គន់សាធារណៈ | សំដៅដល់បង្គន់ទាំងឡាយណា ដែលអនុញ្ញាតឲ្យ**សាធារណៈជនទូទៅ** *(ដោយមិនគិតពីភេទ អាយុ ស្ថានភាពជីវភាព និន្នាការសាសនា...)* **អាចប្រើប្រាស់បានដោយសេរី**។<br><br>ក្នុងករណីនេះបង្គន់សាធារណៈអាចស្ថិតនៅទីសាធារណៈសុទ្ធសាធ ឬនៅតាមអគារ ឬទីតាំងណាមួយដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ ឬឯកជន *(បង្គន់នៅតាមហាងទំនិញ ស្ថានីយ៍ប្រេង...* ឲ្យតែសាធារណៈជនអាចប្រើប្រាស់បាន ទោះត្រូវបង់ប្រាក់ក្តី ឬត្រូវគោរពតាមលក្ខខណ្ឌមួយចំនួនក្តី)។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យP២.២តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**កម្រិត**" (បរិមាណ) នៃភាពស្អាតនៅតាមបង្គន់សាធារណៈនៅតាមរមណីយដ្ឋានទេសចរណ៍ដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាព។ ក្នុងន័យនេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យគណៈកម្មាធិការជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺ៖

- ព័ត៌មានអំពីរមណីយដ្ឋានទេសចរណ៍(ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការបំពាក់និងថែរក្សាបង្គន់សាធារណៈទាំងនោះ
- បង្ហាញអំពីលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យP២.២ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០៣** ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យP២.២ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីរមណីយដ្ឋានទេសចរណ៍ | ស្រង់ស្ថិតិអំពីរមណីយដ្ឋានទេសចរណ៍ទាំងឡាយ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ ដែលមាន | - តារាងសម្រង់ស្ថិតិ[36]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

[36] តារាងទី ២៤

| | | | |
|---|---|---|---|
| | (ដែលមាន) | បញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីរមណីយដ្ឋាននោះ | |
| | ***និង*** | រៀបចំជាផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងរមណីយដ្ឋានទេសចរណ៍ទាំងនោះ។ | - ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវលើការគ្រប់គ្រងថែរក្សាបង្គន់សាធារណៈនៅតាមរមណីយដ្ឋានទេស ចរណ៍ទាំងនោះ | បញ្ជាក់ពីវត្តមានអ្នកដែលទទួលខុសត្រូវជាប្រចាំលើបញ្ហាទាំងនេះ នៅតាមរមណីយដ្ឋានទេសចរណ៍ខាងលើ ដែលអ្នកទទួលខុសត្រូវទាំងនោះអាចជា៖<br>- ម្ចាស់រមណីយដ្ឋាន | - ឯកសារបញ្ជាក់អំពីសមត្ថភាពជាម្ចាស់រមណីយដ្ឋាន *(អាជ្ញាប័ណ្ណរមណីយដ្ឋាន...)*<br>- អង្គការលេខ/រចនាសម្ព័ន្ធ/ការចាត់តាំងដែលអាចបញ្ជាក់ពីវត្តមាននិងចំនួនអ្នកដែលទទួលបន្ទុកអនាម័យនៅតាមទីតាំងទាំងនោះ |
| | ***ឬ*** | - ក្រុមហ៊ុនឯកជនដែលទទួលបន្ទុកចែកចាយធុងសំរាម និងប្រមូលសំរាមជាប្រចាំតាមរយៈកាតព្វកិច្ចកើតចេញពីកិច្ចសន្យាណាមួយ | - កិច្ចសន្យារវាងម្ចាស់ទីតាំង និងក្រុមហ៊ុនឯកជន<br>- ឯកសារបញ្ជាក់អំពីសមត្ថភាពជាម្ចាស់រមណីយដ្ឋាន *(អាជ្ញាប័ណ្ណរមណីយដ្ឋាន...)* |
| | ***ឬ*** | - អង្គភាពដែលទទួលបន្ទុកលើការគ្រប់គ្រងធុងសំរាមនៅតាមទីកន្លែងទាំងនោះ៖ តាមការចាត់តាំងរបស់អាជ្ញាធរទីក្រុង | - កិច្ចសន្យារវាងម្ចាស់ទីតាំង និងអង្គភាពដែលមានកម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ<br>- ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់អ្នកចាត់តាំង<br>- ឯកសារបញ្ជាក់អំពីសមត្ថភាពជាម្ចាស់រមណីយដ្ឋាន *(អាជ្ញាប័ណ្ណរមណីយដ្ឋាន...)* |
| ៣ | លទ្ធផលជាក់ស្តែង | រៀបចំជារបាយការណ៍រូបភាពស្តីពីសោភណ្ឌភាពនៅតាមទីកន្លែងសាធារណៈសំខាន់ៗនីមួយៗ | - រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីទិដ្ឋភាពជាក់ស្តែងនៅតាមទីតាំងនីមួយៗ |

## ៣. លក្ខណៈវិនិច្ឆ័យ P២.៣៖

*"តើ**<u>បង្គន់សាធារណៈ</u>**ទាំងនោះជាកម្មវត្ថុនៃ**<u>ការថែរក្សានិងសម្អាត</u>**យ៉ាងទៀងទាត់ដែរឬទេ?"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**<u>មានការសម្អាតយ៉ាងហោច៤ដងក្នុង១ថ្ងៃ</u>**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ភាពស្អាត | ភាពស្អាតអាចកំណត់បានតាមរយៈអវត្តមាននូវ**<u>សមាសធាតុ៣</u>**គឺ៖ ភាពកខ្វក់ សំរាម/កាកសំណល់ផ្សេងៗដែលនៅរាយប៉ាយ និងក្លិនមិនល្អ។ |
| ២ | ការថែរក្សា | ក្នុងន័យនេះសំដៅដល់**<u>ទង្វើ</u>**ទាំងឡាយណាដែលត្រូវបានគិតគូរ**<u>ធ្វើឡើងដោយអង្គភាពមានសមត្ថ</u>** |

| | | |
|---|---|---|
| | និងសម្អាត | **<u>កិច្ចណាមួយជាក់លាក់</u>** ក្នុងគោលបំណងធ្វើយ៉ាងណារក្សាឲ្យបាននូវ "**<u>ភាពស្អាត</u>**" ដែលជាកម្មវត្ថុនៃការថែរក្សា និងសម្អាតនោះផ្ទាល់។<br><br>**<u>ឧទាហរណ៍៖</u>** សកម្មភាពទាំងនោះអាចជា ការដាក់វេនសម្អាត ឬការចាត់តាំងក្រុម/ជនណាមួយឲ្យនៅសម្អាតជាប្រចាំជាដើម។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យ P២.៣ តម្រូវឲ្យទីក្រុងបេតិកភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**ចំនួន**" (បរិមាណ) នៃការសម្អាតនៅតាមបង្គន់សាធារណៈនៅតាមរមណីយដ្ឋានទេសចរណ៍ដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ទីក្រុងបេតិកភាព ឲ្យបានយ៉ាងហោចណាស់មានការសម្អាត៤ដងក្នុង១ថ្ងៃ។ ដូច្នេះទីក្រុងបេតិកភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យគណៈកម្មាធិការជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺ៖

- ព័ត៌មានអំពីរមណីយដ្ឋានទេសចរណ៍(ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការបំពាក់ និងថែរក្សាបង្គន់សាធារណៈទាំងនោះ
- បង្ហាញអំពីសកម្មភាពនិងលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យ P២.៣ ក៏ដូចជាការណែនាំដល់ទីក្រុងបេតិកភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០៣** ខាងលើ។

| **តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យP២.៣** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីរមណីយដ្ឋានទេសចរណ៍(ដែលមាន) | ស្រង់ស្ថិតិអំពីរមណីយដ្ឋានទេសចរណ៍ទាំងឡាយ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ ដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីរមណីយដ្ឋាននោះ | - តារាងសម្រង់ស្ថិតិ[37]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបចំជាផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងរមណីយដ្ឋានទេសចរណ៍ទាំងនោះ។ | - ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | វត្តមានអ្នកទទួលខុសត្រូវលើការគ្រប់គ្រងថែរក្សាបង្គន់សាធារណៈនៅតាមរមណីយដ្ឋានទេសចរណ៍ទាំង | បញ្ជាក់ពីវត្តមានអ្នកដែលទទួលខុសត្រូវជាប្រចាំលើបញ្ហាទាំងនេះ នៅតាមរមណីយដ្ឋានទេសចរណ៍ខាងលើ ដែលអ្នកទទួលខុសត្រូវទាំងនោះអាចជា៖<br>- ម្ចាស់រមណីយដ្ឋាន *(អ្នកវិនិយោគ ក្រុមហ៊ុន អ្នកម៉ៅការ...)* | - ឯកសារបញ្ជាក់អំពីសមត្ថភាពជាម្ចាស់រមណីយដ្ឋាន *(អាជ្ញាប័ណ្ណរមណីយដ្ឋាន...)*<br>- អង្គការលេខ/វចនាសម្ព័ន្ធ/ការចាត់តាំងដែលអាចបញ្ជាក់ពីវត្តមាននិងចំនួនអ្នកដែលទទួលបន្ទុកអនាម័យនៅតាមទីតាំងទាំងនោះ |

[37] តារាងទី ២៤

| | | | |
|---|---|---|---|
| | នោះ | | |
| | *ឬ* | - ក្រុមហ៊ុនឯកជនដែលទទួលបន្ទុកចែកចាយធុងសំរាម និងប្រមូលសំរាមជាប្រចាំតាមរយៈកាតព្វកិច្ចកើតចេញពីកិច្ចសន្យាណាមួយ | - កិច្ចសន្យារវាងម្ចាស់ទីតាំង និងក្រុមហ៊ុនឯកជន<br>- ឯកសារបញ្ជាក់អំពីសមត្ថភាពជាម្ចាស់រមណីយដ្ឋាន *(អាជ្ញាប័ណ្ណរមណីយដ្ឋាន...)* |
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកលើការគ្រប់គ្រងធុងសំរាមនៅតាមទីកន្លែងទាំងនោះតាមការចាត់តាំងរបស់អាជ្ញាធរទីក្រុង | - កិច្ចសន្យារវាងម្ចាស់ទីតាំង និងអង្គភាពដែលមានកម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ<br>- ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់អ្នកចាត់តាំង<br>- ឯកសារបញ្ជាក់អំពីសមត្ថភាពជាម្ចាស់រមណីយដ្ឋាន *(អាជ្ញាប័ណ្ណរមណីយដ្ឋាន...)* |
| ៣ | សកម្មភាពនិងលទ្ធផលជាក់ស្តែង | ការណែនាំរបស់អាជ្ញាធរទីក្រុងឲ្យមានការសម្អាតយ៉ាងទៀងទាត់នូវបង្គន់សាធារណៈនៅតាមរមណីយដ្ឋានទេសចរណ៍នានា | - ដីកា/សារាចរណែនាំរបស់ទីក្រុងបេក្ខភាព *(ក្នុងករណីដែលកិច្ចការនេះមិនមែនជាសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាពត្រូវមានដីកាសម្រេច/សារាចរណែនាំរបស់អាជ្ញាធរដែលមានសមត្ថកិច្ចនោះអមមកជាមួយ)* |
| | *និង* | រៀបចំជាតារាងអំពីសកម្មភាពនៃការសម្អាតសម្រាប់រមណីយដ្ឋានទេសចរណ៍នីមួយៗដោយមានបញ្ជាក់អំពីប្រភេទផ្សេងៗនៃការសម្អាត និងភាពញឹកញាប់នៃការសម្អាត (យ៉ាងហោចណាស់៤ដងក្នុង១ថ្ងៃ) | - តារាងសម្រង់ស្ថិតិ[38]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

## P៣. សូចនាករលំអិតនៃភាពស្អាតនៅតាមកន្លែងនិងសម្បទាទេសចរណ៍

### កម្មវត្ថុសូចនាករលំអិត P៣

ដូចមានចែងក្នុងច្បាប់ស្តីពីទេសចរណ៍ រមណីយដ្ឋានសំដៅលើទីតាំងដែលមានភាពទាក់ទាញទេសចរ ដូចជាប្រវត្តិសាស្ត្រ ធម្មជាតិ ឆ្នេរសមុទ្រឬរមណីយដ្ឋានដែលរៀបចំកែច្នៃឡើងហើយ ត្រូវបានអនុញ្ញាតឲ្យរៀបចំធ្វើអាជីវកម្មបម្រើឲ្យឧស្សាហកម្មសំរាកលំហែ និងកំសាន្តតាមគោលបំណងទេសចរស្របច្បាប់។ ដូច្នេះ ទីរមណីយដ្ឋាន (ពិសេសនៅទីក្រុងតែម្តង) ត្រូវតែរក្សាឲ្យបាននូវសោភ័ណ្ឌភាព និងភាពស្អាតជានិច្ច។ ក្រៅពីបង្គន់សាធារណៈការដាក់ឲ្យមានធុងសំរាមនិងការសម្អាតថែរក្សាជាប្រចាំនូវទី រមណីយដ្ឋាន គឺជាកត្តាចាំបាច់នឹងត្រូវអនុវត្តឲ្យបានល្អ។

សោភ័ណ្ឌភាព ភាពស្អាតនៅទីរមណីយដ្ឋានទេសចរណ៍ពិតជាចូលរួមយ៉ាងសំខាន់ក្នុងការលើកកំពស់ សម្រស់ទីក្រុង។ ប៉ុន្តែកិច្ចការនេះទាមទារឲ្យមានការយកចិត្តទុកដាក់ខ្ពស់ពីរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងនិងរៀបចំប្រកបដោយការទទួលខុសត្រូវខ្ពស់។

[38] តារាងទី ៤៦

| លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| P៣.១.**ភាពស្អាត**នៅតាម**ទីរមណីយដ្ឋានសំខាន់ៗ**ដែលបង្ហាញនូវភាពទទួលរាក់ទាក់ចំពោះភ្ញៀវទេសចរ | មាន-មិនមាន | ១ |
| P៣.២.តើ**រមណីយដ្ឋានទេសចរណ៍ទាំងនោះ**គឺជាកម្មវត្ថុនៃ**ការថែរក្សានិងសម្អាត**យ៉ាងទៀងទាត់ដែរឬទេ? | យ៉ាងហោច២ដងក្នុង១ថ្ងៃ | ១ |
| P៣.៣.មាន**ធុងសំរាម**គ្រប់គ្រាន់នៅតាម**ទីរមណីយដ្ឋានទេសចរណ៍**ទាំងនោះ | មាន-មិនមាន | ១ |

*(ផ្តល់ពិន្ទុ ៣/១៧ នៃពិន្ទុសរុបរបស់សូចនាករគោលនៃភាពស្អាត)*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណៈវិនិច្ឆ័យ P៣.១៖

*"**ភាពស្អាត**នៅតាម**ទីរមណីយដ្ឋានសំខាន់ៗ**ដែលបង្ហាញនូវភាពទទួលរាក់ទាក់ចំពោះភ្ញៀវទេសចរ។"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**មាន**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ភាពស្អាត | ភាពស្អាតអាចកំណត់បានតាមរយៈអវត្តមាននូវ**សមាសធាតុ៣**គឺ៖ ភាពកខ្វក់ សំរាម/កាកសំណល់ផ្សេងៗ ដែលនៅរាយប៉ាយ និងក្លិនមិនល្អ។ |
| ២ | ទីរមណីយដ្ឋានសំខាន់ៗ | សំដៅដល់ទីតាំង ដែលមានភាពទាក់ទាញទេសចរណ៍ដូចជា វប្បធម៌ ប្រវត្តសាស្ត្រ ធម្មជាតិ ឆ្នេរសមុទ្រ ឬដែលរៀបចំកែច្នៃឡើងហើយត្រូវបានអនុញ្ញាតឲ្យរៀបចំសម្រាប់ធ្វើអាជីវកម្មបម្រើឲ្យការសម្រាកលំហែ និងកម្សាន្ត តាមគោលបំណងទេសចរណ៍ស្របច្បាប់។<br>**ឧទាហរណ៍៖** នៅក្រុងព្រះសីហនុ : រមណីយដ្ឋានទេសចរណ៍ឆ្នេរអូរឈើទាល, រមណីយដ្ឋានទេសចរណ៍អូរត្រេសជាដើម ។ |

## ខ. ការវាយតម្លៃ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យP៣.១តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"កម្រិត"** (បរិមាណ) នៃភាពស្អាតនៅតាមទីរមណីយដ្ឋានសំខាន់ៗដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់បេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៣ គឺ៖

- ព័ត៌មានអំពីទីរមណីយដ្ឋានសំខាន់ៗ(ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការថែរក្សាសម្អាតជាប្រចាំនៅតាមទីកន្លែងទាំងនោះ
- បង្ហាញអំពីលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យP៣.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខ-

ភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណៈវិនិច្ឆ័យP៣.១ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីទីរមណីយដ្ឋានសំខាន់ៗ(ដែលមាន) | ស្រង់ស្ថិតិអំពីទីរមណីយដ្ឋានសំខាន់ៗ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងតារាងគំរូមួយ ដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | -តារាងសម្រង់ស្ថិតិ[39]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបចំជាផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងទីរមណីយដ្ឋានសំខាន់ៗទាំងនោះ។ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវលើការសម្អាតនៅតាមទីកន្លែងទាំងនោះ | បញ្ជាក់ពីវត្តមានអ្នកទទួលបន្ទុកលើការសម្អាតជាប្រចាំនៅតាមទីកន្លែងទាំងនោះដែលអាចជា៖<br>- ស្ថាប័ន ឬអង្គភាពដែលគ្រប់គ្រងទីកន្លែងនោះផ្ទាល់ | - ឯកសារបញ្ជាក់អំពីសមត្ថភាពរបស់ស្ថាប័ន ឬអង្គភាពនេះ*(អាចជាអាជ្ញាបណ្ណទេសចរណ៍)*<br>- ឯកសារបញ្ជាក់អំពីវត្តមាននិងចំនួនអ្នកដែលទទួលបន្ទុកសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ *(អង្គការលេខ/វចនាសម្ព័ន្ធ/ការចាត់តាំង/កិច្ចសន្យា...)* |
| | *ឬ* | - ក្រុមហ៊ុនឯកជន | - កិច្ចសន្យារវាងម្ចាស់ទីតាំង និងក្រុមហ៊ុនឯកជន ដែលមានកម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ<br>- ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់ភាគីជាម្ចាស់ទីតាំងនោះ *(អាចជាអាជ្ញាបណ្ណទេសចរណ៍)* |
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកសម្អាតនៅតាមទីកន្លែងទាំងនោះតាមការចាត់តាំងរបស់អាជ្ញាធរមានសមត្ថកិច្ច | - កិច្ចសន្យារវាងម្ចាស់ទីតាំង និងស្ថាប័ន ឬអង្គភាពនោះ (កម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ)<br>- ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់ភាគីជាម្ចាស់ទីតាំង |
| ៣ | លទ្ធផលជាក់ស្តែង | រៀបចំជារបាយការណ៍រូបភាពស្តីពីសោភ័ណ្ឌភាពនៅតាមរមណីយដ្ឋានទេសចរណ៍សំខាន់ៗនីមួយៗ | - រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីទិដ្ឋភាពជាក់ស្តែងនៅតាមទីតាំងនីមួយៗ |

## ២. លក្ខណៈវិនិច្ឆ័យ P៣.២៖

*"តើ**រមណីយដ្ឋានទេសចរណ៍ទាំងនោះ**គឺជាកម្មវត្ថុនៃ**ការថែរក្សានិងសម្អាត**យ៉ាងទៀងទាត់ដែរឬទេ?"*

[39] តារាងទី ២៣

*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**<u>មានការសម្អាតយ៉ាងហោច២ដងក្នុង១ថ្ងៃ</u>**"*

## ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ទីរមណីយដ្ឋានសំខាន់ៗ | សំដៅដល់ទីតាំង ដែលមានភាពទាក់ទាញទេសចរណ៍ដូចជា វប្បធម៌ ប្រវត្តសាស្ត្រ ធម្មជាតិ ឆ្នេរសមុទ្រ ឬដែលរៀបចំកែច្នៃឡើងហើយត្រូវបានអនុញ្ញាតឲ្យរៀបចំ សម្រាប់ធ្វើអាជីវកម្ម បម្រើឲ្យការសម្រាកលំហែ និងកម្សាន្ត តាមគោលបំណងទេសចរណ៍ស្របច្បាប់។<br>**<u>ឧទាហរណ៍៖</u>** នៅក្រុងព្រះសីហនុ : រមណីយដ្ឋានទេសចរណ៍ឆ្នេរអូរឈើទាល, រមណីយដ្ឋានទេសចរណ៍ អូរត្រេសជាដើម ។ |
| ២ | ការថែរក្សានិងសម្អាត | ក្នុងន័យនេះកម្មវត្ថុនៃការថែរក្សា និងសម្អាតសំដៅដល់**<u>ទង្វើ</u>**ទាំងឡាយណាដែលធ្វើឡើងដោយ **<u>អង្គភាពមានសមត្ថកិច្ចមួយជាក់លាក់</u>** ក្នុងគោលបំណងធ្វើយ៉ាងណារក្សាឲ្យបាននូវ **<u>"ភាពស្អាត"</u>** នៅតាមទីរមណីយដ្ឋាន។<br><br>**<u>ឧទាហរណ៍៖</u>** សកម្មភាពទាំងនេះអាចជា ការដាក់វេនសម្អាត ឬការចាត់តាំងក្រុម/ជនណាមួយឲ្យនៅសម្អាតជាប្រចាំនៅតាមទីរមណីយដ្ឋានទេសចរណ៍។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យP៣.២តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) នៃការថែរក្សា និងសម្អាតនៅតាមទីរមណីយដ្ឋានសំខាន់ៗដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់បេក្ខភាពឲ្យបានយ៉ាងហោចមានការសម្អាត២ដងក្នុង១ថ្ងៃ។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញបំភ្លឺនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៣ គឺ៖

- ព័ត៌មានអំពីទីរមណីយដ្ឋានសំខាន់ៗ(ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការថែរក្សាសម្អាតជាប្រចាំនៅតាមទីកន្លែងទាំងនោះ
- បង្ហាញអំពីសកម្មភាព និងលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យP៣.២ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យP៣.២ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |

| | | | |
|---|---|---|---|
| ១ | ព័ត៌មានអំពីទីរម-ណីយដ្ឋានសំខាន់ៗ (ដែលមាន) | ស្រង់ស្ថិតិអំពីទីរមណីយដ្ឋានសំខាន់ៗ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងតារាងគំរូមួយ ដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | -តារាងសម្រង់ស្ថិតិ[40]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបរាងជាផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងទីរមណីយដ្ឋានសំខាន់ៗទាំងនោះ។ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវលើការសម្អាតនៅតាមទីកន្លែងទាំងនោះ | បញ្ជាក់ពីវត្តមានអ្នកទទួលបន្ទុកលើការសម្អាតជាប្រចាំនៅតាមទីកន្លែងទាំងនោះដែលអាចជា៖<br>- ស្ថាប័ន ឬអង្គភាពដែលគ្រប់គ្រងលើទីកន្លែងនោះផ្ទាល់ | -ឯកសារបញ្ជាក់អំពីសមត្ថភាពរបស់ស្ថាប័ន ឬអង្គភាពនេះ *(អាចជាអាជ្ញាបណ្ណទេសចរណ៍)*<br>-ឯកសារបញ្ជាក់អំពីវត្តមាននិងចំនួនអ្នកដែលទទួលបន្ទុកសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ *(អង្គការលេខ/រចនាសម្ព័ន្ធ/ការចាត់តាំង/កិច្ចសន្យា...)* |
| | *ឬ* | - ក្រុមហ៊ុនឯកជន | -កិច្ចសន្យារវាងម្ចាស់ទីតាំង និងក្រុមហ៊ុនឯកជន (កម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ)<br>-ឯកសារបញ្ជាក់អំពីសមត្ថភាពរបស់ភាគីជាម្ចាស់ទីតាំងនោះ *(អាចជាអាជ្ញាបណ្ណទេសចរណ៍)* |
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកសម្អាតនៅតាមទីកន្លែងទាំងនោះតាមការចាត់តាំងរបស់អាជ្ញាធរមានសមត្ថកិច្ច | - កិច្ចសន្យារវាងម្ចាស់ទីតាំង និងស្ថាប័ន ឬអង្គភាពនេះ (កម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនេះ)<br>- ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់អ្នកចាត់តាំង<br>- ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់ភាគីជាម្ចាស់ទីតាំង |
| ៣ | សកម្មភាពជាក់ស្តែង | ទីក្រុងបេក្ខភាពធ្វើការណែនាំដល់អ្នកទទួលខុសត្រូវនៅតាមទីរមណីយដ្ឋានសំខាន់ៗទាំងឡាយអំពីការយកចិត្តទុកដាក់លើការរក្សាភាពស្អាតនៅតាមទីកន្លែងទាំងនោះ | - ដីកា/សារាចរណែនាំរបស់ទីក្រុងបេក្ខភាព *(ក្នុងករណីដែលកិច្ចការនេះមិនមែនជាសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាព ត្រូវមានដីកាសម្រេច/សារាចរណែនាំរបស់អាជ្ញាធរដែលមានសមត្ថកិច្ចនោះអមជាមួយ)* |
| | *និង* | រៀបចំជាតារាងអំពីសកម្មភាពនៃការសម្អាតសម្រាប់ទីតាំងនីមួយៗដោយមានបញ្ជាក់អំពីប្រភេទផ្សេងៗនៃការសម្អាត និងភាពញឹកញាប់នៃការសម្អាត | -តារាងសម្រង់ស្ថិតិ[41]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

[40] តារាងទី ២៣

[41] តារាងទី ៤៦

| | | | |
|---|---|---|---|
| | | យ៉ាងហោច២ដងក្នុង១ថ្ងៃ | |

### ៣. លក្ខណៈវិនិច្ឆ័យ P៣.៣៖

*"មាន**ធុងសំរាម**គ្រប់គ្រាន់នៅតាម**ទីរមណីយដ្ឋានទេសចរណ៍**។"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**មាន**"*

## ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ធុងសំរាម | ក្នុងន័យនេះ យើងសំដៅត្រឹម**ធុងសំរាមធម្មតា**ដែលអាចត្រឹមផ្ទុកសំណល់គ្រប់ប្រភេទក្នុងចំណុះណាមួយ។ ធុងសំរាមត្រូវតែជាធុងសំរាមសាធារណៈ**សំរាប់សាធារណៈជន** មិនមែនជាធុងសំរាមនៅតាមតូបលក់ចំណីអាហារ ឬហាងទំនិញណាមួយដែលមាននៅក្នុងរមណីយដ្ឋាននោះទេ។ |
| ២ | ទីរមណីយ-ដ្ឋានសំខាន់ៗ | សំដៅដល់ទីតាំង ដែលមានភាពទាក់ទាញទេសចរណ៍ដូចជា វប្បធម៌ ប្រវត្តសាស្ត្រ ធម្មជាតិ ឆ្នេរសមុទ្រ ឬ ដែលរៀបចំកែច្នៃឡើងហើយត្រូវបានអនុញ្ញាតឲ្យរៀបចំ សម្រាប់ធ្វើអាជីវកម្ម បម្រើឲ្យការសម្រាកលំហែ និងកម្សាន្ត តាមគោលបំណងទេសចរណ៍ស្របច្បាប់។<br>**ឧទាហរណ៍៖** នៅក្រុងព្រះសីហនុ : រមណីយដ្ឋានទេសចរណ៍ឆ្នេរអូរឈើទាល, រមណីយដ្ឋានទេសចរណ៍អូរត្រេសជាដើម ។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យP៣.៣តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**ចំនួន**" (បរិមាណ) ធុងសំរាមនៅតាមទីរមណីយដ្ឋានទេសចរណ៍សំខាន់ៗដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់បេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៣ គឺ៖

- ព័ត៌មានអំពីទីរមណីយដ្ឋានសំខាន់ៗ (ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការបំពាក់និងថែរក្សាធុងសំរាមទាំងនោះ
- បង្ហាញអំពីចំនួនធុងសំរាមដែលមាននៅតាមទីរមណីយដ្ឋានសំខាន់នីមួយៗ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យP៣.៣ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណៈវិនិច្ឆ័យP៣.៣ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |

| | | | |
|---|---|---|---|
| ១ | ព័ត៌មានអំពីទីរមណីយដ្ឋានសំខាន់ៗដែលមាន | ស្រង់ស្ថិតិអំពីទីរមណីយដ្ឋានសំខាន់ៗទាំងឡាយ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ ដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | - តារាងសម្រង់ស្ថិតិ[42]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបចំជាផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងទីរមណីយដ្ឋានទាំងនោះ | - ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវលើការគ្រប់គ្រងថែរក្សាធុងសំរាមនៅតាមទីរមណីយដ្ឋានសំខាន់ៗទាំងនោះ | បញ្ជាក់ពីវត្តមានអ្នកដែលទទួលខុសត្រូវជាប្រចាំលើបញ្ហាទាំងនេះ នៅតាមរមណីយដ្ឋានទេសចរណ៍ខាងលើ ដែលអ្នកទទួលខុសត្រូវទាំងនោះអាចជា៖<br>- ម្ចាស់រមណីយដ្ឋាន | - ឯកសារបញ្ជាក់អំពីសមត្ថភាពជាម្ចាស់រមណីយដ្ឋាន *(អាជ្ញាប័ណ្ណរមណីយដ្ឋាន...)*<br>- អង្គការលេខ/រចនាសម្ព័ន្ធ/ការចាត់តាំងដែលអាចបញ្ជាក់ពីវត្តមាននិងចំនួនអ្នកដែលទទួលបន្ទុកអនាម័យនៅតាមទីតាំងទាំងនោះ |
| | ***ឬ*** | - ក្រុមហ៊ុនឯកជនដែលទទួលបន្ទុកចែកចាយធុងសំរាម និងប្រមូលសំរាមជាប្រចាំតាមរយៈកាតព្វកិច្ចកើតចេញពីកិច្ចសន្យាណាមួយ | - កិច្ចសន្យារវាងម្ចាស់ទីតាំង និងក្រុមហ៊ុនឯកជន<br>- ឯកសារបញ្ជាក់អំពីសមត្ថភាពជាម្ចាស់រមណីយដ្ឋាន *(អាជ្ញាប័ណ្ណរមណីយដ្ឋាន...)* |
| | ***ឬ*** | - អង្គភាពដែលទទួលបន្ទុកលើការគ្រប់គ្រងធុងសំរាមនៅតាមទីកន្លែងទាំងនោះតាមការចាត់តាំងរបស់អាជ្ញាធរក្រុង/ខណ្ឌ | - កិច្ចសន្យារវាងម្ចាស់ទីតាំង និងអង្គភាពដែលមានកម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ<br>- ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់អ្នកចាត់តាំង<br>- ឯកសារបញ្ជាក់អំពីសមត្ថភាពជាម្ចាស់រមណីយដ្ឋាន *(អាជ្ញាប័ណ្ណរមណីយដ្ឋាន...)* |
| ៣ | ធុងសំរាមត្រូវមានចំនួនគ្រប់គ្រាន់ | ការណែនាំរបស់អាជ្ញាធរទីក្រុង/ខណ្ឌអំពីការតម្រូវឲ្យមានធុងសំរាមនៅតាមទីតាំងទាំងនោះ | - ដីកា/សារាចរណែនាំរបស់ទីក្រុងបេក្ខភាព *(ក្នុងករណីដែលកិច្ចការនេះមិនមែនជាសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាពត្រូវមានដីកាសម្រេច/សារាចរណែនាំរបស់អាជ្ញាធរដែលមានសមត្ថកិច្ចនោះអមជាមួយ)* |
| | ***និង*** | កំណត់ប្រភេទ/ចំនួន/ទីតាំងដាក់ធុងសំរាមនៅតាមទីរមណីយដ្ឋានសំខាន់ៗ | - តារាងព័ត៌មាន[43]ដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុង/ខណ្ឌបេក្ខភាព |

# P៤. សូចនាករលំអិតនៃភាពស្អាតនៅតាមទីកន្លែងនិងដងវិថីសំខាន់ៗ

## កម្មវត្ថុសូចនាករលំអិត P៤

ក្រៅពីសោភណ្ឌភាព និងភាពស្អាតនៅតាមទីសាធារណៈសំខាន់ៗនានានៃទីក្រុង (ដូចជា ៖ ទីតាំងអគារ រដ្ឋបាល

[42] តារាងទី ២៤

[43] តារាងទី ៣២

សួនច្បារ សួនកំសាន្ត និងទីរមណីយដ្ឋាននានា....។ សោភ័ណ្ឌភាព ជារួមនៅតាមដងវិថី និងទីកន្លែង ផ្សេងៗទៀតដែលរមែងមានការឆ្លងកាត់ញឹកញាប់គួរតែមានការយកចិត្តទុកដាក់ផងដែរ ។ ថ្វីបើទីក្រុងទាំងនេះ មិនតំណាងឲ្យលក្ខណៈពិសេសឬលក្ខណៈសំគាល់របស់ទីក្រុងក៏ដោយ ក៏ប៉ុន្តែទីតាំងទាំងនេះហាក់បីដូចជាធាតុ ផ្សំមួយលម្អ និងលើកសោភ័ណ្ឌភាពក្រុងទាំងមូល។ ក្នុងន័យនេះទីក្រុងដែលស្អាតមិនមែនជាទីក្រុងដែលមាន សភាពល្អ និងមានសោភណ្ឌភាពគួរជាទីមនោរម្យនៅតាមទីតាំង ឬគោលដៅទេសចរណ៍សំខាន់ៗនៃក្រុងនោះ ទេ ប៉ុន្តែត្រូវស្អាតនៅទូទាំងក្រុងតែម្តង។

| **លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|
| P៤.១.**<u>ភាពស្អាត</u>**នៅតាម**<u>កន្លែងសំខាន់ៗដែលមានការឆ្លងកាត់ញឹកញាប់</u>**នៅក្នុងទីក្រុង | មាន-មិនមាន | ១ |
| P៤.២.តើ**<u>កន្លែងទាំងនោះ</u>**ជាកម្មវត្ថុនៃ**<u>ការសម្អាត</u>**ជាប្រចាំដែរឬទេ? | យ៉ាងហោច២ដងក្នុង១ថ្ងៃ | ១ |
| P៤.៣.មាន**<u>ធុងសំរាម</u>**គ្រប់គ្រាន់នៅតាមទី**<u>កន្លែងទាំងនោះ</u>**ដែរឬទេ? | មាន-មិនមាន | ១ |
| P៤.៤.តើមានវត្តមាននៃ**<u>ការគ្រប់គ្រងលើអាកប្បកិរិយា</u>** និង**<u>ការកំណត់អំពីការស្លៀកពាក់</u>**របស់**<u>អ្នកបើកបរ</u>**រថយន្តឈ្នួល រ៉ឺម៉កកង់បី ម៉ូតូឌុប និងអ្នកដំណើរទាំងឡាយនៅលើដងវិថីសាធារណៈដែរឬទេ? | មាន-មិនមាន | ១ |

***(ផ្តល់ពិន្ទុ ៤/១៧ នៃពិន្ទុសរុបរបស់សូចនាករគោលនៃភាពស្អាត)***

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណៈវិនិច្ឆ័យ P៤.១៖

*"**<u>ភាពស្អាត</u>**នៅតាម**<u>កន្លែងសំខាន់ៗដែលមានការឆ្លងកាត់ញឹកញាប់</u>**នៅក្នុងទីក្រុង"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**<u>មាន</u>**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| **ល.រ** | **ពាក្យគន្លឹះ** | **សេចក្តីពន្យល់** |
|---|---|---|
| ១ | ភាពស្អាត | ភាពស្អាតអាចកំណត់បានតាមរយៈអវត្តមាននូវ**<u>សមាសធាតុ៣</u>**គឺ៖ ភាពកខ្វក់ សំរាម/កាកសំណល់ផ្សេងៗដែលនៅរាយប៉ាយ និងក្លិនមិនល្អ។ |
| ២ | ទីកន្លែងសំខាន់ៗដែលមានការឆ្លងកាត់ញឹកញាប់ | សំដៅដល់**<u>ទីតាំង ឬដងវិថី</u>**ទាំងឡាយណាដែលជាចំនុចលេចធ្លោរបស់ទីក្រុងបេក្ខភាព ហើយដែលទីតាំងទាំងនោះមិនមែនជាទីកន្លែងសាធារណៈដូចអត្ថន័យក្នុងសូចនាករលំអិតP១ និងរមណីយដ្ឋានសំខាន់ៗដូចអត្ថន័យក្នុងសូចនាករលំអិតP៣នោះដែរ។ ទីតាំងទាំងនោះ ជាទូទៅរមែងជា**<u>ច្រកចូលសំខាន់ៗ</u>**របស់ទីក្រុងបេក្ខភាពនីមួយៗ។<br><br>**<u>ឧទាហរណ៍៖</u>** នៅខណ្ឌដូនពេញចំនុចលេចធ្លោគឺ វិមានឯករាជ្យ និងដងមហាវិថីព្រះនរោត្តមដែលជាខ្សែភ្ជាប់យ៉ាងសំខាន់ទៅកាន់ច្រកចូលស្ពានជ្រោយចង្វានិងច្រកចូលស្ពានព្រះមុនីវង្ស។<br>ជាកន្លែងសំខាន់ៗដែលមានការឆ្លងកាត់ញឹកញាប់ អាចចាត់បញ្ចូលផងដែរដូចខាងក្រោម៖<br>- ច្រកចូលទីក្រុង<br>- ផ្លូវក្នុងទីក្រុងដែលភ្ជាប់នឹងផ្លូវជាតិ<br>- មហាវិថី វុក្ខវិថី និងតិចិរវិថីទាំងឡាយនៅក្នុងទីក្រុងបេក្ខភាព<br>- ផ្លូវដទៃទៀតដែលស្ថិតនៅក្នុងទីប្រជុំជននៃទីក្រុងបេក្ខភាព |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យP៤.១តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**កម្រិត**" (បរិមាណ) នៃភាពស្អាតនៅតាមទីកន្លែងសំខាន់ៗដែលមានការឆ្លងកាត់ញឹកញាប់ក្នុងដែនសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាព។ ដូច្នេះ បេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៣ គឺ៖

- ព័ត៌មានអំពីទីកន្លែងសំខាន់ៗដែលមានការឆ្លងកាត់ញឹកញាប់ (ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការថែរក្សាសម្អាតជាប្រចាំនៅតាមទីកន្លែងទាំងនោះ
- បង្ហាញអំពីលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យP៤.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខ-ភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

**តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យP៤.១**

| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
|---|---|---|---|
| ១ | ព័ត៌មានអំពីទីកន្លែងសំខាន់ៗ (ដែលមាន) | ស្រង់ស្ថិតិអំពីទីកន្លែងសំខាន់ៗដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ ដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | -តារាងសម្រង់ស្ថិតិ[44]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបចំជាផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងរបស់ទីកន្លែងសំខាន់ៗទាំងនោះ។ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវលើការសម្អាតនៅតាមទីកន្លែងទាំងនោះ | បញ្ជាក់ពីវត្តមានអ្នកទទួលបន្ទុកលើការសម្អាតជាប្រចាំនៅតាមទីកន្លែងទាំងនោះ ដែលអាចជា៖<br>- ក្រុមហ៊ុនឯកជន | -កិច្ចសន្យារវាងម្ចាស់ទីតាំង និងក្រុមហ៊ុនឯកជន (កម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ) |
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកសម្អាតនៅតាមទីកន្លែងទាំងនោះតាមការចាត់តាំងរបស់អាជ្ញាធរមានសមត្ថកិច្ច | -ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់អ្នកចាត់តាំង |
| ៣ | លទ្ធផលជាក់ស្តែង | រៀបចំជារបាយការណ៍រូបភាពស្តីពីសោភណ្ឌភាពនៅតាមទីកន្លែងសាធារណៈសំខាន់ៗនីមួយៗ | -រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីទិដ្ឋភាពជាក់ស្តែងនៅតាមទីតាំងនីមួយៗ |

## ២. លក្ខណវិនិច្ឆ័យ P៤.២៖

*"តើ**កន្លែងទាំងនោះ**ជាកម្មវត្ថុនៃ**ការសម្អាត**ជាប្រចាំដែរឬទេ?"*

[44] តារាងទី ៣៦

*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**មានការសម្អាតយ៉ាងហោច២ដងក្នុង១ថ្ងៃ**"*

## ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ការសម្អាត (ការថែរក្សានិងសម្អាត) | ក្នុងន័យនេះ ការសម្អាតសំដៅដល់**ទង្វើ**ទាំងឡាយណាដែលត្រូវបានធ្វើឡើងដោយ **ស្ថាប័ន ឬអង្គភាពទទួលបន្ទុកជាក់លាក់មួយ** ក្នុងគោលបំណងធ្វើយ៉ាងណារក្សាឲ្យបាននូវ **"ភាពស្អាត"**<br>**ឧទាហរណ៍៖** សកម្មភាពទាំងនោះអាចជា ការដាក់វេនសម្អាត ឬការចាត់តាំងក្រុម/ជនណាមួយឲ្យនៅសម្អាតជាប្រចាំជាដើម។ |
| ២ | ទីកន្លែងសំខាន់ៗដែលមានការឆ្លងកាត់ញឹកញាប់ | សំដៅដល់**ទីតាំង ឬដងវិថី**ទាំងឡាយណាដែលជាចំនុចលេចធ្លោរបស់ទីក្រុងបេក្ខភាព ហើយដែលទីតាំងទាំងនោះមិនមែនជាទីកន្លែងសាធារណៈដូចអត្ថន័យក្នុងសូចនាករលម្អិតP១ និងរមណីយដ្ឋានសំខាន់ៗដូចអត្ថន័យក្នុងសូចនាករលម្អិតP៣នោះដែរ។<br>ទីតាំងទាំងនោះ ជាទូទៅរមែងជា**ច្រកចូលសំខាន់ៗ**របស់ទីក្រុងបេក្ខភាពនីមួយៗ។<br>**ឧទាហរណ៍៖** នៅខណ្ឌដូនពេញចំនុចលេចធ្លោគឺ វិមានឯករាជ្យ និងដងមហាវិថីព្រះនរោត្តមដែលជាខ្សែភ្ជាប់យ៉ាងសំខាន់ទៅកាន់ច្រកចូលស្ពានជ្រោយចង្វានិងច្រកចូលស្ពានព្រះមុនីវង្ស។<br>កន្លែងសំខាន់ៗដែលមានការឆ្លងកាត់ញឹកញាប់អាចត្រូវបានចាត់បញ្ចូលទីតាំងដូចខាងក្រោម៖<br>- ច្រកចូលទីក្រុង/ខណ្ឌ<br>- ផ្លូវក្នុងទីក្រុង/ខណ្ឌដែលបន្តភ្ជាប់នឹងផ្លូវជាតិ<br>- មហាវិថី រុក្ខវិថី និងតិចិរវិថីទាំងឡាយនៅក្នុងទីក្រុងបេក្ខភាព<br>- ដងផ្លូវទាំងឡាយដែលស្ថិតនៅក្នុងទីប្រជុំជននៃទីក្រុងបេក្ខភាព |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យP៤.២តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) នៃការថែរក្សាសម្អាតនៅតាមទីកន្លែងសំខាន់ៗដែលមានការឆ្លងកាត់ញឹកញាប់ដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាព ឲ្យបានយ៉ាងហោច២ដងក្នុង១ថ្ងៃ។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៣ គឺ៖

- ព័ត៌មានអំពីទីកន្លែងសំខាន់ៗដែលមានការឆ្លងកាត់ញឹកញាប់ (ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការថែរក្សាសម្អាតជាប្រចាំនៅតាមទីកន្លែងទាំងនោះ
- បង្ហាញអំពីសកម្មភាព និងលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យP៤.២ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យP៤.២ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |

| | | | |
|---|---|---|---|
| ១ | ព័ត៌មានអំពីទីកន្លែងសំខាន់ៗដែលមាន | ស្រង់ស្ថិតិអំពីទីកន្លែងសំខាន់ៗដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ ដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | -តារាងសម្រង់ស្ថិតិ[45]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបចំជាផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងរបស់ទីកន្លែងសំខាន់ៗទាំងនោះ។ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវលើការសម្អាតនៅតាមទីកន្លែងទាំងនោះ | បញ្ជាក់ពីវត្តមានអ្នកទទួលបន្ទុកលើការសម្អាតជាប្រចាំនៅតាមទីកន្លែងទាំងនោះ<br>ដែលអាចជា៖<br>- ក្រុមហ៊ុនឯកជន | -កិច្ចសន្យារវាងម្ចាស់ទីតាំង និងក្រុមហ៊ុនឯកជនដែលមានកម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ |
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកសម្អាតនៅតាមទីកន្លែងទាំងនោះតាមការចាត់តាំងរបស់ អាជ្ញាធរមានសមត្ថកិច្ច | -ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់អ្នកចាត់តាំង |
| ៣ | សកម្មភាពជាក់ស្តែង | ទីក្រុងបេក្ខភាពធ្វើការណែនាំដល់អ្នកទទួលខុសត្រូវថែរក្សាសម្អាតនៅតាមទីតាំងទាំងនោះអំពីការយកចិត្តទុកដាក់លើការរក្សាភាពស្អាតនៅតាមទីកន្លែងទាំងនោះ | - ដីកា/សារាចរណែនាំរបស់ទីក្រុងបេក្ខភាព *(ក្នុងករណីដែលកិច្ចការនេះមិនមែនជាសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាព ត្រូវមានដីកាសម្រេច/សារាចរណែនាំរបស់អាជ្ញាធរដែលមានសមត្ថកិច្ចនោះអមជាមួយ)* |
| | *និង* | រៀបចំជាតារាងអំពីសកម្មភាពនៃការសម្អាតសម្រាប់ទីតាំងនីមួយៗដោយមានបញ្ជាក់អំពីប្រភេទផ្សេងៗនៃការសម្អាត និងភាពញឹកញាប់នៃការសម្អាតយ៉ាងហោច២ដងក្នុង១ថ្ងៃ | -តារាងសម្រង់ស្ថិតិ[46]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

## ៣. លក្ខណៈវិនិច្ឆ័យ P៤.៣៖

*"មាន__ធុងសំរាម__គ្រប់គ្រាន់នៅតាមទី__កន្លែងទាំងនោះ__ដែរឬទេ?"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា__មាន__"*

## ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ធុងសំរាម | ក្នុងន័យនេះ សំដៅត្រឹម**__ធុងសំរាមធម្មតា__**ដែលអាចត្រឹមផ្ទុកសំណល់គ្រប់ប្រភេទក្នុងចំណុះណាមួយ។<br>ធុងសំរាមត្រូវតែជាធុងសំរាមសាធារណៈ**__សំរាប់សាធារណៈជន__** មិនមែនជាធុងសំរាមនៅតាមតូបលក់ចំណីអាហារ ឬហាងទំនិញណាមួយដែលមាននៅក្នុងរមណីយដ្ឋាននោះទេ។ |

[45] តារាងទី ៣៦

[46] តារាងទី ៣៦

| | | |
|---|---|---|
| ២ | ទីកន្លែងសំខាន់ៗដែលមានការឆ្លងកាត់ញឹកញាប់ | សំដៅដល់**<u>ទីតាំង ឬដងវិថី</u>**ទាំងឡាយណាដែលជាចំនុចលេចធ្លោរបស់ទីក្រុងបេក្ខភាព ហើយដែលទីតាំងទាំងនោះមិនមែនជាទីកន្លែងសាធារណៈដូចអត្ថន័យក្នុងសូចនាករលម្អិតP១ និងរមណីយដ្ឋានសំខាន់ៗដូចអត្ថន័យក្នុងសូចនាករលម្អិតP៣។<br>ទីតាំងទាំងនោះ ជាទូទៅរមែងជា**<u>ច្រកចូលសំខាន់ៗ</u>**របស់ទីក្រុងបេក្ខភាពនីមួយៗ។<br>**<u>ឧទាហរណ៍៖</u>** នៅខណ្ឌដូនពេញចំនុចលេចធ្លោគឺ វិមានឯករាជ្យ និងដងមហាវិថីព្រះនរោត្តមដែលជាខ្សែភ្ជាប់យ៉ាងសំខាន់ទៅកាន់ច្រកចូលស្ពានជ្រោយចង្វានិងច្រកចូលស្ពានព្រះមុនីវង្ស។<br>កន្លែងសំខាន់ៗដែលមានការឆ្លងកាត់ញឹកញាប់អាចត្រូវបានចាត់ទុករាប់បញ្ចូលនូវទីតាំងមួយចំនួនដូចខាងក្រោម៖<br>- ច្រកចូលទីក្រុង/ខណ្ឌ<br>- ផ្លូវក្នុងទីក្រុង/ខណ្ឌដែលបន្តភ្ជាប់នឹងផ្លូវជាតិ<br>- មហាវិថី វុទ្ធិវិថី និងតិចិរវិថីទាំងឡាយនៅក្នុងទីក្រុងបេក្ខភាព<br>- ដងផ្លូវទាំងឡាយដែលស្ថិតនៅក្នុងទីប្រជុំជននៃទីក្រុងបេក្ខភាព |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យP៤.៣តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) ធុងសំរាមនៅតាមទីកន្លែងសំខាន់ៗដែលមានការឆ្លងកាត់ញឹកញាប់ដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺ៖

- ព័ត៌មានអំពីទីកន្លែងសំខាន់ៗដែលមានការឆ្លងកាត់ញឹកញាប់ (ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការបំពាក់និងថែរក្សាធុងសំរាមទាំងនោះ
- បង្ហាញអំពីចំនួនធុងសំរាមដែលមាននៅតាមទីរមណីយដ្ឋានសំខាន់ៗនីមួយៗ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យP៤.៣ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០៣** ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យP៤.៣ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីទីកន្លែងសំខាន់ៗដែលមានការឆ្លងកាត់ញឹកញាប់ដែលមាន | ស្រង់ស្ថិតិអំពីទីកន្លែងសំខាន់ៗទាំងឡាយដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ ដែលមានបញ្ជាក់ពីប្រភេទនិងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | - តារាងសម្រង់ស្ថិតិ[47]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបចំជាផែនទីទីក្រុង/ខណ្ឌដែលមានដៅបញ្ជាក់ចំនុចទីតាំងទីរមណីយដ្ឋាន | - ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

[47] តារាងទី ៣៦

| | | | |
|---|---|---|---|
| | | ទាំងនោះ | |
| ២ | វត្តមានអ្នកទទួលខុសត្រូវលើការសម្អាតនៅតាមទីកន្លែងទាំងនោះ | បញ្ជាក់ពីវត្តមានអ្នកទទួលបន្ទុកលើការសម្អាតជាប្រចាំនៅតាមទីកន្លែងទាំងនោះ ដែលអាចជា៖<br>- ក្រុមហ៊ុនឯកជន | -កិច្ចសន្យារវាងម្ចាស់ទីតាំង និងក្រុមហ៊ុនឯកជន (កម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ) |
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកសម្អាតនៅតាមទីកន្លែងទាំងនោះតាមការចាត់តាំងរបស់អាជ្ញាធរមានសមត្ថកិច្ច | -ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់អ្នកចាត់តាំង |
| ៣ | ធុងសំរាមត្រូវមានចំនួនគ្រប់គ្រាន់ | ការណែនាំរបស់អាជ្ញាធរទីក្រុង/ខណ្ឌអំពីការតម្រូវឲ្យមានធុងសំរាមនៅតាមទីតាំងទាំងនោះ | - ដីកា/សារាចរណែនាំរបស់ទីក្រុងបេក្ខភាព *(ក្នុងករណីដែលកិច្ចការនេះមិនមែនជាសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាពត្រូវមានដីកាសម្រេច/សារាចរណែនាំរបស់អាជ្ញាធរដែលមានសមត្ថកិច្ចនោះអមជាមួយ)* |
| | *និង* | កំណត់ប្រភេទ/ចំនួន/ទីតាំងដាក់ធុងសំរាមនៅតាមទីកន្លែងទាំងនោះ | - តារាងព័ត៌មាន[48]ដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុង/ខណ្ឌបេក្ខភាព |

## ៤. លក្ខណៈវិនិច្ឆ័យ P៤.៤៖

*"តើមានវត្តមាននៃ**ការគ្រប់គ្រងលើអាកប្បកិរិយា** និង**ការកំណត់អំពីការស្លៀកពាក់**របស់**អ្នកបើកបររថយន្តឈ្នួល រ៉ឺម៉កកង់បី ម៉ូតូឌុប និងអ្នកដំណើរទាំងឡាយនៅលើដងវិថីសាធារណៈ**ដែរឬទេ?"*
*"នឹងផ្ដល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**មាន**"*

### ក. សេចក្ដីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្ដីពន្យល់ |
|---|---|---|
| ១ | ការគ្រប់គ្រងលើអាកប្បកិរិយា | សំដៅដល់វិធាន**ការត្រួតពិនិត្យ និងណែនាំ**ដល់**បុគ្គលម្នាក់ៗ ឬក្រុមណាមួយ**ឲ្យគោរពតាម**វិធានរួម**ណាមួយជាកំណត់ក្នុងការប្រាស្រ័យទាក់ទងរវាងគ្នានិងគ្នា និងក្នុងការអនុវត្តវិជ្ជាជីវៈរបស់ខ្លួន។ |
| ២ | ការកំណត់អំពីការស្លៀកពាក់ | សំដៅដល់**ការកំណត់ និងណែនាំ**អំពីការស្លៀកពាក់ដល់**ជន ឬក្រុមណាមួយ**ក្នុងពេលប្រកបជំនាញ វិជ្ជាជីវៈរបស់ខ្លួន តាមរយៈការកំណត់ឯកសណ្ឋាន**ក្នុងការស្លៀកពាក់ ការពាក់ស្លាកសញ្ញាសម្គាល់ ឬពណ៌សម្គាល់ផ្សេងៗជាដើម**។ |
| ៣ | អ្នកបើកបររថយន្តឈ្នួល រ៉ឺម៉កកង់បី ម៉ូតូឌុប និងអ្នកដំណើរទាំងឡាយនៅលើដងវិថីសាធារណៈ | សំដៅអ្នកបើកប**រមធ្យោបាយដឹកជញ្ជូនរួមគ្រប់ប្រភេទ** (ទាំងការដឹកជញ្ជូនក្នុងទីក្រុង និងការដឹកជញ្ជូនឆ្លងព្រំប្រទល់ទីក្រុង) ដូចជា៖<br>- អ្នកបើកបររថយន្តដឹកជញ្ជូនធុនតូច និងធំ<br>- អ្នកបើកបររ៉ឺម៉កកង់បី ម៉ូតូឌុប ជាដើម។ |

### ខ. ការវាយតម្លៃ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យP៤.៤តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជា

48 តារាងទី ៣៣

កម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**ប្រសិទ្ធិភាព**" វិធានការនៃការត្រួតពិនិត្យលើអាកប្បកិរិយា និងការស្លៀកពាក់របស់អ្នកបើកបរមធ្យោបាយដឹកជញ្ជូនរួមទាំងឡាយដែលមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ យន្តការនេះអាចជាវិធាន ឬបទដ្ឋានណាមួយដែលចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៤ គឺ៖

- ផ្តល់ព័ត៌មានអំពីចំនួនអ្នកបើកបរមធ្យោបាយដឹកជញ្ជូនរួម (ដែលមាន)
- បង្ហាញអំពីវត្តមានវិធានការនៃការត្រួតពិនិត្យលើអាកប្បកិរិយានិងការស្លៀកពាក់របស់អ្នកបើកបរទាំងនោះ
- បង្ហាញអំពីវត្តមានអង្គភាពទទួលខុសត្រូវអនុវត្តវិធានការនេះ
- បង្ហាញអំពីសកម្មភាពអនុវត្តជាក់ស្តែងរបស់អង្គភាពនោះ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យP៤.៤ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខ-ភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៤ ខាងលើ។

**តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ□៤.៤**

| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
|---|---|---|---|
| ១ | ព័ត៌មានអំពីចំនួនអ្នកបើកបរមធ្យោបាយដឹកជញ្ជូនរួម (ដែលមាន) | ស្រង់ស្ថិតិអំពីអ្នកបើកបរមធ្យោបាយដឹក-ជញ្ជូនរួមដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[49]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានវិធានការត្រួតពិនិត្យអាកប្បកិរិយានិងការស្លៀកពាក់របស់អ្នកបើកបរទាំងនោះ | រៀបចំជាវិធាន យន្តការ ឬបទដ្ឋានផ្សេងៗសម្រាប់អនុវត្តការត្រួតពិនិត្យអាកប្បកិរិយានិងការស្លៀកពាក់របស់អ្នកបើកបរទាំងនោះ | -សេចក្តីសម្រេច ឬដីកា ឬនីតិវិធីផ្សេងៗដែលមានតម្លៃស្មើស្តីពីការកំណត់យន្តការត្រួតពិនិត្យអាកប្បកិរិយានិងការស្លៀកពាក់របស់អ្នកបើកបរទាំងនោះ |
| ៣ | វត្តមានអង្គភាពមានសមត្ថកិច្ចដែលទទួលខុសត្រូវលើការត្រួតពិនិត្យ | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៤ | សកម្មភាពជាក់ស្តែង | ធ្វើការបែងចែកជាក្រុមការងារតូចៗសម្រាប់ ចុះត្រួតពិនិត្យ (ក្រុមល្បាត) | - បញ្ជីរាយនាមក្រុមការងារទាំងនោះ ដែលមានការបញ្ជាក់ពីអាជ្ញាធរក្រុង/ខណ្ឌ ឬអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបចំជាតារាងផែនការសកម្មភាព | -តារាងផែនការសកម្មភាពរបស់អង្គភាពដែលទទួលខុសត្រូវការងារនេះ |
| | *និង* | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច<br>- រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែង |

[49] តារាងទី ១៩

# P៥. សូចនាកររំលំអិតនៃភាពស៊ីគ្នានៃស្ថាបត្យកម្មរបស់តំបន់ដែលជាអគារសាធារណៈ និងផ្ទះរបស់ប្រជាពលរដ្ឋ

**កម្មវត្ថុសូចនាកររំលំអិត P៥**

ការរៀបចំទីក្រុងដែលស្តែងតាមរយៈការរក្សាបាននូវភាពស៊ីចង្វាក់គ្នានៃរចនាបទអគារស្ថាបត្យកម្មទាំងឡាយនៃទីក្រុង/ខណ្ឌក៏ជាធាតុផ្សំមួយសំខាន់ចូលរួមដល់ការរក្សាបាននូវភាពស្អាតនៅទីក្រុងផងដែរ។ យើងអាចស្រម៉ៃប្រៀបធៀបរវាងទិដ្ឋភាពនៅតាមដងផ្លូវដែលមានអគារជាប់ៗគ្នាដែលមានពណ៌ ទំហំ និងរចនាបទប្រហាក់ប្រហែលគ្នា ឬស៊ីគ្នាពីមួយទៅមួយ និងទិដ្ឋភាពនៅតាមដងផ្លូវដែលមានអគារចំរុះខ្ពស់ទាប ធំតូចៗ (ជាវីឡាផង ជាផ្ទះល្វែងផង ជាអគារសាងសង់តាមបែបប្រពៃណីបុរាណផង និងជាអគារសម័យផង ... ។ល។)ថាតើទិដ្ឋភាពមួយណាដែលមានភាពទាក់ទាញជាង?

| លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| P៥.១.**ភាពស៊ីសង្វាក់គ្នា**នៃ**រចនាបទ**របស់**អគារសាធារណៈ** | មាន-មិនមាន | ១ |
| P៥.២.**ភាពស៊ីសង្វាក់គ្នា**នៃ**រចនាបទ**របស់**លំនៅដ្ឋានប្រជាពលរដ្ឋ** | មាន-មិនមាន | ១ |

*(ផ្តល់ពិន្ទុ ២/១៧ នៃពិន្ទុសរុបរបស់សូចនាករគោលនៃភាពស្អាត)*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណៈវិនិច្ឆ័យ P៥.១៖

*"**ភាពស៊ីសង្វាក់គ្នា**នៃ**រចនាបទ**របស់**អគារសាធារណៈ**"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**មាន**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ភាពស៊ីសង្វាក់គ្នា | ប្រសិនបើវត្ថុពីរ ឬច្រើនមានភាពស៊ីសង្វាក់គ្នា មានន័យថា វត្ថុទាំងនោះអាចធ្វើសមាហរណកម្មគ្នាបានដែលឆ្លុះបញ្ចាំងពីចំណងពាក់ព័ន្ធគ្នាយ៉ាងស្អិតរមួតរវាងគ្នា ។ |
| ២ | រចនាបទ | សំដៅដល់**ទម្រង់ ឬបច្ចេកទេសនៃការសាងសង់**ដែលបំរើដល់កម្មវត្ថុធ្វើយ៉ាងណាឲ្យមានការទាក់ទាញ។<br>ទម្រង់នេះអាចត្រូវឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងអាគារ និងបរិបទសង្គម វប្បធម៌ ព្រៃឈើ និងធម្មជាតិបរិស្ថានជុំវិញដែលស្តែងពីទំនាក់ទំនងរវាងប្រតិបត្តិការរបស់អគារនិងបរិស្ថានជុំវិញ។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យP៥.១តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) អគារសាធារណៈដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាព ដែលរក្សាបាននូវភាពស៊ីសង្វាក់គ្នានៃស្ថាបត្យកម្ម។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៤ គឺ៖

- ព័ត៌មានអំពីអគារសាធារណៈ (ដែលមាន)
- បង្ហាញអំពីវត្តមានវិធានការលើកទឹកចិត្តឬជំរុញការអនុវត្តការរក្សាភាពស៊ីសង្វាក់គ្នានៃអគារសាធារណៈ

- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវអនុវត្តវិធានការដែលបានដាក់ចេញ
- បង្ហាញអំពីលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យP៥.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខ-ភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៤ ខាងលើ។

**តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យP៥.១**

| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
|---|---|---|---|
| ១ | ព័ត៌មានអំពីអគារសាធារណៈ | ស្រង់ស្ថិតិអំពីអគារសាធារណៈដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ ដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | -តារាងសម្រង់ស្ថិតិ[50]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានវិធានការលើកទឹកចិត្តឬជំរុញការអនុវត្ត | រៀបចំជាវិធាន យន្តការ ឬបទដ្ឋានផ្សេងៗសម្រាប់អនុវត្តការលើកទឹកចិត្តឬជំរុញការរក្សាឲ្យបាននូវភាពស៊ីសង្វាក់គ្នានៃរចនាបទអគារសាធារណៈ | -សេចក្តីសម្រេច ឬដីកា ឬនីតិវិធីផ្សេងៗដែលមានតម្លៃស្មើស្តីពីការកំណត់យន្តការលើកទឹកចិត្តឬជំរុញការរក្សាឲ្យបាននូវភាពស៊ីសង្វាក់គ្នានៃរចនាបទអគារសាធារណៈ |
| ៣ | វត្តមានអង្គភាពមានសមត្ថកិច្ចដែលទទួលខុសត្រូវលើការអនុវត្ត | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៤ | លទ្ធផលជាក់ស្តែង | រៀបចំជារបាយការណ៍រូបភាពស្តីពីភាពស៊ីសង្វាក់គ្នានៃរចនាបទអគារសាធារណៈនៅតាមតំបន់នីមួយៗ | -រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីទិដ្ឋភាពជាក់ស្តែងនៅតាមទីតាំងនីមួយៗ |

## ២. លក្ខណវិនិច្ឆ័យ P៥.២៖

*"__ភាពស៊ីសង្វាក់គ្នា__នៃ__រចនាបទ__របស់__លំនៅដ្ឋានប្រជាពលរដ្ឋ__"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា__មាន__"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ភាពស៊ីសង្វាក់គ្នា | ប្រសិនបើវត្ថុពីរ ឬច្រើនមានភាពស៊ីសង្វាក់គ្នា មានន័យថា វត្ថុទាំងនោះអាចធ្វើសមាហរណកម្មគ្នាបានដែលឆ្លុះបញ្ចាំងពីចំណងពាក់ព័ន្ធគ្នាយ៉ាងស្អិតរមួតរវាងគ្នា ។ |
| ២ | រចនាបទ | សំដៅដល់**__ទម្រង់ ឬបច្ចេកទេសនៃការសាងសង់__**ដែលបំរើដល់កម្មវត្ថុធ្វើយ៉ាងណាឲ្យមានការទាក់ទាញ។ ទម្រង់នេះអាចត្រូវឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងអាគារ និងបរិបទសង្គម វប្បធម៌ ព្រៃឈើ និងធម្មជាតិដែលស្តែងពីទំនាក់ទំនងរវាងប្រតិបត្តិការរបស់អគារ និងបរិស្ថានជុំវិញ។ |
| ៣ | លំនៅដ្ឋាន | សំដៅដល់**__លំនៅដ្ឋានរបស់ប្រជាពលរដ្ឋទូទៅ__** ក្នុងគោលបំណងសម្រាប់ការ**__ស្នាក់នៅជាចំបង__**។ |

[50] តារាងទី ០១

| | | |
|---|---|---|
| | ប្រជាពលរដ្ឋ | ត្រូវបានរាប់បញ្ចូលផងដែរនូវផ្ទះជួល បុរី អាផាត់មែន។ល។<br>តែមិនត្រូវបានរាប់បញ្ចូលទេនូវ ៖ អគារក្រុមហ៊ុន អគារការិយាល័យទូទៅ ហាងលក់ទំនិញ ភោជនីយដ្ឋាន ។ល។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យP៥.២តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) នៃលំនៅដ្ឋានប្រជាពលរដ្ឋដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៤ គឺៈ

- ព័ត៌មានអំពីតំបន់លំនៅដ្ឋានប្រជាពលរដ្ឋដែលមាន
- បង្ហាញអំពីវត្តមានវិធានការលើកទឹកចិត្តឬជំរុញការអនុវត្តការរក្សាភាពស៊ីសង្វាក់គ្នានៃលំនៅដ្ឋាន
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវអនុវត្តវិធានការដែលបានដាក់ចេញ
- បង្ហាញអំពីលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យP៥.២ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៤ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យP៥.២ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីតំបន់លំនៅដ្ឋានប្រជាពលរដ្ឋ(ដែលមាន) | ស្រង់ស្ថិតិអំពីតំបន់លំនៅដ្ឋានប្រជាពលរដ្ឋដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ ដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | -តារាងសម្រង់ស្ថិតិ[51]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានវិធានការលើកទឹកចិត្តឬជំរុញការអនុវត្ត | រៀបចំជាវិធាន យន្តការ ឬបទដ្ឋានផ្សេងៗសម្រាប់អនុវត្តការលើកទឹកចិត្តឬជំរុញការរក្សាឲ្យបាននូវភាពស៊ីសង្វាក់គ្នានៃលំនៅដ្ឋានប្រជាពលរដ្ឋនៅតាមតំបន់នានាដែលមាន | -សេចក្តីសម្រេច ឬដីកា ឬនីតិវិធីផ្សេងៗដែលមានតម្លៃស្មើស្តីពីការកំណត់យន្តការលើកទឹកចិត្តឬជំរុញការរក្សាឲ្យបាននូវភាពស៊ីសង្វាក់គ្នានៃរចនាបទលំនៅដ្ឋានប្រជាពលរដ្ឋនៅតាមតំបន់នានា(ដែលមាន) |
| ៣ | វត្តមានអង្គភាពមានសមត្ថកិច្ចដែលទទួលខុសត្រូវលើការអនុវត្ត | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៤ | លទ្ធផលជាក់ស្តែង | រៀបចំជារបាយការណ៍រូបភាពស្តីពីភាពស៊ីសង្វាក់គ្នានៃរចនាបទលំនៅដ្ឋានប្រជាពលរដ្ឋនៅតាមតំបន់នានានៅតាមតំបន់នីមួយៗ | -រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីទិដ្ឋភាពជាក់ស្តែងនៅតាមទីតាំងនីមួយៗ |

[51] តារាងទី ២១

# P៦.សូចនាករលំអិតនៃការតុបតែងលម្អនៅតាមទីរមណីយដ្ឋានសំខាន់ៗ និងសម្បទាទេសចរណ៍

## កម្មវត្ថុសូចនាករលំអិត P៦

សូចនាករលំអិតP៦នេះសំដៅលើសូចនាករ P៦ បំពេញបន្ថែមក្នុងគោលបំណងជំរុញសោភណ្ឌភាពជារួមនៅតាមទីក្រុងបេក្ខភាពឲ្យកាន់តែមានស្រស់ស្អាតឡើងៗ។

| លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| P៦.១.**<u>ភាពស៊ីសង្វាក់គ្នា</u>**នៃ**<u>ការតុបតែងលម្អ</u>**នៅតាម**<u>ទីរមណីយដ្ឋាន</u>**នានាស្របទៅនឹង**<u>លក្ខណៈពិសេសនៃតំបន់នីមួយៗ</u>** (Spécificité de la région) | មាន-មិនមាន | ១ |
| P៦.២.**<u>ភាពស៊ីសង្វាក់គ្នា</u>**នៃ**<u>ការតុបតែងលម្អមធ្យោបាយដឹកជញ្ជូនទេសចរណ៍</u>** | មាន-មិនមាន | ១ |

*(ផ្តល់ពិន្ទុ ២/១៧ នៃពិន្ទុសរុបរបស់សូចនាករគោលនៃភាពស្អាត)*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណវិនិច្ឆ័យ P៦.១៖

*"**<u>ភាពស៊ីសង្វាក់គ្នា</u>**នៃការតុបតែងលម្អនៅតាម**<u>ទីរមណីយដ្ឋាន</u>**នានាស្របទៅនឹង**<u>លក្ខណៈពិសេសនៃតំបន់នីមួយៗ</u>** <u>([illegible])</u>"*

*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**<u>មាន</u>**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ភាពស៊ីសង្វាក់គ្នា | ប្រសិនបើវត្ថុពីរ ឬច្រើនមានភាពស៊ីសង្វាក់គ្នា មានន័យថា វត្ថុទាំងនោះអាចធ្វើសមាហរណកម្មគ្នាបាន ដែលឆ្លុះបញ្ចាំងពីចំណងពាក់ព័ន្ធគ្នាយ៉ាងស្អិតរមួតរវាងគ្នា ។ |
| ២ | រមណីយដ្ឋានទេសចរណ៍ | សំដៅដល់ទីតាំង ដែលមានភាពទាក់ទាញទេសចរណ៍ដូចជា វប្បធម៌ ប្រវត្តសាស្ត្រ ធម្មជាតិ ឆ្នេរ សមុទ្រ ឬដែលរៀបចំកែច្នៃឡើងហើយត្រូវបានអនុញ្ញាតឲ្យរៀបចំសម្រាប់ធ្វើអាជីវកម្ម បម្រើឲ្យការសម្រាកលំហែ និងកម្សាន្ត តាមគោលបំណងទេសចរណ៍ស្របច្បាប់ ។ |
| ៣ | លក្ខណៈពិសេសនៃតំបន់នីមួយៗ (Spécificité de la région) | សំដៅដល់រចនាបទ រូបសំណាក ឬនិមិត្តសញ្ញាណាមួយដែលជាតំណាងតៗគ្នា ឬជាលក្ខណៈសំគាល់ជាពិសេសសម្រាប់តំបន់ឬក្រុមនោះ ឬជាលក្ខណៈបង្ហាញ/សំគាល់ណាមួយដែលមានលក្ខណៈផ្សារភ្ជាប់រវាងតំបន់នេះនឹងពិសេសធម្មជាតិ។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យP៦.១តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**កម្រិត**" (បរិមាណ) ការតុបតែងលម្អនៅតាមទីរមណីយដ្ឋាននានាដែលមាននៅក្នុងដែនសមត្ថកិច្ច

របស់ទីក្រុងបេក្ខភាព ឲ្យមានភាពស៊ីចង្វាក់គ្នា និងស្របទៅនឹងលក្ខណៈពិសេសនៃតំបន់ទាំងនេះ។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យគណៈកម្មាធិការជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៤ គឺៈ

- ព័ត៌មានអំពីទីរមណីយដ្ឋានសំខាន់ៗ (ដែលមាន)
- បង្ហាញអំពីវត្តមានវិធានការលើកទឹកចិត្តឬជំរុញការអនុវត្តការរក្សាភាពស៊ីសង្វាក់គ្នានៃការតុបតែងលម្អនៅតាមរមណីយដ្ឋានទាំងនោះទៅនឹងលក្ខណៈពិសេសនៃតំបន់នោះ
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវអនុវត្តវិធានការដែលបានដាក់ចេញ
- បង្ហាញអំពីលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យP៦.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខ-ភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៤ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យP៦.១ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីរម-ណីយដ្ឋាន (ដែលមាន) | ស្រង់ស្ថិតិអំពីរមណីយដ្ឋានដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[52]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបចំជាផែនទីទីក្រុង/ខណ្ឌដែលមានដៅបញ្ជាក់ចំនុចទីតាំងរបស់តំបន់ទាំងនោះ។ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានវិធានការលើកទឹកចិត្តឬជំរុញការអនុវត្ត | រៀបចំជាវិធាន យន្តការ ឬបទដ្ឋានផ្សេងៗសម្រាប់អនុវត្តការលើកទឹកចិត្តឬជំរុញការរក្សាឲ្យបាននូវភាពស៊ីសង្វាក់គ្នារវាងការតុបតែងលម្អនៅតាមរមណីយដ្ឋាននិងលក្ខណៈពិសេសនៃតំបន់ | -សេចក្តីសម្រេច ឬដីកា ឬនីតិវិធីផ្សេងៗដែលមានតម្លៃស្មើស្តីពីការកំណត់យន្តការលើកទឹកចិត្តឬជំរុញការរក្សាឲ្យបាននូវភាពស៊ីសង្វាក់គ្នារវាងការតុបតែងលម្អនៅតាមរមណីយដ្ឋាននិងលក្ខណៈពិសេសនៃតំបន់ |
| ៣ | វត្តមានអង្គភាពមានសមត្ថកិច្ចដែលទទួលខុសត្រូវលើការអនុវត្ត | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៤ | លទ្ធផលជាក់ស្តែង | រៀបចំជារបាយការណ៍រូបភាពស្តីពីភាពស៊ីសង្វាក់គ្នារវាងការតុបតែងលម្អនៅតាមរមណីយដ្ឋាននិងលក្ខណៈពិសេសនៃតំបន់ | -រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីទិដ្ឋភាពជាក់ស្តែងនៅតាមទីតាំងនីមួយៗ |

## ២. លក្ខណវិនិច្ឆ័យ P៦.២ៈ

*"__ភាពស៊ីសង្វាក់គ្នា__នៃការតុបតែងលម្អ__មធ្យោបាយដឹកជញ្ជូនទេសចរណ៍__"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា__មាន__"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

[52] តារាងទី ០១

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ភាពស៊ីសង្វាក់គ្នា | ប្រសិនបើវត្ថុពីរ ឬច្រើនមានភាពស៊ីសង្វាក់គ្នា មានន័យថា វត្ថុទាំងនោះអាចធ្វើសមាហរណកម្មគ្នាបាន ដែលឆ្លុះបញ្ចាំងពីចំណងពាក់ព័ន្ធគ្នាយ៉ាងស្អិតរមួតរវាងគ្នា ។ |
| ២ | មធ្យោបាយដឹកជញ្ជូនទេសចរណ៍ | សំដៅដល់**យានជំនិះដែលអាចបំលាស់ទីវត្ថុ ឬបុគ្គល** (ទេសចរ) ពីទីកន្លែងមួយទៅទីកន្លែងមួយទៀត ហើយការដឹកជញ្ជូននេះរាប់បញ្ចូលទាំងការដឹកជញ្ជូនភ្ញៀវទេសចររវាងគោលដៅផ្សេងៗនៅក្នុងរមណីយដ្ឋានទេសចរណ៍មួយផងដែរ។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យP៦.២តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**កម្រិត**" (បរិមាណ) ការតុបតែងលម្អមធ្យោបាយដឹកជញ្ជូនទេសចរដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាពធ្វើយ៉ាងណាឲ្យស៊ីគ្នារវាងការតុបតែង និងលក្ខណៈពិសេសនៃតំបន់នោះ។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ** ជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៤** គឺ៖

- ព័ត៌មានអំពីមធ្យោបាយដឹកជញ្ជូនទេសចរ (ដែលមាន)
- បង្ហាញអំពីវត្តមានវិធានការលើកទឹកចិត្តឬជំរុញការអនុវត្តការរក្សាភាពស៊ីសង្វាក់គ្នានៃការតុបតែងលម្អរថយន្តដឹកជញ្ជូនទេសចរនៃតំបន់នោះ
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវអនុវត្តវិធានការដែលបានដាក់ចេញ
- បង្ហាញអំពីលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យP៦.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៤ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យP៦.២ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីមធ្យោបាយដឹកជញ្ជូនទេសចរដែលមាន | ស្រង់ស្ថិតិអំពីមធ្យោបាយដឹកជញ្ជូនទេសចរដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[53]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានវិធានការលើកទឹកចិត្តឬជំរុញការអនុវត្ត | រៀបរាងជាវិធាន យន្តការ ឬបទដ្ឋានផ្សេងៗសម្រាប់អនុវត្តការលើកទឹកចិត្តឬជំរុញការរក្សាឲ្យបាននូវភាពស៊ីសង្វាក់គ្នានៃការតុបតែងលម្អមធ្យោបាយដឹកជញ្ជូនទេសចរដែលមាន | -សេចក្តីសម្រេច ឬដីកា ឬនីតិវិធីផ្សេងៗដែលមានតម្លៃស្មើស្តីពីការកំណត់យន្តការលើកទឹកចិត្តឬជំរុញការរក្សាឲ្យបាននូវភាពស៊ីសង្វាក់គ្នានៃការ តុបតែងលម្អមធ្យោបាយដឹកជញ្ជូនទេសចរដែលមាន |
| ៣ | វត្តមានអង្គភាពមានសមត្ថកិច្ចដែលទទួលខុសត្រូវលើការអនុវត្ត | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |

[53] តារាងទី ១០

| | | | |
|---|---|---|---|
| ៤ | លទ្ធផលជាក់ស្តែង | រៀបចំជារបាយការណ៍រូបភាពស្តីពីភាពស៊ីសង្វាក់គ្នានៃការតុបតែងលម្អមធ្យោបាយដឹកជញ្ជូនទេសចរដែលមាន | - រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីទិដ្ឋភាពជាក់ស្តែងនៅតាមទីតាំងនីមួយ ៗ |

# ផ្នែកទី៣
# សូចនាករគោលស្តីអំពីការគ្រប់គ្រងសំណល់

ការគ្រប់គ្រងសំណល់នៅសំដៅដល់៖ ការប្រមូល ការដឹកជញ្ជូន ការធ្វើប្រព្រឹត្តកម្មការប្រើប្រាស់ សំណល់ឡើងវិញ ឬការលុបបំបាត់ សំណល់ចោលតែម្តង។ ការគ្រប់គ្រងសំណល់មានបំណងសំខាន់ចូលរួម ដល់ការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានរបស់សំណល់ទាំងនោះមកលើ ៖ សុខភាពរបស់ប្រជាពលរដ្ឋ បរិស្ថាន និងសោភ័ណភាពរបស់ក្រុង។

នាពាក់កណ្តាលចនៃសតវត្សទី២១នេះ បរិមាណសំណល់ទូទាំងពិភពលោកមានការកើនឡើងគួរឲ្យកត់សម្គាល់ (កំណើននេះស្របនឹងកំណើននៃការអភិវឌ្ឍឧស្សាហកម្ម) ។ នេះជាក្តីបារម្ភមួយរបស់ពិភពលោកចំពោះឥទ្ធិពលអាក្រក់ដែលអាចបង្កមកពីសំណល់ឧស្សាហកម្ម។ (ប្រព័ន្ធគ្រប់គ្រងនិងធ្វើប្រព្រឹត្តកម្មសំណល់ នៅលើពិភពលោកជួបប្រទះនូវការលំបាកច្រើនក្នុងការអនុវត្តនោះ) យ៉ាងណាក៏ដោយការគ្រប់គ្រងសំណល់ គឺជាចំណុចដែលត្រូវយកចិត្តទុកដាក់ខ្ពស់ហើយយ៉ាងហោចណាស់គ្រប់គ្រងតាមវិធីសាស្ត្រសាមញ្ញគួរតែអាជ្ញាធរក្រុង/ខណ្ឌបេក្ខភាពត្រូវយកចិត្តទុកដាក់ចាប់ផ្តើមអនុវត្ត ។

ច្បាស់ណាស់ថា តាមរយៈសូចនាករគោលទី៣នេះ ចលនាប្រឡងប្រណាំងទីក្រុងស្អាតមានសំដៅជំរុញឲ្យមានការរៀបចំផែនការគ្រប់គ្រងសំណល់នៅតាមទីក្រុងបេក្ខភាព។ ដើម្បីធានាប្រសិទ្ធភាពនូវការអនុវត្តរបស់សូចនាករលម្អិតមួយចំនួនក្នុងសូចនាករគោលទី៣នេះក្រុងបេក្ខភាពត្រូវតែត្រៀមរៀបចំគម្រោងប្រមូល និងធ្វើប្រព្រឹត្តកម្មសំណល់រាវ និងសំណល់រឹងព្រមទាំងកាត់បន្ថយការបញ្ចេញចោលនូវសំណល់ដែលមានជាតិពុល។

ម៉្យាងទៀតសូចនាករគោលទី៣នេះ លើកទឹកចិត្តឲ្យមាន យុទ្ធនាការបញ្ជ្រាបការយល់ដឹងដែលពាក់ព័ន្ធ នឹងកិច្ចការដល់គ្រប់ភាគីពាក់ព័ន្ធក្នុងក្រុង។

## D១. សូចនាករលំអិតនៃការប្រមូលសំណល់រាវ

### កម្មវត្ថុសូចនាករលំអិតD១

សំណល់រាវគឺជាប្រភពបំពុលដ៏សំខាន់ដល់ធនធានធម្មជាតិ និងបរិស្ថាន ពិសេសគឺប្រភពទឹកធម្មជាតិ ផ្សេងៗតែម្ដង។ ការធ្វេសប្រហែសមិនបានយកចិត្តទុកដាក់គ្រប់គ្រងលើសំណល់រាវឲ្យបានត្រឹមត្រូវជា ឧទាហរណ៍ អាក្រក់មួយដែលបណ្ដាលឲ្យមានការបំពុលទឹកយ៉ាងធ្ងន់ធ្ងរដែលបញ្ហាទាំងនេះកើតមានច្រើនករណីមក ហើយនៅប្រទេសអភិវឌ្ឍ និងកំពុងអភិវឌ្ឍមួយចំនួននៅលើពិភពលោក។ ការបំពុលទឹកបានកំពុងក្លាយជាបញ្ហា ដែលបណ្ដាទីក្រុងភាគច្រើនលើពិភពលោកពិសេសទីក្រុងថ្មីៗត្រូវយកចិត្តទុកដាក់ដោយហេតុថាការបំពុលទឹក បង្កផលជាអវិជ្ជមានជាខ្លាំងដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុង ឧទាហរណ៍ កង្វះទឹកស្អាតសម្រាប់ប្រើប្រាស់ បណ្ដាលឲ្យមានជំងឺឆ្លងរាគត្បាតផ្សេងៗ និងតម្រូវឲ្យមានការចំណាយថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់ដើម្បីស្ដារ ប្រភពទឹកឡើងវិញ។

| **លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|
| D១.១. ភាគរយនៃ**ប្រជាពលរដ្ឋ**ដែលភ្ជាប់ខ្លួនទៅក្នុង**បណ្ដាញដែលមានវិធានការគ្រប់គ្រងលើទឹកដែលបានប្រើប្រាស់រួច** | យ៉ាងហោចណាស់មាន៣០%ដែលបានចូលរួម | ១ |
| D១.២. ភាពញឹកញាប់នៃការប្រមូល**សំណល់រាវ** (ឧទាហរណ៍នៅតាមសណ្ឋាគារ។ល។) | យ៉ាងហោច១ដងក្នុង១សប្ដាហ៍ | ១ |

*(ផ្តល់ពិន្ទុ ២/៨ នៃពិន្ទុសរុបរបស់សូចនាករគោលស្តីពីការគ្រប់គ្រងសំណល់)*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណៈវិនិច្ឆ័យ D១.១៖

*"ភាគរយនៃ<u>ប្រជាពលរដ្ឋ</u>ដែលភ្ជាប់ខ្លួនទៅក្នុង**<u>បណ្តាញដែលមានវិធានការគ្រប់គ្រងលើទឹកដែលបាន</u>** <u>ប្រើប្រាស់រួច</u>។"*

*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**<u>យ៉ាងហោចណាស់មានប្រជាពលរដ្ឋ៣០%បានចូលរួមក្នុង</u>** <u>វិធានការនេះ</u>"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ប្រជាពលរដ្ឋ | សំដៅដល់ជនគ្រប់រូបដែលមាន**<u>អត្រានុកូលដ្ឋាន</u>**នៅក្នុងដែនសមត្ថកិច្ចទីក្រុង គឺរាប់បញ្ចូលទាំងប្រជាកសិករ ប្រជាជនមូលដ្ឋាន អាជីវករ អ្នកធ្វើការការិយាល័យ។ល។ |
| ២ | បណ្តាញដែលមានវិធានការគ្រប់គ្រងលើទឹកដែលបានប្រើប្រាស់រួច | សំដៅដល់បណ្តាញប្រមូលសំណល់រាវ (**<u>សំណល់រាវធម្មតា</u>**) ដែលចេញពីផ្ទះបាយ បន្ទប់ទឹក និងដែល**<u>មកពីការប្រើប្រាស់ប្រចាំថ្ងៃផ្សេងទៀតរបស់ប្រជាពលរដ្ឋទូទៅ</u>**។ បណ្តាញនោះអាចជាប្រព័ន្ធបង្ហូររួម ឬរថយន្តបូមសំណល់រាវតាមផ្ទះជាដើម។ |

## ២. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យD១.១តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) ប្រជាពលរដ្ឋដែលបានភ្ជាប់ខ្លួនទៅនឹងបណ្តាញដែលមានវិធានការគ្រប់គ្រងលើទឹកដែលប្រើប្រាស់រួចដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់បេក្ខភាព (**គឺយ៉ាងហោចមានប្រជាពលរដ្ឋ៣០%បានចូលរួមក្នុងវិធានការនេះ**។) ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ គ.ជ.វ.ទ ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៤ គឺ៖

- ព័ត៌មានអំពីចំនួនប្រជាពលរដ្ឋដែលដើរតួជាប្រភពបញ្ចេញសំណល់រាវ
- ព័ត៌មានអំពីបណ្តាញប្រមូលសំណល់រាវដែលមាន
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើបណ្តាញប្រមូលសំណល់រាវទាំងនោះ
- បង្ហាញអំពីលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យD១.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៤ ខាងលើ។

## តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យD១.១

| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
|---|---|---|---|
| ១ | ព័ត៌មានអំពីចំនួនប្រជាពលរដ្ឋ | ស្រង់ស្ថិតិអំពីចំនួនប្រជាពលរដ្ឋដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[54]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | ព័ត៌មានអំពីបណ្តាញប្រមូលសំណល់រាវ | ស្រង់ស្ថិតិអំពីចំនួនបណ្តាញប្រមូលសំណល់រាវដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[55]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបចំជាផែនទីទីក្រុង/ខណ្ឌដែលមានដៅបញ្ជាក់ចំនុចទីតាំងបណ្តាញប្រមូលសំណល់រាវទាំងនោះ ។ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ៣ | វត្តមានអ្នកទទួលខុសត្រូវបណ្តាញប្រមូលសំណល់រាវទាំងនោះ | បញ្ជាក់ពីវត្តមានអ្នកទទួលបន្ទុកលើការប្រមូលសំណល់រាវ ដែលអាចជា៖<br>- ក្រុមហ៊ុនឯកជន | -កិច្ចសន្យារវាងម្ចាស់ទីតាំង និងក្រុមហ៊ុនឯកជន(ដែលមានកម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ) |
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកសម្អាតនៅតាមទីកន្លែងទាំងនោះតាមការចាត់តាំងរបស់អាជ្ញាធរមានសមត្ថកិច្ច | -ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់អ្នកចាត់តាំង |
| ៣ | លទ្ធផលជាក់ស្តែង | រៀបចំជាតារាងអំពីសកម្មភាពនៃការប្រមូល សំណល់រាវ ដោយមានបញ្ជាក់ថាមាន ប្រជាជនយ៉ាងហោច ៣០%បានចូលរួមក្នុងវិធានការនេះ | -តារាងសម្រង់ស្ថិតិ[56]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

## ២. លក្ខណៈវិនិច្ឆ័យD១.២៖

*"ភាពញឹកញាប់នៃការប្រមូល**<u>សំណល់រាវ</u>**"*
*"នឹងទទួលបាន ១ពិន្ទុប្រសិនបើមានការប្រមូលសំណល់រាវ**<u>យ៉ាងហោចណាស់១ដងក្នុងមួយសប្តាហ៍</u>**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | សំណល់រាវ | សំដៅលើសារធាតុ ឬវត្ថុរាវដែលបញ្ចេញពីប្រភពផ្សេងៗ (ដូចជា៖ សំណល់មកពីការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ សណ្ឋាគារ រោងចក្រ សហគ្រាស.... ) |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យD១.២តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ភាពញឹកញាប់"** (បរិមាណ) នៃការប្រមូលសំណល់រាវពីប្រជាជនដែលបានភ្ជាប់ខ្លួននឹងបណ្តាញប្រមូលទឹកដែលប្រើប្រាស់រួច។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបញ្ជាក់បំភ្លឺនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៤ គឺ៖

---

[54] តារាងទី ៣៧

[55] តារាងទី ១៤

[56] តារាងទី ៤០

- ព័ត៌មានអំពីចំនួនប្រជាពលរដ្ឋដែលដើរតួជាប្រភពបញ្ចេញសំណល់រាវ
- ព័ត៌មានអំពីបណ្តាញប្រមូលសំណល់រាវ (ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើបណ្តាញប្រមូលសំណល់រាវទាំងនោះ
- បង្ហាញអំពីសកម្មភាព និងលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យD១.២ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៤ ខាងលើ។

| **តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យD១.២** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីចំនួនប្រជាពលរដ្ឋ | ស្រង់ស្ថិតិអំពីចំនួនប្រជាពលរដ្ឋដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[57]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | ព័ត៌មានអំពីបណ្តាញប្រមូលសំណល់រាវ | ស្រង់ស្ថិតិអំពីចំនួនបណ្តាញប្រមូលសំណល់រាវដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[58]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបចំជាផែនទីទីក្រុង/ខណ្ឌដែលមានដៅបញ្ជាក់ចំនុចទីតាំងបណ្តាញប្រមូលសំណល់រាវទាំងនោះ។ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ៣ | វត្តមានអ្នកទទួលខុសត្រូវបណ្តាញប្រមូលសំណល់រាវទាំងនោះ | បញ្ជាក់ពីវត្តមានអ្នកទទួលបន្ទុកលើការប្រមូល្សំណល់រាវ ដែលអាចជា៖<br>- ក្រុមហ៊ុនឯកជន | -កិច្ចសន្យារវាងម្ចាស់ទីតាំង និងក្រុមហ៊ុនឯកជនដែលមានកម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ |
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកសម្អាតនៅតាមទីកន្លែងទាំងនោះតាមការចាត់តាំងរបស់អាជ្ញាធរមានសមត្ថកិច្ច | -ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់អ្នកចាត់តាំង |
| ៣ | សកម្មភាពនិងលទ្ធផលជាក់ស្តែង | ការណែនាំរបស់អាជ្ញាធរទីក្រុងឲ្យមានការប្រមូលសំណល់រាវយ៉ាងទៀងទាត់ | - ដីកា/សារាចរណែនាំរបស់ទីក្រុងបេក្ខភាព *(ក្នុងករណីដែលកិច្ចការនេះមិនមែនជាសមត្ថកិច្ចរបស់ទីក្រុង/ខណ្ឌបេក្ខភាព ត្រូវមានដីកា សម្រេច/សារាចរណែនាំរបស់អាជ្ញាធរដែលមានសមត្ថកិច្ចនោះអមជាមួយ)* |
| | *និង* | រៀបចំជាតារាងអំពីសកម្មភាពនៃការប្រមូលសំណល់រាវសម្រាប់តំបន់នីមួយៗដោយមានបញ្ជាក់អំពីប្រភេទផ្សេងៗនៃការប្រមូល និងភាពញឹកញាប់នៃការប្រមូល(យ៉ាងហោចណាស់១ដងក្នុង១សប្តាហ៍) | - តារាងសម្រង់ស្ថិតិ[59]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

[57] តារាងទី ៣៧

[58] តារាងទី ១៤

[59] តារាងទី ៤០

# D២. សូចនាករលំអិតនៃការប្រមូលសំណល់រឹង

**កម្មវត្ថុសូចនាករលំអិត D២**

សំណល់រឹងគឺជាប្រភពបំពុលមួយប្រភេទដែល គួរយកចិត្តទុកដាក់គ្រប់គ្រងឲ្យបានល្អដោយហេតុថាសំណល់រឹងប្រភេទនេះនាំឲ្យមានការបំពុលដី និងប្រភពទឹកផ្សេងៗយ៉ាងខ្លាំងប្រសិនបើមិនមានការគ្រប់គ្រងឲ្យបានឲ្យបានត្រឹមត្រូវ។ មួយវិញទៀត ការគ្រប់គ្រងសំណល់រឹងមិនបានល្អត្រឹមត្រូវ ឧទាហរណ៍ដូចជាការប្រមូលសំណល់រឹងឬការទុកដាក់មិនបានត្រឹមត្រូវ ក៏បង្កផលប៉ះពាល់ជាអវិជ្ជមានដល់សោភណ្ឌភាពទីក្រុងផងដែរ។

| លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| D២.១.ភាគរយនៃ**ប្រជាពលរដ្ឋ**ដែលស្ថិតក្នុង**ការប្រមូលសំណល់រឹង**ជាទៀងទាត់ | អប្បបរមា៥០% | ១ |
| D២.២.ភាពញឹកញាប់ក្នុងការប្រមូល**សំណល់រឹង** | យ៉ាងហោច១ដងក្នុង១ថ្ងៃ | ១ |

*(ផ្តល់ពិន្ទុ ២/៨ នៃពិន្ទុសរុបរបស់សូចនាករគោលស្តីអំពីការគ្រប់គ្រងសំណល់)*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណៈវិនិច្ឆ័យ D២.១៖

*"ភាគរយនៃ**ប្រជាពលរដ្ឋ**ដែលស្ថិតនៅក្នុង**ការប្រមូលសំណល់រឹង**ជាទៀងទាត់។"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**មានចំនួនប្រជាជនអប្បបរមា៥០%ស្ថិតនៅក្នុងការប្រមូលសំណល់រឹងជាទៀងទាត់**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ប្រជាពលរដ្ឋ | សំដៅដល់ជនគ្រប់រូបដែលមាន**អត្រានុកូលដ្ឋាន**នៅក្នុងដែនសមត្ថកិច្ចនៃទីក្រុងបេក្ខភាព |
| ២ | សំណល់រឹង | សំដៅទៅលើសារធាតុ ឬវត្ថុរឹងដែលបញ្ចេញពីប្រភពបំពុលផ្សេងៗ (ដូចជា៖ មកពីការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ សណ្ឋាគារ សហគ្រាស...។ល។) |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យD២.១តម្រូវឲ្យបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) ប្រជាពលរដ្ឋដែលស្ថិតនៅក្នុងការប្រមូលសំណល់រឹងជាទៀងទាត់។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបញ្ជាក់បំភ្លឺនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺ៖

- ព័ត៌មានអំពីចំនួនប្រជាពលរដ្ឋដែលដើរតួជាប្រភពបញ្ចេញសំណល់រឹង

- បង្ហាញអំពីវត្ថុមានអ្នកទទួលខុសត្រូវលើការប្រមូលសំណល់រឹង
- បង្ហាញអំពីលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យD២.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវនិច្ឆ័យD២.១ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីចំនួនប្រជាពលរដ្ឋ | ស្រង់ស្ថិតិអំពីចំនួនប្រជាពលរដ្ឋដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[60]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្ថុមានអ្នកទទួលខុសត្រូវលើការប្រមូលសំណល់រឹង | បញ្ជាក់ពីវត្ថុមានអ្នកទទួលបន្ទុកលើការប្រមូលសំណល់ភរ ដែលអាចជា៖<br>- ក្រុមហ៊ុនឯកជន | -កិច្ចសន្យារវាងម្ចាស់ទីតាំង និងក្រុមហ៊ុនឯកជនដែលមានកម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ |
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកសម្អាតនៅតាមទីកន្លែងទាំងនោះតាមការចាត់តាំងរបស់អាជ្ញាធរមានសមត្ថកិច្ច | -ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់អ្នកចាត់តាំង |
| ៣ | លទ្ធផលជាក់ស្តែង | រៀបចំជាតារាងអំពីសកម្មភាពនៃការប្រមូលសំណល់រឹង ដោយមានបញ្ជាក់ថាមានប្រជាជនយ៉ាងហោច ៥០%បានចូលរួមក្នុងវិធានការនេះ | -តារាងសម្រង់ស្ថិតិ[61]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

## ២. លក្ខណវនិច្ឆ័យ D២.២៖

*"ភាពញឹកញាប់នៃការប្រមូល**សំណល់រឹង**"*
*"នឹងទទួលបាន ១ពិន្ទុប្រសិនបើមានការប្រមូលសំណល់រឹង**យ៉ាងហោចណាស់១ដងក្នុងមួយថ្ងៃ**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| **ល.រ** | **ពាក្យគន្លឹះ** | **សេចក្តីពន្យល់** |
|---|---|---|
| ១ | សំណល់រឹង | សំដៅទៅលើសារធាតុ ឬវត្ថុរឹងដែលបញ្ចេញពីប្រភពបំពុលផ្សេងៗ (ដូចជា៖ មកពីការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ សណ្ឋាគារ សហគ្រាស...។ល។) |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យD២.២តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ភាពញឹកញាប់"** (បរិមាណ) នៃការប្រមូលសំណល់រឹងពីប្រជាពលរដ្ឋ។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ** ធ្វើការវាយតម្លៃ។

---

[60] តារាងទី ៣៧

[61] តារាងទី ១៥

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៣ គឺ៖

- ព័ត៌មានអំពីចំនួនប្រជាពលរដ្ឋដែលជាប្រភពបញ្ចេញសំណល់រឹង
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការប្រមូលសំណល់រឹង
- បង្ហាញអំពីសកម្មភាពនិងលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យD២.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខ-ភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| **តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យD២.២** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីចំនួនប្រជាពលរដ្ឋ | ស្រង់ស្ថិតិអំពីចំនួនប្រជាពលរដ្ឋដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[62]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវលើការប្រមូលសំណល់រឹង | បញ្ជាក់ពីវត្តមានអ្នកទទួលបន្ទុកលើការប្រមូលសំណល់រាវ ដែលអាចជា៖<br>- ក្រុមហ៊ុនឯកជន | -កិច្ចសន្យារវាងម្ចាស់ទីតាំង និងក្រុមហ៊ុនឯកជនដែលមានកម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ |
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកសម្អាតនៅតាមទីកន្លែងទាំងនោះតាមការចាត់តាំងរបស់អាជ្ញាធរមានសមត្ថកិច្ច | -ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់អ្នកចាត់តាំង |
| ៣ | សកម្មភាពនិងលទ្ធផលជាក់ស្តែង | ការណែនាំរបស់អាជ្ញាធរទីក្រុង/ខណ្ឌឲ្យមានការប្រមូលសំណល់រឹងយ៉ាងទៀងទាត់ | - ដីកា/សារាចរណែនាំរបស់ទីក្រុងបេក្ខភាព *(ក្នុងករណីដែលកិច្ចការនេះមិនមែនជាសមត្ថកិច្ចរបស់ទីក្រុង/ខណ្ឌបេក្ខភាព ត្រូវមានដីកាសម្រេច/សារាចរណែនាំរបស់អាជ្ញាធរដែលមានសមត្ថកិច្ចនោះអមជាមួយ )* |
| | *និង* | រៀបចំជាតារាងអំពីសកម្មភាពនៃការប្រមូលសំណល់រឹងសម្រាប់តំបន់នីមួយៗដោយមានបញ្ជាក់អំពីប្រភេទផ្សេងៗនៃការប្រមូល និងភាពញឹកញាប់នៃការប្រមូល(យ៉ាងហោចណាស់១ដងក្នុង១សប្តាហ៍) | - តារាងសម្រង់ស្ថិតិ[63]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

# D៣.សូចនាករលំអិតអំពីការស្តុក និងការធ្វើប្រព្រឹត្តកម្មសំណល់រាវ

## កម្មវត្ថុសូចនាករលំអិត D៣

ដូចដែលបានលើកមកបរិយាយក្នុងសូចនាករលំអិត □១ សំណល់រាវអាចផ្តល់ផលប៉ះពាល់អវិជ្ជមានជា ច្រើនក៏ដោយក៏យើងទទួលស្គាល់ ការរស់នៅប្រចាំថ្ងៃរបស់មនុស្ស និងសេដ្ឋកិច្ចតំបន់។ ទោះយ៉ាងណាក៏ដោយ ជនគ្រប់រូបក៏បាន

---

62 តារាងទី ៣៧

63 តារាងទី ៣៨

ទទួលស្គាល់ផងដែរថា យើងមិនអាចលុបបំបាត់សំណល់រាវបាននោះទេ ព្រោះវាកើតមានពី សកម្មភាពរស់នៅប្រចាំថ្ងៃរបស់មនុស្ស។ ផ្ទុយទៅវិញ សំណល់រាវអាចនឹងកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃស្រប តាមកំណើនតម្រូវការ និងកំណើនប្រជាជនពិសេសនៅទីក្រុងតែម្តង។ ដូច្នេះ ដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានរបស់សំណល់រាវចាំបាច់ត្រូវមានការគ្រប់គ្រងឲ្យបានត្រឹមត្រូវតាមរយៈការប្រើប្រាស់វិធីសាស្ត្របច្ចេកទេសផ្សេងៗដូចជា៖ ការស្តុក ឬការធ្វើប្រព្រឹត្តកម្មជាដើម។

| លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| D៣.១.លទ្ធភាពដែលអាច<u>ស្តុកសំណល់រាវ (មានបំពាក់ធុងស្តុកសំណល់រាវ)</u>។ | មាន-មិនមាន | ១ |
| D៣.២.ចំនួនភាគរយនៃសណ្ឋាគារ និងផ្ទះសំណាក់ដែលមានអាចស្តុកសម្រាប់ធ្វើ<u>**ប្រព្រឹត្តិកម្មសំណល់**</u>។ | អប្បបរមា៥០% | ១ |

*(ផ្តល់ពិន្ទុ ២/៨ នៃពិន្ទុសរុបរបស់សូចនាករគោលស្តីអំពីការគ្រប់គ្រងសំណល់)*

# ការណែនាំសម្រាប់បេក្ខភាព

## ១. លក្ខណវិនិច្ឆ័យ D៣.១៖

*"លទ្ធភាពដែលអាច<u>ស្តុកសំណល់រាវ (មានបំពាក់ធុងស្តុកសំណល់រាវ)</u>។"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា<u>មាន</u>"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ការស្តុកសំណល់រាវ | សំដៅដល់មធ្យោបាយផ្សេងៗក្នុង<u>**ការស្តុក រក្សាទុកធ្វើប្រព្រឹត្តកម្មបឋម**</u>លើសំណល់រាវដែលបញ្ចេញមកពីប្រភពបំពុលផ្សេងៗ (ដូចជា៖ លំនៅដ្ឋានប្រជាពលរដ្ឋ សណ្ឋាគារ សហគ្រាសជាដើម) ។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យD៣.១តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.**សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំណុះ"** (បរិមាណ) អាងស្តុក ឬធុងស្តុកសំណល់រាវសម្រាប់ប្រើប្រាស់នៅក្នុងទីក្រុងបេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺ៖

- ព័ត៌មានអំពីអាងស្តុកសំណល់រាវ (ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការគ្រប់គ្រងថែរក្សាអាងស្តុកសំណល់រាវទាំងនោះ
- បង្ហាញអំពីលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យD៣.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខ

ភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណៈវិនិច្ឆ័យD៣.១ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីអាងស្តុកសំណល់រាវ (ដែលមាន) | ស្រង់ស្ថិតិអំពីអាងស្តុកសំណល់រាវទាំងឡាយ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ ដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | -តារាងសម្រង់ស្ថិតិ[64]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបចំជាផែនទី ទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងអាងស្តុកទាំងនោះ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវលើការបំពាក់និងថែរក្សាអាងស្តុកសំណល់រាវទាំងនោះ | បញ្ជាក់ពីវត្តមានអ្នកទទួលបន្ទុកលើការបំពាក់និងថែរក្សាអាងស្តុកសំណល់រាវដែលអាចជា៖<br>- ក្រុមហ៊ុនឯកជន | -កិច្ចសន្យារវាងម្ចាស់ទីតាំង និងក្រុមហ៊ុនឯកជនដែលមានកម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ |
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកសម្អាតនៅតាមទីកន្លែងទាំងនោះតាមការចាត់តាំងរបស់អាជ្ញាធរមានសមត្ថកិច្ច | -ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់អ្នកចាត់តាំង |
| ៣ | លទ្ធផលជាក់ស្តែង | រៀបចំជារបាយការណ៍រូបភាពស្តីពីអាងស្តុកសំណល់រាវទាំងឡាយដែលមាន | -រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីទិដ្ឋភាពជាក់ស្តែងនៅតាមទីតាំងនីមួយៗ |

### ២. លក្ខណៈវិនិច្ឆ័យ D៣.២៖

*"ចំនួនភាគរយនៃសណ្ឋាគារ និងផ្ទះសំណាក់ដែលមាន__អាងស្តុកសម្រាប់ធ្វើប្រព្រឹត្តកម្មសំណល់__។"*
*"នឹងទទួលបាន១ពិន្ទុ__ប្រសិនបើយ៉ាងហោចណាស់៥០%នៃចំនួនសណ្ឋាគារនិងផ្ទះសំណាក់ដែលមាន__ មានអាងស្តុកសម្រាប់ធ្វើប្រព្រឹត្តកម្មសំណល់រាវ។"*

## ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| **ល.រ** | **ពាក្យគន្លឹះ** | **សេចក្តីពន្យល់** |
|---|---|---|
| ១ | អាងស្តុកសម្រាប់ធ្វើប្រព្រឹត្តកម្មសំណល់រាវ (ការស្តុកសំណល់រាវ) | សំដៅដល់មធ្យោបាយផ្សេងៗក្នុង**__ការស្តុក រក្សាទុកធ្វើប្រព្រឹត្តកម្មបឋម__**លើសំណល់រាវដែលបញ្ចេញមកពីប្រភពបំពុលផ្សេងៗ (ដូចជា៖ លំនៅដ្ឋានប្រជាពលរដ្ឋ សណ្ឋាគារ សហគ្រាស ជាដើម) ។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យD៣.២តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) សណ្ឋាគារ និងផ្ទះសំណាក់ដែលមានអាងស្តុកសម្រាប់ធ្វើប្រព្រឹត្តកម្ម

[64] តារាងទី ០៧

សំណល់រាវ។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៣ គឺ៖

- ព័ត៌មានអំពីសណ្ឋាគារនិងផ្ទះសំណាក់ (ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការគ្រប់គ្រងថែរក្សាអាងស្តុកសំណល់រាវទាំងនោះ
- បង្ហាញអំពីលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យD៣.២ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| **តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យD៣.២** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីសណ្ឋា-គារនិងផ្ទះសំណាក់ (ដែលមាន) | ស្រង់ស្ថិតិអំពីសណ្ឋាគារនិងផ្ទះសំណាក់ទាំងឡាយ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ ដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | -តារាងសម្រង់ស្ថិតិ[65]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវលើការបំពាក់និងថែរក្សាអាងស្តុកសំណល់រាវទាំងនោះ | បញ្ជាក់ពីវត្តមានអ្នកទទួលបន្ទុកលើការបំពាក់និងថែរក្សាអាងស្តុកសំណល់រាវ ដែលអាចជា៖<br>- ក្រុមហ៊ុនឯកជន | -កិច្ចសន្យារវាងម្ចាស់ទីតាំង និងក្រុមហ៊ុនឯកជនដែលមានកម្មវត្ថុជាការសម្អាតជាប្រចាំនៅតាមទីតាំងទាំងនោះ |
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកសម្អាតនៅតាមទីកន្លែងទាំងនោះតាមការចាត់តាំងរបស់អាជ្ញាធរមានសមត្ថកិច្ច | -ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់អ្នកចាត់តាំង |
| ៣ | លទ្ធផលជាក់ស្តែង | រៀបចំជាតារាងអំពីអាងស្តុកសំណល់រាវនៅតាមសណ្ឋាគារនិងផ្ទះសំណាក់ ដោយមានបញ្ជាក់ថាមានសណ្ឋាគារនិងផ្ទះសំណាក់យ៉ាងហោច៥០%មានអាងស្តុក | -តារាងសម្រង់ស្ថិតិ[66]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

## D៤.សូចនាករលំអិតនៃការស្តុក និងការធ្វើប្រព្រឹត្តកម្មលើសំណល់រឹង

### កម្មវត្ថុសូចនាករលំអិត D៤

ដូចដែលបានលើកមកបរិយាយក្នុង សូចនាករលំអិត □២ សំណល់រឹងអាចនឹងផ្តល់ផលប៉ះពាល់ជា អវិជ្ជមាន ប៉ុន្តែយើងនៅតែទទួលស្គាល់ថាមិនអាចលុបបំបាត់សំណល់រឹងបានទាំងស្រុងនោះទេ ដោយហេតុថាវាកើតចេញពីសកម្មភាព

[65] តារាងទី ២៣

[66] តារាងទី ០៧

រស់នៅរបស់មនុស្សជារៀងរាល់ថ្ងៃ។ ដូច្នេះ ដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានរបស់សំណល់រឹងចាំបាច់ត្រូវមានការគ្រប់គ្រងឲ្យបានត្រឹមត្រូវតាមរយៈការប្រើប្រាស់វិធីសាស្រ្តបច្ចេកទេសផ្សេងៗ។

| លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| D៤.១.**<u>លទ្ធភាពដែលអាចស្តុកសំណល់រឹង</u>** ក្រៅអំពី**<u>ការស្តុកចោលដោយគ្មានការការពារ</u>**ឱ្យបានត្រឹមត្រូវ។ | មាន-មិនមាន | ១ |

*(ផ្តល់ពិន្ទុ ១/៨ នៃពិន្ទុសរុបរបស់សូចនាករគោលស្តីពីការគ្រប់គ្រងសំណល់)*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ២. លក្ខណៈវិនិច្ឆ័យ D៤.១៖

*"<u>លទ្ធភាពដែលអាចស្តុកសំណល់រឹង</u> ក្រៅអំពី<u>ការស្តុកចោលដោយគ្មានការការពារ</u>ឱ្យបានត្រឹមត្រូវ។"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា<u>មាន</u>"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | លទ្ធភាពស្តុកសំណល់រឹង | សំដៅដល់មធ្យោបាយផ្សេងៗក្នុង**<u>ការស្តុក រក្សាសំណល់រឹង</u>**ទាំងឡាយដែលបញ្ចេញមកពីប្រភពបំពុលផ្សេងៗ(ដូចជា៖ លំនៅដ្ឋានប្រជាពលរដ្ឋ សណ្ឋាគារ រោងចក្រសហគ្រាស) ។ |
| ២ | ការស្តុកចោលដោយគ្មានការការពារ | សំដៅដល់លទ្ធភាពផ្សេងៗក្នុងការស្តុកសំណល់រឹង<u>ដែលប្រាសចាកពីបច្ចេកទេសត្រឹមត្រូវ</u> ។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យD៤.១តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំណុះ"** (បរិមាណ) ទីកន្លែងស្តុកសំណល់រឹងដែលរៀបចំតាមក្បួនខ្នាតបច្ចេកទេសត្រឹមត្រូវ។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបញ្ជាក់បង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៣ គឺ៖

- ព័ត៌មានអំពីកន្លែងស្តុកសំណល់រឹង (ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការគ្រប់គ្រងថែរក្សាកន្លែងស្តុកសំណល់រឹងទាំងនោះ
- បង្ហាញអំពីលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យD៤.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

## តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណៈវិនិច្ឆ័យD៤.១

| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
|---|---|---|---|
| ១ | ព័ត៌មានអំពីកន្លែងស្តុកសំណល់រឹង (ដែលមាន) | ស្រង់ស្ថិតិអំពីកន្លែងស្តុកសំណល់រឹងទាំងឡាយ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងតារាងគំរូមួយ ដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | -តារាងសម្រង់ស្ថិតិដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបចំជាផែនទី ទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងកន្លែងស្តុកទាំងនោះ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវលើកន្លែងស្តុកសំណល់រឹងទាំងនោះ | បញ្ជាក់ពីវត្តមានអ្នកទទួលបន្ទុកលើកន្លែងស្តុកសំណល់រឹងដែលអាចជា៖ - ក្រុមហ៊ុនឯកជន | -កិច្ចសន្យារបស់ក្រុមហ៊ុនឯកជនដែលមានកម្មវត្ថុជាការការថែរក្សាគ្រប់គ្រងកន្លែងស្តុកសំណល់រឹងទាំងនោះ |
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកថែរក្សាគ្រប់គ្រងទីកន្លែងទាំងនោះតាមការចាត់តាំងរបស់អាជ្ញាធរមានសមត្ថកិច្ច | -ឯកសារបញ្ជាក់អំពីសមត្ថកិច្ចរបស់អ្នកចាត់តាំង |
| ៣ | លទ្ធផលជាក់ស្តែង | រៀបចំជារបាយការណ៍រូបភាពស្តីពីកន្លែងស្តុកសំណល់រឹងទាំងឡាយដែលមាន | -រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីទិដ្ឋភាពជាក់ស្តែងនៅតាមទីតាំងនីមួយៗ |

## D៥.សូចនាករលំអិតនៃការបែងចែកសំណល់រឹង

### កម្មវត្ថុសូចនាករលំអិត D៥

ទន្ទឹមនឹងវិធានការក្នុងការស្តុកទុក និងធ្វើប្រព្រឹត្តកម្មសំណល់រឹង ការកែប្រែសំណល់ (Reuse or Recycling) ដើម្បីយកមកប្រើប្រាស់ឡើងវិញបានកំពុងអនុវត្តនៅលើពិភពលោក ពិសេសប្រទេសអភិវឌ្ឍ។ ជាការពិតការអនុវត្តបែបនេះ ចូលរួមយ៉ាងសំខាន់ដល់ការកាត់បន្ថយសំណល់ កាត់បន្ថយការប្រើប្រាស់វត្ថុ ធាតុដើម និងជំរុញលើកទឹកចិត្តដល់ការប្រមូលសំណល់ដោយហេតុថាពេលខ្លះគេអាចរកប្រាក់កំរៃបានតាម រយៈការទិញលក់សំណល់ទាំងនោះដូចវត្ថុធាតុដើមដទៃៗដែរ។

ថ្វីត្បិតតែការអនុវត្តបែបនេះ នៅកម្ពុជាពុំទាន់មានទ្រង់ទ្រាយធំនៅឡើយប៉ុន្តែក៏សង្កេតឃើញមានការប្រើប្រាស់សំណល់ឡើងខ្លះដែរដូចជា៖ សំណល់លោហៈធាតុ សំបកកំប៉ុង ដប ប្លាស្ទិក បាវ ។ល។ ដូច្នេះ ការបែងចែកសំណល់រឹង ពីសំណល់ដទៃពិសេសពពួកសំណុលដែលមានជាតិពុលអាចជួយសំរាលមួយផ្នែក ដល់លទ្ធភាពប្រើប្រាស់សំណល់ឡើងវិញឲ្យបានកាន់តែច្រើន និងជួយកាត់បន្ថយការបញ្ចេញសំណល់ពុល ទៅក្នុងបរិស្ថានដោយមិនបានឆ្លងកាត់ប្រព្រឹត្តកម្មត្រឹមត្រូវ។

| លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| D៥.១.លទ្ធភាពដែលអាចឱ្យសហគ្រាសទាំងឡាយនិង/ឬប្រជាជនមូលដ្ឋានអាចធ្វើ**ការបែងចែកសំណល់**រវាង**សំណល់ធម្មតា** និង**សំណល់ដែលមានជាតិពុល**(ថ្មពិលអាគុយ ប្រេងដែលប្រើប្រាស់រួច។ល។) | មាន-មិនមាន | ១ |

*(ផ្តល់ពិន្ទុ ១/៨ នៃពិន្ទុសរុបរបស់សូចនាករគោលស្តីអំពីការគ្រប់គ្រងសំណល់)*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណវនិច្ឆ័យ D៥.១៖

*"លទ្ធភាពដែលអាចឱ្យសហគ្រាសទាំងឡាយ និង/ឬប្រជាជនមូលដ្ឋានអាចធ្វើ**ការបែងចែកសំណល់**រវាង **សំណល់ធម្មតា** និង**សំណល់ដែលមានជាតិពុល**។"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**មាន**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ការបែងចែកសំណល់ | សំដៅដល់វិធី ឬមធ្យោបាយផ្សេងៗក្នុង**ការស្តុកទុក ឬទុកដាក់សំណល់រឹង**ដែលបញ្ចេញពីប្រភពបំពុលផ្សេងៗ(ដូចជា៖ លំនៅដ្ឋានប្រជាពលរដ្ឋ សណ្ឋាគារ រោងចក្រសហគ្រាស) **ទៅតាមប្រភេទ**មុននឹងបញ្ជូនទៅកន្លែងស្តុករួម។ |
| ២ | សំណល់ធម្មតា | សំដៅដល់សំណល់រឹងដែលបញ្ចេញដោយប្រភពបំពុលផ្សេងៗ (ដូចជា៖ លំនៅដ្ឋានប្រជាពលរដ្ឋ សណ្ឋាគារ...) ហើយសំណល់ទាំងនោះ**មានកម្រិតបំពុលស្រាល** ។ |
| ៣ | សំណល់មានជាតិពុល | សំដៅលើសំណល់ទាំងឡាយណាដែល**មានផលប៉ះពាល់អវិជ្ជមានខ្លាំងចំពោះភាវៈដែលមានជីវិត** (មជ្ឈដ្ឋានធម្មជាតិ ប្រជាជន...)។ សំណល់ទាំងនោះរួមមាន អាគុយ ស៊ីរ៉ាំង ថ្មពិល ដបថ្នាំសំលាប់សត្វចង្រៃ...។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យD៥.១តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"បរិមាណ"** សំណល់មានជាតិពុលដែលបានឆ្លងកាត់ការបែងចែកសំណល់។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៤ គឺ៖

- ព័ត៌មានអំពីកន្លែងដែលអាចឲ្យប្រជាពលរដ្ឋធ្វើការបែងចែកសំណល់
- បង្ហាញអំពីវិធានការលើកទឹកចិត្ត និង/ឬជំរុញឲ្យមានការបែកចែកសំណល់
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការអនុវត្តវិធានការដែលបានដាក់ចេញ
- បង្ហាញអំពីលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យD៥.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៤ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវនិច្ឆ័យD៥.១ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |

| | | | |
|---|---|---|---|
| ១ | ព័ត៌មានអំពីកន្លែងបែកចែកសំណល់ដែលមាន | ស្រង់ស្ថិតិអំពីកន្លែងបែងចែកសំណល់ទាំងឡាយ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[67]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបចំជាផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងកន្លែងស្តុកទាំងនោះ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានវិធានការលើកទឹកចិត្តឬជំរុញការអនុវត្ត | រៀបរាងជាវិធាន យន្តការ ឬបទដ្ឋានផ្សេងៗ សម្រាប់អនុវត្តការលើកទឹកចិត្តឬជំរុញឲ្យមានការបែងចែកសំណល់ | -សេចក្តីសម្រេច ឬដីកា ឬនីតិវិធីផ្សេងៗដែលមានតម្លៃស្មើស្តីពីការកំណត់យន្តការលើកទឹកចិត្តឬជំរុញឲ្យមានការបែងចែកសំណល់ |
| ៣ | វត្តមានអង្គភាពមានសមត្ថកិច្ចដែលទទួលខុសត្រូវលើការអនុវត្ត | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៤ | លទ្ធផលជាក់ស្តែង | រៀបចំជាតារាងរាយនាមអំពីប្រភេទសំណល់ពុលដែលប្រមូលបាន | -តារាងសម្រង់ស្ថិតិ[68]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

[67] តារាងទី ២១

[68] តារាងទី ២២

# ផ្នែកទី៤
# សូចនាករគោលនៃការបញ្ជ្រាបការយល់ដឹង

ការបញ្ជ្រាបការយល់ដឹងអាចចាត់ទុកជាទម្រង់មួយនៃការផ្ទេរ/ផ្តល់ចំណេះដឹង ឬការយល់ដឹងទូទៅផ្សេងៗ (ជាទូទៅវាកើតចេញពីសកម្មភាពជាទំលាប់ដដែលៗ)។ ដូចនេះគោលបំណងនៃការបញ្ជ្រាបការយល់ដឹងនេះ គឺចង់ផ្សព្វផ្សាយព័ត៌មានអំពីកំហុសផ្សេងៗដែលកើតចេញពីការអនុវត្តខុសរាល់ថ្ងៃ និងចង់ផ្សព្វផ្សាយ/ណែនាំអំពី ឥរិយាបទ និងការអនុវត្តល្អៗមួយចំនួនដែលអាចចូលរួមធ្វើឲ្យជីវិតនិងការរស់នៅកាន់តែប្រសើរឡើង។

ចលនាប្រលងប្រណាំងទីក្រុងស្អាតផ្តោតជាពិសេសដល់ការក្រើនរំលឹកឲ្យយកចិត្តទុកដាក់លើបរិស្ថាន និងភាពស្អាត។ ចំពោះគោលដៅដែលត្រូវធ្វើការបញ្ជ្រាបដល់នោះរួមមាន៖ ប្រជាជនដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុងបេក្ខភាព ប្រតិបត្តិករទេសចរណ៍ និងភ្ញៀវទេសចរ។

ការបញ្ជ្រាបការយល់ដឹង គឺជាយន្តការមួយយ៉ាងសំខាន់សម្រាប់ជម្រុញការអនុវត្តចលនាប្រឡងប្រណាំងទីក្រុង-ស្អាត។ យន្តការនេះត្រូវបានចាត់ទុកថាជាមូលដ្ឋានគ្រឹះ និងជាសកម្មភាពដែលទីក្រុងបេក្ខភាពត្រូវយក ចិត្តទុកដាក់ដើម្បីក្រើនរំលឹកឲ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់យល់ដឹងនិងចាប់ផ្តើមចូលរួមអនុវត្តជាបណ្តើរៗដល់ការថែរក្សាបរិស្ថានស្អាត។ សូចនាករលម្អិតដែលបានលើកឡើងក្នុងសូចនាករគោលទី៤នេះ មានគោលបំណងតម្រង់ទិសអនុវត្តរបស់ទីក្រុងបេក្ខភាពដោយផ្អែកលើ៖ ប្រជាជន និងប្រតិបត្តិករទេសចរណ៍ និងភ្ញៀវទេសចរ ។

ការបញ្ជ្រាបការយល់ដឹងគឺជាសកម្មភាពក្រើនរំលឹកដាស់តឿនដល់ប្រជាពលរដ្ឋនិងភាគីពាក់ព័ន្ធហើយអាចធ្វើឡើងក្រោមរូបភាពផ្សេងៗគ្នា។ ដូច្នេះ តាមរយៈសូចនាករគោលនេះ **គ.ជ.វ.ទ** មិនតម្រូវនូវសកម្មភាពជាពិសេសណាមួយទេ ដោយទុកលទ្ធភាពឲ្យទីក្រុងបេក្ខភាពនានា ជាអ្នកសម្រេចជ្រើសយកវិធីសាស្ត្រដែលសក្តិ-សមនឹងស្ថានភាពរបស់ខ្លួន។ ដោយឡែក ការវាយតម្លៃត្រូវបានផ្តោតជាសំខាន់លើប្រសិទ្ធភាព និងភាពញឹកញាប់របស់សកម្មភាពដែលបានដាក់ចេញ។ ការបញ្ជ្រាបការយល់ដឹងអាចនឹងត្រូវបានអនុវត្តក្រោមកិច្ចសហការជាមួយនឹងភាគីពាក់ព័ន្ធផ្សេងៗ។

## I១. សូចនាករលំអិត

## នៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថាននិងភាពស្អាតដល់ប្រជាជនមូលដ្ឋាន

| លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| ៤១.១.សកម្មភាពក្នុង**ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន**ដល់**ប្រជាជនមូលដ្ឋាន** (បើកការប្រជុំបង្កើតក្រុមគាំពារបរិស្ថាន ។ល។) | មាន-មិនមាន | ១ |
| ៤១.២.តើ**សកម្មភាពបញ្ជ្រាបការយល់ដឹង**ទាំងនេះត្រូវបានធ្វើឡើងញឹកញាប់ដែរឬទេ? | យ៉ាងហោចណាស់ ២ដងក្នុងមួយឆ្នាំ | ១ |
| ៤១.៣.វត្តមាន**មធ្យោបាយផ្តល់ព័ត៌មានអំពីបរិស្ថាន** (បដាព័ត៌មាន ខិតប័ណ្ណផ្សព្វផ្សាយ) | មាន-មិនមាន | ១ |

***(ផ្តល់ពិន្ទុ ៣/៧ នៃពិន្ទុសរុបរបស់សូចនាករគោលនៃការបញ្ជ្រាបការយល់ដឹង)***

## ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

### ១. លក្ខណវិនិច្ឆ័យ ៤១.១

*"សកម្មភាពក្នុង**ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន**ដល់**ប្រជាជនមូលដ្ឋាន** (បើកការប្រជុំបង្កើតក្រុមគាំពារ បរិស្ថាន។ល។)"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**មាន**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| លរ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន | សំដៅដល់ការ**ពន្យល់ណែនាំអំពីបរិស្ថាន**តាមរយៈ**ប្រព័ន្ធឬរបៀបផ្សព្វផ្សាយផ្សេងៗ**ដល់**សាធារណជន** លើបញ្ហានានាដែលផ្តោតជាសំខាន់ពី**វិធីនិងរបៀបងាយៗក្នុងការចូលរួមដល់ការថែរក្សាបរិស្ថានធម្មជាតិ**ជុំវិញដោយការអនុវត្តផ្សេងៗ**ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ**។ |
| ២ | ប្រជាជនមូលដ្ឋាន | សំដៅដល់ជនគ្រប់រូបដែលមាន**អត្រានុកូលដ្ឋាន**រស់នៅក្នុងដែនសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាព។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យ៤១.១តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ប្រសិទ្ធិភាព"** នៃសកម្មភាពនៃការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថាននិងភាពស្អាតដល់ប្រជាពលរដ្ឋមូលដ្ឋាន។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺ៖

- ព័ត៌មានអំពីវិធីសាស្ត្រផ្សេងៗនៃការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថាននិងភាពស្អាត(ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវអនុវត្ត
- បង្ហាញអំពីសកម្មភាពអនុវត្តជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យ៤១.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាព

នូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណៈវិនិច្ឆ័យ១.១ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
| ១ | ព័ត៌មានអំពីវិធីសាស្ត្រផ្សេងៗនៃការបណ្តុះបណ្តាលការយល់ដឹង | ស្រង់ស្ថិតិអំពីវិធីសាស្ត្រផ្សេងៗនៃការបណ្តុះបណ្តាលការយល់ដឹងអំពីបរិស្ថាននិងភាពស្អាតដែលបានអនុវត្តកន្លងមកឬដែលបានដាក់ចេញ ចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[69]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអង្គភាព ដែលទទួលខុសត្រូវលើការអនុវត្ត | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៣ | សកម្មភាពអនុវត្តជាក់ស្តែង | រៀបចំជារបាយការណ៍ស្តីពីសកម្មភាពបណ្តុះបណ្តាលការយល់ដឹងដែលបានអនុវត្តកន្លងមក | -រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីទិដ្ឋភាពជាក់ស្តែងសម្រាប់សកម្មភាពនីមួយៗ |

## ២. លក្ខណៈវិនិច្ឆ័យ ៉១.២

*"តើ<u>សកម្មភាពបណ្តុះបណ្តាលការយល់ដឹង</u>ទាំងនេះត្រូវបានធ្វើឡើងញឹកញាប់ដែរឬទេ?"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថាធ្វើបាន<u>**យ៉ាងហោចណាស់២ដងក្នុងមួយឆ្នាំ**</u>"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | សកម្មភាពបណ្តុះបណ្តាលការយល់ដឹង*(ការបណ្តុះបណ្តាលការយល់ដឹងពីបរិស្ថាន)* | សំដៅដល់ការ<u>ពន្យល់ណែនាំអំពីបរិស្ថាន</u>តាមរយៈ<u>ប្រព័ន្ធឬរបៀបផ្សព្វផ្សាយផ្សេងៗ</u>ដល់<u>សាធារណជន</u>លើបញ្ហានានា<br>ដែលផ្តោតជាសំខាន់ពី<u>វិធីនិងរបៀបងាយៗក្នុងការចូលរួមដល់ការថែរក្សាបរិស្ថានធម្មជាតិ</u>ជុំវិញ ដោយការអនុវត្តផ្សេងៗ<u>ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ</u>។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យ១.២តម្រូវឲ្យទីក្រុងបេតិកភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**ភាពញឹកញាប់**" (បរិមាណ) នៃការបណ្តុះបណ្តាលការយល់ដឹងអំពីបរិស្ថាននិងភាពស្អាតដល់ប្រជាពលរដ្ឋមូលដ្ឋាន។ ដូច្នេះ ទីក្រុងបេតិកភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៣ គឺៈ

- ព័ត៌មានអំពីវិធីសាស្ត្រផ្សេងៗនៃការបណ្តុះបណ្តាលការយល់ដឹងអំពីបរិស្ថាននិងភាពស្អាត

---

[69] តារាងទី ៤៥

- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវអនុវត្ត
- បង្ហាញអំពីលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យ១.២ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ១.២ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
| ១ | ព័ត៌មានអំពីវិធីសាស្រ្តផ្សេងៗនៃការបញ្ជ្រាបការយល់ដឹង | ស្រង់ស្ថិតិអំពីវិធីសាស្រ្តផ្សេងៗនៃការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថាននិងភាពស្អាតដែលបានអនុវត្តកន្លងមកឬដែលបានដាក់ចេញ ចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[70]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអង្គភាពដែលទទួលខុសត្រូវលើការអនុវត្ត | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៣ | លទ្ធផលជាក់ស្តែង | រៀបចំជាតារាងសកម្មភាពចុះអនុវត្តសកម្មភាពបញ្ជ្រាបការយល់ដឹងរបស់អង្គភាពដែលទទួលខុសត្រូវអនុវត្តទាំងនោះ ដោយបញ្ជាក់ថាមានសកម្មភាពយ៉ាងហោចណាស់២ដងក្នុង១ឆ្នាំ | -តារាងសម្រង់ស្ថិតិ[71]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

### ៣. លក្ខណវិនិច្ឆ័យ ១.៣

*"វត្តមាន**<u>មធ្យោបាយផ្តល់ព័ត៌មានអំពីបរិស្ថាន</u>** (បដាព័ត៌មាន ខិតប័ណ្ណផ្សព្វផ្សាយ)"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**<u>មាន</u>**"*

## ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | មធ្យោបាយផ្តល់ព័ត៌មានអំពីបរិស្ថាន | សំដៅដល់**<u>របៀបឬវិធីផ្សេងៗ</u>**សម្រាប់ធ្វើការ**<u>ទំនាក់ទំនង ផ្តល់ព័ត៌មាននិងដំណឹងផ្សេងៗ (ដោយមិនចាំបាច់មានអ្នកធ្វើការបរិយាយ</u>**ពោលគឺតាមរយៈបដាពត៌មាន ឬខិតប័ណ្ណផ្សព្វផ្សាយ) ដែលទាក់ទងទៅនឹងបញ្ហានានាពាក់ព័ន្ធនឹង**<u>ធម្មជាតិនិងបរិស្ថានជុំវិញក្នុងតំបន់នោះ</u>** ដល់**<u>សាធារណជន</u>**ឲ្យបានជ្រួតជ្រាប។ |

## ខ. លក្ខខណ្ឌតម្រូវ

[70] តារាងទី ៤៥

[71] តារាងទី ២៨

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យ៖១.៣តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**ចំនួន**" មធ្យោបាយផ្តល់ព័ត៌មានអំពីបរិស្ថានដល់ប្រជាពលរដ្ឋមូលដ្ឋាន។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺ៖

- ព័ត៌មានអំពីមធ្យោបាយផ្សេងៗនៃការបញ្ជ្រាបការយល់ដឹង
- បង្ហាញអំពីវត្ថុមានអ្នកទទួលខុសត្រូវអនុវត្ត
- បង្ហាញអំពីការអនុវត្តជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យ៖១.៣ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០៣** ខាងលើ។

| **តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ៖១.៣** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីមធ្យោបាយផ្សេងៗនៃការបញ្ជ្រាបការយល់ដឹង | ស្រង់ស្ថិតិអំពីមធ្យោបាយផ្សេងៗនៃការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថាន ចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[72]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្ថុមានអង្គភាពដែលទទួលខុសត្រូវលើការគ្រប់គ្រងថែរក្សា | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៣ | ការអនុវត្តជាក់ស្តែង | កំណត់ប្រភេទ/ចំនួន/ទីតាំងនៃមធ្យោបាយផ្សព្វផ្សាយដែលមាន | -តារាងព័ត៌មាន[73]ដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុងបេក្ខភាព |

# ៖២. សូចនាករលំអិតនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថាននិងភាពស្អាតដល់ប្រតិបត្តិករទេសចរណ៍

| **លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|
| ៖២.១.វត្ថុមាន<u>ឯកសារផ្សេងៗនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន</u>ដែលឯកសារទាំងនោះធ្វើឡើងសំដៅដល់<u>ប្រតិបត្តិករទេសចរណ៍</u>ទាំងឡាយ (កូនសៀវភៅ ការណែនាំ) | មាន-មិនមាន | ១ |
| ៖២.២.ភាពញឹកញាប់នៃ<u>សកម្មភាពបញ្ជ្រាបការយល់ដឹងពីបរិស្ថាននិងភាពស្អាត</u>ដល់<u>ប្រតិបត្តិករទេសចរណ៍</u> | យ៉ាងហោចណាស់ ១ដងក្នុងមួយឆ្នាំ | ១ |

[72] តារាងទី ៤៥

[73] តារាងទី ៤៥

*( ផ្ដល់ពិន្ទុ ២/៧ នៃពិន្ទុសរុបរបស់សូចនាករគោលនៃការបញ្ជ្រាបការយល់ដឹង )*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណវិនិច្ឆ័យ ៤២.១

*"វត្តមាន__ឯកសារផ្សេងៗនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន__ ដែលឯកសារទាំងនោះធ្វើឡើងសំដៅដល់__ប្រតិបត្តិករទេសចរណ៍__ទាំងឡាយ (កូនសៀវភៅ ការណែនាំ)"*
*"នឹងផ្ដល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា__មាន__"*

### ក. សេចក្ដីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្ដីពន្យល់ |
|---|---|---|
| ១ | ឯកសារនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន | សំដៅដល់កម្រងឯកសារផ្សេងៗសម្រាប់ធ្វើការ__ពន្យល់ណែនាំអំពីបរិស្ថាន__ ដល់__សាធារណជន__ លើបញ្ហានានាដែលផ្ដោតជាសំខាន់ពី__វិធីនិងរបៀបងាយៗក្នុងការចូលរួមដល់ការថែរក្សាបរិស្ថានធម្មជាតិ__ជុំវិញដោយការអនុវត្តផ្សេងៗ__ក្នុងសកម្មភាពប្រចាំថ្ងៃ__។<br>ឯកសារទាំងនោះអាចជា៖ ឯកសារសរសេរ ឬរូបភាព ឬខ្សែវីដេអូ។ល។ |
| ២ | ប្រតិបត្តិករទេសចរណ៍ | សំដៅដល់ដល់__បុគ្គល__ដែលប្រតិបត្តិ ប្រកបអាជីព ឬ__ធ្វើអាជីវកម្មលើសេវាកម្មទេសចរណ៍__។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យ៤២.១តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ឯកសារ"** សម្រាប់ធ្វើការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថាននិងភាពស្អាតដល់ប្រតិបត្តិករទេសចរណ៍។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ៤២.១ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ឯកសារសម្រាប់ធ្វើការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថាននិងភាពស្អាត | រៀបរាងជាឯកសារផ្សេងៗសម្រាប់ធ្វើការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថាននិងភាពស្អាត ដែលផ្ដោតជាសំខាន់សម្រាប់ណែនាំដល់ប្រតិបត្តិករទេសចរណ៍ | -ឯកសារចុងក្រោយដោយមានការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច |

## ២. លក្ខណវិនិច្ឆ័យ ៤២.២

*"ភាពញឹកញាប់នៃ__សកម្មភាពបញ្ជ្រាបការយល់ដឹងពីបរិស្ថាននិងភាពស្អាត__ដល់__ប្រតិបត្តិករទេសចរណ៍__"*
*"នឹងផ្ដល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថាធ្វើបាន__យ៉ាងហោចណាស់១ដងក្នុងមួយឆ្នាំ__"*

### ក. សេចក្ដីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្ដីពន្យល់ |
|---|---|---|

| | | |
|---|---|---|
| ១ | សកម្មភាពបញ្ជ្រាបការយល់ដឹងពីបរិស្ថាននិងភាពស្អាត*(ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន)* | សំដៅដល់ការ**ពន្យល់ណែនាំអំពីបរិស្ថាន**តាមរយៈ**ប្រព័ន្ធឬរបៀបផ្សព្វផ្សាយផ្សេងៗ**ដល់**សាធារណជន** ជុំវិញបញ្ហានានា(ឲ្យយល់ពី**វិធីនិងរបៀបងាយៗក្នុងការចូលរួមដល់ការថែរក្សាបរិស្ថាន**ជុំវិញដោយការអនុវត្តផ្សេងៗ**ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ**)។ |
| ២ | ប្រតិបត្តិករទេសចរណ៍ | សំដៅដល់ដល់**បុគ្គល**ដែលប្រតិបត្តិ ប្រកបអាជីព ឬ**ធ្វើអាជីវកម្មលើសេវាកម្មទេសចរណ៍**។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យ|២.២តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**ភាពញឹកញាប់**" (បរិមាណ) នៃការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថាននិងភាពស្អាតដល់ប្រតិបត្តិករទេសចរណ៍។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺៈ

- ព័ត៌មានអំពីវិធីសាស្ត្រផ្សេងៗនៃការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថាននិងភាពស្អាត(ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវអនុវត្ត
- បង្ហាញអំពីលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យ|២.២ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០៣** ខាងលើ។

| **តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ|១.២** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីវិធីសាស្ត្រផ្សេងៗនៃការបញ្ជ្រាបការយល់ដឹង | ស្រង់ស្ថិតិអំពីវិធីសាស្ត្រផ្សេងៗនៃការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថាននិងភាពស្អាតដែលបានអនុវត្តកន្លងមកឬដែលបានដាក់ចេញ ចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[74]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអង្គភាពដែលទទួលខុសត្រូវលើការអនុវត្ត | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៣ | លទ្ធផលជាក់ស្តែង | រៀបចំជាតារាងសកម្មភាពចុះអនុវត្តសកម្មភាពបញ្ជ្រាបការយល់ដឹងរបស់អង្គភាពដែលទទួលខុសត្រូវអនុវត្តទាំងនោះ ដោយបញ្ជាក់ថាមានសកម្មភាពយ៉ាងហោចណាស់១ដងក្នុង១ឆ្នាំ | -តារាងសម្រង់ស្ថិតិ[75]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

# |៣. សូចនាករលំអិតនៃការបញ្ជ្រាបការយល់ដឹងពីបរិស្ថានដល់ភ្ញៀវទេសចរ

[74] តារាងទី ៤៥

[75] តារាងទី ២៨

| លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| ៣.១.វត្តមាន**<u>មធ្យោបាយផ្ដល់ព័ត៌មានអំពីបរិស្ថាន</u>** (បដាព័ត៌មាន និង ខិតប័ណ្ណផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹង។ល។) | មាន-មិនមាន | ១ |
| ៣.២.**<u>សកម្មភាពបញ្ជ្រាបការយល់ដឹងពីបរិស្ថាន</u>**ធ្វើឡើងដោយ**<u>ប្រតិបត្តិករទេសចរណ៍</u>**នៅតាមគោលដៅទេសចរណ៍ | មាន-មិនមាន | ១ |

*(ផ្ដល់ពិន្ទុ ២/៧ នៃពិន្ទុសរុបរបស់សូចនាករគោលនៃការបញ្ជ្រាបការយល់ដឹង)*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណៈវិនិច្ឆ័យ ៣.១

*"វត្តមាន**<u>មធ្យោបាយផ្ដល់ព័ត៌មានអំពីបរិស្ថាន</u>** (បដាព័ត៌មាន និងខិតប័ណ្ណផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹង។ល។)"*
*"នឹងផ្ដល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**<u>មាន</u>**"*

### ក. សេចក្ដីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្ដីពន្យល់ |
|---|---|---|
| ១ | មធ្យោបាយផ្ដល់ព័ត៌មានអំពីបរិស្ថាន | សំដៅដល់**<u>របៀបឬវិធីផ្សេងៗ</u>**សម្រាប់ធ្វើការ**<u>ទំនាក់ទំនង ផ្ដល់ព័ត៌មាននិងដំណឹងផ្សេងៗ</u>** **<u>(ដោយមិនចាំបាច់មានអ្នកធ្វើការបរិយាយ</u>**ពោលគឺតាមរយៈបដាពត៌មាន និងខិតប័ណ្ណផ្សព្វផ្សាយ) ដែលទាក់ទងទៅនឹងបញ្ហានានាពាក់ព័ន្ធនឹង**<u>ធម្មជាតិនិងបរិស្ថានជុំវិញក្នុងតំបន់នោះ</u>** ដល់**<u>សាធារណជន</u>**ឲ្យបានជ្រួតជ្រាប។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យ៣.១តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) នៃមធ្យោបាយផ្ដល់ព័ត៌មានអំពីបរិស្ថានដល់ភ្ញៀវទេសចរ។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៣ គឺៈ

- ព័ត៌មានអំពីមធ្យោបាយផ្សេងៗនៃការបញ្ជ្រាបការយល់ដឹង
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវអនុវត្ត
- បង្ហាញអំពីការអនុវត្តជាក់ស្ដែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យ៣.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាព នូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ៣.១ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |

| | | | |
|---|---|---|---|
| ១ | ព័ត៌មានអំពីមធ្យោបាយផ្សេងៗនៃការបញ្ជ្រាបការយល់ដឹង | ស្រង់ស្ថិតិអំពីមធ្យោបាយផ្សេងៗនៃការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថានដែលមាន ចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[76]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអង្គភាពដែលទទួលខុសត្រូវលើការគ្រប់គ្រងថែរក្សា | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៣ | ការអនុវត្តជាក់ស្តែង | កំណត់ប្រភេទ/ចំនួន/ទីតាំងនៃមធ្យោបាយផ្សព្វផ្សាយដែលមាន | - តារាងព័ត៌មាន[77]ដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុង/ខណ្ឌបេតិកភាព |

## ២. លក្ខណវិនិច្ឆ័យ ៣.២

*"__សកម្មភាពបញ្ជ្រាបការយល់ដឹងពីបរិស្ថាន__ធ្វើឡើងដោយ__ប្រតិបត្តិករទេសចរណ៍__នៅតាមគោលដៅទេសចរណ៍"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា__មាន__"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | សកម្មភាពបញ្ជ្រាបការយល់ដឹងពីបរិស្ថាន *(ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន)* | សំដៅដល់ការ__ពន្យល់ណែនាំអំពីបរិស្ថាន__តាមរយៈ__ប្រព័ន្ធឬរបៀបផ្សព្វផ្សាយផ្សេងៗ__ដល់__សាធារណជន__ ជុំវិញបញ្ហានានា(ឲ្យយល់ពី__វិធីនិងរបៀបងាយៗក្នុងការចូលរួមដល់ការថែរក្សាបរិស្ថាន__ជុំវិញដោយការអនុវត្តផ្សេងៗ__ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ__)។ |
| ២ | ប្រតិបត្តិករទេសចរណ៍ | សំដៅដល់__បុគ្គល__ដែលប្រតិបត្តិ ប្រកបអាជីព ឬ__ធ្វើអាជីវកម្មលើសេវាកម្មទេសចរណ៍__។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យ៣.២តម្រូវឲ្យទីក្រុងបេតិកភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) ប្រតិបត្តិករទេសចរណ៍ដែលបានចូលរួមក្នុងសកម្មភាពធ្វើការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថានដល់ភ្ញៀវទេសចរ។ ដូច្នេះ ទីក្រុងបេតិកភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០២** គឺ៖

- បង្ហាញអំពីការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ចដល់ប្រតិបត្តិករទេសចរណ៍ឲ្យធ្វើការបញ្ជ្រាបការយល់ដឹងដល់ភ្ញៀវទេសចរអំពីបរិស្ថាន
- បង្ហាញអំពីលទ្ធផលជាក់ស្តែង។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យ៣.២ ក៏ដូចជាការណែនាំដល់ទីក្រុងបេតិកភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០២** ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ៣.២ |
|---|

[76] តារាងទី ៤៥

[77] តារាងទី ៤៥

| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
|---|---|---|---|
| ១ | ការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច | រៀបរាងជាវិធាន យន្តការ ឬបទដ្ឋានផ្សេងៗ សម្រាប់អនុវត្តការលើកទឹកចិត្តឬជំរុញឲ្យប្រតិបត្តិករទេសចរណ៍ទាំងឡាយធ្វើការបញ្ជ្រាបការយល់ដឹងពីបរិស្ថានដល់ភ្ញៀវទេសចរ | -សេចក្តីសម្រេច ឬដីកា ឬនីតិវិធីផ្សេងៗដែលមានតម្លៃស្មើស្តីពីការកំណត់យន្តការលើកទឹកចិត្តឬជំរុញឲ្យប្រតិបត្តិករទេសចរណ៍ទាំងឡាយធ្វើការបញ្ជ្រាបការយល់ដឹងពីបរិស្ថានដល់ភ្ញៀវទេសចរ |
| ២ | លទ្ធផលជាក់ស្តែង | រៀបចំជាតារាងស្ថិតិអំពីប្រតិបត្តិករទេសចរណ៍ដែលបានចូលរួម | -តារាងសម្រង់ស្ថិតិ[78]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | របាយការណ៍រូបភាពអំពីសកម្មភាពដែលបានអនុវត្តជាក់ស្តែង | -រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីទិដ្ឋភាពជាក់ស្តែងសម្រាប់សកម្មភាពនីមួយៗ |

[78] តារាងទី ២៨

# ផ្នែកទី៥
# សូចនាករគោលនៃតំបន់បៃតង

តំបន់បៃតងក្នុងតំបន់ទីក្រុងជាទីតាំងទាំងឡាយណាដែលមានរៀបចំដាំលម្អដោយផ្កា ដើមឈើ ឬស្មៅ...។ តំបន់បៃតងត្រូវស្ថិតនៅក្នុងក្រុង និងអាចជាតំបន់ជុំវិញ ហើយត្រូវបើកជាសាធារណៈ និងអាចចូលទៅបានដោយថ្មើរជើង (សួនច្បារសាធារណៈ ឧទ្យានកំសាន្ត រមណីយដ្ឋានទេសចរណ៍ តាមបែបធម្មជាតិ...)។

ជាទូទៅ តំបន់បៃតងជាទីកន្លែងសម្រាប់ប្រជាជនទូទៅអាចជួបជុំសម្រាកលំហែកំសាន្តដែលជាការចូលរួមចំណែកយ៉ាងសំខាន់ដល់ការលើកកម្ពស់សុខមាលភាពក្នុងការរស់នៅរបស់ប្រជាជនក្នុងតំបន់សមត្ថកិច្ចរបស់ក្រុង/ខណ្ឌបេក្ខភាព។ ដោយឡែករង្វង់មូលនានាមិនត្រូវបានចាត់បញ្ចូលថាជាតំបន់បៃតងនោះទេ ដោយហេតុថាជាទូទៅរង្វង់មូលគ្រាន់តែជាចំណែកមួយនៃផ្លូវសាធារណៈ ហើយមិនមែនសម្រាប់ដើរលំហែកំសាន្តនោះទេ។ មួយវិញទៀត វាលស្រែ (ទោះបីស្ថិតនៅក្នុងដែនដីក្រុង /ខណ្ឌក៏ដោយ) ក៏មិនត្រូវបានចាត់បញ្ចូលជាតំបន់បៃតងផងដែរ ដោយហេតុថា វាលស្រែមិនមែនជាទីតាំងដែលត្រូវបានគិតគូររៀបចំដាំតុបតែងលម្អជាពិសេសសម្រាប់សាធារណៈជននោះឡើយ។ តំបន់បៃតងក៏នៅតែជាប្រធានបទសំខាន់ទោះបីជាតំបន់បៃតងមិនត្រូវបានរំលេចច្រើននៅក្នុងស្តង់ដា ទីក្រុងស្អាតក៏ដោយ។

តំបន់បៃតងជាធាតុផ្សំមួយដែលចូលរួមធ្វើឲ្យការរស់នៅរបស់ប្រជាជនមានភាពកាន់តែប្រសើរឡើងតាមរយៈការផ្តល់នូវទីកន្លែងធម្មជាតិដ៏ខៀវស្រងាត់នៅក្នុងតំបន់ទីក្រុង។ ជាទូទៅ តំបន់បៃតងត្រូវបានគិតគូររៀបចំឲ្យមានមួយចំនួនរួចទៅហើយនៅតាមក្រុង/ខណ្ឌបេក្ខភាពនានា។ បន្ថែមលើនេះ ចលនាប្រឡងប្រណាំងទីក្រុងស្អាតមានបំណងចូលរួមជម្រុញបន្ថែមលើចំនុចនេះដោយផ្តោតជាសំខាន់លើការបង្កើនទំហំរបស់តំបន់បៃតងឲ្យសមស្របនឹងបរិបទនាពេលបច្ចុប្បន្ន និងការយកចិត្តទុកដាក់ថែរក្សាតំបន់ទាំងនោះឲ្យសក្តិសមជាទីសម្រាកលំហែដែលប្រកបដោយផាសុខភាព។

ទន្ទឹមនឹងនោះ ការរៀបចំឲ្យមានតំបន់បៃតងនេះជាប្រភពខ្ជះខ្ជាយធនធានផងដែរ ប្រសិនបើមិនមានការគ្រប់គ្រង ដោយហ្មត់ចត់។

សូចនាករគោលទី៥នោះ ចង់ឲ្យក្រុង/ខណ្ឌបេក្ខភាពរៀបចំតំបន់បៃតងរបស់ខ្លួនដោយគិតគូរលើពីរចំនុចសំខាន់គឺៈ

- **ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ការបំពាក់សម្ភារៈបរិក្ខា និងការតុបតែងលម្អផ្សេងៗ**
  ជាទូទៅ កង្វះបរិក្ខាផ្សេងៗនៅតាមសួនសាធារណៈដូចជា ៖ កៅអីវែងសម្រាប់អង្គុយជាដើម និងកង្វះពន្លឺភ្លើងបំភ្លឺនៅពេលយប់ជាហេតុធ្វើឲ្យកន្លែងនោះមិនបានសមប្រកបជាទីកន្លែងសម្រាកលំហែ តែបែរជាអាចនឹងក្លាយជាទីតាំងទំនេរសម្រាប់ប្រជាជនដែលខ្វះលំនៅដ្ឋានចាប់ ទីយកធ្វើជាលំនៅតាមបែបអនាធិបតេយ្យទៅវិញ។ ទាក់ទងនឹងសោភ័ណភាពជារួមនៅតាម តំបន់បៃតងឲ្យមានការបំពាក់ធុងសំរាមឲ្យបានគ្រប់គ្រាន់នៅតាមទីតាំងទាំងនោះ ដែលនេះជាកត្តាចាំបាច់ជៀសវាងការចោលសំរាមពាសវាលពាសកាលជាយថាហេតុ។
- ការចំណាយលើការដាំដុះ និងការថែទាំតំបន់បៃតងក៏ត្រូវតែជាសកម្មភាពដែលគិតគូរដល់បរិស្ថានផងដែរ (ចំណាយថវិការតិច និងមិនប្រើប្រាស់ថាមពលហួសហេតុ)។ មានន័យថា ក្រុង/ខណ្ឌបេក្ខភាពគួរគិតគូរជ្រើសយកតែប្រភេទរុក្ខជាតិណាដែលមានតម្លៃថោក ស្រួលដាំ និងស្រួលថែទាំ។ គួរអនុវត្ត

ការថែទាំតាមវិធីសាស្ត្រសាមញ្ញ និងគិតគូរដល់បរិស្ថានដូចជា៖ ជៀសវាងប្រើជីគីមីដោយងាកមកប្រើជីកំប៉ុស ឬជីលាមកសត្វ...។

ជារួម នៅក្នុងសូចនាករគោលទី៥នេះ ចលនាប្រឡងប្រណាំងទីក្រុងស្អាតរំពឹងចង់ឲ្យក្រុង/ខណ្ឌបេក្ខភាពអនុវត្តការគ្រប់គ្រងតំបន់បៃតងរបស់ខ្លួនតាមវិធីសាស្ត្រសាមញ្ញងាយស្រួលអនុវត្ត និងទទួលបានលទ្ធផលសមស្របអាចទទួលយកបាន។

## V១.សូចនាករលំអិតនៃការបង្កើត និងបែងចែកតំបន់បៃតង

| លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| □១.១.ភាគរយតំបន់បៃតងធៀបនឹងផ្ទៃក្រឡាទីក្រុងទាំងមូល | ធំជាង៥% | ១ |

*(ផ្តល់ពិន្ទុ ១/៤ នៃពិន្ទុសរុបរបស់សូចនាករគោលនៃតំបន់បៃតង)*

## ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

### ១. លក្ខណៈវិនិច្ឆ័យ V១.១

*"ភាគរយ__តំបន់បៃតង__ធៀបនឹង__ផ្ទៃក្រឡាទីក្រុងទាំងមូល__"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា__ផ្ទៃតំបន់បៃតងមានទំហំលើសពី៥%ធៀបនឹងផ្ទៃក្រឡាទីក្រុងទាំងមូល__"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | តំបន់បៃតង | សំដៅដល់ទីតាំងទាំងឡាយណាដែលត្រូវបាន__រៀបចំកែច្នៃ ឬថែរក្សាទុក__ជាកន្លែងសម្រាប់ឲ្យ__សាធារណជន__ទាំងឡាយ__សម្រាកលំហែកំសាន្តជាមួយនឹងធម្មជាតិ និងផ្លាស់ប្តូរយកខ្យល់អាកាសបរិសុទ្ធ__។<br>តំបន់បៃតងត្រូវតែជាទីតាំងមួយដែលអាចដើរកំសាន្តបាន ឬមានកន្លែងអង្គុយលំហែ។ល។ |
| ២ | ផ្ទៃក្រឡាទីក្រុងទាំងមូល | សំដៅដល់__ផ្ទៃដីក្រុង ឬខណ្ឌបេក្ខភាព__យោងតាមព្រំប្រទល់រដ្ឋបាលថ្មីក្រោមច្បាប់ស្តីពី... |

### ខ. លក្ខខណ្ឌតម្រូវ

ដោយហេតុថា ការរៀបចំតំបន់បៃតងជាការងារដែលត្រូវមានការគិតគូរខ្លាំងពីព្រោះត្រូវផ្សារភ្ជាប់យ៉ាងស្អិតរមួតនឹងផែនការប្រើប្រាស់ដីដែលជាកិច្ចការងារថ្មី ដូច្នេះ ការបំពេញលក្ខខណ្ឌសម្រាប់លក្ខណៈវិនិច្ឆ័យV១.១សម្រាប់រយៈកាលដំបូងនេះត្រូវបានបន្ធូរបន្ថយដោយ **គ.ជ.វ.ទ.** ផ្តល់លទ្ធភាពដល់ទីក្រុងជាបេក្ខភាពដើម្បីអាចបំពេញលក្ខខណ្ឌរបស់លក្ខណៈវិនិច្ឆ័យនេះបាននូវជំរើស ៣ដូចខាងក្រោម៖

**ករណីទី១៖ មានផ្ទៃដីតំបន់បៃតងដែលមានស្រាប់ធំជាង៥%ធៀបនឹងផ្ទៃក្រឡាសរុបរបស់ទីក្រុងបេក្ខភាព**

- ព័ត៌មានអំពីតំបន់បៃតងទាំងអស់ (ទាំងមានស្រាប់ និងគំរោង) ដែលមាន
- បង្ហាញថាមានផ្ទៃដីតំបន់បៃតងដែលមានស្រាប់ធំជាង៥%ធៀបនឹងផ្ទៃក្រឡាសរុបរបស់ទីក្រុងបេក្ខភាព

**ករណីទី២៖ មានផលបូកសរុបរួមទាំងផ្ទៃដីតំបន់បៃតងដែលមានស្រាប់ និងផ្ទៃដីតំបន់បៃតងដែលស្ថិតនៅជាគំរោង**

**នៅឡើយ ធំជាង៥%ធៀបនឹងផ្ទៃក្រឡាសរុបរបស់ទីក្រុងបេក្ខភាព**

- ព័ត៌មានអំពីតំបន់បៃតងទាំងអស់ (ទាំងមានស្រាប់ និងគំរោង) ដែលមាន
- បង្ហាញថាមានផ្ទៃដីតំបន់បៃតងដែលមានស្រាប់បូករួមទាំងផ្ទៃដីតំបន់បៃតងដែលជាគំរោងធំជាង៥%ធៀបនឹងផ្ទៃក្រឡាសរុបរបស់ទីក្រុងបេក្ខភាព
- បង្ហាញពីវត្តមានអ្នកទទួលខុសត្រូវលើការអនុវត្តគំរោង
- សកម្មភាពអនុវត្តជាក់ស្តែង

**ករណីទី៣៖ មានផលបូកសរុបរួមផ្ទៃដីតំបន់បៃតងដែលនៅជាគំរោង ធំជាង៥%ធៀបនឹងផ្ទៃក្រឡាសរុបរបស់ទីក្រុងបេក្ខភាព** (*សម្រាប់តែករណីដែលទីក្រុងបេក្ខភាពណាដែលមិនទាន់មានតំបន់បៃតងដែលមានស្រាប់ទាល់តែសោះ*)

- ព័ត៌មានអំពីគំរោងរៀបចំតំបន់បៃតងទាំងអស់(ដែលមាន)
- បង្ហាញថាមានផ្ទៃដីតំបន់បៃតងដែលជាគំរោង ធំជាង៥%ធៀបនឹងផ្ទៃក្រឡាសរុបរបស់ទីក្រុងបេក្ខភាព
- បង្ហាញពីវត្តមានអ្នកទទួលខុសត្រូវលើការអនុវត្តគំរោង
- សកម្មភាពអនុវត្តជាក់ស្តែង

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យV១.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវសម្រាប់ករណីទាំង ០៣ ខាងលើ។

| **តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ□១.១** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| **<u>ករណីទី១៖</u> មានផ្ទៃដីតំបន់បៃតងដែលមានស្រាប់ធំជាង៥%ធៀបនឹងផ្ទៃក្រឡាសរុបរបស់ទីក្រុងបេក្ខភាព** | | | |
| ១ | ព័ត៌មានអំពីតំបន់បៃតងទាំងអស់ (ទាំងមានស្រាប់ និងគំរោង) | ស្រង់ស្ថិតិអំពីតំបន់បៃតងដែលមាន ចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[79]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបចំផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងតំបន់បៃតងទាំងនោះ។ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | តំបន់បៃតងមានទំហំច្រើនជាង៥ % ធៀបនឹងផ្ទៃដីសរុប | រៀបរាងជាលិខិតរដ្ឋបាលបញ្ជាក់លើទំហំផ្ទៃដីតំបន់បៃតងដែលមានស្រាប់គិតត្រឹមថ្ងៃដាក់ពាក្យ ដោយបញ្ជាក់ថាមានទំហំធំជាង៥%ធៀបនឹងផ្ទៃដីសរុបរបស់ទីក្រុងនោះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតផ្សេងៗដែលមានតម្លៃស្មើស្តីពីការបញ្ជាក់លើទំហំតំបន់បៃតងដែលមានស្រាប់គិតត្រឹមថ្ងៃដាក់ពាក្យ |
| **ករណីទី២៖ មានផលបូកសរុបរួមទាំងផ្ទៃដីតំបន់បៃតងដែលមានស្រាប់ និងផ្ទៃដីតំបន់បៃតងដែលស្ថិតនៅជាគំរោងនៅឡើយធំជាង៥%ធៀបនឹងផ្ទៃក្រឡាសរុបរបស់ទីក្រុងបេក្ខភាព** | | | |
| ១ | ព័ត៌មានអំពីតំបន់បៃតងទាំងអស់ | ស្រង់ស្ថិតិអំពីតំបន់បៃតងដែលមានចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[80]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

[79] តារាងទី ៣០

[80] តារាងទី ៣០

| | | | |
|---|---|---|---|
| | (ទាំងមានស្រាប់ និងគំរោង) | | |
| | ***និង*** | រៀបចំផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងតំបន់បៃតងទាំងនោះ។ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | តំបន់បៃតងមានទំហំច្រើនជាង៥% ធៀបនឹងផ្ទៃដីសរុប | រៀបរាងជាលិខិតរដ្ឋបាលបញ្ជាក់លើទំហំផ្ទៃដីតំបន់បៃតងដែលមានស្រាប់បូករួមនឹងទំហំតំបន់បៃតងដែលនៅជាគំរោងរៀបចំគិតត្រឹមថ្ងៃដាក់ពាក្យដោយបញ្ជាក់ថាមានទំហំធំជាង៥% ធៀបនឹងផ្ទៃដីសរុបរបស់ទីក្រុងនោះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតផ្សេងៗដែលមានតម្លៃស្មើស្តីពីការបញ្ជាក់លើទំហំតំបន់បៃតងដែលមានស្រាប់បូករួមនឹងទំហំតំបន់បៃតងដែលនៅជាគំរោងរៀបចំគិតត្រឹមថ្ងៃដាក់ពាក្យ |
| ៣ | វត្តមានអ្នកទទួលខុសត្រូវលើការអនុវត្តគំរោង | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៤ | សកម្មភាពអនុវត្តជាក់ស្តែង | រៀបរាងជាផែនការសកម្មភាពសម្រាប់ដំណើរការរៀបចំតំបន់បៃតង | -ផែនការសកម្មភាព[81]ដែលមានការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច |
| **ករណីទី៣៖ មានផលបូកសរុបរួមផ្ទៃដីតំបន់បៃតងដែលនៅជាគំរោងធំជាង៥%ធៀបនឹងផ្ទៃក្រឡាសរុបរបស់ទីក្រុងបេតិកភាព (សម្រាប់តែករណីដែលទីក្រុងបេតិកភាពណាដែលមិនទាន់មានតំបន់បៃតងដែលមានស្រាប់ទាល់តែសោះ)** | | | |
| ១ | ព័ត៌មានអំពីគំរោងរៀបចំជាតំបន់បៃតង(ដែលមាន) | ស្រង់ស្ថិតិអំពីគំរោងរៀបចំជាតំបន់បៃតងដែលមានចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[82]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបរាងជាផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងតំបន់បៃតងទាំងនោះ។ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | តំបន់បៃតងមានទំហំច្រើនជាង ៥%ធៀបនឹងផ្ទៃដីសរុប | រៀបរាងជាលិខិតរដ្ឋបាលបញ្ជាក់លើទំហំផ្ទៃដីតំបន់បៃតងដែលនៅជាគំរោងរៀបចំទាំងនោះ (គិតត្រឹមថ្ងៃដាក់ពាក្យ) ដោយបញ្ជាក់ថាមានទំហំធំជាង ៥%ធៀបនឹងផ្ទៃដីសរុបរបស់ទីក្រុងនោះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតផ្សេងៗដែលមានតម្លៃស្មើស្តីពីការបញ្ជាក់លើទំហំតំបន់បៃតងដែលនៅជាគំរោងរៀបចំទាំងនោះ (គិតត្រឹមថ្ងៃដាក់ពាក្យ) ដោយបញ្ជាក់ថាមានទំហំធំជាង៥%ធៀបនឹងផ្ទៃដីសរុបរបស់ទីក្រុងនោះ |
| ៣ | វត្តមានអ្នកទទួលខុសត្រូវលើការអនុវត្តគំរោង | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៤ | សកម្មភាពអនុវត្តជាក់ស្តែង | រៀបចំផែនការសកម្មភាពសម្រាប់ដំណើរការរៀបចំតំបន់បៃតង | -ផែនការសកម្មភាព[83]ដែលមានការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច |

[81] តារាងទី ៤២

[82] តារាងទី ៣០

[83] តារាងទី ៤២

## V២. សូចនាករលំអិតនៃការថែទាំនិងរៀបចំតំបន់បៃតង

| លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| V២.១.**លើកកម្ពស់សោភ័ណភាពតំបន់បៃតងដែលមានស្រាប់** (ការដាក់ភ្លើងបំភ្លឺ កៅអីសាធារណៈ ផ្លូវដើរ) | មាន-មិនមាន | ១ |
| V២.២.ភាពញឹកញាប់ក្នុង**ការថែទាំតំបន់បៃតង** | យ៉ាងហោចណាស់៣ដងក្នុងមួយសប្តាហ៍ | ១ |

*(ផ្តល់ពិន្ទុ ២/៤ នៃពិន្ទុសរុបរបស់សូចនាករគោលនៃតំបន់បៃតង)*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណវិនិច្ឆ័យ V២.១

*"**លើកកម្ពស់សោភ័ណភាពតំបន់បៃតងដែលមានស្រាប់** (ការដាក់ភ្លើងបំភ្លឺ កៅអីសាធារណៈ ផ្លូវដើរ)"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**មាន**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | លើកកម្ពស់សោភណ្ឌភាព | សំដៅដល់**ការបំពាក់សំភារៈ ការតុបតែងរៀបចំនានា**ដើម្បីលម្អផង និងដើម្បីធ្វើឲ្យតំបន់បៃតងនោះកាន់តែមានភាពទាក់ទាញ និងសំបូរបែបទៅដោយគ្រឿងបរិក្ខាផ្សេងៗសម្រាប់ឲ្យសាធារណជនដែលចូលមកកំសាន្ត**មានលក្ខណៈកាន់តែងាយស្រួល** ដូចជា៖ មានកៅអីសម្រាប់អង្គុយលេង មានភ្លើងសម្រាប់បំភ្លឺនៅពេលយប់ងងឹងមានផ្លូវដើរក្រាលថ្មឬការ៉ូឡដែលងាយស្រួលក្នុងការធ្វើដំណើរ មានបង្គន់អនាម័យ ។ល។ |
| ២ | តំបន់បៃតងដែលមានស្រាប់ | សំដៅដល់តំបន់បៃតងទាំងឡាយណាដែលត្រូវបាន**រៀបចំសព្វគ្រប់** ឬដែលបានដាក់ឲ្យសាធារណជន**ប្រើប្រាស់អាចចូលលេងកំសាន្តបាន**។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យV២.១តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"កម្រិត"** (បរិមាណ) នៃការរៀបចំបំពាក់សំភារៈបរិក្ខាផ្សេងៗនៅតាមតំបន់បៃតងទាំងឡាយដែលកំពុងដំណើរការ (សាធារណជនអាចចូលលេងកំសាន្តបានដោយសេរី) ដើម្បីលើកកម្ពស់សោភ័ណទីកន្លែងទាំងនោះ។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៣ គឺ៖

- ព័ត៌មានអំពីតំបន់បៃតងដែលមានស្រាប់(ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវនៅតាមតំបន់ទាំងនោះ
- ព័ត៌មានអំពីសំភារៈបរិក្ខាផ្សេងៗដែលមាននៅតាមតំបន់បៃតងទាំងនោះ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យV២.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណៈវិនិច្ឆ័យ V២.១ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
| ១ | ព័ត៌មានអំពីតំបន់បៃតង(ដែលមាន) | ស្រង់ស្ថិតិអំពីតំបន់បៃតង(ដែលមាន) ចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[84]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបរាងជាផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងតំបន់បៃតងទាំងនោះ។ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវគ្រប់គ្រងនិងថែរក្សា | - ក្រុមហ៊ុនឯកជន | - កិច្ចសន្យារបស់ក្រុមហ៊ុនឯកជននោះដែលមានកម្មវត្ថុជាការគ្រប់គ្រងថែរក្សាតំបន់បៃតងនោះ |
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកគ្រប់គ្រងនិងថែរក្សានៅតាមតំបន់បៃតងទាំងនោះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៣ | ព័ត៌មានអំពីសំភារៈបរិក្ខាផ្សេងៗដែលមាននៅតាមតំបន់បៃតង(ដែលមាន) | ស្រង់ស្ថិតិអំពីសំភារៈបរិក្ខាផ្សេងៗដែលមាននៅតាមតំបន់បៃតងទាំងនោះ ចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[85]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | របាយការណ៍រូបភាពនៅតាមតំបន់បៃតងនីមួយៗ | -រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីទិដ្ឋភាពជាក់ស្តែងសម្រាប់សកម្មភាពនីមួយៗ |

## ២. លក្ខណៈវិនិច្ឆ័យ V២.២

*"ភាពញឹកញាប់ក្នុង**ការថែទាំតំបន់បៃតង**"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថាធ្វើបាន**យ៉ាងហោចណាស់៣ដងក្នុងមួយសប្តាហ៍**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ការថែទាំតំបន់បៃតង | សំដៅដល់**ការថែរក្សា សម្អាត**តំបន់បៃតង និងសំភារៈបរិក្ខាផ្សេងៗដែលមាននៅក្នុងទីតាំងនោះ។ |
| ២ | ៣ដងក្នុងមួយសប្តាហ៍ | មានន័យជាទូទៅគឺធ្វើយ៉ាងណាឲ្យបាន៣ដងក្នុងមួយសប្តាហ៍។ ក៏ប៉ុន្តែ ការថែទាំចំនួន៣ដងក្នុងមួយសប្តាហ៍ត្រូវតែគិតគូររៀបចំយ៉ាងណាទៅតាមរយៈពេលមួយដែលឆ្លើយតបនឹងវិធានការថែទាំមួយដែលត្រឹមត្រូវ និងមិនមែនឲ្យតែបានបង្រួបៗនោះទេ (ឧទាហរណ៍៖ ៣ដងក្នុងរយៈពេល៣ថ្ងៃជាប់ៗគ្នា ឬ៣ដងតែក្នុងពេលមួយថ្ងៃ...) |

### ខ. លក្ខខណ្ឌតម្រូវ

[84] តារាងទី ៣០

[85] តារាងទី ២៩

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យV២.២តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**ភាពញឹកញាប់**" (បរិមាណ) នៃការថែទាំតំបន់បៃតងដែលមានស្រាប់ក្នុងដែនសមត្ថកិច្ចទីក្រុងនោះ។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺ៖

- ព័ត៌មានអំពីតំបន់បៃតងដែលមានស្រាប់(ដែលមាន)
- បង្ហាញអំពីវត្ថុមានអ្នកទទួលខុសត្រូវនៅតាមតំបន់ទាំងនោះ
- បង្ហាញអំពីសកម្មភាពអនុវត្តជាក់ស្តែងលើការថែទាំឲ្យបានយ៉ាងហោចណាស់៣ដងក្នុងមួយសប្តាហ៍។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យV២.២ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០៣** ខាងលើ។

| **តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យV២.២** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីតំបន់បៃតង(ដែលមាន) | ស្រង់ស្ថិតិអំពីតំបន់បៃតងដែលមាន ចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[86]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបរាងជាផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងតំបន់បៃតងទាំងនោះ។ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្ថុមានអ្នកទទួលខុសត្រូវគ្រប់គ្រងនិងថែរក្សា | - ក្រុមហ៊ុនឯកជន | - កិច្ចសន្យារបស់ក្រុមហ៊ុនឯកជននោះដែលមានកម្មវត្ថុជាការគ្រប់គ្រងថែរក្សាតំបន់បៃតងនោះ |
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកគ្រប់គ្រង និងថែរក្សានៅតាមតំបន់បៃតងទាំងនោះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៣ | សកម្មភាពអនុវត្តជាក់ស្តែង | រៀបរាងជាតារាងកាលវិភាគថែទាំសម្រាប់តំបន់បៃតងនីមួយៗ ដោយមានបញ្ជាក់ថាមានការថែទាំយ៉ាងហោចណាស់៣ដងក្នុងមួយសប្តាហ៍ | -តារាងសម្រង់ស្ថិតិ[87]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

## V៣. សូចនាករលំអិតនៃការគ្រប់គ្រងតំបន់បៃតង

| **លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|
| □៣.១.**<u>ការគិតគូរអំពីលក្ខខណ្ឌបរិស្ថានក្នុងការគ្រប់គ្រងតំបន់បៃតង</u>** (ការជ្រើសរើសទីតាំង វិធីស្រោចទឹក ការប្រើប្រាស់ជីកំប៉ុស។ល។) | មាន-មិនមាន | ១ |

*(ផ្តល់ពិន្ទុ ១/៤ នៃពិន្ទុសរុបរបស់សូចនាករគោលនៃតំបន់បៃតង)*

## ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

[86] តារាងទី ៣០

[87] តារាងទី ៣១

## ១. លក្ខណវិនិច្ឆ័យ V៣.១

*"**ការគិតគូរអំពីលក្ខខណ្ឌបរិស្ថានក្នុងការគ្រប់គ្រងតំបន់បៃតង** (ការជ្រើសរើសទីតាំង វិធីស្រោចទឹក ការប្រើប្រាស់ ជីកំប៉ុស ។ល។)"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**មាន**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ការគិតគូរអំពីលក្ខខណ្ឌបរិស្ថានក្នុងការគ្រប់គ្រងតំបន់បៃតង | សំដៅដល់រាល់**វិធីសាស្ត្រផ្សេងៗ**ក្នុងការរៀបចំជាតំបន់បៃតង និងថែរក្សាធម្មជាតិទាំងឡាយដែលមាននៅក្នុងតំបន់នោះ ដោយគោរពតាមគោលការណ៍និរន្តរភាព ដោយសន្សំសំចៃ និង**រក្សាឲ្យបាននូវតុល្យភាពរវាងធម្មជាតិ ការប្រើប្រាស់ និងឱកាសសម្រាប់ទ្រទ្រង់ការថែទាំ**។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យV៣.១តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ប្រសិទ្ធភាព"** នៃការណែនាំដល់អ្នកគ្រប់គ្រងនៅតាមតំបន់បៃតងទាំងឡាយឲ្យមានគិតគូរអំពីលក្ខខណ្ឌបរិស្ថានក្នុងការគ្រប់គ្រងតំបន់បៃតង។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យគណៈកម្មាធិការជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺៈ

- ព័ត៌មានអំពីតំបន់បៃតង(ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវនៅតាមតំបន់ទាំងនោះ
- បង្ហាញអំពីលទ្ធផលជាក់ស្តែងក្នុងការថែរក្សាតំបន់បៃតងទាំងនោះ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យV៣.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០៣** ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ□៣.១ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីតំបន់បៃតងដែលមាន (ទាំងមានស្រាប់ និងក្នុងគំរោង) | ស្រង់ស្ថិតិអំពីតំបន់បៃតង(ដែលមាន) ចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[88]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបរាងជាផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងតំបន់បៃតងទាំងនោះ។ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវគ្រប់គ្រង និងថែរក្សា | - ក្រុមហ៊ុនឯកជន | - កិច្ចសន្យារបស់ក្រុមហ៊ុនឯកជននោះដែលមានកម្មវត្ថុជាការគ្រប់គ្រងថែរក្សាតំបន់បៃតងនោះ |

[88] តារាងទី ៣០

| | | | |
|---|---|---|---|
| | *ឬ* | - អង្គភាពដែលទទួលបន្ទុកគ្រប់គ្រងនិងថែរក្សានៅតាមតំបន់បៃតងទាំងនោះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀត ដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៣ | លទ្ធផលជាក់ស្តែង | ការណែនាំរបស់អាជ្ញាធរទីក្រុងឲ្យមានការគ្រប់គ្រងថែទាំតំបន់បៃតងឲ្យបានត្រឹមត្រូវ | - ដីកា/សារាចរណែនាំរបស់ទីក្រុងបេក្ខភាព *(ក្នុងករណីដែលកិច្ចការនេះមិនមែនជាសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាព ត្រូវមានដីកាសម្រេច/សារាចរណែនាំរបស់អាជ្ញាធរដែលមានសមត្ថកិច្ចនោះអមជាមួយ)* |
| | *និង* | ស្រង់ស្ថិតិអំពីវិធីសាស្ត្រផ្សេងៗក្នុងការគ្រប់គ្រងថែទាំដែលមាននៅតាមតំបន់បៃតងទាំងនោះចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[89]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

[89] តារាងទី ៣១

# ផ្នែកទី៦
# សូចនាករគោលនៃសុវត្ថិភាពសុខាភិបាល សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង

"**សន្តិសុខ និងសុវត្ថិភាព**"គឺជាកត្តាគន្លឹះជាយុទ្ធសាស្ត្រសំរាប់គោលនយោបាយទេសចរណ៍ពោលគឺពង្រឹងភាពប្រកួត -ប្រជែងនិងបង្កើនភាពទាក់ទាញនៃគោលដៅទេសចរណ៍។

ជាទូទៅការគិតគូរអំពីសន្តិសុខ-សុវត្ថិភាព គឺជាកាតព្វកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិតែម្តង។ ការធានាសុវត្ថិភាពដល់ភ្ញៀវទេសចរក៏ដូចជាប្រជាពលរដ្ឋមូលដ្ឋានជាកម្មវត្ថុនៃសូចនាករ គោលទី៦ ដែលសំដៅបង្កើនការទស្សនារបស់ភ្ញៀវទេសចរ (frequentation) និងធានានូវភាពសុខដុមនីយកម្ម រវាងភ្ញៀវទេសចរអន្តរជាតិ និងប្រជាពលរដ្ឋមូលដ្ឋាន។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ សូចនាករគោលនេះបានរៀបចំឡើងដោយផ្តោតជាសំខាន់លើយន្តការនានាដែលចូលរួមទប់ស្កាត់រាល់អំពើល្មើសដែលអាចធ្វើឲ្យប៉ះពាល់ដល់បុគ្គលហើយការប៉ះពាល់នេះ អាចជា៖ ការប៉ះពាល់ដល់សិទ្ធិកម្មសិទ្ធិរបស់បុគ្គលគ្រប់រូប*(ដូចជាអំពើលួច ឬអំពើអសកម្មទាំងឡាយណាដែល បំផ្លិចបំផ្លាញដល់ទ្រព្យសម្បត្តិឯកជន/សាធារណៈ...)* ការប៉ះពាល់ដល់រូបរាងកាយ*(ការប្រើប្រាស់សាធាតុញៀន ដែលហាមឃាត់ការជួញដូរផ្លូវភេទជាដើម...)* និងការប៉ះពាល់ដល់សតិអារម្មណ៍*(ការរើសអើងគ្រប់ រូបភាព...)*។

តាមរយៈសូចនាករគោលនេះ ចលនាប្រឡងប្រណាំងទីក្រុងស្អាតបានលើកឡើងជាវិធានការ និង យុទ្ធសាស្ត្រអនុវត្តមួយចំនួនដែលអាចនឹងចូលរួមកាត់បន្ថយនូវរាល់បញ្ហាអវិជ្ជមានដូចដែលបានរៀបរាប់ខាងលើ។

សូចនាករគោលទី៦នេះ គឺជាសូចនាករគោលសំខាន់ទីពីរ(**មានពិន្ទុសរុបចំនួន១៤ពិន្ទុ**)នៅក្នុងការប្រឡងប្រណាំងទីក្រុងស្អាតនេះ។ សូចនាករគោលនេះមានកម្មវត្ថុ ជម្រុញឲ្យទីក្រុងបេក្ខភាពនានាចាត់វិធានផ្សេងៗដើម្បីចូលរួមដល់ការកាត់បន្ថយហានិភ័យដែលអាចកើតមានឡើងតាមគ្រប់រូបភាពទាំងអស់(សុវត្ថិភាពជាស្ថានភាពមួយដែលគ្មានហានិភ័យត្រូវបានបន្ថយជាអតិបរមា) និងក្នុងគោលបំណងចូលរួមដល់ការអភិវឌ្ឍវិស័យទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជានិងចូលរួមធ្វើឲ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍ប្រកបដោយភាពកក់ក្តៅ។

តាមរយៈសូចនាករគោលទី៦នេះ ទីក្រុងបេក្ខភាពទាំងឡាយនឹងត្រូវវាយតម្លៃដោយផ្អែកលើចំនុច ៣សំខាន់គឺ៖

**ទីមួយ៖** អំពីវត្តមាននៃមណ្ឌលសុខភាព/សង្គ្រោះបឋមនិងវិធានការត្រួតពិនិត្យសុវត្ថិភាព**អនាម័យជារួម និង អនាម័យចំណីអាហារ**។ ជាទូទៅ ការត្រួតពិនិត្យលើសេវាកម្មចំណីអាហារ គឺជាការក្រើនរំលឹកដល់ពាណិជ្ជករទាំងអស់អំពីវិធាន ស្តង់ដា និងការណែនាំផ្សេងៗអំពីអនាម័យ។ ក្នុងន័យនេះ ពាណិជ្ជករត្រូវចូលរួមចំណែកទទួលខុសត្រូវចំពោះសុវត្ថិភាពអ្នកប្រើប្រាស់ (អាជ្ញាប័ណ្ណ លិខិត ការបញ្ជាក់ផ្សេងៗលើគុណភាពផលិតផលឬសេវាកម្មសុទ្ធសឹងជាទណ្ឌិករគាំទ្រដល់ជំនឿទុកចិត្តរបស់អ្នកប្រើប្រាស់)។

**ទីពីរ ៖** ទន្ទឹមនឹងអនាម័យ **សណ្តាប់ធ្នាប់**នៅតាមតំបន់ទីប្រជុំជនឬគោលដៅទេសចរណ៍នៅតាមទីក្រុង (សុវត្ថិភាពនៃការធ្វើដំណើរលើផ្លូវថ្នល់ និងសណ្តាប់ធ្នាប់នៅក្នុងទីក្រុង) គឺក៏ជាលក្ខណៈវិនិច្ឆ័យមួយសំខាន់ក្នុងសូចនាករនេះ។ ឧទាហរណ៍ ការកំណត់តំបន់សម្រាប់ធ្វើដំណើរកំសាន្តតាមរយៈការរៀបចំឲ្យមានផ្លូវសំរាប់ថ្មើជើង ផែនទីទេសចរណ៍ ការរៀបចំឲ្យមានបណ្ណ ឯកសណ្ឋាន ឬលក្ខណៈសម្គាល់ផ្សេងៗទៀតចំពោះភ្នាក់ងារបើកបរ មធ្យោបាយធ្វើដំណើរសាធារណៈ (transport public)វត្តមានភ្នាក់ងារនគរបាលយកចិត្តទុកដាក់ចំពោះភ្ញៀវទេសចរ (នគរបាលទេសចរ នគរបាលសណ្តាប់ធ្នាប់...)។

**ទីបី៖** ការបង្ការ ការបង្កើនវិធានការដើម្បីត្រួតពិនិត្យ និងក្រើនរំលឹកដល់ភ្ញៀវទេសចរ និងប្រជាជនដែលរស់នៅ

ក្នុងទីក្រុងឲ្យជៀសវាងអំពើមួយចំនួនដែលជាបទល្មើស គឺជាលក្ខណវិនិច្ឆ័យសំខាន់មួយដែរក្នុងសូចនាករនេះ។

# S១.សូចនាករលំអិតនៃសុវត្ថភាពសុខាភិបាល

**កម្មវត្ថុសូចនាករលំអិត S១**

សូចនាករលម្អិត □១ នឹងឆ្លុះបញ្ចាំងដល់គ្រប់ទីក្រុងបេក្ខភាពឲ្យយល់កាន់តែច្បាស់អំពីអត្ថន័យនិងលក្ខខណ្ឌដែលអាចនឹងទទួលបានពិន្ទុ ពោលគឺចង្អុលបង្ហាញដល់គ្រប់ទីក្រុងបេក្ខភាពនូវអ្វីដែលស្តង់ដាទីក្រុងស្អាតបានតំរូវដូចជា៖ ប្រភេទលិខិតបទដ្ឋាន សំណុំឯកសារ និងភស្តុតាងទាំងឡាយណាដែលអាចលើកយកមកធ្វើជាសំអាងបញ្ជាក់ដើម្បីទទួលបានពិន្ទុដូចចែងក្នុងលក្ខណវិនិច្ឆ័យនីមួយៗ។

តារាងខាងក្រោមនេះបង្ហាញអំពីលក្ខណវិនិច្ឆ័យទាំង ៥ នៃសូចនាករលម្អិតS១ ដែលជាកម្មវត្ថុនៃការពិភាក្សាដើម្បីធ្វើការណែនាំដល់ទីក្រុងបេក្ខភាព។

| លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| S១.១. មាន**<u>មណ្ឌលសុខភាព</u>**គ្រប់គ្រាន់នៅតាមទីក្រុង/ខណ្ឌ | យ៉ាងហោចណាស់១ ក្នុង១សង្កាត់ | ១ |
| S១.២. លទ្ធភាពនៃ**<u>ការត្រួតពិនិត្យអនាម័យ</u>**តាម**<u>ភោជនីយដ្ឋាន</u>** (ត្រូវធ្វើឡើងដោយមន្ទីរសុខាភិបាល) | យ៉ាងហោច៣ដងក្នុងមួយខែ | ១ |
| S១.៣. លទ្ធភាពនៃ**<u>ការត្រួតពិនិត្យអនាម័យ</u>**តាម**<u>ផ្សារលក់ចំណី</u>** (ត្រូវធ្វើឡើងដោយមន្ទីរសុខាភិបាល) | យ៉ាងហោច៣ដងក្នុងមួយខែ | ១ |
| S១.៤. លទ្ធភាពនៃ**<u>ការត្រួតពិនិត្យអនាម័យ</u>**របស់**<u>អ្នកលក់ដូរចល័ត</u>** (ត្រូវធ្វើឡើងដោយមន្ទីរសុខាភិបាល) | យ៉ាងហោច៣ដងក្នុងមួយខែ | ១ |
| S១.៥. ភាគរយ**<u>អាជីវកម្ម</u>**ដែលមាន**<u>លិខិតបញ្ជាក់អនាម័យពីក្រសួង ឬមន្ទីរសុខាភិបាល</u>** | យ៉ាងហោច៧0% | ១ |

*( ផ្តល់ពិន្ទុ ៥/១៤ នៃពិន្ទុសរុបរបស់សូចនាករគោលនៃសុវត្ថិភាពនិងអនាម័យទីក្រុង )*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណវិនិច្ឆ័យ S១.១

*"មាន**<u>មណ្ឌលសុខភាព</u>**គ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង"*
*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថាមាន**<u>យ៉ាងហោច១ក្នុង១សង្កាត់</u>**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | មណ្ឌលសុខភាព | សំដៅដល់កន្លែងផ្តល់ប្រឹក្សាយោបល់ ពិនិត្យសុខភាព និងផ្តល់សេវាសុខភាពផ្សេងៗ។ |

| | | |
|---|---|---|
| | | មណ្ឌលសុខភាពមិនកំណត់ត្រឹមគ្រឹះស្ថានសេវាសាធារណៈទេ ក្នុងន័យនេះអាចជាៈ កន្លែងពិគ្រោះសុខភាពឬសង្គ្រោះបឋមមន្ទីរពេទ្យ បង្អែក មន្ទីរពេទ្យឯកជន គ្លីនីក ។ល។<br><br>ដោយឡែក មិនត្រូវបានចាត់ទុកជាមណ្ឌលសុខភាពចំពោះកន្លែងផ្តល់សេវាសុខភាពឯកទេស (ដែលផ្តល់សេវាសុខភាពតែមួយឬពីរមុខ ឧទាហរណ៍ដូចជាៈ ពេទ្យធ្មេញ ពេទ្យឯកទេសរបេង ។ល។) |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យទ១.១តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះគឺ **"ចំនួន"** (បរិមាណ) មណ្ឌលសុខភាពនៅក្នុងដែនសមត្ថកិច្ចរដ្ឋបាលរបស់ទីក្រុងបេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.**ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០២** គឺៈ

- ផ្តល់ព័ត៌មានអំពីចំនួននិងទីតាំងនៃមណ្ឌលសុខភាពទាំងអស់(ដែលមាន)
- បង្ហាញថាទីក្រុងបេក្ខភាពមានមណ្ឌលសុខភាពគ្រប់គ្រាន់ (យ៉ាងហោចណាស់១ក្នុង១សង្កាត់)។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យទ១.១ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០២** ខាងលើ។

**តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវនិច្ឆ័យ១.១**

| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
|---|---|---|---|
| ១ | ព័ត៌មានអំពីមណ្ឌលសុខភាព *(ទាំងមានស្រាប់និងក្នុងគម្រោង)* | ស្រង់ទិន្នន័យ/ចំនួនមណ្ឌលសុខភាព(មន្ទីរពេទ្យ/គ្លីនិក)ដែលស្ថិតក្នុងដែនសមត្ថកិច្ចនៃទីក្រុងបេក្ខភាពក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[90]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបចំផែនទីកំណត់ទីតាំងមណ្ឌល សុខភាពដែលមានក្នុងដែនសមត្ថកិច្ចរដ្ឋ បាលគ្រប់គ្រងរបស់ទីក្រុងបេក្ខភាព | -ផែនទីរដ្ឋបាលបង្ហាញទីតាំងមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | មានមណ្ឌលសុខភាពគ្រប់គ្រាន់ | រៀបចំជាលិខិតរដ្ឋបាលដែលមានសុពលភាពអាចបញ្ជាក់អំពីចំនួនមណ្ឌលសុខភាពនៅតាមសង្កាត់នីមួយៗ *(បញ្ជាក់ថាមានមណ្ឌលសុខភាពយ៉ាងហោចណាស់១ក្នុង១សង្កាត់)* | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច |

## ២. លក្ខណវនិច្ឆ័យ ទ ១.២

*"លទ្ធភាពនៃ**ការត្រួតពិនិត្យអនាម័យ**តាម**ភោជនីយដ្ឋាន** (ត្រូវធ្វើឡើងដោយមន្ទីរសុខាភិបាល)"*

[90] តារាងទី ០២

*"នឹងផ្តល់ជូន ១ពិន្ទុ ប្រសិនបើអាចបង្ហាញថាមានការត្រួតពិនិត្យ__យ៉ាងហោច៣ដងក្នុង១ខែ__"*

## ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ការត្រួតពិនិត្យអនាម័យ | សំដៅដល់ការត្រួតពិនិត្យលើគុណភាពនិងកម្រិតអនាម័យនូវសេវាកម្មចំណីអាហារ និងចំណីអាហារផ្ទាល់តែម្តង។ |
| ២ | ភោជនីយដ្ឋាន | សំដៅដល់ទាំង**អាហារដ្ឋាននិងភោជនីយដ្ឋានទេសចរណ៍**[91] និងទាំង**អាហារដ្ឋាននិងភោជនីយដ្ឋានទទួលបម្រើភ្ញៀវក្នុងស្រុក**[92]។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យទ១.២តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) ភោជនីយដ្ឋាននានាដែលមាននៅក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរដ្ឋបាលរបស់ទីក្រុងបេក្ខភាព ដែលបានចុះត្រួតពិនិត្យអនាម័យក្នុង១ខែៗ។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.**ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៤ គឺ៖

- ផ្តល់ព័ត៌មានអំពីចំនួននិងទីតាំងនៃភោជនីយដ្ឋានទាំងអស់(ដែលមាន)
- បង្ហាញពីវត្តមានវិធានការត្រួតពិនិត្យអនាម័យនៅតាមភោជនីយដ្ឋានទាំងនោះ
- បង្ហាញពីវត្តមានអ្នកទទួលខុសត្រូវអនុវត្តវិធានការត្រួតពិនិត្យដែលបានដាក់ចេញ
- បង្ហាញពីសកម្មអនុវត្តជាក់ស្តែងរបស់អង្គភាពទទួលខុសត្រូវទាំងនោះក្នុងការចុះអនុវត្តជាក់ស្តែងឲ្យបានយ៉ាងហោច៣ដងក្នុង១ខែ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យទ១.២ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៤ ខាងលើ។

**តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណៈវិនិច្ឆ័យ១.២**

| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
|---|---|---|---|
| ១ | ព័ត៌មានអំពីចំនួនភោជនីយដ្ឋាន | ស្រង់ទិន្នន័យ/ចំនួនភោជនីយដ្ឋានដែលស្ថិតក្នុងដែនសមត្ថកិច្ចនៃទីក្រុងបេក្ខភាពក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[93]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានវិធានការត្រួតពិនិត្យ | រៀបចំជាវិធានការ យន្តការ ឬបទដ្ឋានផ្សេងៗសម្រាប់អនុវត្តការត្រួតពិនិត្យ អនាម័យនៅតាមភោជនីយដ្ឋាន | -សេចក្តីសម្រេច ឬដីកា ឬនីតិវិធីផ្សេងៗដែលមានតម្លៃស្មើស្តីពីការកំណត់យន្តការត្រួតពិនិត្យអនាម័យនៅតាមភោជនីយដ្ឋាន |

[91]សំដៅដល់អគារ ឬទីតាំងដែលរៀបចំឡើងដើម្បីបម្រើសេវាកម្មម្ហូបអាហារ និងភេសជ្ជៈសម្រាប់ភ្ញៀវជាចម្បង។

[92]សំដៅដល់អគារ ឬទីតាំងដែលរៀបចំឡើងដើម្បីបម្រើសេវាកម្មម្ហូបអាហារ និងភេសជ្ជៈសម្រាប់ប្រជាពលរដ្ឋទូទៅជាចម្បង។

[93] តារាងទី ២៥

| | | | |
|---|---|---|---|
| ៣ | វត្តមានអង្គភាពមានសមត្ថកិច្ច ទទួលបន្ទុកត្រួតពិនិត្យ | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៤ | សកម្មភាពជាក់ស្តែង | ធ្វើការបែងចែកជាក្រុមការងារតូចៗសម្រាប់ចុះត្រួតពិនិត្យ (ក្រុមល្បាត) | -បញ្ជីរាយនាមក្រុមការងារទាំងនោះ ដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុងឬអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបចំជាតារាងផែនការសកម្មភាពដែលមានការបញ្ជាក់បង្ហាញថាមានការត្រួតពិនិត្យនៅតាមភោជនីយដ្ឋានទាំងនោះយ៉ាងហោចណាស់៣ដងក្នុង១ខែ | -តារាងផែនការសកម្មភាព[94]របស់អង្គភាពដែលទទួលខុសត្រូវការងារនេះ |
| | ***និង*** | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច<br>- រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែង |

**៣. លក្ខណវនិច្ឆ័យ ទ១.៣**

*"លទ្ធភាពនៃ**ការត្រួតពិនិត្យអនាម័យ**តាម**ផ្សារលក់ចំណីអាហារ**(ត្រូវធ្វើឡើងដោយមន្ទីរសុខាភិបាល)"*
*"នឹងផ្តល់ជូន **១ពិន្ទុ** ប្រសិនបើអាចបង្ហាញថាមានការត្រួតពិនិត្យ**យ៉ាងហោច៣ដងក្នុង១ខែ**"*

## ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ការត្រួតពិនិត្យអនាម័យ | សំដៅដល់ការត្រួតពិនិត្យលើគុណភាពនិងកម្រិតអនាម័យនូវសេវាកម្មចំណីអាហារ និងចំណីអាហារផ្ទាល់តែម្តង។ |
| ២ | ផ្សារលក់ចំណីអាហារ | សំដៅដល់ទីផ្សារទាំងឡាយណាដែលជាកន្លែងផ្តល់ ផ្គត់ផ្គង់(លក់ដុំឬលក់រាយ) ដល់ប្រជាពលរដ្ឋទូទៅនូវម្ហូបចំណីគ្រប់ប្រភេទ (បន្លែ ត្រី សាច់...) ក្នុងគ្រប់សណ្ឋាន (អាហារស្រស់ អាហារក្លាសេ អាហារកំប៉ុង...)។ |

[94] តារាងទី ៤២

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យទ១.៣តម្រូវទីក្រុងឲ្យបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**ចំនួន**" (បរិមាណ) ផ្សារលក់ចំណីអាហារនានាដែលមាននៅក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ទីក្រុងបេក្ខភាព ដែលត្រូវបានចុះត្រួតពិនិត្យក្នុង១ខែៗ។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៤ គឺៈ

- ផ្តល់ព័ត៌មានអំពីចំនួននិងទីតាំងនៃផ្សារលក់ចំណីអាហារទាំងអស់(ដែលមាន)
- បង្ហាញពីវត្តមានវិធានការត្រួតពិនិត្យអនាម័យនៅតាមផ្សារលក់ចំណីអាហារទាំងនោះ
- បង្ហាញពីវត្តមានអ្នកទទួលខុសត្រូវអនុវត្តវិធានការត្រួតពិនិត្យដែលបានដាក់ចេញ
- បង្ហាញពីសកម្មអនុវត្តជាក់ស្តែងរបស់អង្គភាពទទួលខុសត្រូវទាំងនោះក្នុងការចុះអនុវត្តជាក់ស្តែងឲ្យបានយ៉ាងហោច៣ដងក្នុង១ខែ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យទ១.៣ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៤ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ□១.៣ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីផ្សារលក់ចំណីអាហារ(ដែលមាន) | ស្រង់ទិន្នន័យ/ចំនួនផ្សារលក់ចំណីអាហារដែលស្ថិតក្នុងដែនសមត្ថកិច្ចនៃទីក្រុងបេក្ខភាពក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[95]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានវិធានការត្រួតពិនិត្យ | រៀបរាងជាវិធានការ យន្តការ ឬបទដ្ឋានផ្សេងៗសម្រាប់អនុវត្តការត្រួតពិនិត្យអនាម័យនៅតាមផ្សារលក់ចំណីអាហារ | -សេចក្តីសម្រេច ឬដីកា ឬនីតិវិធីផ្សេងៗដែលមានតម្លៃស្មើស្តីពីការកំណត់យន្តការត្រួតពិនិត្យអនាម័យនៅតាមផ្សារលក់ចំណីអាហារ |
| ៣ | វត្តមានអង្គភាពមានសមត្ថកិច្ច ទទួលបន្ទុកត្រួតពិនិត្យ | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៤ | សកម្មភាពជាក់ស្តែង | ធ្វើការបែងចែកជាក្រុមការងារតូចៗសម្រាប់ចុះត្រួតពិនិត្យ (ក្រុមល្បាត) | -បញ្ជីរាយនាមក្រុមការងារទាំងនោះ ដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុងឬអាជ្ញាធរមានសមត្ថកិច្ច |

[95] តារាងទី ១៦

| | | | |
|---|---|---|---|
| | *និង* | រៀបចំជាតារាងផែនការសកម្មភាព ដែលមានការបញ្ជាក់បង្ហាញថាមានការត្រួតពិនិត្យនៅតាមផ្សារលក់ចំណីអាហារទាំងនោះយ៉ាងហោចណាស់៣ដងក្នុង១ខែ | -តារាងផែនការសកម្មភាព[96]របស់អង្គភាពដែលទទួលខុសត្រូវការងារនេះ |
| | *និង* | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច<br>- រូបថត រូបភាពខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែង |

## ៤. លក្ខណៈវិនិច្ឆ័យ ទ១.៤

*"លទ្ធភាពនៃ**<u>ការត្រួតពិនិត្យអនាម័យ</u>**របស់**<u>អ្នកលក់ដូរចល័ត</u>**(ត្រូវធ្វើឡើងដោយមន្ទីរសុខាភិបាល)"*
*"នឹងផ្តល់ជូន **១ពិន្ទុ** ប្រសិនបើអាចបង្ហាញថាមានការត្រួតពិនិត្យ**<u>យ៉ាងហោច៣ដងក្នុង១ខែ</u>**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ការត្រួតពិនិត្យអនាម័យ | សំដៅដល់ការត្រួតពិនិត្យលើគុណភាពនិងកម្រិតអនាម័យ ចំណីអាហារ និងអ្នកផ្តល់សេវាកម្មចំណីអាហារនេះតែម្តង។ |
| ២ | អ្នកលក់ដូរចល័ត | សំដៅដល់អាជីករដែលប្រកបរបរជាអ្នកផ្តល់ ផ្គត់ផ្គង់ចំណីអាហារ (ឆ្អិនស្រាប់ ឬចម្អិននៅហ្នឹងកន្លែង) ដល់ប្រជាពលរដ្ឋទូទៅតាមរយៈទីតាំងអាជីវកម្មមួយដែលអាចចល័តបានយ៉ាងងាយស្រួលពីទីកន្លែងមួយទៅកាន់ទីកន្លែងមួយទៀត ឬអាចរុះរើបានយ៉ាងងាយស្រួលក្នុងរយៈពេលខ្លី ឬជាទីតាំងអាជីវកម្មមួយដែលមិនមានលក្ខណៈជាអចិន្ត្រៃយ៍។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យទ១.៤តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) តូបលក់ដូរចល័តនានាដែលមាននៅក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ទីក្រុងបេក្ខភាព។ ដូច្នេះ បេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន 04 គឺ៖

- ផ្តល់ព័ត៌មានអំពីចំនួននិងទីតាំងនៃតូបលក់ដូរចល័តទាំងអស់(ដែលមាន)
- បង្ហាញពីវត្តមានវិធានការត្រួតពិនិត្យអនាម័យនៅតាមតូបលក់ដូរចល័តទាំងនោះ
- បង្ហាញពីវត្តមានអ្នកទទួលខុសត្រូវអនុវត្តវិធានការត្រួតពិនិត្យដែលបានដាក់ចេញ

[96] តារាងទី ៤២

- បង្ហាញពីសកម្មអនុវត្តជាក់ស្តែងរបស់អង្គភាពទទួលខុសត្រូវទាំងនោះក្នុងការចុះអនុវត្តជាក់ស្តែងឲ្យបានយ៉ាងហោច៣ដងក្នុង១ខែ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យ១.៤ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៤ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ ១.៤ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីតួបលក់ដូរចល័ត (ដែលមាន) | ស្រង់ទិន្នន័យ/ចំនួនតូបលក់ដូរចល័តដែលស្ថិតក្នុងដែនសមត្ថកិច្ចនៃទីក្រុងបេក្ខភាពក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[97]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានវិធានការត្រួតពិនិត្យ | រៀបរាងជាវិធានការ យន្តការ ឬបទដ្ឋាន ផ្សេងៗសម្រាប់អនុវត្តការត្រួតពិនិត្យ អនាម័យនៅតាមតូបលក់ដូរចល័តដែលមាន | -សេចក្តីសម្រេច ឬដីកា ឬនីតិវិធីផ្សេងៗ ដែលមានតម្លៃស្មើស្តីពីការកំណត់យន្តការត្រួតពិនិត្យអនាម័យនៅតាមតូបលក់ដូរចល័ត |
| ៣ | វត្តមានអង្គភាពមានសមត្ថកិច្ច ទទួលបន្ទុកត្រួតពិនិត្យ | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | -សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ |
| ៤ | សកម្មភាពជាក់ស្តែង | ធ្វើការបែងចែកជាក្រុមការងារតូចៗសម្រាប់ចុះត្រួតពិនិត្យ (ក្រុមល្បាត) | -បញ្ជីរាយនាមក្រុមការងារទាំងនោះ ដែលមានការបញ្ជាក់ពីអាជ្ញាធរក្រុង/ខណ្ឌ ឬអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបចំជាតារាងផែនការសកម្មភាពដែលមានការបញ្ជាក់បង្ហាញថាមានការត្រួតពិនិត្យនៅតាមតូបលក់ដូរចល័តទាំងនោះយ៉ាងហោចណាស់៣ដងក្នុង១ខែ | -តារាងផែនការសកម្មភាព[98]របស់អង្គភាពដែលទទួលខុសត្រូវការងារនេះ |

[97] តារាងទី ១៧

[98] តារាងទី ៤២

| | | | |
|---|---|---|---|
| | *និង* | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច<br>- រូបថត រូបភាពខ្សែវីដេអូ ឬឯកសារផ្សេងៗ ដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែង |

## ៥. លក្ខណៈវិនិច្ឆ័យ ទ១.៥

*"ភាគរយ**<u>អាជីវកម្ម</u>**ដែលមាន**<u>លិខិតបញ្ជាក់អនាម័យ</u>**ពីក្រសួងឬមន្ទីរសុខាភិបាល"*
*"នឹងផ្តល់ជូន **១ពិន្ទុ** ប្រសិនបើអាចបង្ហាញថាមានយ៉ាងហោច៧០%"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | អាជីវកម្ម | សំដៅដល់ប្រភេទអាជីវកម្មទាំង៣ដូចដែលបានលើកឡើងក្នុងលក្ខណវិនិច្ឆ័យទាំង៣ខាងលើរួមមានៈ ភោជនីយដ្ឋាន ផ្សារលក់ចំណីអាហារ និងអ្នកលក់ដូរចល័ត។ |
| ២ | លិខិតបញ្ជាក់អនាម័យ | សំដៅដល់វិញ្ញាបនប័ត្របញ្ជាក់អនាម័យដែលចេញដោយក្រសួង/មន្ទីរសុខាភិបាលសម្រាប់ទីតាំងអាជីវកម្មមួយចំនួន ពិសេសអាជីវកម្មទាំងឡាយដែលមានលក្ខណៈអត្ថចរិកសេវាកម្មរបស់ខ្លួនផ្សារភ្ជាប់នឹងសុខមាលភាពរបស់អ្នកប្រើប្រាស់សេវានោះ ដូចជា៖ លក់ដូរគ្រឿងឧបភោគបរិភោគ ភោជនីយដ្ឋាន សណ្ឋាគារ...។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យទ១.៥តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) ទីតាំងអាជីវកម្មដែលមានលិខិតបញ្ជាក់អនាម័យត្រឹមត្រូវពីក្រសួង ឬមន្ទីរសុខាភិបាល។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០២** គឺ៖

- ផ្តល់ព័ត៌មានអំពីចំនួននិងទីតាំងនៃទីតាំងអាជីវកម្មទាំងអស់(ដែលមាន)
- បង្ហាញថាក្នុងចំណោមទីតាំងអាជីវកម្មទាំងអស់មានយ៉ាងហោចណាស់៧០%ដែលមានលិខិតបញ្ជាក់អនាម័យ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យទ១.៥ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៤ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណៈវិនិច្ឆ័យ□១.៥ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |

| | | | |
|---|---|---|---|
| ១ | ព័ត៌មានអំពីទីតាំងអាជីវកម្ម (ដែលមាន) | ស្រង់ទិន្នន័យ/ចំនួនទីតាំងអាជីវកម្មដែលស្ថិតក្នុងដែនសមត្ថកិច្ចនៃទីក្រុងបេក្ខភាពក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[99]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | មានទីតាំងអាជីវកម្មយ៉ាងហោច ៧០%មានលិខិតបញ្ជាក់អនាម័យ | រៀបរាងជាលិខិតរដ្ឋបាលដែលមានសុពលភាពអាចបញ្ជាក់អំពីចំនួនទីតាំងអាជីវកម្មទាំងអស់ដែលមាន *(បញ្ជាក់ថាមានទីតាំងអាជីវកម្មយ៉ាងតិច៧០%នៃចំនួនសរុបមានលិខិតបញ្ជាក់អនាម័យ)* | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច |

# ទ១២.សូចនាករលំអិតនៃសន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង

## កម្មវត្ថុសូចនាករលំអិត ទ១២

**សូចនាករលម្អិតនៃសន្តិសុខ និងសណ្តាប់ធ្នាប់**សំដៅចូលរួមយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍ដោយខិតខំបង្កើនការទស្សនារបស់ភ្ញៀវទេសចរនិងធានានូវភាពសុខដុម្បនីយកម្មរវាងភ្ញៀវទេសចរអន្តរជាតិ និងប្រជាជនមូលដ្ឋាន។ ជាទូទៅការគិតគូរអំពីសន្តិសុខ-សុវត្ថិភាព គឺជាកាតព្វកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិផ្ទាល់តែម្តង។

តារាងខាងក្រោមនេះបង្ហាញអំពីលក្ខណវិនិច្ឆ័យទាំង **៦** នៃសូចនាករលំអិតទ១២ ដែលជាកម្មវត្ថុនៃការពិភាក្សាដើម្បីធ្វើការណែនាំដល់ទីក្រុងបេក្ខភាព។

| លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| ទ១២.១ តើ<u>**មន្ត្រីនគរបាលទេសចរណ៍**</u>មានចំនួនគ្រប់គ្រាន់ដែរឬទេបើធៀបនឹងចំនួនទេសចរ? | មាន-មិនមាន | ១ |
| ទ១២.២ ភាគរយ<u>**មន្ត្រីនគរបាលទេសចរណ៍**</u>ដែលបានទទួលការហ្វឹកហ្វាត់ជំនាញ (ភាសានិងការទទួលភ្ញៀវ) | យ៉ាងហោច៨០% | ១ |
| ទ១២.៣ចំនួន<u>**ពាក្យបណ្តឹងដែលមានកម្មវត្ថុទាក់ទងនឹងសុវត្ថិភាពភ្ញៀវទេសចរ**</u>ទទួលបានក្នុងមួយឆ្នាំៗ | តិចជាង ១០ | ១ |
| ទ១២.៤ ភាគរយនៃ<u>**អ្នកបើករថយន្តឈ្នួល ម៉ូតូឌុប រ៉ឺម៉កកង់បី**</u> ដែលមានឯកសណ្ឋាន | យ៉ាងហោច៥០% | ១ |
| ទ១២.៥តើមានការគិតគូរលើ<u>**ចំណតសំរាប់ រថយន្ត ម៉ូតូ កង់...**</u>នៅតាម<u>**ដងវិថីសំខាន់ៗ**</u>នៃទីក្រុងដែរឬទេ? | មាន-មិនមាន | ១ |
| ទ១២.៦តើមានការគិតគូរលើ<u>**ចំណតសំរាប់ថ្ងៃគូ និងថ្ងៃសេស**</u>នៅតាម<u>**វិថីសំខាន់ៗ**</u>នៃទីក្រុងដែរឬទេ? | មាន-មិនមាន | |

[99] តារាងទី ១៨

*( ផ្ដល់ពិន្ទុ ៦/១៤ នៃពិន្ទុសរុបរបស់សូចនាករគោលនៃសុវត្ថិភាពនិងអនាម័យទីក្រុង )*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណៈវិនិច្ឆ័យ S២.១

*"តើ__មន្ត្រីនគរបាលទេសចរណ៍__មានចំនួនគ្រប់គ្រាន់ដែរឬទេបើធៀបនឹងចំនួនភ្ញៀវទេសចរ?"*
*"នឹងផ្ដល់ជូន **១ពិន្ទុ** ប្រសិនបើអាចបង្ហាញថា__**មាន**__"*

### ក. សេចក្ដីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្ដីពន្យល់ |
|---|---|---|
| ១ | មន្ត្រីនគរបាលទេសចរណ៍ | សំដៅដល់មន្ត្រីនគរបាលដែលស្ថិតនៅក្រោមក្របខណ្ឌអគ្គស្នងការនគរបាលជាតិ មិនសំដៅដល់មន្ត្រីអធិការកិច្ចទេសចរណ៍នោះទេ។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យS២.១តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) មន្ត្រីនគរបាលទេសចរណ៍ដែលមាននៅក្នុងក្រមខណ្ឌរបស់ទីក្រុងបេក្ខភាពនីមួយៗ។ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០២** គឺៈ

- ផ្ដល់ព័ត៌មានអំពីចំនួនមន្ត្រីនគរបាលទេសចរណ៍ទាំងអស់(ដែលមាន)
- បង្ហាញអំពីសកម្មភាពអនុវត្តជាក់ស្ដែងរបស់មន្ត្រីនគរបាលទេសចរណ៍ទាំងនោះ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យS២.១ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០២** ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ□២.១ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីចំនួនមន្ត្រីនគរបាលទេសចរណ៍ | ស្រង់ទិន្នន័យអំពីចំនួនមន្ត្រីនគរបាលទេសចរណ៍ទាំងអស់មានចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[100]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | សកម្មភាពអនុវត្តជាក់ស្ដែងរបស់មន្ត្រីនគរបាលទេសចរណ៍ | ធ្វើការបែងចែកជាក្រុមការងារតូចៗសម្រាប់ចុះត្រួតពិនិត្យ (ក្រុមល្បាត) | -បញ្ជីរាយនាមក្រុមការងារទាំងនោះដែលមានការបញ្ជាក់ពីអាជ្ញាធរក្រុង/ខណ្ឌ ឬអាជ្ញាធរមានសមត្ថកិច្ច |

---

[100] តារាងទី ២៦

| | | | |
|---|---|---|---|
| | និង | រៀបចំជាតារាងផែនការសកម្មភាព | -តារាងផែនការសកម្មភាព[101]របស់អង្គភាពដែលទទួលខុសត្រូវការងារនេះ |
| | និង | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា<br>និងការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច<br>- រូបថត រូបភាពខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែង |

## ២. លក្ខណៈវិនិច្ឆ័យ ទ២.២

*"ភាគរយចំនួន**មន្ត្រីនគរបាលទេសចរណ៍**ដែលបានទទួលការហ្វឹកហ្វាត់ជំនាញ(ភាសានិងការទទួលភ្ញៀវ)" "នឹងផ្តល់ជូន ១ពិន្ទុ ប្រសិនបើអាចបង្ហាញថា**មន្ត្រីយ៉ាងហោចណាស់៨០%នៃចំនួនសរុបទទួលបានការហ្វឹកហាត់ជំនាញ**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | មន្ត្រីនគរបាលទេសចរណ៍ | សំដៅដល់មន្ត្រីនគរបាលដែលស្ថិតនៅក្រោមក្របខណ្ឌអគ្គស្នងការនគរបាលជាតិ មិនសំដៅដល់មន្ត្រីអធិការកិច្ចទេសចរណ៍នោះទេ។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យទ២.២តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) មន្ត្រីនគរបាលទេសចរណ៍ដែលទទួលបានការបណ្តុះបណ្តាលនិងបំពាក់-បំប៉នវគ្គជំនាញភាសា និងបដិសណ្ឋារកិច្ច។ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺៈ

- ផ្តល់ព័ត៌មានអំពីចំនួនមន្ត្រីនគរបាលទេសចរណ៍ទាំងអស់(ដែលមាន)
- ផ្តល់ព័ត៌មានអំពីវគ្គបណ្តុះបណ្តាលជំនាញភាសា និងបដិសណ្ឋារកិច្ចដែលមាន និងបញ្ជាក់ពីចំនួនមន្ត្រីដែលបានចូលរួមក្នុងមួយវគ្គៗ
- បង្ហាញថាមានមន្ត្រីនគរបាលទេសចរណ៍យ៉ាងហោចណាស់៨០%ដែលទទួលបានការបណ្តុះបណ្តាលលើវគ្គជំនាញភាសានិងបដិសណ្ឋារកិច្ច

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យទ២.២ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០៣** ខាងលើ។

### តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ□២.២

[101] តារាងទី ៤២

| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
|---|---|---|---|
| ១ | ព័ត៌មានអំពីចំនួនមន្ត្រីនគរបាលទេសចរណ៍ | ស្រង់ទិន្នន័យអំពីចំនួនមន្ត្រីនគរបាលទេសចរណ៍ទាំងអស់ដោយមានចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[102]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | ព័ត៌មានអំពីវគ្គបណ្តុះបណ្តាលនិងមន្ត្រីដែលបានចូលរួម | ស្រង់ទិន្នន័យអំពីវគ្គបណ្តុះបណ្តាលជំនាញភាសានិងបដិសណ្ឋារកិច្ចដែលមាន និងចំនួនមន្ត្រីនគរបាលទេសចរណ៍ដែលបានចូលរួម (ចុះក្នុងតារាងគំរូមួយ) | -តារាងសម្រង់ស្ថិតិ[103]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ៣ | មន្ត្រីនគរបាលទេសចរណ៍ទទួលបានការហ្វឹកហាត់ជំនាញ | រៀបចំជាលិខិតរដ្ឋបាលដែលមានសុពលភាពអាចបញ្ជាក់អំពីចំនួនមន្ត្រីនគរបាលទេសចរណ៍ដែលឆ្លងកាត់វគ្គបណ្តុះបណ្តាលភាសានិងបដិសណ្ឋារកិច្ច *(បញ្ជាក់ថាមានយ៉ាងហោចណាស់៨០%)* | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច |

## ៣. លក្ខណៈវិនិច្ឆ័យ ទ២.៣

*"ចំនួន<u>ពាក្យបណ្តឹងដែលមានកម្មវត្ថុទាក់ទងនឹងសុវត្ថិភាពភ្ញៀវទេសចរ</u>ទទួលបានក្នុងមួយឆ្នាំៗ"*
*"នឹងផ្តល់ជូន **១ពិន្ទុ** ប្រសិនបើអាចបង្ហាញថា<u>**មានតិចជាង១០**</u>"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ពាក្យបណ្តឹងដែលមានកម្មវត្ថុទាក់ទងនឹងសុវត្ថិភាពភ្ញៀវទេសចរ | សំដៅដល់ពាក្យបណ្តឹងទាំងឡាយណាដែលមានកម្មវត្ថុជាការប្តឹងទាស់នឹងអំពើល្មើស ឬសកម្មភាពអសកម្មទាំងឡាយដែលមានផលប៉ះពាល់ដល់សុខសុវត្ថិភាពលើរូបរាងកាយ និងទ្រព្យសម្បត្តិរបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិដែលមកទស្សនាកំសាន្តនៅក្នុងដែនសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាព។<br>ពាក្យបណ្តឹងនេះអាចជាបណ្តឹងដែលធ្វើឡើងដោយទេសចរខ្លួនឯងផ្ទាល់ ឬសាធារណជនគ្រប់រូបដែលពាក់ព័ន្ធ។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យទ២.៣តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) ពាក្យបណ្តឹងដែលមានកម្មវត្ថុទាក់ទងនឹងសុវត្ថិភាពទេសចរណ៍ក្នុងរយៈពេលមួយឆ្នាំ និងកើតមានឡើងក្នុងដែនសមត្ថកិច្ចរដ្ឋបាលគ្រប់គ្រងរបស់ទីក្រុងបេក្ខភាពក្នុងទីក្រុងរបស់ខ្លួន។ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

---

[102] តារាងទី ២៦

[103] តារាងទី ២៦

លក្ខខណ្ឌតម្រូវទាំងនោះមាន ០២ គឺ៖

- ផ្តល់ព័ត៌មានអំពីចំនួនពាក្យបណ្តឹងដែលមានកម្មវត្ថុទាក់ទងនឹងសុវត្ថិភាពភ្ញៀវទេសចរទាំងអស់(ដែលមាន)
- បង្ហាញថាក្នុងរយៈពេលមួយឆ្នាំសមត្ថកិច្ចទទួលពាក្យបណ្តឹងទាំងនោះមានចំនួនតិចជាង១០។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យS២.៣ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០២ ខាងលើ។

| **តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ□២.៣** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីចំនួនពាក្យបណ្តឹង(ដែលមាន) | ស្រង់ទិន្នន័យចំនួនពាក្យបណ្តឹងដែលទទួលបានក្នុងមួយឆ្នាំៗ (ចុះក្នុងតារាងគំរូមួយ) | -តារាងសម្រង់ស្ថិតិ[104]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | ពាក្យបណ្តឹងដែលធ្វើឡើងមានចំនួនតិចជាង១០ក្នុងរយៈពេល១ឆ្នាំ | រៀបចំជាលិខិតរដ្ឋបាលដែលមានសុពលភាពអាចបញ្ជាក់អំពីចំនួនពាក្យបណ្តឹងដែលបានធ្វើឡើង *(បញ្ជាក់ថាមានចំនួនតិចជាង១០)* | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច |

## ៤. លក្ខណវិនិច្ឆ័យ S២.៤

*"ភាគរយនៃ__អ្នកបើកបររថយន្តឈ្នួល ម៉ូតូឌុប រ៉ឺម៉កកង់បី__ដែលមានឯកសណ្ឋាន"*
*"នឹងផ្តល់ជូន ១ពិន្ទុ ប្រសិនបើអាចបង្ហាញថា__មាន__"*

### លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យS២.៣តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) អ្នកបើកបររថយន្តឈ្នួល ម៉ូតូឌុប រ៉ឺម៉កកង់បី នៅក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ទីក្រុងបេក្ខភាព ដែលមានឯកសណ្ឋានត្រឹមត្រូវ។ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៣ គឺ៖

- ផ្តល់ព័ត៌មានអំពីចំនួនអ្នកបើកបររថយន្តឈ្នួល ម៉ូតូឌុប រ៉ឺម៉កកង់បីទាំងអស់(ដែលមាន)
- បង្ហាញអំពីលក្ខណៈសំគាល់ឯកសណ្ឋាន(ដែលមាន) សម្រាប់អ្នកបើកបរទាំងនោះ
- បង្ហាញថាអ្នកបើកបរយ៉ាងហោច៥០%នៃចំនួនសរុបមានឯកសណ្ឋាន។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យS២.៣ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| **តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ□២.៤** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |

[104] តារាងទី ២៧

| | | | |
|---|---|---|---|
| ១ | ព័ត៌មានអំពីចំនួនអ្នកបើកបរ(ដែលមាន) | ស្រង់ទិន្នន័យចំនួនអ្នកបើកបរ(ដែលមាន) ចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[105]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | លក្ខណៈសំគាល់ឯកសណ្ឋាន | រៀបចំជាលិខិតរដ្ឋបាលដែលមានសុពលភាពកំណត់ឯកសណ្ឋានសម្រាប់អ្នកបើកបរទាំងនោះ | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច<br>-រូបតាងរបស់ឯកសណ្ឋានទាំងនោះ |
| ៣ | អ្នកបើកបរដែលមានឯកសណ្ឋានមានយ៉ាងហោច៥០% | រៀបរាងជាលិខិតរដ្ឋបាលដែលមានសុពលភាពអាចបញ្ជាក់អំពីចំនួនអ្នកបើកបរទាំងអស់ដែលមានឯកសណ្ឋាន *(បញ្ជាក់ថាមានអ្នកបើកបរយ៉ាងហោច៥០%នៃចំនួនសរុបមានឯកសណ្ឋាន)* | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច |

## ៥. លក្ខណៈវិនិច្ឆ័យ ទ២.៥

*"តើមានការគិតគូរលើ**<u>ចំណតសម្រាប់រថយន្ត ម៉ូតូ កង់</u>**នៅតាម**<u>ដងវិថីសំខាន់ៗ</u>**នៃទីក្រុង/ខណ្ឌដែរឬទេ?"*
*"នឹងផ្តល់ជូន **១ពិន្ទុ** ប្រសិនបើអាចបង្ហាញថា**<u>មាន</u>**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ចំណតរថយន្ត ម៉ូតូ កង់ | ទីតាំងផ្សេងៗដែលអាចជា ចិញ្ចើមផ្លូវ ចំណែកផ្លូវ ឬទីតាំងចំណត (Parking lot) ដែលអាចចតរថយន្ត ម៉ូតូ កង់បាន។<br>ចំណតឯកជនមិនត្រូវបានរាប់បញ្ចូលទេសម្រាប់ករណីនេះ។ |
| ២ | ដងវិថីសំខាន់ៗ | សំដៅដល់ដងវិថីទាំងឡាយណាដែលស្ថិតនៅតាមទីកន្លែងដែលមានការឆ្លងកាត់ញឹកញាប់។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណៈវិនិច្ឆ័យទ២.៥តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) ចំណតរថយន្ត ម៉ូតូ កង់នៅតាមដងវិថីសំខាន់ៗនៅក្នុងទីក្រុងបេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺ៖

- ផ្តល់ព័ត៌មានអំពីចំនួននិងទីតាំងចំណតរថយន្ត ម៉ូតូ កង់ទាំងអស់(ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវនៅតាមចំណតទាំងនោះ
- បង្ហាញអំពីការដាក់ឲ្យដំណើរការជាក់ស្តែងនូវចំណតទាំងនោះ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណៈវិនិច្ឆ័យទ២.៥ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខ

[105] តារាងទី ១៩

ភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណៈវិនិច្ឆ័យ ២.៥ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
| ១ | ព័ត៌មានអំពីចំនួននិងទីតាំងចំណត(ដែលមាន) | ស្រង់ទិន្នន័យចំនួននិងទីតាំងចំណត(ដែលមាន) ចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[106]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបចំជាផែនទីដែលមានដៅចំនុចទីតាំងចំណតទាំងនោះ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវគ្រប់គ្រងនៅតាមចំណតទាំងនោះ | ចាត់តាំងអង្គភាពទទួលខុសត្រូវ ឬស្វែងរកដៃគូវិនិយោគ ឬក្រុមហ៊ុនធ្វើសហការរៀបចំនិងគ្រប់គ្រងដំណើរការការងារនេះ | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលអាចបញ្ជាក់អំពីវត្តមានអ្នកទទួលខុសត្រូវនៅតាមចំណតទាំងនោះ |
| ៣ | ដំណើរការជាក់ស្តែងនូវចំណតទាំងនោះ | រៀបចំជាវិធាន ឬបទបញ្ជា ឬលិខិតបទដ្ឋាន ផ្សេងៗដែលមានតម្លៃស្មើស្តីពីការប្រើប្រាស់ចំណតទាំងនោះ | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច |

## ៦. លក្ខណៈវិនិច្ឆ័យ S ២.៦

*"តើមានការគិតគូរលើ**ចំណតសំរាប់ថ្ងៃគូ និងថ្ងៃសេស**នៅតាម**វិថីសំខាន់ៗ**នៃទីក្រុងដែរឬទេ?"*
*"នឹងផ្តល់ជូន **១ពិន្ទុ** ប្រសិនបើអាចបង្ហាញថា**មាន**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ចំណតសំរាប់ថ្ងៃគូនិងថ្ងៃសេស | សំដៅដល់ការអនុវត្តក្នុងការរៀបចំចំណែកថ្នល់ណាមួយសម្រាប់បំរើជាកន្លែងសម្រាប់ចតយានជំនិះផ្សេងៗ ដោយមានការបែងចែកការអនុញ្ញាតឲ្យចតឆ្លាស់គ្នារវាងថ្ងៃគូ និងថ្ងៃសេស។ |
| ២ | ដងវិថីសំខាន់ៗ | សំដៅដល់ដងវិថីទាំងឡាយណាដែលស្ថិតនៅតាមទីកន្លែងដែលមានការឆ្លងកាត់ញឹកញាប់។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យS២.៦តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) ចំណតសម្រាប់ថ្ងៃគូនិងថ្ងៃសេសនៅក្នុងទីក្រុងបេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

[106] តារាងទី ១២

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៣ គឺ៖

- ផ្តល់ព័ត៌មានអំពីចំនួននិងទីតាំងចំណតសម្រាប់ថ្ងៃធម្មតានិងថ្ងៃសេសទាំងអស់(ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវនៅតាមចំណតទាំងនោះ
- បង្ហាញអំពីការដាក់ឲ្យដំណើរការដាក់ស្តែងនូវចំណតទាំងនោះ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យ៦២.៥ក៏ដូចជាការណែនាំដល់បេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ□២.៦ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីចំនួននិងទីតាំងចំណត(ដែលមាន) | ស្រង់ទិន្នន័យចំនួននិងទីតាំងចំណត(ដែលមាន)ចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[107]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបចំជាផែនទីដែលមានដៅចំនុចទីតាំងចំណតទាំងនោះ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវគ្រប់គ្រងនៅតាមចំណតទាំងនោះ | ចាត់តាំងអង្គភាពទទួលខុសត្រូវ ឬស្វែងរកដៃគូវិនិយោគ ឬក្រុមហ៊ុនធ្វើសហការរៀបចំនិងគ្រប់គ្រងដំណើរការការងារនេះ | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលអាចបញ្ជាក់អំពីវត្តមានអ្នកទទួលខុសត្រូវនៅតាមចំណតទាំងនោះ |
| ៣ | ដំណើរការដាក់ស្តែងនូវចំណតទាំងនោះ | រៀបចំជាវិធាន ឬបទបញ្ជា ឬលិខិតបទដ្ឋានផ្សេងៗដែលមានតម្លៃស្មើស្តីពីការប្រើប្រាស់ចំណតទាំងនោះ | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច |

## S៣.សូចនាកររលំអិតនៃសកម្មភាពបង្ការ និងទប់ស្កាត់អំពើល្មើស

**សូចនាកររលម្អិតនៃសកម្មភាពបង្ការ និងទប់ស្កាត់អំពើល្មើស** គឺជាវិធានការត្រួតពិនិត្យ ទប់ស្កាត់និងក្រើនរំលឹកដល់ភ្ញៀវទេសចរ និងប្រជាជនដែលរស់នៅក្នុងតំបន់មួយឲ្យជៀសវាងនូវទង្វើជាបទល្មើសដែលអាចធ្វើឲ្យប៉ះពាល់ដល់បុគ្គលដូចជាការប៉ះពាល់ដល់រូបរាង្គកាយ (ការប្រើប្រាស់សារធាតុញៀន ការហាមឃាត់ជួញដូរផ្លូវភេទជាដើម...) និងការប៉ះពាល់ដល់សតិអារម្មណ៍ (ការរើសអើងគ្រប់រូបភាព...)។ ជាទូទៅការបញ្ជ្រាបការយល់ដឹងអំពីសកម្មភាពបង្កា និងទប់ស្កាត់អំពើល្មើសដល់ប្រតិបត្តិករទេសចរណ៍អាចធ្វើតាម លើវិធីសាស្ត្រផ្សេងៗជាអាទិ៍៖ ការបិតប្រកាសផ្សាយជាសាធារណៈ(បដា/ខិតប័ណ្ណផ្សព្វផ្សាយ ការពិនិត្យអត្តសញ្ញាណរបស់ភ្ញៀវទេសចរដែលចូលមកទស្សនាការដាក់ពង្រាយកម្លាំងនៅតាមតំបន់ដែលអាចនឹងមានបទល្មើសខាងលើជាយថាហេតុ...ជាដើម។

ទីក្រុង បេក្ខភាពនឹងផ្តល់ឯកសារផែនការសកម្មភាពទាំងអស់ទាក់ទងនឹងការបង្កានិងទប់ស្កាត់អំពើល្មើសដែល

[107] តារាងទី ១២

បានរៀបរាប់ខាងលើដើម្បីឲ្យ **គ.ជ.វ.ទ.**សម្រេចចិត្តផ្តល់ពិន្ទុដោយតម្លាភាព។

តារាងខាងក្រោមនេះបង្ហាញអំពីលក្ខណវិនិច្ឆ័យទាំង **៣** នៃសូចនាករលំអិតទ៣ និងជាកម្មវត្ថុនៃការពិភាក្សាដើម្បីធ្វើការណែនាំដល់ទីក្រុងបេក្ខភាព។

| លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| ទ៣.១ សកម្មភាពបង្ការនិងទប់ស្កាត់អំពើល្មើសទាក់ទងនឹងការជួញដូរផ្លូវភេទ (មានការបិតផ្សាយការត្រួតពិនិត្យលិខិតសម្គាល់ខ្លួនពេលចូលសណ្ឋាគារជាដើម) | មាន-មិនមាន | ១ |
| ទ៣.២សកម្មភាពបង្ការ និងទប់ស្កាត់អំពើល្មើសទាក់ទងនឹងការជួញដូរគ្រឿងញៀន (មានការបិតផ្សាយការត្រួតពិនិត្យលិខិតសម្គាល់ខ្លួនពេលចូលសណ្ឋាគារជាដើម) | មាន-មិនមាន | ១ |
| ទ៣.៣សកម្មភាពបង្ការ និងទប់ស្កាត់អំពើល្មើសចោរកម្ម | មាន-មិនមាន | ១ |

*(ផ្តល់ពិន្ទុ ៣/១៤ នៃពិន្ទុសរុបរបស់សូចនាករគោលនៃសុវត្ថិភាពនិងអនាម័យទីក្រុង)*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណៈវិនិច្ឆ័យទ៣.១

*"__សកម្មភាពបង្ការនិងទប់ស្កាត់អំពើល្មើសទាក់ទងនឹងការជួញដូរផ្លូវភេទ__(មានការបិតផ្សាយការត្រួតពិនិត្យលិខិតសម្គាល់ខ្លួនពេលចូលសណ្ឋាគារជាដើម)"*

*"នឹងផ្តល់ជូន **១ពិន្ទុ** ប្រសិនបើអាចបង្ហាញថា__មាន__"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | សកម្មភាពបង្ការនិងទប់ស្កាត់អំពើល្មើសទាក់ទងនឹងការជួញដូរផ្លូវភេទ | សំដៅដល់គ្រប់សកម្មភាពទាំងឡាយណាដែលត្រូវបានដាក់ចេញ ឬគាំទ្រដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបង្ការ ទប់ស្កាត់ ឬលុបបំបាត់ចោលនូវការជួញដូរផ្លូវភេទ។<br><br>សកម្មភាពទាំងនោះទាំងនោះអាចជា៖ ការត្រួតពិនិត្យលើអត្តសញ្ញាណប័ណ្ណរបស់ភ្ញៀវដែលប្រើប្រាស់សេវាស្នាក់នៅ ការចុះត្រួតពិនិត្យដោយផ្ទាល់ ការជំរុញការសហការរបស់ប្រតិបត្តិករទេសចរណ៍ឲ្យជូនដំណឹងមកមន្ត្រីមានសមត្ថកិច្ចក្នុងករណីសង្ស័យ។ល។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យទ៣.១តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"*ប្រសិទ្ធភាព*"** វិធានការឬយន្តការនៃការបង្ការនិងទប់ស្កាត់ការជួញដូរផ្លូវភេទនៅក្នុងទីក្រុងបេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺ៖

- បង្ហាញអំពីវិធានការដែលបានដាក់ចេញ ឬសកម្មភាពដែលបានអនុវត្តកន្លងមក
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវអនុវត្តការងារនេះ
- បង្ហាញអំពីសកម្មភាពអនុវត្តជាក់ស្តែងរបស់អ្នកដែលទទួលខុសត្រូវអនុវត្តការងារនេះ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យS៣.១ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ□៣.១ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | វត្តមានវិធានការបង្ការ ទប់ស្កាត់ការជួញដូរផ្លូវភេទ | រៀបចំជាវិធាន ឬបទបញ្ជា ឬលិខិតបទដ្ឋានផ្សេងៗដែលមានតម្លៃស្មើស្តីពីការអនុវត្តការដាក់ទោសផ្សេងៗដល់ការជួញដូរផ្លូវភេទ ឬដែលមានកម្មវត្ថុសំដៅបង្ការ ទប់ស្កាត់អំពើទាំងនោះ | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវអនុវត្ត | រៀបចំជាវិធាន ឬបទបញ្ជា ឬលិខិតបទដ្ឋានផ្សេងៗដែលមានតម្លៃស្មើស្តីពីការចាត់តាំងអង្គភាពមួយដែលមានសមាសភាពនិងតួនាទីភារកិច្ចគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចការងារនេះ | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលអាចបញ្ជាក់អំពីវត្តមានអ្នកទទួលខុសត្រូវអនុវត្តការងារ |
| ៣ | សកម្មភាពអនុវត្តជាក់ស្តែង | ធ្វើការបែងចែកជាក្រុមការងារតូចៗសម្រាប់ចុះត្រួតពិនិត្យ (ក្រុមល្បាត) | -បញ្ជីរាយនាមក្រុមការងារទាំងនោះដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុងឬអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបចំជាតារាងផែនការសកម្មភាព | -តារាងផែនការសកម្មភាព[108]របស់អង្គភាពដែលទទួលខុសត្រូវការងារនេះ |
| | *និង* | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច<br>- រូបថត រូបភាពខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែង |

## ២. លក្ខណវិនិច្ឆ័យ S ៣.២

*"<u>សកម្មភាពបង្ការនិងទប់ស្កាត់អំពើល្មើសទាក់ទងនឹងការជួញដូរគ្រឿងញៀន</u>(មានការបិតផ្សាយការត្រួតពិនិត្យលិខិតសម្គាល់ខ្លួនពេលចូលសណ្ឋាគារជាដើម)"*

*"នឹងផ្តល់ជូន **១ពិន្ទុ** ប្រសិនបើអាចបង្ហាញថា<u>**មាន**</u>"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|

[108] តារាងទី ៤២

| | | |
|---|---|---|
| ១ | សកម្មភាពបង្ការនិងទប់ស្កាត់អំពើល្មើសទាក់ទងនឹងការជួញដូរគ្រឿងញៀន | សំដៅដល់គ្រប់សកម្មភាពទាំងឡាយណាដែលត្រូវបានដាក់ចេញ ឬគាំទ្រដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបង្ការ ទប់ស្កាត់ ឬលុបបំបាត់ចោលនូវការជួញដូរគ្រឿងញៀន។<br>សកម្មភាពទាំងនោះអាចជា៖ ការចុះត្រួតពិនិត្យដោយផ្ទាល់ ការជំរុញការសហការរបស់ប្រតិបត្តិករទេសចរណ៍និងសាធារណជនឲ្យជូនដំណឹងមកមន្ត្រីមានសមត្ថកិច្ចក្នុងករណីសង្ស័យ។ល។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យ៣.២តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះគឺ **"ប្រសិទ្ធិភាព"** វិធានការឬយន្តការនៃការបង្ការនិងទប់ស្កាត់ការជួញដូរគ្រឿងញៀននៅក្នុងទីក្រុងបេក្ខភាព។ ទីក្រុងបេក្ខភាពត្រូវបង្ហាញលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.**ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺ៖

- បង្ហាញអំពីវិធានការដែលបានដាក់ចេញ ឬសកម្មភាពដែលបានអនុវត្តកន្លងមក
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវអនុវត្តការងារនេះ
- បង្ហាញអំពីសកម្មភាពអនុវត្តជាក់ស្តែងរបស់អ្នកដែលទទួលខុសត្រូវអនុវត្តការងារនេះ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យ៣.២ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០៣** ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ៣.២ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | វត្តមានវិធានការបង្ការ ទប់ស្កាត់ការជួញដូរគ្រឿងញៀន | រៀបចំជាវិធាន ឬបទបញ្ជា ឬលិខិតបទដ្ឋានផ្សេងៗដែលមានតម្លៃស្មើស្តីពីការអនុវត្តការដាក់ទោសផ្សេងៗដល់ការជួញដូរគ្រឿងញៀន ឬដែលមានកម្មវត្ថុសំដៅបង្ការ ទប់ស្កាត់អំពើទាំងនោះ | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវអនុវត្ត | រៀបចំជាវិធាន ឬបទបញ្ជា ឬលិខិតបទដ្ឋានផ្សេងៗដែលមានតម្លៃស្មើស្តីពីការចាត់តាំងអង្គភាពមួយដែលមានសមាសភាពនិងតួនាទីភារកិច្ចគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចការងារនេះ | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលអាចបញ្ជាក់អំពីវត្តមានអ្នកទទួលខុសត្រូវអនុវត្តការងារ |
| ៣ | សកម្មភាពអនុវត្តជាក់ស្តែង | ធ្វើការបែងចែកជាក្រុមការងារតូចៗសម្រាប់ចុះត្រួតពិនិត្យ (ក្រុមល្បាត) | -បញ្ជីរាយនាមក្រុមការងារទាំងនោះដែលមានការបញ្ជាក់ពីអាជ្ញាធរក្រុង/ខណ្ឌ ឬអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបចំជាតារាងផែនការសកម្មភាព | -តារាងផែនការសកម្មភាព[109]របស់អង្គភាពដែលទទួលខុសត្រូវការងារនេះ |
| | ***និង*** | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា |

[109] តារាងទី ៤២

| | | | |
|---|---|---|---|
| | | | និងការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច<br>- រូបថត រូបភាពខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែង |

## ៣. លក្ខណវនិច្ឆ័យទ៣.៣

*"សកម្មភាពបង្ការ និងទប់ស្កាត់អំពើល្មើសចោរកម្ម"*
*"នឹងផ្តល់ជូន **១ពិន្ទុ** ប្រសិនបើអាចបង្ហាញថា**មាន**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | សកម្មភាពបង្ការ និងទប់ស្កាត់អំពើល្មើសចោរកម្ម | សំដៅដល់គ្រប់សកម្មភាពទាំងឡាយណាដែលត្រូវបានដាក់ចេញ ឬគាំទ្រដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបង្ការ ទប់ស្កាត់ ឬលុបបំបាត់ចោលនូវអំពើចោរកម្ម។<br>សកម្មភាពទាំងនោះទាំងនោះអាចជា៖ ការចុះត្រួតពិនិត្យដោយផ្ទាល់ ការជំរុញការសហការរបស់ប្រតិបត្តិករទេសចរណ៍និងសាធារណជន។ល។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យទ៣.៣តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះគឺ **"ប្រសិទ្ធភាព"** វិធានការឬយន្តការនៃការបង្ការនិងទប់ស្កាត់អំពើចោរកម្មនៅក្នុងទីក្រុងបេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៣ គឺ៖

- បង្ហាញអំពីវិធានការដែលបានដាក់ចេញ ឬសកម្មភាពដែលបានអនុវត្តកន្លងមក
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវអនុវត្តការងារនេះ
- បង្ហាញអំពីសកម្មភាពអនុវត្តជាក់ស្តែងរបស់អ្នកដែលទទួលខុសត្រូវអនុវត្តការងារនេះ។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យទ៣.៣ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវនិច្ឆ័យ□៣.៣ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | វត្តមានវិធានការបង្ការ ទប់ស្កាត់អំពើចោរកម្ម | រៀបចំជាវិធាន ឬបទបញ្ជា ឬលិខិតបទដ្ឋានផ្សេងៗដែលមានតម្លៃស្មើស្តីពីការអនុវត្តការដាក់ទោសផ្សេងៗដល់អំពើចោរកម្ម ឬដែលមានកម្មវត្ថុសំដៅបង្ការ ទប់ស្កាត់អំពើទាំងនោះ | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច |

| | | | |
|---|---|---|---|
| ២ | វត្តមានអ្នកទទួលខុសត្រូវអនុវត្ត | រៀបចំជាវិធាន ឬបទបញ្ជា ឬលិខិតបទដ្ឋានផ្សេងៗ ដែលមានតម្លៃស្មើស្តីពីការចាត់តាំងអង្គភាពមួយ ដែលមានសមាសភាពនិងតួនាទីភារកិច្ចគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចការងារនេះ | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋាន ដែលមានតម្លៃស្មើដែលអាចបញ្ជាក់អំពីវត្តមានអ្នកទទួលខុសត្រូវអនុវត្តការងារ |
| ៣ | សកម្មភាពអនុវត្តជាក់ស្តែង | ធ្វើការបែងចែកជាក្រុមការងារតូចៗសម្រាប់ចុះត្រួតពិនិត្យ (ក្រុមល្បាត) | -បញ្ជីរាយនាមក្រុមការងារទាំងនោះដែលមានការបញ្ជាក់ពីអាជ្ញាធរក្រុង/ខណ្ឌ ឬអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបចំជាតារាងផែនការសកម្មភាព | -តារាងផែនការសកម្មភាព[110]របស់អង្គភាពដែលទទួលខុសត្រូវការងារនេះ |
| | ***និង*** | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច<br>- រូបថត រូបភាពខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែង |

# ផ្នែកទី៧
# សូចនាករគោលនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍

ហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ គឺជាធាតុផ្សំដែលមិនអាចខ្វះបានក្នុងគោលនយោបាយអភិវឌ្ឍទីក្រុង។ ជាការពិតណាស់ ភាពសំបូរបែបនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាផ្សេងៗ ពិតជាចូលរួមសម្រួលដល់ការធ្វើដំណើរ និងដឹកជញ្ជូនព្រមទាំងបំពេញសេចក្តីត្រូវការរបស់ភ្ញៀវទេសចរ។ ទន្ទឹមនឹងនោះ ការអភិវឌ្ឍវិស័យទេសចរណ៍ត្រូវពឹងផ្អែកយ៉ាង

[110] តារាងទី ៤២

សំខាន់លើហេដ្ឋារចនាសម្ព័ន្ធ ការតភ្ជាប់ និងភាពគ្រប់គ្រាន់នៃសម្បទាទ្រទ្រង់ផ្សេងៗ។ ផ្ទុយមកវិញប្រសិនបើអ្វីៗដូចបានរ៉ាយរ៉ាប់ខាងលើនេះមានការខ្វះខាត ឬរអាក់រអួលដោយប្រការណាមួយនោះ វាក៏អាចបណ្តាលឲ្យមានការរាំងស្ទះដល់ការអភិវឌ្ឍក្រុងក៏ដូចជាការអភិវឌ្ឍវិស័យទេសចរណ៍របស់ក្រុងនោះផងដែរ។

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ មិនត្រឹមតែចូលរួមដល់ការផ្តល់ភាពងាយស្រួលដល់ការចូលទៅកាន់គោលដៅទេសចរណ៍នានាប៉ុន្តែទេថែមទាំងអាចជាការទាក់ទាញទេសចរណ៍មួយផងដែរ។ ក្នុងន័យនេះ ការយកចិត្តទុកដាក់លើការរៀបចំហេដ្ឋា-រចនាសម្ព័ន្ធ និងគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគឺមានសារៈសំខាន់យ៉ាងខ្លាំងហើយ នេះក៏ជាកម្មវត្ថុមួយសម្រាប់សូចនាករគោលនេះផងដែរ។

សូចនាករគោលស្តីពីហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍នេះជាប្រធានបទមួយដ៏មានសារៈសំខាន់សម្រាប់ការប្រឡងប្រណាំងទីក្រុងស្អាត (ផ្តល់ពិន្ទុសរុបរួមមាន១៤ពិន្ទុ)។ សូចនាករគោលដែលត្រូវបានរៀបរាង មកនេះមានគោលបំណងបង្ហាញអំពីអត្ថប្រយោជន៍ និងទំនាក់ទំនងយ៉ាងស្អិតរមួតរវាងហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងការអភិវឌ្ឍវិស័យទេសចរណ៍។

ទន្ទឹមនឹងនោះ ភាពពេញចិត្តរបស់ភ្ញៀវទេសចរត្រូវបានរាប់បញ្ចូលជាសូចនាករលំអិត នៃសូចនាករគោលនេះដោយហេតុថា នេះជាអ្វីដែលទីក្រុងបេក្ខភាពត្រូវតែយកចិត្តទុកដាក់ដើម្បីទាក់ទាញភ្ញៀវទេសចរ ដូច្នេះ ការវាស់ស្ទង់អំពីកម្រិតពេញចិត្តរបស់ភ្ញៀវទេសចរចំពោះទីក្រុងបេក្ខភាពត្រូវតែធ្វើជាប្រចាំត្រីមាស ដើម្បីស្វែងយល់អំពីចំនុចល្អ កំហុស ឬកង្វះខាតដែលមានទាក់ទងនឹងការអនុវត្តរបស់ទីក្រុងបេក្ខភាព។ ប្រសិនបើ ទីក្រុងបេក្ខភាពអាចសម្រេចបាននូវវត្ថុបំណងរបស់សូច-នាករគោលទី៧នេះ ការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងដែនសមត្ថកិច្ចខ្លួននឹងទទួលបាននូវភាពស្រស់ស្រាយជាងមុន និងរឹតតែបញ្ចេញនូវភាពទាក់ទាញរបស់ខ្លួនដល់ភ្ញៀវទេសចរទាំងឡាយឲ្យចូលមកទស្សនាកំសាន្តកាន់តែច្រើនឡើងៗថែមទៀត។

# T១.សូចនាករលំអិតនៃហេដ្ឋារចនាសម្ព័ន្ធទីក្រុង

## កម្មវត្ថុនៃសូចនាករលំអិត T១

សូចនាករលម្អិត ស្តីពីហេដ្ឋារចនាសម្ព័ន្ធទីក្រុងមានបំណងចង់ស្វែងយល់ឲ្យកាន់តែច្បាស់អំពីហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាព និងក៏ដើម្បីផ្ទៀងផ្ទាត់មើលថា តើទីក្រុងបេក្ខភាពបានគិតគូរដល់ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជួយសម្រួលដល់លក្ខខណ្ឌរស់នៅរបស់ប្រជាជនឬទេ? ក្នុងន័យនេះ ចលនាប្រឡងប្រណាំងទីក្រុងស្អាតមានគោលបំណងលើកទឹកចិត្តដល់ទីក្រុងបេក្ខភាពមានការយកចិត្តទុកលើការដាក់រៀបចំហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ (ទាំងផ្នែករឹង និងផ្នែកទន់)។

តារាងខាងក្រោមនេះបង្ហាញអំពីលក្ខណវិនិច្ឆ័យទាំង ៦ នៃសូចនាករលម្អិតT១ និងជាកម្មវត្ថុនៃការពិភាក្សាដើម្បីធ្វើការណែនាំដល់ទីក្រុងបេក្ខភាព។

| លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| T១.១. តើមាន**<u>ផ្លូវថ្នល់</u>**(ផ្លូវកៅស៊ូ ផ្លូវបេតុង)គ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង? | យ៉ាងហោចណាស់២៥% នៃផ្ទៃទីក្រុង | ១ |
| T១.២. តើមាន**<u>មតេយ្យសាលា</u>** ឬ**<u>សាលាបឋមសិក្សា</u>**គ្រប់គ្រាន់ដែរឬទេ នៅតាមទីក្រុង? | ៥០០ម៉ែត្រពីទីប្រជុំជន | ១ |
| T១.៣. តើមាន**<u>អនុវិទ្យាល័យ</u>**គ្រប់គ្រាន់ដែរ ឬទេនៅតាមទីក្រុង? | ១០០០ម៉ែត្រពីទីប្រជុំជន | ១ |
| T១.៤. តើមាន**<u>វិទ្យាល័យ</u>**គ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង? | ១៥០០ម៉ែត្រពីទីប្រជុំជន | ១ |
| T១.៥. តើមាន**<u>សួនកំសាន្តសម្រាប់កុមារ</u>**គ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង? | យ៉ាងហោច១០%នៃតំបន់សាងសង់បាន | ១ |
| T១.៦. តើមាន**<u>ទីតាំងសំរាប់លេងកីឡា</u>**គ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង? | យ៉ាងហោច១០%នៃតំបន់សាងសង់បាន | |

*(ផ្តល់ពិន្ទុ ៦/១៤ នៃពិន្ទុសរុបរបស់សូចនាករគោលនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារទេសចរណ៍)*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណៈវិនិច្ឆ័យ T១.១

*"តើមាន**<u>ផ្លូវថ្នល់</u>**(ផ្លូវកៅស៊ូ ផ្លូវបេតុង)គ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង?"*
*"នឹងផ្តល់ជូន **១ពិន្ទុ** ប្រសិនបើអាចបង្ហាញថា**<u>មានយ៉ាងហោចណាស់គ្របដណ្តប់លើផ្ទៃដីក្រុង២៥%</u>**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ផ្លូវថ្នល់ | សំដៅដល់ផ្លូវថ្នល់ទាំងឡាយ (គ្រប់ប្រភេទរួមមានដូចជា៖ ផ្លូវជាតិ មហាវិថី វិថី ផ្លូវលំ...) ដែលជាផ្លូវសាធារណៈដែលមានក្នុងដែនសមត្ថកិច្ចរដ្ឋបាលរបស់ទីក្រុងបេក្ខភាព។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យT១.១តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ប្រវែង"** (បរិមាណ) ផ្លូវគមនាគមន៍សម្រាប់ប្រើប្រាស់នៅក្នុងទីក្រុងបេក្ខភាព។ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួន ដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.**ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០២** គឺៈ

- ផ្តល់ព័ត៌មានអំពីចំនួនប្រវែង និងទំហំទ្រូងផ្លូវថ្នល់ទាំងអស់(ដែលមាន)
- បង្ហាញថាទីក្រុងបេក្ខភាពមានផ្លូវថ្នល់ដែលជាផ្លូវកៅស៊ូ ឬផ្លូវបេតុងគ្របដណ្តប់លើផ្ទៃដីក្រុងយ៉ាងហោច២៥% នៃទំហំផ្ទៃដីសរុប។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យT១.១ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០២** ខាងលើ។

| **តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ១.១** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីចំនួនប្រវែង និងទំហំផ្លូវថ្នល់ *(ទាំងមានស្រាប់ និង គម្រោង)* | ស្រង់ទិន្នន័យផ្លូវថ្នល់ (ទាំងមានស្រាប់ និងស្ថិតនៅជាគម្រោងស្ថាបនា) ចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[111]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបរាងជាផែនទីកំណត់ទីតាំងផ្លូវថ្នល់ (ទាំងមានស្រាប់ និងស្ថិតនៅជាគម្រោងស្ថាបនា) ដែលមានក្នុងដែនសមត្ថកិច្ចរដ្ឋបាលគ្រប់គ្រងរបស់ទីក្រុងបេក្ខភាព | -ផែនទីរដ្ឋបាលបង្ហាញទីតាំងមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | មានផ្លូវថ្នល់ដែលជាផ្លូវកៅស៊ូ ឬផ្លូវបេតុងយ៉ាងហោចគ្របដណ្តប់លើផ្ទៃដី ២៥%នៃផ្ទៃដីសរុបទីក្រុង | រៀបរាងជាលិខិតរដ្ឋបាលដែលមានសុពលភាពអាចបញ្ជាក់អំពីទំហំផ្លូវថ្នល់ដែលជាផ្លូវកៅស៊ូ និងផ្លូវបេតុងដែលមានស្រាប់ និងដែលស្ថិតនៅក្នុងគម្រោងស្ថាបនា *(បញ្ជាក់ថាមានយ៉ាងហោចណាស់២៥% នៃផ្ទៃដីសរុបទីក្រុង)* | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច |

## ២. លក្ខណវិនិច្ឆ័យ T១.២

*"តើមាន**មត្តេយ្យសាលា ឬសាលាបឋមសិក្សា**គ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង?"*

*"នឹងទទួលបាន **១ពិន្ទុ**ប្រសិនបើ**មានយ៉ាងហោចណាស់ចំនួន ១ក្នុងបរិវេណ ៥០០ម៉ែត្រ ពីទីប្រជុំជន**"*

[111] តារាងទី ០៣

## ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | មតេយ្យសាលា | សំដៅដល់គ្រឹះស្ថានអប់រំ (សាធារណៈ ឬឯកជន) ដែលផ្តល់ការអប់រំ (សេវាសាធារណៈ ឬឯកជន) ថ្នាក់ក្រោមបឋមដល់សាធារណជនទូទៅ។ |
| ២ | សាលាបឋមសិក្សា | សំដៅដល់គ្រឹះស្ថានអប់រំ (សាធារណៈ ឬឯកជន) ដែលផ្តល់ការអប់រំ (សេវាសាធារណៈ ឬឯកជន) ថ្នាក់បឋមសិក្សា (ថ្នាក់ទី១ដល់ថ្នាក់ទី៦)<br>ឬដែលមានតំលៃស្មើដល់សាធារណជនទូទៅ។ |
| ៣ | ទីប្រជុំជន | ការកំណត់ទីប្រជុំជនអាចធ្វើឡើងតាមវិធី ២យ៉ាងដូចខាងក្រោម៖<br>**<u>របៀបទី១៖</u>**<br>-ជាសង្កាត់ដែលសាលាក្រុង/ខណ្ឌតាំងនៅ<br>**<u>របៀបទី២៖</u>**<br>-ជាសង្កាត់ដែលមានប្រជាជនរស់នៅចាប់ពី៣០ ០០០នាក់ឡើងទៅ និង<br>-មានប្រជាជនលើសពី៥០%ដែលប្រកបរបរមិនមែនកសិកម្ម និង<br>-មានដង់ស៊ីតេប្រជាជនចាប់ពី១០០នាក់/គម²ឡើងទៅ។<br>បញ្ជាក់៖ ការកំណត់ទីប្រជុំជនតាមរបៀបទីពីរ អាចបណ្តាលឲ្យមានទីប្រជុំជនច្រើននៅក្នុងទីក្រុងបេក្ខភាពតែមួយ។ ទីក្រុងបេក្ខភាពអាចជ្រើសយករបៀបកំណត់តែមួយគត់ក្នុងចំណោមរបៀបទាំងពីរខាងលើ សម្រាប់ការប្រឡងប្រណាំងមួយលើកៗ។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យT១.២តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) មតេយ្យសាលា ឬសាលាបឋមសិក្សានៅក្នុងទីក្រុងបេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួន ដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.**ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០២** គឺ៖

- ផ្តល់ព័ត៌មានអំពីចំនួន និងទីតាំងមតេយ្យសាលា និងសាលាបឋមសិក្សាទាំងអស់(ដែលមាន)
- បង្ហាញថាទីក្រុងបេក្ខភាពមានមតេយ្យសាលា និងសាលាបឋមសិក្សាគ្រប់គ្រាន់ (យ៉ាងហោចណាស់មាន១ក្នុងបរិវេណ៥០០ម៉ែត្រពីទីប្រជុំជន)។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យT១.២ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០២** ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវនិច្ឆ័យ□១.២ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីមតេយ្យសាលា និងសាលាបឋមសិក្សា*(ទាំង* | ស្រង់ទិន្នន័យមតេយ្យសាលា និងសាលាបឋមសិក្សា (ទាំងមានស្រាប់ និងស្ថិតនៅ | -តារាងសម្រង់ស្ថិតិ[112]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |

[112] តារាងទី ០៤

| | | | |
|---|---|---|---|
| | *មានស្រាប់ និង គម្រោង )* | ជាគម្រោងសាងសង់) ចុះក្នុងតារាងគំរូមួយ | |
| ២ | មានមតេយ្យសាលា និងសាលាបឋមសិក្សាយ៉ាងហោច១ក្នុងបរិវេណ៥០០ម៉ែត្រពីទីប្រជុំជន | រៀបរាងជាលិខិតរដ្ឋបាលដែលមានសុពលភាពអាចបញ្ជាក់អំពីចំនួនមតេយ្យសាលា និងសាលាបឋមសិក្សាដែលមានស្រាប់ និងដែលស្ថិតនៅក្នុងគម្រោងស្ថាបនា *(បញ្ជាក់ថាមានយ៉ាងហោចណាស់១ក្នុងបរិវេណ៥០០ម៉ែត្រពីទីប្រជុំជន)* | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច |

### ៣. លក្ខណៈវិនិច្ឆ័យT១.៣

*"តើមាន**<u>អនុវិទ្យាល័យ</u>**គ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង?"*

*"នឹងផ្តល់ជូន **១ពិន្ទុ**ប្រសិនបើអាចបង្ហាញថា**<u>មានយ៉ាងហោចណាស់មានចំនួន ១ ក្នុងបរិវេណ ១០០០ម៉ែត្រ ពីទីប្រជុំជន</u>**"*

## ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | អនុវិទ្យាល័យ | សំដៅដល់គ្រឹះស្ថានអប់រំ (សាធារណៈ ឬឯកជន) ដែលផ្តល់ការអប់រំ (សេវាសាធារណៈ ឬឯកជន) ថ្នាក់មធ្យមសិក្សាបឋមភូមិ ឬដែលមានតំលៃស្មើ ដល់សាធារណជនទូទៅ។ |
| ២ | ទីប្រជុំជន | ការកំណត់ទីប្រជុំជនអាចធ្វើឡើងតាមវិធី ២យ៉ាងដូចខាងក្រោម៖<br>**<u>របៀបទី១៖</u>**<br>-ជាសង្កាត់ដែលសាលាក្រុង/ខណ្ឌតាំងនៅ<br>**<u>របៀបទី២៖</u>**<br>-ជាសង្កាត់ដែលមានប្រជាជនរស់នៅចាប់ពី៣០ ០០០នាក់ឡើងទៅ និង<br>-មានប្រជាជនលើសពី៥០%ដែលប្រកបរបរមិនមែនកសិកម្ម និង<br>-មានដង់ស៊ីតេប្រជាជនចាប់ពី១០០នាក់/គម$^{២}$ឡើងទៅ។<br>បញ្ជាក់៖ ការកំណត់ទីប្រជុំជនតាមរបៀបទីពីរ អាចបណ្តាលឲ្យមានទីប្រជុំជនច្រើននៅក្នុងទីក្រុងបេក្ខភាពតែមួយ។ ទីក្រុងបេក្ខភាពអាចជ្រើសយករបៀបកំណត់តែមួយគត់ក្នុងចំណោមរបៀបទាំងពីរខាងលើ សម្រាប់ការប្រឡងប្រណាំងមួយលើកៗ។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យT១.៣តម្រូវឲ្យបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.រ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) អនុវិទ្យាល័យនៅក្នុងទីក្រុងបេក្ខភាព។ បេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួន ដើម្បីជាទុនសម្រាប់ឲ្យគណៈកម្មាធិការជាតិធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០២** គឺ៖

- ផ្តល់ព័ត៌មានអំពីចំនួន និងទីតាំងអនុវិទ្យាល័យទាំងអស់ដែលមាន
- បង្ហាញថាទីក្រុងបេក្ខភាពមានអនុវិទ្យាល័យគ្រប់គ្រាន់ (យ៉ាងហោចណាស់មាន១ក្នុងបរិវេណ១០០០ម៉ែត្រពីទីប្រជុំជន)។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យT១.៣ក៏ដូចជាការណែនាំដល់បេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០២ ខាងលើ។

| **តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ□១.៣** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីអនុវិទ្យាល័យ *(ទាំងមានស្រាប់ និងគម្រោង)* | ស្រង់ទិន្នន័យអនុវិទ្យាល័យ (ទាំងមានស្រាប់ និងស្ថិតនៅជាគម្រោង សាងសង់) ចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[113]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | មានអនុវិទ្យាល័យយ៉ាងហោច១ក្នុងបរិវេណ១០០០ម៉ែត្រពីទីប្រជុំជន | រៀបរាងជាលិខិតរដ្ឋបាលដែលមានសុពលភាពអាចបញ្ជាក់អំពីចំនួនអនុវិទ្យាល័យដែលមានស្រាប់ និងដែលស្ថិតនៅក្នុងគម្រោងស្ថាបនា*(បញ្ជាក់ថាមានយ៉ាងហោចណាស់១ក្នុងបរិវេណ១០០០ម៉ែត្រពីទីប្រជុំជន)* | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច |

## ៤. លក្ខណវិនិច្ឆ័យT ១.៤

*"តើមាន__វិទ្យាល័យ__គ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង?"*
*"នឹងផ្តល់ជូន **១ពិន្ទុ**ប្រសិនបើអាចបង្ហាញថា__**មានយ៉ាងហោចណាស់មានចំនួន ១ ក្នុងបរិវេណ ១៥០០ម៉ែត្រ ពីទីប្រជុំជន**__"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| **ល.រ** | **ពាក្យគន្លឹះ** | **សេចក្តីពន្យល់** |
|---|---|---|
| ១ | វិទ្យាល័យ | សំដៅដល់គ្រឹះស្ថានអប់រំ (សាធារណៈ ឬឯកជន) ដែលផ្តល់ការអប់រំ (សេវាសាធារណៈ ឬឯកជន) ថ្នាក់មធ្យមសិក្សាទុតិយភូមិ ឬដែលមានតំលៃស្មើ ដល់សាធារណជនទូទៅ។ |
| ២ | ទីប្រជុំជន | ការកំណត់ទីប្រជុំជនអាចធ្វើឡើងតាមវិធី ២យ៉ាងដូចខាងក្រោម៖<br>__**របៀបទី១៖**__<br>-ជាសង្កាត់ដែលសាលាក្រុង/ខណ្ឌតាំងនៅ<br>__**របៀបទី២៖**__<br>-ជាសង្កាត់ដែលមានប្រជាជនរស់នៅចាប់ពី៣០ ០០០នាក់ឡើងទៅ និង<br>-មានប្រជាជនលើសពី៥០%ដែលប្រកបរបរមិនមែនកសិកម្ម និង<br>-មានដង់ស៊ីតេប្រជាជនចាប់ពី១០០នាក់/គម$^2$ឡើងទៅ។<br>បញ្ជាក់៖ ការកំណត់ទីប្រជុំជនតាមរបៀបទីពីរ អាចបណ្តាលឲ្យមានទីប្រជុំជនច្រើននៅក្នុងទីក្រុងបេក្ខភាពតែមួយ។ ទីក្រុងបេក្ខភាពអាចជ្រើសយករបៀបកំណត់តែមួយគត់ក្នុងចំណោមរបៀបទាំងពីរខាងលើ សម្រាប់ការប្រឡងប្រណាំងមួយ |

[113] តារាងទី ០៥

| | | |
|---|---|---|
| | | លើកៗ។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យT១.៤តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**ចំនួន**" (បរិមាណ) វិទ្យាល័យនៅក្នុងទីក្រុងបេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួន ដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.**ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០២** គឺៈ

- ផ្តល់ព័ត៌មានអំពីចំនួន និងទីតាំងវិទ្យាល័យទាំងអស់ដែលមាន
- បង្ហាញថាទីក្រុងបេក្ខភាពមានវិទ្យាល័យគ្រប់គ្រាន់ (យ៉ាងហោចណាស់មាន១ក្នុងបរិវេណ១៥០០ម៉ែត្រពីទីប្រជុំជន)។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យT១.៤ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០២** ខាងលើ។

| **តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ១.៤** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីវិទ្យាល័យ *(ទាំងមានស្រាប់ និងគម្រោង)* | ស្រង់ទិន្នន័យវិទ្យាល័យ (ទាំងមានស្រាប់ និងស្ថិតនៅជាគម្រោងសាងសង់) ចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[114]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | មានវិទ្យាល័យយ៉ាងហោច១ក្នុងបរិវេណ១៥០០ម៉ែត្រពីទីប្រជុំជន | រៀបរាងជាលិខិតរដ្ឋបាលដែលមានសុពលភាពអាចបញ្ជាក់អំពីចំនួនវិទ្យាល័យដែលមានស្រាប់ និងដែលស្ថិតនៅក្នុងគម្រោងស្ថាបនា*(បញ្ជាក់ថាមានយ៉ាងហោចណាស់ ១ ក្នុងបរិវេណ១០០០ម៉ែត្រពីទីប្រជុំជន)* | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច |

## ៥. លក្ខណវិនិច្ឆ័យT១.៥

*"តើមាន**<u>សួនកម្សាន្តសម្រាប់កុមារ</u>**គ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង?"*
*"នឹងផ្តល់ជូន **១ពិន្ទុ**ប្រសិនបើអាចបង្ហាញថា**<u>មាន១០%នៃតំបន់សាងសង់បាននៃទីក្រុង</u>**"*

## ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| **ល.រ** | **ពាក្យគន្លឹះ** | **សេចក្តីពន្យល់** |
|---|---|---|

[114] តារាងទី ០៦

| | | |
|---|---|---|
| ១ | សួនសម្បាន្ត សម្រាប់កុមារ | សំដៅដល់សួនច្បារ ទីធ្លាសាធារណៈនានាដែលមានបំពាក់សំភារៈបរិក្ខាសម្រាប់ឲ្យកុមារលេងកំសាន្ត (តាមបែបអត្តពលកម្ម) និងបើកទូលាយសម្រាប់សាធារណជនទូទៅ ទោះត្រូវបង់ប្រាក់ក្តី ឬដោយឥតគិតថ្លៃក្តី។ |
| ២ | តំបន់សាងសង់បាន | សំដៅដល់តំបន់ដែលជំរុញឲ្យមានការអភិវឌ្ឍ និងការសាងសង់លើគ្រប់វិស័យ។ តំបន់នេះត្រូវបានបែងចែកជាតំបន់លំនៅដ្ឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់ដឹកជញ្ជូន តំបន់សេវាកម្មទេសចរណ៍ តំបន់រដ្ឋបាល និងតំបន់សេវាសាធារណៈ តំបន់លំហសាធារណៈ និងផ្ទៃបៃតង តំបន់វប្បធម៌ និងសាសនា និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យT១.៥តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ទំហំ"** (បរិមាណ) សួនកំសាន្តសម្រាប់កុមារនៅក្នុងទីក្រុងបេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួន ដើម្បីជាទុនសម្រាប់ឲ្យ**គ.ជ.វ.ទ.**ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០២** គឺៈ

- ផ្តល់ព័ត៌មានអំពីចំនួន និងទីតាំងសួនកំសាន្តសម្រាប់កុមារទាំងអស់ដែលមាន
- បង្ហាញថាទីក្រុងបេក្ខភាពមានសួនកំសាន្តសម្រាប់កុមារគ្រប់គ្រាន់ (យ៉ាងហោចណាស់គ្របដណ្តប់លើផ្ទៃដី១០% នៃផ្ទៃដីសរុបនៃតំបន់សាងសង់បាន)។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យT១.៥ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០២** ខាងលើ។

| **តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវនិច្ឆ័យ១.៥** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីសួនកំសាន្តសម្រាប់កុមារ*(ទាំងមានស្រាប់ និងគម្រោង)* | ស្រង់ទិន្នន័យសួនកំសាន្តសម្រាប់កុមារ (ទាំងមានស្រាប់ និងស្ថិតនៅជាគម្រោងសាងសង់) ចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[115]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបចំផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងសួនកំសាន្តទាំងនោះ។ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | មានផ្ទៃដីសួនកំសាន្តសម្រាប់កុមារសរុបយ៉ាងហោចណាស់ស្មើ១០%នៃតំបន់សាងសង់បាន | រៀបរាងជាលិខិតរដ្ឋបាលដែលមានសុពលភាពអាចបញ្ជាក់អំពីផ្ទៃដីសរុបសួនកំសាន្តសម្រាប់កុមារដែលមានស្រាប់ និងដែលស្ថិតនៅក្នុងគម្រោងស្ថាបនា*(បញ្ជាក់ថាមានយ៉ាងហោចណាស់១០%នៃតំបន់សាងសង់បាន)* | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច |

[115] តារាងទី ០១

## ៦. លក្ខណៈវិនិច្ឆ័យ T១.៦

*"តើមាន**ទីតាំងសម្រាប់លេងកីឡា**គ្រប់គ្រាន់ដែរឬទេនៅតាមទីក្រុង?"*
*"នឹងផ្តល់ជូន **១ពិន្ទុ** ប្រសិនបើអាចបង្ហាញថា**មាន១០%នៃតំបន់សាងសង់បានរបស់ទីក្រុង**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ទីតាំងសម្រាប់លេងកីឡា | សំដៅដល់សួនច្បារទីធ្លាសាធារណៈនានាដែលមានបំពាក់សំភារៈបរិក្ខាសម្រាប់ឲ្យសាធារណជនទូទៅអាចលេងកីឡាផ្សេងៗ ឬហាត់ប្រាណ និងបើកទូលាយសម្រាប់សាធារណជនទូទៅ ទោះត្រូវបង់ប្រាក់ក្តី ឬដោយឥតគិតថ្លៃក្តី។ |
| ២ | តំបន់សាងសង់បាន | សំដៅដល់តំបន់ដែលជំរុញឲ្យមានការអភិវឌ្ឍ និងការសាងសង់លើគ្រប់វិស័យ។ តំបន់នេះ ត្រូវបានបែងចែកជាតំបន់លំនៅដ្ឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់ដឹកជញ្ជូន តំបន់សេវាកម្មទេសចរណ៍ តំបន់រដ្ឋបាល និងតំបន់សេវាសាធារណៈ តំបន់លំហសាធារណៈ និងផ្ទៃបៃតង តំបន់វប្បធម៌ និងសាសនា និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យT១.៦តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ទំហំ"** (បរិមាណ) ទីតាំងសម្រាប់លេងកីឡានៅក្នុងទីក្រុងបេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួន ដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.**ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០២** គឺ៖

- ផ្តល់ព័ត៌មានអំពីចំនួន និងទីតាំងនៃទីកន្លែងសម្រាប់លេងកីឡាទាំងអស់(ដែលមាន)
- បង្ហាញថាទីក្រុងបេក្ខភាពមានទីតាំងសម្រាប់លេងកីឡាគ្រប់គ្រាន់ (យ៉ាងហោចណាស់គ្របដណ្តប់លើផ្ទៃដី១០% នៃផ្ទៃដីសរុបនៃតំបន់សាងសង់បាន)។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យT១.៦ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០២** ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យ១.៦ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |

| | | | |
|---|---|---|---|
| ១ | ព័ត៌មានអំពីទីតាំងសម្រាប់លេងកីឡា*(ទាំងមានស្រាប់និងគម្រោង)* | ស្រង់ទិន្នន័យទីតាំងសម្រាប់លេងកីឡា (ទាំងមានស្រាប់និងស្ថិតនៅជាគម្រោងសាងសង់) ចុះក្នុងតារាងគំរូមួយ | -តារាងសម្រង់ស្ថិតិ[116]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបចំផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងទីតាំងសម្រាប់លេងកីឡាទាំងនោះ។ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | មានផ្ទៃដីទីតាំងសម្រាប់លេងកីឡាសរុបយ៉ាងហោចណាស់ស្មើ១០%នៃតំបន់សាងសង់បាន | រៀបរាងជាលិខិតរដ្ឋបាលដែលមានសុពលភាពអាចបញ្ជាក់អំពីផ្ទៃដីសរុបទីតាំងសម្រាប់លេងកីឡាដែលមានស្រាប់និងដែលស្ថិតនៅក្នុងគម្រោងស្ថាបនា *(បញ្ជាក់ថាមានយ៉ាងហោចណាស់១០%នៃតំបន់សាងសង់បាន)* | -សេចក្តីសម្រេចដីកា ឬលិខិតបទដ្ឋានដែលមានតម្លៃស្មើដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច |

## T២. សូចនាកររលំអិតនៃប្លង់មេសម្រាប់អភិវឌ្ឍទេសចរណ៍

សូចនាកររលំអិតនេះ មានគោលបំណងសិក្សាស្វែងយល់ឲ្យកាន់តែច្បាស់អំពីប្លង់មេសម្រាប់អភិវឌ្ឍទេសចរណ៍ដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាពនីមួយៗ និងក៏ដើម្បីផ្ទៀងផ្ទាត់មើលថា តើទីក្រុងបេក្ខភាពបានគិតគូរដល់ការរៀបចំប្លង់មេសម្រាប់អភិវឌ្ឍទេសចរណ៍ក្នុងទីក្រុងឬទេ? លើសពីនេះការរៀបចំផែនការយុទ្ធសាស្ត្រលម្អិតសម្រាប់ការអភិវឌ្ឍទេសចរណ៍នៅក្នុងទីក្រុងបេក្ខភាពឲ្យមានភាពស៊ីសង្វាក់គ្នាមួយប្លង់មេជាការចាំបាច់បំផុតសំរាប់ការអភិវឌ្ឍទេសចរនៅក្នុងទីក្រុងដោយហេតុថាការផ្តល់ភាពងាយស្រួលដល់ភ្ញៀវទេសចរឲ្យចូលទៅកាន់ទីកន្លែងទេសចរណ៍(access) គឺជាការទាក់ទាញទេសចរមួយដ៏សំខាន់។ ទន្ទឹមនឹងនោះ ស្ថាបត្យកម្មនានានៅតាមទីក្រុងមួយចំនួនត្រូវបានចាត់ទុកថាជាសម្បត្តិបេតិកភណ្ឌ និងជាអត្តសញ្ញាណរបស់ក្រុងគឺជាកត្តា អភិវឌ្ឍទេសចរទីក្រុង(Tourisme Urbain)។ ការរៀបចំគម្រោងអភិរក្សស្នាដៃស្ថាបត្យ-កម្មមិនត្រឹមតែចូលរួមដល់ការកំណត់ទីតាំង បរិមាណ និងការយកចិត្តទុកដាក់អភិរក្សនៃស្នាដៃស្ថាបត្យកម្មបុរាណប៉ុណ្ណោះទេតែថែមទាំងលើកកម្ពស់តម្លៃ នៃសម្បត្តិបេតិកភ័ណ្ឌទាំងនេះ និងចូលរួមដល់ការអភិវឌ្ឍទីក្រុង(City Tourism)។

**សៀវភៅបន្ទុកគឺជាសៀវភៅដែលកត់ត្រារាល់សកម្មភាពទាំងអស់ដែលពាក់ព័ន្ធនឹងប្រធានបទរបស់សៀវភៅនោះដែលត្រូវបានរៀបចំតាមលំដាប់ពេលវេលាមួយច្បាស់លាស់។ សៀវភៅបន្ទុកអាចជាកំណត់ត្រារាល់សកម្មភាព (គ្រប់សកម្មភាពរបស់ទីក្រុងបេក្ខភាពដែលពាក់ព័ន្ធនឹងការលើកកម្ពស់ និងយកចិត្តទុកដាក់ថែទាំ និងការពារសម្បត្តិបេតិកភណ្ឌទាំងនោះ)ប្រចាំថ្ងៃ ប្រចាំខែ ឬប្រចាំឆ្នាំ (យោងតាមតម្រូវការចាំបាច់)...។ ដូច្នេះសៀវភៅបន្ទុកអាចជាទិន្នន័យយ៉ាងសំខាន់សម្រាប់បម្រើដល់ការរៀបចំចងក្រងគម្រោងផែនការផ្សេងៗ។**

តារាងខាងក្រោមនេះបង្ហាញអំពីលក្ខណវិនិច្ឆ័យទាំង ០២ នៃសូចនាករលម្អិតT២ និងជាកម្មវត្ថុនៃការពិភាក្សាដើម្បីធ្វើការណែនាំដល់ទីក្រុងបេក្ខភាពនៃការប្រឡងប្រណាំងទីក្រុងស្អាត។

| លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|

[116] តារាងទី ០១

| | | |
|---|---|---|
| T២.១.តើមាន**ផែនការអភិវឌ្ឍទេសចរណ៍**ដែរឬទេ? | មាន-មិនមាន | ១ |
| T២.២.តើមាន**ផែនការអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ** នៅក្នុងទីក្រុងដែរឬទេ? | មាន-មិនមាន | ១ |

*(ផ្តល់ពិន្ទុ ២/១៤ នៃពិន្ទុសរុបរបស់សូចនាករគោលនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍)*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណៈវិនិច្ឆ័យ T២.១

*"តើមាន**ផែនការអភិវឌ្ឍទេសចរណ៍**ដែរឬទេ?"*
*"នឹងផ្តល់ជូន **១ពិន្ទុ**ប្រសិនបើអាចបង្ហាញថា**មាន**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ផែនការអភិវឌ្ឍទេសចរណ៍ | សំដៅដល់ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់ក្រោមជាតិ ដែលជាផែនការទូទៅសម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍទេសចរណ៍ក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមួយ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យT២.១តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ឯកសារផែនការអភិវឌ្ឍទេសចរណ៍"** ដែលត្រូវបានចងក្រងឡើងដោយមានការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ។ **គ.ជ.វ.ទ.** ផ្តល់លទ្ធភាព **០២** ផ្សេងគ្នាសម្រាប់ទីក្រុងបេក្ខភាពទទួលបានពិន្ទុពីលក្ខណវិនិច្ឆ័យT២.១ ដូចតទៅ៖

**<u>ករណីទី១</u>៖ ឯកសារផែនការអភិវឌ្ឍទេសចរណ៍ត្រូវបានចងក្រងរួចរាល់**

- ប្រគល់ជូនមក គ.ជ.វ.ទ. នូវ **"ឯកសារផែនការអភិវឌ្ឍទេសចរណ៍"**មួយច្បាប់។

**<u>ករណីទី២</u>៖ ឯកសារផែនការអភិវឌ្ឍទេសចរណ៍មិនទាន់ចងក្រងរួចចប់សព្វគ្រប់**

- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការរៀបចំចងក្រង **"ឯកសារផែនការអភិវឌ្ឍទេសចរណ៍"**
- បង្ហាញអំពីសកម្មភាពដែលបានអនុវត្តជាក់ស្តែងដើម្បីរៀបចំចងក្រង **"ឯកសារផែនការអភិវឌ្ឍទេសចរណ៍"**។

ខាងក្រោមនេះ ជាការពិភាក្សាលើករណីទាំងពីរនេះ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌនីមួយៗនៃករណីទាំងពីរខាងលើ។

| តារាងពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យT២.១ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| **<u>ករណីទី១</u>៖** | | | |
| ១ | ឯកសារផែន | រៀបចំជាឯកសារផែនការអភិវឌ្ឍ | - ឯកសារផែនការអភិវឌ្ឍទេសចរណ៍របស់ទីក្រុង |

| | | | |
|---|---|---|---|
| | ការអភិវឌ្ឍទេសចរណ៍ | ទេសចរណ៍មួយច្បាប់ និងមានភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនានា | បេក្ខភាពដែលមានការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច |
| **ករណីទី២៖** | | | |
| ១ | វត្តមានអ្នកទទួលខុសត្រូវលើការរៀបចំឯកសារ | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | - សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ។ |
| ២ | សកម្មភាពអនុវត្តជាក់ស្តែង | មានរៀបចំជាផែនការសកម្មភាព ឬផែនការអនុវត្តនានាសម្រាប់ដំណើរការការរៀបរាងជាឯកសារផែនការអភិវឌ្ឍទេសចរណ៍នេះឡើងមក | - តារាងផែនការសកម្មភាព[117]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | មានរៀបចំជារបាយការណ៍បូកសរុបការងារដែលសម្រេចបានគិតត្រឹមថ្ងៃដាក់ពាក្យ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់ពីអាជ្ញាធរទីក្រុងបេក្ខភាព<br>- រូបថត រូបភាពខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែងដែលបានអនុវត្តកន្លងមក |

## ២. លក្ខណវិនិច្ឆ័យ T២.២

*"តើមាន**<u>ផែនការអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ</u>**នៅក្នុងទីក្រុងដែរឬទេ?"*
*"នឹងផ្តល់ជូន **១ពិន្ទុ**ប្រសិនបើអាចបង្ហាញថា**<u>មាន</u>**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ផែនការអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ | សំដៅដល់ផែនការអភិរក្ស និងអភិវឌ្ឍទាំងឡាយណានៅតាមទី ស្ថានីយ៍ វប្បធម៌ ប្រវត្តិសាស្ត្រនានា ដែលផែនការទាំងនោះត្រូវបានរៀបចំធ្វើឡើងក្នុងកម្មវត្ថុថែរក្សាការពារសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រទាំងនោះឲ្យនៅស្ថិតស្ថេរគង់វង្ស។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យT២.២តម្រូវឲ្យទីក្រុងបេក្ខភាពរៀបចំបញ្ជូនមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ឯកសារផែនការអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ"** ដែលត្រូវបានចងក្រងឡើងដោយមានការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ គឺទីក្រុងបេក្ខភាពនោះផ្ទាល់។ **គ.ជ.វ.ទ.** ផ្តល់លទ្ធភាព **០២** ផ្សេងគ្នាសម្រាប់ទីក្រុងបេក្ខភាពទទួលបានពិន្ទុពីលក្ខណវិនិច្ឆ័យT២.២ ដូចតទៅ៖

**<u>ករណីទី១</u>៖ ឯកសារផែនការអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រត្រូវបានចងក្រងរួចរាល់**

- ប្រគល់ជូនមក គ.ជ.វ.ទ. នូវ **"ឯកសារផែនការអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ"**មួយច្បាប់។

[117] តារាងទី ៤២

**<u>ករណីទី២</u>៖ ឯកសារផែនការអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រមិនទាន់ចងក្រងរួចចប់សព្វគ្រប់**

- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវលើការរៀបចំចងក្រង **"ឯកសារផែនការអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ"**
- បង្ហាញអំពីសកម្មភាពដែលបានអនុវត្តជាក់ស្តែងដើម្បីរៀបចំចងក្រង **"ឯកសារផែនការអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ"។**

ខាងក្រោមនេះ ជាការពិភាក្សាលើករណីទាំងពីរនេះ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌនីមួយៗនៃករណីទាំងពីរខាងលើ។

**តារាងពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណៈវិនិច្ឆ័យT២.២**

| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
|---|---|---|---|
| **<u>ករណីទី១</u>៖** | | | |
| ១ | ឯកសារផែនការអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ | រៀបរាងជាឯកសារផែនការអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រមួយច្បាប់ និងមានភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនានា | - ឯកសារផែនការអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្ររបស់ទីក្រុងបេក្ខភាពដែលមានការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច |
| **<u>ករណីទី២</u>៖** | | | |
| ១ | វត្តមានអ្នកទទួលខុសត្រូវលើការរៀបចំឯកសារ | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | - សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ។ |
| ២ | សកម្មភាពអនុវត្តជាក់ស្តែង | មានរៀបចំជាផែនការសកម្មភាព ឬផែនការអនុវត្តនានាសម្រាប់ដំណើរការការរៀបរាងជាឯកសារផែនការអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រនេះឡើងមក | - តារាងផែនការសកម្មភាព[118]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | មានរៀបចំជារបាយការណ៍បូកសរុបការងារដែលសម្រេចបានគិតត្រឹមថ្ងៃដាក់ពាក្យ | - របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់ពីអាជ្ញាធរទីក្រុងបេក្ខភាព<br>- រូបថត រូបភាពខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីសកម្មភាពជាក់ស្តែងដែលបានអនុវត្តកន្លងមក |

# T៣. សូចនាករលំអិតនៃមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍

សូចនាករលំអិតស្តីពីមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ជាតម្រូវការចាំបាច់សំរាប់ភ្ញៀវទេសចរក្នុងការស្វែងរកព័ត៌មាននានាដើម្បីធ្វើការសំរេច និងជ្រើសរើសគោលដៅកម្សាន្ត។ ការសម្រួលនូវមធ្យោបាយផ្តល់ព័ត៌មានដល់ភ្ញៀវទេសចរ គឺចូលរួមសម្រួលដល់ដំណើរទស្សនាចររបស់ភ្ញៀវកាន់តែច្រើន និងបង្កើនការពេញចិត្ត និងសប្បាយរីករាយកាន់តែខ្លាំង ព្រមទាំង

[118] តារាងទី ៤២

ធ្វើឲ្យភ្ញៀវទេសចរអាចស្គាល់អំពីគោលដៅទេសចរណ៍ផ្សេងៗរបស់ទីក្រុងបានកាន់តែច្រើនថែមទៀត និងក៏ជាប្រយោជន៍សម្រាប់ការអភិវឌ្ឍទេសចរណ៍ក្នុងក្រុងផងដែរ។

តារាងខាងក្រោមនេះបង្ហាញអំពីលក្ខណវិនិច្ឆ័យទាំង ០១ នៃសូចនាករលម្អិតT៣ និងជាកម្មវត្ថុនៃការពិភាក្ស ដើម្បីធ្វើការណែនាំដល់ទីក្រុងបេក្ខភាព។

| **លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|
| T៣.១. តើមាន<u>**មជ្ឈមណ្ឌលពត៌មានទេសចរណ៍**</u>នៅតាម<u>**តំបន់ទេសចរណ៍សំខាន់ៗ**</u>គ្រប់គ្រាន់ដែរឬទេ? | គ្រប់គ្រាន់-មិនគ្រប់គ្រាន់ | ១ |

*(ផ្តល់ពិន្ទុ ១/១៤ នៃពិន្ទុសរុបរបស់សូចនាករគោលនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍)*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណវិនិច្ឆ័យ T៣.១

*"តើមាន<u>**មជ្ឈមណ្ឌលព័ត៌មានទេសចរណ៍**</u>នៅតាម<u>**តំបន់ទេសចរណ៍សំខាន់ៗ**</u>គ្រប់គ្រាន់ដែរឬទេ?"*
*"នឹងផ្តល់ជូន **១ពិន្ទុ** ប្រសិនបើអាចបង្ហាញថា<u>**មានគ្រប់គ្រាន់**</u>"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| **ល.រ** | **ពាក្យគន្លឹះ** | **សេចក្តីពន្យល់** |
|---|---|---|
| ១ | មជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ | សំដៅដល់ទីកន្លែងសម្រាប់ផ្តល់ព័ត៌មាន ពិសេសព័ត៌មានទាក់ទងនឹងទេសចរណ៍នៅក្នុងទីក្រុងនោះផ្ទាល់ ដូចជា៖ ព័ត៌មានអំពីរមណីយដ្ឋាន អាហារដ្ឋាន កន្លែងស្នាក់នៅ ពីធីបុណ្យផ្សេងៗ រមណីយដ្ឋានទេសចរណ៍ និងសកម្មភាពកំសាន្តផ្សេងៗជាដើម ដល់សាធារណជនទូទៅ ពិសេសភ្ញៀវទេសចរដែលចូលមកទស្សនាកំសាន្ត។ |
| ២ | តំបន់ទេសចរណ៍សំខាន់ៗ (រមណីយដ្ឋានសំខាន់ៗ) | សំដៅដល់រមណីយដ្ឋានទេសចរណ៍ទាំងឡាយណានៅតាមទីក្រុងបេក្ខភាពដែលជា<u>**គោលដៅសំខាន់នៃការទស្សនារបស់ភ្ញៀវទេសចរ**</u>ដែលចូលមកទស្សនាកំសាន្តក្នុងទីក្រុងបេក្ខភាពនោះ។<br><u>**ឧទាហរណ៍**</u>៖បើទៅទស្សនាក្រុងព្រះសីហនុគឺទៅសំរាកលំហែនៅតាមឆ្នេរសមុទ្រនានារបស់ក្រុង។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យT៣.១តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) មជ្ឈមណ្ឌលព័ត៌មានទេសចរណ៍នៅក្នុងដែនសមត្ថកិច្ចរបស់ទីក្រុងបេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន ០៤ គឺ៖

- ព័ត៌មានអំពីចំនួននិងទីតាំងទីរមណីយដ្ឋានសំខាន់ៗ(ដែលមាន)
- ព័ត៌មានអំពីចំនួន និងទីតាំងមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍(ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវគ្រប់គ្រងនៅតាមមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ទាំងនោះ
- បង្ហាញថាមានមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍គ្រប់គ្រាន់។

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យT៣.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៤ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវនិច្ឆ័យT៣.១ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីទីរមណីយដ្ឋានសំខាន់ៗ | ស្រង់ស្ថិតិអំពីទីរមណីយដ្ឋានសំខាន់ៗទាំងឡាយ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយដែលមានបញ្ជាក់ពីប្រភេទនិងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | - តារាងសម្រង់ស្ថិតិ[119]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបចំជាផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងទីរមណីយដ្ឋានទាំងនោះ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | ព័ត៌មានអំពីមជ្ឈ-មណ្ឌលព័ត៌មានទេសចរណ៍ | ស្រង់ស្ថិតិអំពីមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយដែលមានបញ្ជាក់ពីប្រភេទនិងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | -តារាងសម្រង់ស្ថិតិ[120]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបចំជាផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងទាំងនោះ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ៣ | វត្តមានអ្នកទទួលខុសត្រូវ | រៀបចំឲ្យមានជាអង្គភាពមួយដែលមានសមាសភាពនិងយន្តការគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះ | - សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ។ |
| ៤ | មានមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍គ្រប់គ្រាន់ | រៀបចំជាសេចក្តីម្រេច ដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើដែលបញ្ជាក់មានមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ក្នុងចំនួនគ្រប់គ្រាន់ | - សេចក្តីសម្រេច ឬដីកា ឬលិខិតបទដ្ឋានដទៃទៀតដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពអ្នកដែលត្រូវបំពេញការងារនេះ។ |

# T៤. សូចនាករលំអិតនៃទីតាំងលក់ទំនិញ

[119] តារាងទី ២៤

[120] តារាងទី ០១

សូចនាករលម្អិតស្តីពីទីតាំងលក់ទំនិញ គឺមានគោលបំណងចង្អុលបង្ហាញដល់ទីក្រុងបេក្ខភាពដើម្បី ផ្ទៀងផ្ទាត់មើលថាតើទីក្រុងបេក្ខភាពបានគិតគូរពីការរៀបចំទីតាំងលក់ទំនិញដើម្បីសម្រួលដល់លក្ខខណ្ឌរស់នៅរបស់ប្រជាជនក្នុងទីក្រុងឬទេ? ឬក៏ថាតើទីក្រុងបេក្ខភាពបានរៀបចំកម្មវិធីប្រមូលផ្តុំអាជីវករបង្កើតជាមជ្ឈមណ្ឌលពាណិជ្ជកម្មនៅក្នុងទីក្រុង/ខណ្ឌរបស់ខ្លួនឬទេ? ទីក្រុងបេក្ខភាពនីមួយៗគួរតែរៀបចំឲ្យមានផ្សាររាត្រីនៅក្នុងទីក្រុងរបស់ខ្លួន ដើម្បីជាការទាក់ទាញភ្ញៀវទេសចរឲ្យចូលរួមនាំចេញផលិតផលទាំងនោះ។ ក្នុងន័យនេះគឺចូលរួមដល់ផលិតផលក្នុងស្រុកដូចជាផលិតផលសិប្បកម្ម (កន្រ្តកឈើត្បាញ......) ឬ(ហូល ផាមួង)ជាដើម។

តារាងខាងក្រោមនេះបង្ហាញអំពីលក្ខណវិនិច្ឆ័យទាំង **០២** នៃសូចនាករលម្អិតT៤ និងជាកម្មវត្ថុនៃការពិភាក្សាដើម្បីធ្វើការណែនាំដល់ទីក្រុងបេក្ខភាព។

| **លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|
| T៤.១.តើមាន**<u>មជ្ឈមណ្ឌលពាណិជ្ជកម្ម</u>**(Shopping center) នៅក្នុងទីក្រុងដែរឬទេ? | យ៉ាងហោចណាស់១ | ១ |
| T៤.២.តើមាន**<u>ផ្សាររាត្រី</u>**នៅក្នុងទីក្រុងដែរឬទេ? | យ៉ាងហោចណាស់១ | ១ |

*(ផ្តល់ពិន្ទុ ២/១៤ នៃពិន្ទុសរុបរបស់សូចនាករគោលនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍)*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណវិនិច្ឆ័យ T ៤.១

*"តើមាន**<u>មជ្ឈមណ្ឌលពាណិជ្ជកម្ម</u>**(Shopping center) នៅក្នុងទីក្រុងដែរឬទេ?"*
*"នឹងផ្តល់ជូន **១ពិន្ទុ**ប្រសិនបើអាចបង្ហាញថា**<u>មានយ៉ាងហោចណាស់១</u>**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| **ល.រ** | **ពាក្យគន្លឹះ** | **សេចក្តីពន្យល់** |
|---|---|---|
| ១ | មជ្ឈមណ្ឌលពាណិជ្ជកម្ម | សំដៅដល់ទីផ្សារទំនិញទាំងឡាយណា ដែលត្រូវបានរៀបចំឡើងតាមបច្ចេកវិទ្យាសម័យទំនើប ហើយស្ថិតក្នុងទីបិទជិត (ការពារពីខ្យល់ ពន្លឺព្រះអាទិត្យ ភ្លៀង...) និងមានតូប ស្តង់ ឬហាងលក់ទំនិញច្រើនប្រភេទ (លក់ម្ហូបអាហារ ត្រី សាច់ នំ ចំណី សំលៀកបំពាក់ ឧបករណ៍ប្រើប្រាស់ គ្រឿងអេឡិចត្រូនិច...) នៅផ្តុំគ្នា និងភ្ជាប់គ្នាដោយផ្លូវដើរដែលមានលក្ខណៈងាយស្រួល និងស្ថិតនៅក្នុងទីបិទជិតនោះដែរ។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យT៤.១តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.**សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) មជ្ឈមណ្ឌលពាណិជ្ជកម្ម (Shopping Center) នៅក្នុងទីក្រុងបេក្ខភាព។ ដូច្នេះទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.**ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺ៖

- ព័ត៌មានអំពីចំនួន និងទីតាំងមជ្ឈមណ្ឌលពាណិជ្ជកម្ម(ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវគ្រប់គ្រងនៅតាមមជ្ឈមណ្ឌលពាណិជ្ជកម្មទាំងនោះ

- បង្ហាញអំពីសកម្មភាពដំណើរការជាក់ស្តែងរបស់មជ្ឈមណ្ឌលពាណិជ្ជកម្មទាំងនោះ

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យT៤.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៣ ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យT៤.១ | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីមជ្ឈមណ្ឌលពាណិជ្ជកម្មដែលមាន | ស្រង់ស្ថិតិអំពីមជ្ឈមណ្ឌលពាណិជ្ជកម្មទាំងឡាយ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | - តារាងសម្រង់ស្ថិតិ[121]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | *និង* | រៀបចំផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងមជ្ឈមណ្ឌលពាណិជ្ជកម្មទាំងនោះ។ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវ | បង្ហាញវត្តមាននីតិបុគ្គល ឬរូបវន្តបុគ្គលដែលមានសមាសភាពជាអ្នកគ្រប់គ្រងលើមជ្ឈមណ្ឌលពាណិជ្ជកម្មនីមួយៗ | - លិខិតបទដ្ឋានគតិយុត្តដែលមានតម្លៃអាចបញ្ជាក់ពីសមាសភាពជាអ្នកគ្រប់គ្រងលើមជ្ឈមណ្ឌលពាណិជ្ជកម្មនីមួយៗ |
| ៣ | សកម្មភាពដំណើរការជាក់ស្តែង | រៀបចំជាតារាងកាលវិភាគម៉ោងដំណើរការរបស់មជ្ឈមណ្ឌលពាណិជ្ជកម្មទាំងនោះ | - តារាងព័ត៌មានដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុង/ខណ្ឌបេក្ខភាព |

## ២. លក្ខណវិនិច្ឆ័យ T៤.២

*"តើមាន__ផ្សាររាត្រី__នៅក្នុងទីក្រុងដែរឬទេ?"*
*"នឹងផ្តល់ជូន **១ពិន្ទុ**ប្រសិនបើអាចបង្ហាញថា__**មានយ៉ាងហោចណាស់មួយ**__"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ផ្សាររាត្រី | សំដៅដល់ទីផ្សារទាំងឡាយណាដែលបើកលក់នៅពេលយប់ក្នុងគោលបំណងសំរាប់ឲ្យភ្ញៀវទេសចរដើរលំហែកំសាន្ត ឬដើរទិញរបស់របរវត្ថុអនុស្សាវរីយ៍ ឬផ្លក់រស់ជាតិអាហារ ដែលមិនសំដៅទៅលើទីផ្សារដែលលក់ឧបភោគបរិភោគ ឬសម្ភារៈបរិក្ខាប្រើប្រាស់ប្រចាំថ្ងៃនោះទេ។ |

[121] តារាងទី ០១

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យT៤.២តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក **គ.ជ.វ.ទ.** សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) ផ្សាររាត្រីនៅក្នុងទីក្រុងបេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យគណៈ **គ.ជ.វ.ទ.** ធ្វើការវាយតម្លៃ។

លក្ខខណ្ឌតម្រូវទាំងនោះមាន **០៣** គឺ៖

- ព័ត៌មានអំពីចំនួន និងទីតាំងផ្សាររាត្រី(ដែលមាន)
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវគ្រប់គ្រងនៅតាមផ្សាររាត្រីទាំងនោះ
- បង្ហាញអំពីសកម្មភាពដំណើរការជាក់ស្តែងរបស់ផ្សាររាត្រីទាំងនោះ

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យT៤.២ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០៣** ខាងលើ។

| **តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យT៤.២** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីផ្សាររាត្រីដែលមាន | ស្រង់ស្ថិតិអំពីផ្សាររាត្រីទាំងឡាយដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងតារាងគំរូមួយដែលមានបញ្ជាក់ពីប្រភេទ និងព័ត៌មានផ្សេងៗអំពីទីកន្លែងទាំងនោះ | - តារាងសម្រង់ស្ថិតិដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| | ***និង*** | រៀបចំផែនទីទីក្រុងដែលមានដៅបញ្ជាក់ចំនុចទីតាំងផ្សាររាត្រីទាំងនោះ។ | -ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវ | បង្ហាញវត្តមាននីតិបុគ្គល ឬរូបវន្តបុគ្គលដែលមានសមាសភាពជាអ្នកគ្រប់គ្រងលើផ្សាររាត្រីនីមួយៗ | - លិខិតបទដ្ឋានគតិយុត្តដែលមានតម្លៃអាចបញ្ជាក់ពីសមាសភាពជាអ្នកគ្រប់គ្រងលើផ្សាររាត្រីនីមួយៗ |
| ៣ | សកម្មភាពដំណើរការជាក់ស្តែង | រៀបចំជាតារាងកាលវិភាគម៉ោងដំណើរការរបស់ផ្សាររាត្រីទាំងនោះ | - តារាងព័ត៌មានដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុងបេក្ខភាព |

## T៥. សូចនាករលំអិតនៃកម្រិតភាពពេញចិត្តរបស់ភ្ញៀវទេសចរ

ភាពពេញចិត្តរបស់ភ្ញៀវទេសចរត្រូវបានរាប់បញ្ចូលជាសូចនាករលម្អិតក្នុងសូចនាករគោលក្នុងនេះដោយហេតុថា ការស្ទង់ពីកម្រិតពេញចិត្តនៃភ្ញៀវទេសចរណ៍គឺជាអ្វីដែលទីក្រុងបេក្ខភាពត្រូវតែយកចិត្តទុកដាក់ ដូច្នេះ ការវាស់ស្ទង់ពីកម្រិតពេញចិត្តរបស់ភ្ញៀវទេសចរចំពោះទីក្រុងបេក្ខភាព(ភាពពេញចិត្តរបស់ភ្ញៀវទេសចរទាក់ទងទៅនឹងអារម្មណ៍របស់ភ្ញៀវទេសចរលើគោលដៅទស្សនាណាមួយបន្ទាប់ពីបានទស្សនា ឬបានទាញយកបទពិសោធពីទីតាំងនោះរួចហើយ)គឺធ្វើជាប្រចាំឆមាសដើម្បីស្វែងយល់អំពីចំនុចល្អ កំហុស ឬកង្វះខាតដែលមានទាក់ទងទៅនឹងការអនុវត្តរបស់ទីក្រុងបេក្ខភាព និងដើម្បីកែលម្អចំនុចខ្វះខាត។ សូចនាករលម្អិតនេះសំដៅជម្រុញឲ្យទីក្រុងបេក្ខភាពចាត់នូវវិធានការផ្សេងៗដើម្បីលើកកម្ពស់ និងកែលម្អ

សេវាកម្ម និងសម្បទាផ្សេងៗរបស់ខ្លួនដើម្បីធ្វើយ៉ាងណាឲ្យភ្ញៀវទេសចរកាន់តែពេញចិត្ត។ ប្រសិនបើទីក្រុងបេក្ខភាពណាមួយអាចធ្វើឲ្យភ្ញៀវទេសចរ ទទួលនូវអារម្មណ៍ពេញចិត្តពេញថ្លើមនោះ ទេសចរទាំងនោះភាគច្រើននឹងត្រលប់មកម្តងទៀត (Repeat tourist) និងអាចឈានដល់ការជួយផ្សព្វផ្សាយបន្តអំពីទីក្រុងនោះដល់មិត្តភក្តិ ញាតិមិត្តរបស់ពួកគាត់ថែមទៀត (នេះជាការជួយផ្សព្វផ្សាយដោយមិនគិតប្រាក់កម្រៃ)។

តារាងខាងក្រោមនេះបង្ហាញអំពីលក្ខណវិនិច្ឆ័យទាំង ០៣ នៃសូចនាករលម្អិតT៥ និងជាកម្មវត្ថុនៃការពិភាក្សាដើម្បីធ្វើការណែនាំដល់ទីក្រុងបេក្ខភាព។

| លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|
| T៥.១. ភាគរយនៃចំនួនភ្ញៀវទេសចរដែលពេញចិត្តចំពោះ**<u>ការស្វាគមន៍រាក់ទាក់</u>**របស់**<u>ប្រជាជនមូលដ្ឋាន</u>** | យ៉ាងហោចណាស់៧០% | ១ |
| T៥.២. ភាគរយនៃចំនួនភ្ញៀវទេសចរដែលពេញចិត្តចំពោះ**<u>ភាពស្អាតនៅតាមទីរមណីយដ្ឋានសំខាន់ៗ និងសម្បទា ទេសចរណ៍</u>** | យ៉ាងហោចណាស់៧០% | ១ |
| T៥.៣. ភាគរយនៃចំនួនភ្ញៀវទេសចរ ដែលពេញចិត្តចំពោះ**<u>ការតុបតែងលម្អនៅតាមទីរមណីយដ្ឋានសំខាន់ៗ និងសម្បទាទេសចរណ៍</u>** | យ៉ាងហោចណាស់៧០% | ១ |

*(ផ្តល់ពិន្ទុ ៣/១៤ នៃពិន្ទុសរុបរបស់សូចនាករគោលនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍)*

# ការណែនាំសម្រាប់ទីក្រុងបេក្ខភាព

## ១. លក្ខណវិនិច្ឆ័យ T៥.១

*"ភាគរយនៃចំនួនភ្ញៀវទេសចរដែលពេញចិត្តចំពោះ<u>ការស្វាគមន៍រាក់ទាក់</u>របស់<u>ប្រជាជនមូលដ្ឋាន</u>"*

*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា**<u>មានចំនួនភ្ញៀវទេសចរយ៉ាងហោចណាស់ ៧០%នៃចំនួនទេសចរសរុបមានការពេញចិត្តចំពោះការស្វាគមន៍រាក់ទាក់របស់ប្រជាជនមូលដ្ឋាន</u>**"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ការស្វាគមន៍រាក់ទាក់ | សំដៅដល់ការស្វាគមន៍តាមបែបបដិសណ្ឋារកិច្ច (ដែលអាចជាសេវាកម្មផ្សេងៗដែលផ្តល់ជូន ឬអាកប្បកិរិយាប្រាស្រ័យទាក់ទងតាមរូបភាពផ្សេងៗ)។ |
| ២ | ប្រជាជនមូលដ្ឋាន | សំដៅដល់**<u>ប្រជាពលរដ្ឋទូទៅ</u>**ដែលរស់នៅ និងមានអត្រានុកូលដ្ឋាននៅក្នុងដែនសមត្ថកិច្ចរដ្ឋបាលរបស់ទីក្រុងបេក្ខភាពនោះ ទោះជាប្រជាពលរដ្ឋនោះប្រកបរបរអ្វីក៏ដោយ។ |
| ៣ | ភាពស្អាត | ភាពស្អាតអាចកំណត់បានតាមរយៈអវត្តមាននូវ<u>សមាសធាតុ៣</u>គឺ៖ ភាពកខ្វក់ សំរាម/កាកសំណល់ផ្សេងៗដែលនៅរាយប៉ាយ និងក្លិនមិនល្អ។ |

| | | |
|---|---|---|
| ៤ | ទីរមណីយដ្ឋានសំខាន់ៗ | សំដៅដល់រមណីយដ្ឋានទេសចរណ៍ទាំងឡាយណានៅតាមទីក្រុងបេក្ខភាពដែលជា**គោលដៅសំខាន់នៃការទស្សនារបស់ភ្ញៀវទេសចរ**ដែលចូលមកទស្សនាកំសាន្តក្នុងទីក្រុងបេក្ខភាពនោះ។<br>**ឧទាហរណ៍៖**បើទៅទស្សនាក្រុងព្រះសីហនុគឺទៅសំរាកលំហែនៅតាមឆ្នេរសមុទ្រនានារបស់ក្រុង។ |
| ៥ | សម្បទាទេសចរណ៍ | សំដៅដល់**ទីតាំងសេវាកម្ម**ទាំងឡាយណាដែលបំរើឲ្យដល់វិស័យទេសចរណ៍។ |

## ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យT៥.១ តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក**គ.ជ.វ.ទ.**សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**ចំនួន**" (បរិមាណ) ភ្ញៀវទេសចរដែលមានការពេញចិត្តចំពោះការស្វាគមន៍រាក់ទាក់របស់ប្រជាជនមូលដ្ឋានដែលចូលមកទស្សនាកំសាន្តនៅក្នុងទីក្រុងបេក្ខភាព។ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.**ធ្វើការវាយតម្លៃ។ លក្ខខណ្ឌតម្រូវទាំងនោះមាន **០៤** គឺ៖

- ព័ត៌មានអំពីស្ថិតិទេសចរដែលចូលមកទស្សនាកំសាន្តក្នុងទីក្រុងបេក្ខភាព
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវគ្រប់គ្រងលើកិច្ចការងារចុះស្ទាបស្ទង់មតិនេះ
- ឯកសារកម្រងសំនួរដែលបានរៀបចំឡើង
- បង្ហាញអំពីលទ្ធផលនៃការស្ទាបស្ទង់មតិដែលទទួលបានការពេញចិត្តពីភ្ញៀវទេសចរយ៉ាងតិច៧០%

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យT៥.១ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០៣** ខាងលើ។

**តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យT៥.១**

| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
|---|---|---|---|
| ១ | ព័ត៌មានអំពីភ្ញៀវទេសចរ(ដែលមាន) | ស្រង់ស្ថិតិអំពីចំនួនភ្ញៀវទេសចរដែលមានចុះក្នុងគំរូមួយ | - តារាងសម្រង់ស្ថិតិដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវ | បង្ហាញវត្តមាននីតិបុគ្គល ឬរូបវន្តបុគ្គលដែលមានសមាសភាពជាអ្នកទទួលអនុវត្តការងារធ្វើការស្ទាបស្ទង់មតិនេះ | - លិខិតបទដ្ឋានគតិយុត្តដែលមានតម្លៃអាចបញ្ជាក់ពីសមាសភាពជាអ្នកទទួលអនុវត្តការងារនេះ |
| ៣ | ឯកសារកម្រងសំនួរ | រៀបចំជាកម្រងសំនួរសម្រាប់ចុះធ្វើការស្ទាបស្ទង់មតិអំពីភាពពេញចិត្តរបស់ទេសចរចំពោះការស្វាគមន៍រាក់ទាក់របស់ប្រជាជនមូលដ្ឋាន | - ឯកសារកម្រងសំនួរដែលមានការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច |
| ៤ | លទ្ធផលនៃការស្ទាបស្ទង់មតិ | រៀបចំជាតារាងសម្រង់ស្ថិតិដែលបានមកពីការស្ទាបស្ទង់មតិ | - តារាងព័ត៌មាន[122]ដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុងបេក្ខភាព |
| | *និង* | ធ្វើការវាយតំលៃលើទិន្នន័យដែលប្រមូលបានដោយបញ្ជាក់បង្ហាញថាមានភ្ញៀវទេសចរយ៉ាងតិច៧០%នៃចំនួនសរុបដែលបានធ្វើការស្ទាប | - លិខិតបទដ្ឋានគតិយុត្តដែលមានការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច |

[122] តារាងទី៤៧

| | | | |
|---|---|---|---|
| | | ស្ទង់មតិមានការពេញចិត្តចំពោះការស្វាគមន៍រាក់ទាក់របស់ប្រជាជនមូលដ្ឋាន | |

## ២. លក្ខណៈវិនិច្ឆ័យ T៥.២

*"ភាគរយនៃចំនួនភ្ញៀវទេសចរដែលពេញចិត្តចំពោះ__ភាពស្អាត__នៅតាម__ទីរមណីយដ្ឋានសំខាន់ៗ__ និង __សម្បទាទេសចរណ៍__"*

*"នឹងផ្តល់ជូន ១ពិន្ទុប្រសិនបើអាចបង្ហាញថា__មានចំនួនភ្ញៀវទេសចរយ៉ាងហោចណាស់ ៧០%នៃចំនួនទេសចរសរុបមានការពេញចិត្តនឹងភាពស្អាតជារួមរបស់រមណីយដ្ឋានសំខាន់ៗ និងសម្បទាទេសចរ__"*

### ក. សេចក្តីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់ |
|---|---|---|
| ១ | ភាពស្អាត | ភាពស្អាតអាចកំណត់បានតាមរយៈអវត្តមាននូវ__សមាសធាតុ៣__គឺ៖ ភាពកខ្វក់ សំរាម/កាកសំណល់ផ្សេងៗដែលនៅរាយប៉ាយ និងក្លិនមិនល្អ។ |
| ២ | ទីរមណីយដ្ឋានសំខាន់ៗ | សំដៅដល់រមណីយដ្ឋានទេសចរណ៍ទាំងឡាយណានៅតាមទីក្រុងបេតិកភាពដែលជា__គោលដៅសំខាន់នៃការទស្សនារបស់ភ្ញៀវទេសចរ__ដែលចូលមកទស្សនាកំសាន្តក្នុងទីក្រុង/ខណ្ឌបេតិកភាពនោះ។<br>__ឧទាហរណ៍៖__បើទៅទស្សនាក្រុងព្រះសីហនុគឺទៅសំរាកលំហែនៅតាមឆ្នេរសមុទ្រនានារបស់ក្រុង។ |
| ៣ | សម្បទាទេសចរណ៍ | សំដៅដល់__ទីតាំងសេវាកម្ម__ទាំងឡាយណាដែលបំរើឲ្យដល់វិស័យទេសចរណ៍។ |

### ខ. លក្ខខណ្ឌតម្រូវ

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យT៥.២ តម្រូវឲ្យទីក្រុងបេតិកភាពបង្ហាញមក**គ.ជ.វ.ទ.**សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ **"ចំនួន"** (បរិមាណ) ភ្ញៀវទេសចរដែលមានការពេញចិត្តចំពោះភាពស្អាតនៅតាមទីរមណីយដ្ឋានសំខាន់ៗ និងសម្បទាទេសចរណ៍ដែលមាននៅក្នុងទីក្រុងបេតិកភាព។ ដូច្នេះ ទីក្រុងបេតិកភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួនដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.**ធ្វើការវាយតម្លៃ។ លក្ខខណ្ឌតម្រូវទាំងនោះមាន **០៤** គឺ៖

- ព័ត៌មានអំពីស្ថិតិទេសចរដែលចូលមកទស្សនាកំសាន្តក្នុងទីក្រុងបេតិកភាព
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវគ្រប់គ្រងលើកិច្ចការងារចុះស្ទាបស្ទង់មតិនេះ
- ឯកសារកម្រងសំនួរដែលបានរៀបចំឡើង
- បង្ហាញអំពីលទ្ធផលនៃការស្ទាបស្ទង់មតិដែលទទួលបានការពេញចិត្តពីភ្ញៀវទេសចរយ៉ាងតិច៧០%

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យT៥.២ ក៏ដូចជាការណែនាំដល់ទីក្រុងបេតិកភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង **០៤** ខាងលើ។

| តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណៈវិនិច្ឆ័យT៥.២ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |

| | | | |
|---|---|---|---|
| ១ | ព័ត៌មានអំពីភ្ញៀវទេសចរដែលមាន | ស្រង់ស្ថិតិអំពីចំនួនភ្ញៀវទេសចរដែលមានចុះក្នុងគំរូមួយ | - តារាងសម្រង់ស្ថិតិដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវ | បង្ហាញវត្តមាននីតិបុគ្គល ឬរូបវន្តបុគ្គលដែលមានសមាសភាពជាអ្នកទទួលអនុវត្តការងារធ្វើការស្ទាបស្ទង់មតិនេះ | - លិខិតបទដ្ឋានគតិយុត្តដែលមានតម្លៃអាចបញ្ជាក់ពីសមាសភាពជាអ្នកទទួលអនុវត្តការងារនេះ |
| ៣ | ឯកសារកម្រងសំនួរ | រៀបចំជាកម្រងសំនួរសម្រាប់ចុះធ្វើការស្ទាបស្ទង់មតិអំពីភាពពេញចិត្តរបស់ទេសចរចំពោះភាពស្អាតនៅតាមទីរមណីយដ្ឋានសំខាន់ៗ និងសម្បទាទេសចរណ៍ដែលមាន | - ឯកសារកម្រងសំនួរដែលមានការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច |
| ៤ | លទ្ធផលនៃការស្ទាបស្ទង់មតិ | រៀបចំជាតារាងសម្រង់ស្ថិតិដែលបានមកពីការស្ទាបស្ទង់មតិ | - តារាងព័ត៌មាន[123]ដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុងបេក្ខភាព |
| | *និង* | ធ្វើការវាយតំលៃលើទិន្នន័យដែលប្រមូលបានដោយបញ្ជាក់បង្ហាញថាមានភ្ញៀវទេសចរយ៉ាងតិច៧០%នៃចំនួនសរុបដែលបានធ្វើការស្ទាបស្ទង់មតិមានការពេញចិត្តចំពោះភាពស្អាតនៅតាមទីរមណីយដ្ឋានសំខាន់ៗ និងសម្បទាទេសចរណ៍ | - លិខិតបទដ្ឋានគតិយុត្តដែលមានការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច |

### ៣. លក្ខណៈវិនិច្ឆ័យ T៥.៣

*"ភាគរយនៃចំនួនភ្ញៀវទេសចរដែលពេញចិត្តចំពោះការតុបតែងលម្អនៅតាម**ទីរមណីយដ្ឋានសំខាន់ៗ** និង**សម្បទាទេសចរណ៍**"*

*"នឹងផ្ដល់ជូន **១ពិន្ទុ**ប្រសិនបើអាចបង្ហាញថា**មានចំនួនភ្ញៀវទេសចរយ៉ាងហោចណាស់ ៧០%នៃចំនួនទេសចរសរុបមានការពេញចិត្តនឹងការតុបតែងលម្អរនៅតាមទីរមណីយដ្ឋានសំខាន់ៗ និងសម្បទាទេសចរណ៍ដែលមាន**"*

## ក. សេចក្ដីពន្យល់ពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្ដីពន្យល់ |
|---|---|---|
| ២ | ទីរមណីយដ្ឋានសំខាន់ៗ | សំដៅដល់រមណីយដ្ឋានទេសចរណ៍ទាំងឡាយណានៅតាមទីក្រុងបេក្ខភាពដែលជា**គោលដៅសំខាន់នៃការទស្សនារបស់ភ្ញៀវទេសចរ**ដែលចូលមកទស្សនាកំសាន្តក្នុងទីក្រុងបេក្ខភាពនោះ។<br>**ឧទាហរណ៍៖**បើទៅទស្សនាក្រុងព្រះសីហនុគឺទៅសំរាកលំហែនៅតាមឆ្នេរសមុទ្រនានារបស់ក្រុង។ |
| ៣ | សម្បទាទេសចរណ៍ | សំដៅដល់**ទីតាំងសេវាកម្ម**ទាំងឡាយណាដែលបំរើឲ្យដល់វិស័យទេសចរណ៍។ |

## ខ. លក្ខខណ្ឌតម្រូវ

[123] តារាងទី ៤៧

យើងសង្កេតឃើញថា អ្វីដែលលក្ខណវិនិច្ឆ័យT៥.៣ តម្រូវឲ្យទីក្រុងបេក្ខភាពបង្ហាញមក**គ.ជ.វ.ទ.**សម្រាប់ជាកម្មវត្ថុនៃការវាយតម្លៃនោះ គឺ "**ចំនួន**" (បរិមាណ) ភ្ញៀវទេសចរដែលពេញចិត្តចំពោះការតុបតែងលម្អនៅតាមទីរមណីយដ្ឋានសំខាន់ៗ និងសម្បទាទេសចរណ៍ដែលមាននៅក្នុងទីក្រុងបេក្ខភាព។ ដូច្នេះ ទីក្រុងបេក្ខភាពត្រូវបង្ហាញនូវលក្ខខណ្ឌតម្រូវមួយចំនួន ដើម្បីជាទុនសម្រាប់ឲ្យ **គ.ជ.វ.ទ.**ធ្វើការវាយតម្លៃ។ លក្ខខណ្ឌតម្រូវទាំងនោះមាន ០៤ គឺ៖

- ព័ត៌មានអំពីស្ថិតិទេសចរដែលចូលមកទស្សនាកំសាន្តក្នុងទីក្រុងបេក្ខភាព
- បង្ហាញអំពីវត្តមានអ្នកទទួលខុសត្រូវគ្រប់គ្រងលើកិច្ចការងារចុះស្ទាបស្ទង់មតិនេះ
- ឯកសារកម្រងសំនួរដែលបានរៀបចំឡើង
- បង្ហាញអំពីលទ្ធផលនៃការស្ទាបស្ទង់មតិដែលទទួលបានការពេញចិត្តពីភ្ញៀវទេសចរយ៉ាងតិច៧០%

ខាងក្រោមនេះ ជាការពិភាក្សាលើលក្ខខណ្ឌតម្រូវរបស់លក្ខណវិនិច្ឆ័យT៥.៣ ក៏ដូចជាការណែនាំដល់ទីក្រុងបេក្ខភាពនូវចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង ០៤ ខាងលើ។

| **តារាងពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃលក្ខណវិនិច្ឆ័យT៥.៣** | | | |
|---|---|---|---|
| **ល.រ** | **លក្ខខណ្ឌ** | **ការបំពេញលក្ខខណ្ឌ** | **ភស្តុតាងបញ្ជាក់** |
| ១ | ព័ត៌មានអំពីភ្ញៀវទេសចរដែលមាន | ស្រង់ស្ថិតិអំពីចំនួនភ្ញៀវទេសចរដែលមានចុះក្នុងគំរូមួយ | - តារាងសម្រង់ស្ថិតិដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានអ្នកទទួលខុសត្រូវ | បង្ហាញវត្តមាននីតិបុគ្គល ឬរូបវន្តបុគ្គលដែលមានសមាសភាពជាអ្នកទទួលអនុវត្តការងារធ្វើការស្ទាបស្ទង់មតិនេះ | - លិខិតបទដ្ឋានគតិយុត្តដែលមានតម្លៃអាចបញ្ជាក់ពីសមាសភាពជាអ្នកទទួលអនុវត្តការងារនេះ |
| ៣ | ឯកសារកម្រងសំនួរ | រៀបចំជាកម្រងសំនួរសម្រាប់ចុះធ្វើការស្ទាបស្ទង់មតិអំពីភាពពេញចិត្តរបស់ទេសចរចំពោះការតុបតែងលម្អនៅតាមទីរមណីយដ្ឋានសំខាន់ៗ និងសម្បទាទេសចរណ៍ | - ឯកសារកម្រងសំនួរដែលមានការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច |
| ៤ | លទ្ធផលនៃការស្ទាបស្ទង់មតិ | រៀបចំជាតារាងសម្រង់ស្ថិតិដែលបានមកពីការស្ទាបស្ទង់មតិ | - តារាងព័ត៌មាន[124]ដែលមានការបញ្ជាក់ពីអាជ្ញាធរទីក្រុងបេក្ខភាព |
| | *និង* | ធ្វើការវាយតំលៃលើទិន្នន័យដែលប្រមូលបានដោយបញ្ជាក់បង្ហាញថាមានភ្ញៀវទេសចរយ៉ាងតិច៧០%នៃចំនួនសរុបដែលបានធ្វើការស្ទាបស្ទង់មតិ មានការពេញចិត្តចំពោះការតុបតែងលម្អនៅតាមទីរមណីយដ្ឋានសំខាន់ៗ និងសម្បទាទេសចរណ៍ | - លិខិតបទដ្ឋានគតិយុត្តដែលមានការបញ្ជាក់សុពលភាពពីអាជ្ញាធរមានសមត្ថកិច្ច |

[124] តារាងទី ៤៧

# ឧបសម្ព័ន្ធ

# តារាងទី០១

**<u>ការណែនាំ:</u>** បេក្ខភាពត្រូវគូសសញ្ញា “✓” ក្នុងប្រអប់នៅក្នុងផ្នែកទាំងឡាយណាដែលខ្លួនមាន

| តារាងស្ថិតិទីកន្លែងសាធារណៈសំខាន់ៗនៃទីក្រុង/ខណ្ឌ.......................... | | | | | | |
|---|---|---|---|---|---|---|
| ល.រ | ឈ្មោះ | កាលបរិច្ឆេទ សាងសង់/រៀបចំ | ទំហំដី | ទីតាំង | តំបន់ដែលតាំងនៅ | ទំនាក់ទំនង អ្នកទទួលខុសត្រូវ |
| ☐ ក. អគារសាធារណៈ | | | | | | |
| ១ | | | | | | |
| ២ | | | | | | |
| ... | | | | | | |
| ☐ ខ. តំបន់បៃតង | | | | | | |
| ១ | | | | | | |
| ២ | | | | | | |
| ... | | | | | | |
| ☐ គ. សួនកុមារ | | | | | | |
| ១ | | | | | | |
| ២ | | | | | | |
| ... | | | | | | |
| ☐ ឃ. ទីតាំងសំរាប់លេងកីឡា | | | | | | |
| ១ | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | | | | | | |
| ... | | | | | | |
| ☐ ង .ចំណតរថយន្តក្រុង/ឈ្នួល | | | | | | |
| ១ | | | | | | |
| ២ | | | | | | |
| ... | | | | | | |
| ☐ ច. ចំនតសាធារណៈសំរាប់យាន្តជំនិះទូទៅ | | | | | | |
| ១ | | | | | | |
| ២ | | | | | | |
| ... | | | | | | |
| ☐ ឆ. បង្គន់សាធារណៈ | | | | | | |
| ១ | | | | | | |
| ២ | | | | | | |
| ... | | | | | | |
| ☐ ជ. រមណីយដ្ឋានទេសចរណ៍ | | | | | | |
| ១ | | | | | | |
| ២ | | | | | | |
| ... | | | | | | |
| ☐ ឈ. មជ្ឈមណ្ឌលព័ត៌មាន | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ... | | | | | | |
| ☐ ញ. ទីផ្សារសំខាន់ៗ | | | | | | |
| ១ | | | | | | |
| ២ | | | | | | |
| ... | | | | | | |
| ☐ ដ. មជ្ឈមណ្ឌលពាណិជ្ជកម្ម | | | | | | |
| ១ | | | | | | |
| ២ | | | | | | |
| ... | | | | | | |
| ☐ ឋ. មណ្ឌលសុខភាព | | | | | | |
| ១ | | | | | | |
| ២ | | | | | | |
| ... | | | | | | |

ធ្វើនៅ ............ខែ ....ថ្ងៃទី ....................ឆ្នាំ ២០១......

**អ្នកធ្វើតារាង**

(ហត្ថលេខាអ្នកធ្វើ)

(ឈ្មោះអ្នកធ្វើ)

# ភាពទី០២

# គំរូតារាងស្ថិតអំពីមណ្ឌលសុខភាព

ព័ត៌មានរបស់ក្រុង/ខណ្ឌ..........

ចូរគូសសញ្ញា "✓" ក្នុងប្រអប់នៅក្នុងផ្នែកទាំងឡាយណាដែលឆ្លើយតបនឹងស្ថានភាពក្រុង/ខណ្ឌ របស់អ្នក

| តារាងស្ថិតអំពីមណ្ឌលសុខភាពកំពុងដំណើរការសម្រាប់ឆ្នាំ ២០១... | | | | | |
|---|---|---|---|---|---|
| ☐ ក .មណ្ឌលសុខភាព (សេវាសាធារណៈ) | | | | | |
| ល.រ | ឈ្មោះ | ទីតាំង | លទ្ធភាពទទួល | ចំនួនបុគ្គលសុខាភិបាល | លេខទំនាក់ទំនង |
| ១ | | | | | |
| ២ | | | | | |
| ... | | | | | |
| ☐ខ .មណ្ឌលសុខភាពឯកជន | | | | | |
| ល.រ | ឈ្មោះ | ទីតាំង | លទ្ធភាពទទួល | ចំនួនបុគ្គលសុខាភិបាល | លេខទំនាក់ទំនង |
| ១ | | | | | |
| ២ | | | | | |
| ... | | | | | |

**តារាងស្ថិតអំពីមណ្ឌលសុខភាព (គំរោង) សម្រាប់ឆ្នាំ ...**

☐ ក .មណ្ឌលសុខភាព (សេវាសាធារណៈ)

| ល.រ | ឈ្មោះ | ទីតាំង | កាលបរិច្ឆេទចាប់ផ្ដើមការដ្ឋាន | កាលបរិច្ឆេទគ្រោងនឹងដាក់ឲ្យដំណើរការ |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ... | | | | |

☐ខ .មណ្ឌលសុខភាពឯកជន

| ល.រ | ឈ្មោះ | ទីតាំង | កាលបរិច្ឆេទចាប់ផ្ដើមការដ្ឋាន | កាលបរិច្ឆេទគ្រោងនឹងដាក់ឲ្យដំណើរការ |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ... | | | | |

ធ្វើនៅ......ឆ្នាំ ២០១ ............ខែ ....ថ្ងៃទី .....................

អ្នកធ្វើតារាង

(ហត្ថលេខាអ្នកធ្វើ)

(ឈ្មោះអ្នកធ្វើ)

# តារាងទី០៣

# គំរូតារាងស្ថិតិអំពីផ្លូវថ្នល់

ព័ត៌មានរបស់ក្រុង/ខណ្ឌ..........

ចូរគូសសញ្ញា "✓" ក្នុងប្រអប់នៅក្នុងផ្នែកទាំងឡាយណាដែលឆ្លើយតបនឹងស្ថានភាពក្រុង/ខណ្ឌ របស់អ្នក

| **តារាងស្ថិតិអំពីផ្លូវថ្នល់សម្រាប់ឆ្នាំ ២០១...** | | | | | |
|---|---|---|---|---|---|
| **☐ ក .ផ្លូវក្រាលកៅស៊ូ** | | | | | |
| **ល.រ** | **ឈ្មោះ/លេខ** | **ទីតាំង** | **ប្រវែង (ម)** | **ចាប់ផ្តើម** | |
| | | | | **ពី** | **ដល់** |
| ១ | | | | | |
| ២ | | | | | |
| ... | | | | | |
| **☐ខ .ផ្លូវក្រាលបេតុង** | | | | | |
| **ល.រ** | **ឈ្មោះ/លេខ** | **ទីតាំង** | **ប្រវែង (ម)** | **ចាប់ផ្តើម** | |
| | | | | **ពី** | **ដល់** |
| ១ | | | | | |
| ២ | | | | | |
| ... | | | | | |
| **☐គ .ប្រភេទផ្លូវផ្សេងទៀត** | | | | | |

| ល.រ | ឈ្មោះ/លេខ | ទីតាំង | ប្រវែង (ម) | ចាប់ផ្តើម | |
|---|---|---|---|---|---|
| | | | | ពី | ដល់ |
| ១ | | | | | |
| ២ | | | | | |
| ... | | | | | |

ធ្វើនៅ......ឆ្នាំ ២០១ ............ខែ ....ថ្ងៃទី .....................

**អ្នកធ្វើតារាង**

(ហត្ថលេខាអ្នកធ្វើ)

(ឈ្មោះអ្នកធ្វើ)

# តារាងទី០៤

## គំរូតារាងស្ថិតអំពីមតេយ្យសាលា និងសាលាបឋមសិក្សា

ព័ត៌មានរបស់ក្រុង/ខណ្ឌ..........

ចូរគូសសញ្ញា "✓" ក្នុងប្រអប់នៅក្នុងផ្នែកទាំងឡាយណាដែលឆ្លើយតបនឹងស្ថានភាពក្រុង/ខណ្ឌ របស់អ្នក

| តារាងស្ថិតអំពីមតេយ្យសាលា និងសាលាបឋមសិក្សាសម្រាប់ឆ្នាំ ២០១... | | | | | |
|---|---|---|---|---|---|
| ☐ក .មតេយ្យសាលា | | | | | |
| **ល.រ** | **ឈ្មោះ** | **ទីតាំង** | **ទំហំ (ម²)** | **ចំនួនថ្នាក់រៀន** | **ចំនួនសិស្ស (លទ្ធភាពទទួល)** |
| ១ | | | | | |
| ២ | | | | | |
| ... | | | | | |
| ☐ខ. បឋមសិក្សា | | | | | |
| **ល.រ** | **ឈ្មោះ** | **ទីតាំង** | **ទំហំ (ម²)** | **ចំនួនថ្នាក់រៀន** | **ចំនួនសិស្ស (លទ្ធភាពទទួល)** |
| ១ | | | | | |
| ២ | | | | | |
| ... | | | | | |

ធ្វើនៅ .....................ថ្ងៃទី...... ឆ្នាំ ............ខែ ....

**អ្នកធ្វើតារាង**

(ហត្ថលេខាអ្នកធ្វើ)

(ឈ្មោះអ្នកធ្វើ)

# តារាងទី០៥

# គំរូតារាងស្ថិតអំពីអនុវិទ្យាល័យ

ព័ត៌មានរបស់ក្រុង/ខណ្ឌ..........

ចូរគូសសញ្ញា "✓" ក្នុងប្រអប់នៅក្នុងផ្នែកទាំងឡាយណាដែលឆ្លើយតបនឹងស្ថានភាពក្រុង/ខណ្ឌ របស់អ្នក

| តារាងស្ថិតអំពីអនុវិទ្យាល័យសម្រាប់ឆ្នាំ ២០១... | | | | | |
|---|---|---|---|---|---|
| **ល.រ** | **ឈ្មោះ** | **ទីតាំង** | **ទំហំ** (**ម**$^{២}$) | **ចំនួនថ្នាក់រៀន** | **ចំនួនសិស្ស** (**លទ្ធភាពទទួល**) |
| ១ | | | | | |
| ២ | | | | | |
| ... | | | | | |

ធ្វើនៅ......ឆ្នាំ ២០១ ............ខែ ....ថ្ងៃទី .....................

**អ្នកធ្វើតារាង**

(ហត្ថលេខាអ្នកធ្វើ)

(ឈ្មោះអ្នកធ្វើ)

# តារាងទី០៦

# គំរូតារាងស្ថិតអំពីចឡាល័យ

ព័ត៌មានរបស់ក្រុង/ខណ្ឌ..........

ចូរគូសសញ្ញា "✓" ក្នុងប្រអប់នៅក្នុងផ្នែកទាំងឡាយណាដែលឆ្លើយតបនឹងស្ថានភាពក្រុង/ខណ្ឌ របស់អ្នក

| **តារាងស្ថិតអំពីចឡាល័យសម្រាប់ឆ្នាំ ២០១...** | | | | | |
|---|---|---|---|---|---|
| **ល.រ** | **ឈ្មោះ** | **ទីតាំង** | **ទំហំ** (ម$^{២}$) | **ចំនួនថ្នាក់រៀន** | **ចំនួនសិស្ស (លទ្ធភាពទទួល)** |
| ១ | | | | | |
| ២ | | | | | |
| ... | | | | | |

ធ្វើនៅ......ឆ្នាំ ២០១ ............ខែ ....ថ្ងៃទី .....................

**អ្នកធ្វើតារាង**

(ហត្ថលេខាអ្នកធ្វើ)

(ឈ្មោះអ្នកធ្វើ)

# តារាងទី០៧

# គំរូតារាងសម្រង់ស្ថិតអំពីអាងស្តុកសំណល់រាវ

ព័ត៌មានរបស់ក្រុង(ឈ្មោះទីក្រុងបេក្ខភាព)ខណ្ឌ/

ចូរគូសសញ្ញា "✓" ក្នុងប្រអប់នៅក្នុងផ្នែកទាំងឡាយណាដែលឆ្លើយតបនឹងស្ថានភាពក្រុង/ខណ្ឌ របស់អ្នក

## តារាងសម្រង់ស្ថិតអំពីអាងស្តុកសំណល់រាវសម្រាប់ឆ្នាំ២០១...

☐ កប្រភេទអាងស្តុករួម .

| លរ. | អំពីអាងស្តុក | | | អ្នកប្រើប្រាស់ | | អំពីអ្នកទទួលខុសត្រូវ | | |
|---|---|---|---|---|---|---|---|---|
| | ឈ្មោះ | លទ្ធភាពទទួលសរុប ម)៣( | លទ្ធភាពធ្វើប្រព្រឹត្តកម្ម | គិតជាគ្រួសារ | គិតជា% | ឈ្មោះ | អាស័យដ្ឋាន | លេខទំនាក់ទំនង |
| ១ | | | | | | | | |
| ២ | | | | | | | | |
| ... | | | | | | | | |

☐ ខប្រភេទអាងស្តុក .ឯកជន

| លរ. | អំពីអាងស្តុក | | | អំពីម្ចាស់អាងស្តុក | | |
|---|---|---|---|---|---|---|
| | ប្រភេទ | លទ្ធភាពទទួលសរុប ម)៣( | លទ្ធភាពធ្វើប្រព្រឹត្តកម្ម | ឈ្មោះ | អាស័យដ្ឋាន | លេខទំនាក់ទំនង |
| ១ | | | | | | |
| ២ | | | | | | |
| ... | | | | | | |

**<u>សំគាល់៖</u>**

**-លទ្ធភាពទទួលសរុប)ម៣(៖** សំដៅដល់ចំនុះផ្ទុករបស់បណ្តាញប្រមូលសំណល់រាវគិតជាម៉ែតគូបក្នុង ១វិនាទី។

**-អ្នកប្រើប្រាស់៖** សំដៅដល់សាធារណជនទាំងឡាយណាដែលបានភ្ជាប់ខ្លួនបណ្តាញប្រមូល នោះជាអចិន្ត្រៃយ៍។

**-លទ្ធភាពធ្វើប្រព្រឹត្តកម្ម៖** សំដៅដល់ការបរិយាយរបស់អ្នកទទួលខុសត្រូវអំពីលទ្ធភាពធ្វើប្រព្រឹត្តកម្ម សំណល់រាវរបស់អាងស្តុកដោយមានបញ្ជាក់ពីកម្រិតភាគរយនៃការធ្វើប្រព្រឹត្តកម្ម (ចំហេះ)មុននឹងបញ្ចេញចោលក្នុងបរិស្ថានវិញ។ ប្រសិនបើមិនមានលទ្ធភាពធ្វើប្រព្រឹត្តកម្មនោះទេ សូមបញ្ជាក់ពាក្យថា។"គ្មាន"

ធ្វើនៅ......ឆ្នាំ ២០១ ............ខែ ....ថ្ងៃទី .....................

**អ្នកធ្វើតារាង**

(ហត្ថលេខាអ្នកធ្វើ)

(ឈ្មោះអ្នកធ្វើ)

# តារាងទី០៨

# គំរូតារាងសម្រង់ស្ថិតប្រភពទឹកនិងគុណភាពប្រភពទឹកទាំងនោះ

ព័ត៌មានរបស់ក្រុង...ខណ្ឌ/

ចូរគូសសញ្ញា "✓ខណ្ឌរបស់អ្នក/ក្នុងប្រអប់នៅក្នុងផ្នែកទាំងឡាយណាដែលឆ្លើយតបនឹងស្ថានភាពក្រុង "

| **តារាងស្ថិតប្រភពទឹកនិងគុណភាពទឹកសម្រាប់ឆ្នាំ ២០១...** | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| **ខែមករា** | | | | | | | | | | |
| **ល.រ.** | **ឈ្មោះ** | **កំពស់ទឹក** | | **ទំហំផ្ទៃទឹក** | | **ទីតាំង** | **គុណភាពទឹក** | | **សន្និដ្ឋាន** |
| | | រដូវប្រាំង | រដូវវស្សា | រដូវប្រាំង | រដូវវស្សា | | □□ | កំរិតបំពុល (%) | |
| **☐ក .ទន្លេ** | | | | | | | | | |
| ១ | | | | | | | | | |
| ២ | | | | | | | | | |
| ... | | | | | | | | | |
| **☐ខ .ស្ទឹង** | | | | | | | | | |
| ១ | | | | | | | | | |
| ២ | | | | | | | | | |
| ... | | | | | | | | | |
| **☐គ .បឹង** | | | | | | | | | |
| ១ | | | | | | | | | |
| ២ | | | | | | | | | |
| ... | | | | | | | | | |
| **☐ឃ .ព្រែកប្រភពផ្សេងទៀត/ប្រឡាយ/** | | | | | | | | | |
| ១ | | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២ | | | | | | | | |
| ... | | | | | | | | |

**□ខ .អណ្តូង**

| លរ. | កាលបរិច្ឆេទ | ប្រភេទ | | | លទ្ធភាពផ្គត់ផ្គង់ | ទីតាំង | គុណភាពទឹក | | សន្និដ្ឋាន |
|---|---|---|---|---|---|---|---|---|---|
| | | ជីក | ស្នប់ | បូម | | | □□ | អាសេនិច(%) | |
| ១ | | | | | | | | | |
| ២ | | | | | | | | | |
| ... | | | | | | | | | |

ធ្វើនៅ......ឆ្នាំ ២០១ ............ខែ ....ថ្ងៃទី .....................

**អ្នកធ្វើតារាង**

**សំគាល់**

- **<u>ឈ្មោះ</u>** ៖ សំដៅដល់ឈ្មោះផ្លូវការរបស់ប្រភពទឹកនីមួយៗ។ **(ហត្ថលេខាអ្នកធ្វើ)**
- **<u>កាលបរិច្ឆេទ</u>** ៖ សំដៅដល់កាលបរិច្ឆេទនៃការដាក់ឲ្យប្រើប្រាស់អណ្តូង។ **(ឈ្មោះអ្នកធ្វើ)**
- **<u>លទ្ធភាពផ្គត់ផ្គង់</u>**៖ សំដៅដល់បរិមាណទឹកសម្រាប់ប្រើប្រាស់ដែលអណ្តូងអាចផ្តល់ឲ្យធៀបទៅនឹងតម្រូវការ។
- **<u>សន្និដ្ឋាន</u>** ៖ សំដៅដល់ការសន្និដ្ឋានរបស់អង្គភាពទទួលខុសត្រូវត្រួតពិនិត្យគុណភាពទឹកនៅតាមប្រភពនីមួយៗទៅលើគុណភាពទឹកនៃប្រភពនោះ ធៀបនឹងកម្រិតស្តង់ដារបស់ក្រសួងបរិស្ថាន *(ទាបជាង ខ្ពស់ជាង ឬត្រឹមត្រូវតាមស្តង់ដា និងត្រូវបញ្ជាក់ថាតើជាប្រភពទឹកកំពុងប្រើប្រាស់ឬយ៉ាងណា)*។

# តារាងទី០៩

# គំរូតារាងសម្រង់ស្ថិតប្រភពផ្គត់ផ្គង់ទឹកសម្រាប់បរិភោគនិងគុណភាពទឹកទាំងនោះ

ព័ត៌មានរបស់ក្រុង...ខណ្ឌ/

ចូរគូសសញ្ញា "✓ខណ្ឌរបស់អ្នក/ក្នុងប្រអប់នៅក្នុងផ្នែកទាំងឡាយណាដែលឆ្លើយតបនឹងស្ថានភាពក្រុង "

| **តារាងស្ថិតប្រភពផ្គត់ផ្គង់ទឹកសម្រាប់បរិភោគនិងគុណភាពទឹកសម្រាប់ឆ្នាំ ២០១...** | | | | | | | |
|---|---|---|---|---|---|---|---|
| **ខែមករា** | | | | | | | |
| ☐ **កអាងស្តុកទឹកប្រើប្រាស់សាធារណៈ .** | | | | | | | |
| **លរ.** | **កាលបរិច្ឆេទ** | **ប្រភពថវិការ** | **លទ្ធភាពផ្គត់ផ្គង់** | **ទីតាំង** | **អង្គភាពគ្រប់គ្រង** | **កម្រិត**pH | **សន្និដ្ឋាន** |
| ១ | | | | | | | |
| ២ | | | | | | | |
| ... | | | | | | | |
| ☐ **ខប្រភពផ្គត់ផ្គង់ផ្សេងៗ .** | | | | | | | |
| **លរ.** | **ឈ្មោះសំគាល់** | **អ្នកគ្រប់គ្រង** | **លទ្ធភាពផ្គត់ផ្គង់** | **ទីតាំង** | **មានការទទួលស្គាល់ពី** | **កម្រិត** pH | **សន្និដ្ឋាន** |
| ១ | | | | | | | |
| ២ | | | | | | | |
| ... | | | | | | | |

ធ្វើនៅ......ឆ្នាំ ២០១ ...........ខែ ....ថ្ងៃទី ....................

**អ្នកធ្វើតារាង**

